សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ ធ្នូ ឆ្នាំ 2012

# លីអាហូណា



## ព្រះវិហារបរិសុទ្ធ ៖ ការផ្លាស់ប្រែដួងចិត្ត និង គេហដ្ឋាន ទំព័រ 24, 28


បេសកកម្ម មិត្តភក្តិ គ្រួសារ ៖ ការរំឭកចាំបីយ៉ាងអំពីបុណ្យគ្រីស្ទម៉ាស់ ទំព័រ 40, 43, 44

អំណោយបួនយ៉ាង ដែលពុំត្រូវការវេចខ្ចប់ ទំព័រ 54

អត្ថន័យនៃផ្កាយបុណ្យគ្រីស្ទម៉ាស់ ទំព័រ 66



© វ៉លធើរ រ៉ែន, ហាមថតចម្លង

ដំណឹងល្អពីសេចក្តីអំណរដ៏អស្ចារ្យ ដោយ វ៉លធើរ រ៉ែន

*« រីឯនៅស្រុកនោះឯង មានពួកអ្នកគង្វាលដែលចាំយាម រក្សាហ្វូងចៀមរបស់ខ្លួននៅឯវាលក្នុងវេលាយប់ ។*

*« នោះមើល មានទេវតានៃព្រះអម្ចាស់មកឈរជិតគេ...*

*« តែទេវតាប្រាប់ថា កុំខ្លាចអី មើលខ្ញុំមកប្រាប់ដំណឹងល្អដល់អ្នករាល់គ្នា ពីសេចក្តីអំណរយ៉ាង អស្ចារ្យ ដែលសម្រាប់បណ្តាជនទាំងអស់គ្នា ។*

*« ត្បិតនៅថ្ងៃនេះ មានព្រះអង្គសង្គ្រោះមួយអង្គ ប្រសូតដល់អ្នករាល់គ្នានៅក្រុងហ្លួងដាវីឌ គឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់ » (លូកា 2:7–11) ។*



# លីអាហូណា ខែ ធ្នូ ឆ្នាំ 2012

## សារលិខិត


4 **សារលិខិតគណៈប្រធានទីមួយ ៖ ការរកឃើញនូវអារម្មណ៍នៃបុណ្យគ្រីស្ទម៉ាស់សារជាថ្មី**
ដោយ ប្រធាន ថូម៉ាស អេស ម៉នសុន

7 **សារលិខិតសួរសុខទុក្ខ៖ ការបង្រៀនសួរសុខទុក្ខ, កិច្ចការនៃសេចក្ដីសង្គ្រោះ**


**នៅលើគម្រប**
ខាងមុខ ៖ រូបថតនៃព្រះវិហារបរិសុទ្ធ មេសា អារីហ្សូណា ដោយ ខានដេស រីត ។ ខាងក្រោយ ៖ រូបថតនៃព្រះវិហារបរិសុទ្ធ អូកលិន កាលីហ្វញ៉ា ដោយ ប៊ីលី លីន អាលិន និង រូបថតនៃព្រះវិហារបរិសុទ្ធ ស៊ីឌនី អូស្ត្រាលី និង ពន្លឺភ្លើង ដោយ ខូលីន លីហ្គេតវូឌ ។



## អត្ថបទពិសេសៗ


10 **ប្រពៃណីនៃពន្លឺ និង ទីបន្ទាល់**
ដោយអែលឌើរ អិល ថមភើរី
*ចំនុចខ្លឹមនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ គឺបុគ្គលម្នាក់ៗ ក្រុមគ្រួសារ និង គេហដ្ឋាន ដែលសាសនាចក្រឧបត្ថម្ភគាំទ្រលើផ្នែកទាំងនេះ ។*

16 **ការទុកចោលនូវភាពមិនអនុគ្រោះចោលមួយអន្លើរ**
ដោយ អែលឌើរ ដេវីឌ អេស. ប៉ាកស្ទើរ
*យើងអាចទុកចោលនូវភាពមិនអនុគ្រោះចោលមួយអន្លើរ ហើយងើបចេញពីភាពងងឹត ដោយសារជំនួយរបស់ព្រះអម្ចាស់ ។*

20 **ពួកព្យាការីនៅរដូវបុណ្យគ្រីស្ទម៉ាស់**
ដោយ ឡូរ៉ា អេហ្វ. វិលលីស
*ដំណើររឿងអំពីពួកព្យាការីថ្ងៃចុងក្រោយបង្ហាញអំពីអារម្មណ៍នៃបុណ្យគ្រីស្ទម៉ាស់ ។*

24 **ការផ្លាស់ប្រែដ៏ពិសិដ្ឋ**
ដោយ អើរ៉ុន អិល. វេស្ទ
*ភូមិមួយបានផ្លាស់ប្រែ ។ គ្រួសារមួយបានផ្លាស់ប្រែ ។*

32 **សុវត្ថិភាព និងសន្តិភាពនៃកាន់តាមព្រះបញ្ញត្តិទាំងឡាយ**
ដោយ ប៊ីស្សព ហ្គេរី អ៊ី ស្ទីវិនសុន
*រូបមន្តមួយ ដែលមាននៅក្នុងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ បើកបង្ហាញច្រកផ្លូវទៅកាន់សុភមង្គល ។*


## ផ្នែកទាំងឡាយ


8 **អ្វីដែលយើងជឿ: ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទត្រូវបានស្ដារឡើងវិញតាមរយៈព្យាការីយ៉ូសែបស្ម៊ីធ**

31 **ការបម្រើក្នុងសាសនាចក្រ: ការទទួលអារម្មណ៍ពីសេចក្ដីស្រឡាញ់របស់ទ្រង់តាមរយៈការបម្រើ**
ដោយ ម៉ីស្សែល វ៉ាឌីន

36 **សម្លេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

74 **ព័ត៌មានអំពីសាសនាចក្រ**

79 **យោបល់ទាំងឡាយសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ**

80 **លុះត្រាជួបទៀត: ពន្លឺ, កិច្ចការសាធារណៈ និង ក្ដីអំណរក្នុងដំណឹងល្អ**
ដោយអែលឌើរ ឃ្វីនធិន អិល ឃុក

## ពួកមជ្ឈិមវ័យវ័យក្មេង





40 **ពួកគេបានទិយាយមកកាន់យើង: គ្រីស្ទម៉ាស់នៅក្នុងខ្លួនអ្នក**
ដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន

43 **គ្រឿងតុបតែងបុណ្យគ្រីស្ទម៉ាស់, មិត្តភក្តិដែលលក្ខណៈដូចព្រះគ្រីស្ទ**
ដោយ ម៉ារី អិន យុក
*បុណ្យគ្រីស្ទម៉ាស់នៃឆ្នាំ 1984 គឺជាផ្លូវបំបែកមួយនៅក្នុងជីវិតរបស់ខ្ញុំ ។*

44 **កន្សែងដៃបុណ្យគ្រីស្ទម៉ាស់**
ដោយស្កត អិម មួយ
*តើហេតុអ្វីបានជាម្ដាយរបស់ខ្ញុំ ជូនកន្សែងដៃមួយដល់បងស្រីរបស់ខ្ញុំជារៀងរាល់ឆ្នាំ ?*




*ចាំមើលថាតើអ្នកអាចរកឃើញរូបលីអាហូណា ដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ គ្រឿងតុបតែងបុណ្យគ្រីស្ទម៉ាស់ ។*




## យុវវ័យ


28 **ការផ្ដោតទៅលើគ្រួសារដ៏ជានិរន្តន៍**
ដោយ មីនឌី រ៉េ ហ្វ្រីតមែន
*របៀបដែលគំរូរបស់យុវវ័យពីររូប បានជួយដល់ឪពុកម្ដាយរបស់ពួកគេ ។*

46 **សំណួរ និង ចម្លើយទាំងឡាយ**
*តើខ្ញុំឆ្លើយសំណួររបស់មិត្តខ្ញុំអំពីព្រះវិហារបរិសុទ្ធបានដោយរបៀបណាទៅ បើខ្លួនខ្ញុំផ្ទាល់ មិនសូវដឹងអំពីព្រះវិហារបរិសុទ្ធផងនោះ ?*

48 **របៀបដើម្បីថ្វាយអំណោយដល់ព្រះគ្រីស្ទ**
ដោយប្រធាន ហិនរី ប៊ី អាវរិង
*អំណោយបីយ៉ាង ដែលយើងអាចថ្វាយព្រះអង្គសង្គ្រោះ ដើម្បីធ្វើឱ្យទ្រង់មានក្ដីអំណរ ។*

49 **បណ្ណប្រកាស: ឱ ចូរយើងមកក្រាបថ្វាយទ្រង់**

50 **ដើម្បីកម្លាំងនៃយុវជន: តើអ្វីទៅជាការដើរលេងជាគូ ?**
ដោយ លែរី អិម. ហ្គិបសុន

52 **ដោយសារតែក្រុមគ្រួសារ**
ដោយ ហ៊ីការី ឡូហ្វទូស
*អ៊ីនទូវ, អេរីន, និង អាឌីណា និយាយអំពីមូលហេតុដែលក្រុមគ្រួសាររបស់ពួកគេ មានសារៈសំខាន់ចំពោះពួកគេ ។*

54 **អំណោយដែលអ្នកពុំអាចវេចខ្ចប់បាន**
ដោយ អេលីស អាឡិចសាន់ដ្រា ហូមស៍
*នេះគឺជាយោបល់អំពីអំណោយដែលពុំអាចបំភ្លេចបានចំនួនបួន—ពុំតម្រូវឱ្យវេចខ្ចប់ ។*

56 **មួយបន្ទាត់ម្ដងៗ: កូរិនថូសទី1 15:20–22**

57 **មកពីតំបន់បេសកកម្ម: ការផ្ដល់អាហារដល់អ្នកទាំងឡាយដែលស្រេកឃ្លាន**
ដោយ ដាលីន ស៊ី. វិលខក

58 **ការធំឡើងជាមួយគ្នាក្នុងនាមជាឌីកុន**
*ឌីកុនពីររូបនេះ ជាមនុស្សផ្សេងគ្នា ប៉ុន្តែយ៉ាងហោចណាស់ ពួកគេមានរឿងមួយដូចគ្នា ។*


## កុមារ





59 **សាក្សីពិសេស: តើខ្ញុំអាចធ្វើជាសាក្សីម្នាក់របស់ព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ?**
ដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន

60 **អំណោយរបស់ខ្ញុំចំពោះព្រះយេស៊ូវ**
ដោយរ៉ាឈែល លីន បាអឺ
*តើខ្ញុំអាចបង្ហាញក្ដីស្រឡាញ់ចំពោះព្រះយេស៊ូវដោយរបៀបណា ? ខ្ញុំបានរកឃើញចម្លើយរបស់ខ្ញុំនៅក្នុងគេហដ្ឋាន ។*

62 **ទំព័ររបស់យើង**

63 **គំនិតភ្លឺថ្លា**

64 **ពន្លឺនៃលោកិយ**
ដោយ យីមប៊ើរលី រីឌ
*តើមនុស្សគ្រប់គ្នាអាចមើលទៅរូបប្រសូតកម្មសប្បាយរីករាយបានដោយរបៀបណា បើព្រះយេស៊ូវ ពុំអាចបញ្ឈប់រឿងអាក្រក់មិនឱ្យកើតឡើងបាននោះ ?*

66 **ការនាំមេរៀនថ្នាក់កុមារមកក្នុងលំនៅដ្ឋាន: ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រារបស់ព្រះ**

68 **ការអធិស្ឋានក្នុងថ្ងៃបុណ្យគ្រីស្ទម៉ាស់បានទទួលចម្លើយ**
ដោយ ភេហ្គី ស្កុនឃិន
*គ្រួសាររបស់ភេហ្គី គ្មានអាហារសម្រាប់ថ្ងៃបុណ្យគ្រីស្ទម៉ាស់ទេ ។*

70 **សម្រាប់កុមារតូចៗ**

81 **រូបភាពពីព្រះគម្ពីរមរមន**

**ខែ ធ្នូ ឆ្នាំ 2012 វ៉ុល 12 លេខទី 6**
**លីអាហូណា 10492 258**

ទស្សនាវដ្ដីអន្តរជាតិជាផ្លូវការនៃសាសនាចក្រនៃព្រះ យេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** ថូម៉ាស អេស ម៉នសុន, ហិនរី ប៊ី អាវរិង, ឌៀថើរ អេហ្វ អុជដូហ្វ

**ក្រុមនៃពួកសាវក 12 នាក់ ៖** ប៊យដ៍ ឃេ ផាកកឺ, អិល ថម ភែរី, រ័សុល អិម ណិលសុន, ដាល្លិន អេក អូក, អិម រ័សុល បាឡឺដ, រីឆាដ ជេ ស្កត, របឺត ឌី ហ៊ែល, ជែហ្វ្រី អរ៍ ហូឡិន, ដេវីឌ អេ បែដណា,ឃ្វីនថិន អិលឃុក, ឌី ថត គ្រីស្តូហ្វឺសិន, និង នែល អិល អាន់ឌើរសិន

**អ្នកបោះពុម្ពផ្សាយ ៖** ក្រេហ្គ អេ. ខាដុន
**អ្នកណែនាំ ៖** ស្ប៉េន អែម. បូវែន, ប្រ៉ែតលី ឌី. ហ្វូស្ទើរ, គ្រីស្តូហ្វែល ហ្គូលឌិន ជុញ្ញ័រ, អាន់ថូនី ឌី. ភើគីន

**នាយកផ្នែកចាត់ការ ៖** ដេវីឌ ធី. វ៉ានើរ
**នាយកផ្នែកការគាំទ្រដល់គ្រួសារ និង សមាជិក ៖** វិនសិន អេ. វ៉ុន
**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អរ. ឡយប៊ើហ្គ

**អ្នកគ្រប់គ្រងអាជីវកម្ម ៖** ហ្គាហ្វ ខានុន
**អ្នកចាត់ការបោះពុម្ពផ្សាយ ៖** អ័រ. វ៉ាល ចនសុន
**ជំនួយការចាត់ចែងបោះពុម្ពផ្សាយ ៖** ឡារ៉ែន ផតទើរ ហ្គាន
**ជំនួយការផ្នែកបោះពុម្ព ៖** ម៉ាលីសា ហ្សែនទីណូ

**ការសរសេរ និង ការពិនិត្យ ៖** សូសាន បារ៉ែត, វ៉ាយអិន ខារ, ដេវីឌ ឌីកសុន, ដេវីឌ អេ. អ៊ែតវើត, ម៉ាថាយ ឌី. ហ្លីតតុន, មីនឌី រ៉េ ហ្រ៊ីតមែន, ហ៊ីការី លូហ្វតុស, ល្បៀ ម៉ាក់ក្លាណាហាន, មីហ្គែល អរ. ម៉ូរីស, រីឆាត អិម. រ៉មនី, ប៉ុល វ៉ានដែនប៊ើរហ្គី, ជូល្បៀ វូឌប៊ើរី
**អ្នកបោះពុម្ព ៖** ជេហ្វ អិល ម៉ាទីន

**នាយកចាត់ចែងផ្នែកសិល្បៈ ៖** ជេ ស្កត នូតស៊ិន
**នាយកផ្នែកសិល្បៈ ៖** ថាត អរ. ភីទើរសុន
**ផ្នែករៀបចំតុបតែង ៖** ជេនណិត អាន់ទ្រូ, ហ្វេ ភី. អាន់ត្រូស, ស៊ី. ឃីមបឺល បុត, ថូម៉ាស ឆាល, ខារី លីន ស៊ី. ហែរិន, ខូលីន ហ៊ីងគ្លី, អេរិក ភី. ចនសិន, ស្កត អិម. ម៉ុយ, ប្រាត ធៀវ
**អ្នកសម្របសម្រួលផ្នែកកម្មសិទ្ធិបញ្ញា ៖** ខូលិត ទីប៊ើរឃើរ អុន
**អ្នកគ្រប់គ្រងផលិតកម្ម ៖** ជេន អាន ភិទើរស៍
**ក្រុមផលិតកម្ម ៖** ខុននី បោឆប ប្រ៊ីត, ហោវើត ជី. ប្រោណ, ជូលី ប៊ើរឌីត, ប្រាយអិន ដប៊ុលយូ. ហ្គីហ្គី, ខាធ្លីន ហោវើត, ដានីស ខើរប៊ី, ហ្គីននី ជេ. នីលសុន, ធី ភីលឈី, ហ្គេល ថាត វ៉ាហ្វើរធី
**អ្នកបោះពុម្ព ៖** ជេហ្វ អិល ម៉ាទីន

**នាយកផ្នែកបោះពុម្ព ៖** គ្រីជ ឃេ ស៊ីជវីគន
**នាយកផ្នែកការចែកចាយ ៖** អ៊ីវ៉ានឡាស៊ិន

**សំរាប់ជំនាវ និងតម្លៃខាងក្រៅសហរដ្ឋអាមេរិក និងកាណាដា សូមទាក់ទងមជ្ឈមណ្ឌលចែកចាយនៃសាសនាចក្រក្នុងមូលដ្ឋាន ឬអ្នកដឹកនាំវួដ ឬសាខា។ ផ្ញើការបោះពុម្ព ឬសំណួរទាំងឡាយតាមអ៊ិនធើរណិត liahona.lds.org, តាម *Liahona*, Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។**

*លីអាហូណា* ( ព្រះគម្ពីរមរមនមានន័យថា «ត្រីវិស័យ» ឬ «វត្ថុនាំផ្លូវ» ) ត្រូវបាន បោះពុម្ពជាភាសា អាល់ប៊ើនី, អាមេនី, ប៊ីស្លាម្យេ, ប៊ុលហ្គារី, ខ្មែរ, ស៊ីប៊ូអាណូ, ចិន, ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូនី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហៃទី, ហ៊ិនឌី, ហុងហ្គារី, អាយឡែនឌិច, ឥណ្ឌូណេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាវេន, លីទុយអានី, ម៉ាឡាកាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី, ណរវ៉េ, ប៉ូឡូញ, ព័រទុយហ្គាល, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស៊ីនហាឡា, ស្លូវ៉ានី, អេស្ប៉ាញ, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, តាមីល, តេលូហ្គូ, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ើឌូ និងវៀតណាម។ ( ភាពញឹកញាប់ប្រែប្រួលតាមភាសា ) ។

© 2012 ដោយ Intellectual Reserve, Inc. រក្សាសិទ្ធិគ្រប់យ៉ាង។ បោះពុម្ពនៅក្នុងសហរដ្ឋអាមេរិក ។

អត្ថបទ និងរូបភាពផ្សេងៗនៅក្នុងទស្សនាវដ្ដី លីអាហូណា អាចថតចម្លងបាន ដើម្បីប្រើប្រាស់នៅតាមគេហដ្ឋាន មិននៅក្នុងសាសនាចក្រ តែមិនមែនសំរាប់ធ្វើអាជីវកម្ម។ រូបភាពមួយចំនួនមិនអាចថតចម្លងបានទេ ចំពោះរូបភាពមួយចំនួនដែលត្រូវបានហាមឃាត់។ បើមានសំណួរ លោកអ្នកអាចទាក់ទងជាមួយ Intellectual Property Office, 50 E. North Temple St., Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org.

**For Readers in the United States and Canada:**
December 2012 Vol. 12 No. 6. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address *must* be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (Visa, MasterCard, American Express) may be taken by phone. (Canada Poste Information: Publication Agreement #40017431)

POSTMASTER: Send address changes to Salt Lake Distribution Center, Church Magazines, PO Box 26368, Salt Lake City, UT 84126-0368.

# រឿងជាច្រើនទៀតនៅលើអ៊ិនធើរណែត Liahona.lds.org




## សម្រាប់មនុស្សពេញវ័យ

បន្ទាប់ពីរឹករាយនឹង «ពួកព្យាការីនៅរដូវបុណ្យគ្រីស្ទម៉ាស់» (ទំព័រ 20), អ្នកអាចចូលមើលក្នុង **christmas.lds.org** ដើម្បីមើល “The Coat: A Story of Charity” ចេញមកពីជីវិតរបស់ប្រធាន ចច អាល់ប៊ើត ស្មីធ ។




## សម្រាប់យុវវ័យ

ខេវិន និង ចាកហ្គីលីន (សូមមើល ទំព័រ 28) គឺជាបងប្អូនមកពី អែល សាល់វ៉ាឌ័រ ដែលមានពរជ័យនៃការចូលរួមក្នុងការប្រារព្ធពិធីវប្បធម៌ មុនពេលព្រះវិហារបរិសុទ្ធ សាន សាល់វ៉ាឌ័រ អែលសាល់វ៉ាឌ័រ ត្រូវបានឧទ្ទិសឆ្លង ។ ដើម្បីមើលវីដេអូ អំពីការចែកចាយពីការផ្លាស់ប្តូរជីវិតរបស់ពួកគេ, សូមចូលទៅ **lds.org/go/temple12**។

នៅទំព័រ 50 បងប្រុស ហ្គីបសុន នៃគណៈប្រធានយុវជនទូទៅ ឆ្លើយចំពោះសំណួរមួយចំនួនអំពីការដើរលេងជាគូរ ។ អ្នកអាចរៀនបន្ថែមទៀតអំពីការដើរលេងជាគូរ ចេញមកពីកូនសៀវភៅ*ដើម្បីកម្លាំងនៃយុវជន*ទៅ **youth.lds.org**។

## ជាភាសារបស់អ្នក

*លីអាហូណា* និងឯកសារផ្សេងទៀតរបស់សាសនាចក្រ មានជាច្រើនភាសា សូមចូលទៅកាន់ **www.languages.lds.org**។

## ប្រធានបទទាំងឡាយក្នុងច្បាប់នេះ

*លេខទំព័រទាំងឡាយគឺតំណាងឱ្យទំព័រទីមួយនៃអត្ថបទ ។*

*បព្វជិតភាពអើរ៉ុន, 58*
*ការធ្វើឱ្យសកម្មឡើងវិញ, 28*
*ភាពមិនអនុគ្រោះ 16*
*ដង្វាយធួន, 38, 39*
*ពរជ័យទាំងឡាយ, 16, 32*
*ព្រះគម្ពីរមរមន, 8*
*បុណ្យគ្រីស្ទម៉ាស់, 4, 20, 38, 39, 40, 43, 44, 48, 49, 54, 57, 60, 66, 68*
*ប្រវត្តិសាស្ត្រសាសនាចក្រ, 20*
*ការប្រែចិត្តជឿ, 24, 32*
*ការដើរលេងជាគូ, 50*
*សេចក្ដីស្លាប់, 39, 64*
*គំរូ, 10*
*ក្រុមគ្រួសារ, 10, 24, 28, 31, 38, 39, 44, 52, 54, 60*
*ការដឹងគុណ, 16, 54*
*សុភមង្គល, 32*
*ព្រះយេស៊ូវគ្រីស្ទ, 37, 49, 56, 59, 64, 66, 73*
*ចិត្តសប្បុរស, 4, 36, 37, 44, 48, 60, 68, 70*
*កិច្ចការផ្សព្វផ្សាយសាសនា, 40, 57, 80*
*ការគោរពប្រតិបត្តិ, 32, 59*
*ការអធិស្ឋាន, 68*
*ព្យាការីទាំងឡាយ, 8, 20*
*ការស្តារឡើងវិញ, 8*
*ការរស់ឡើងវិញ, 56, 64*
*ពលិកម្ម, 37*
*ការបម្រើ, 4, 31, 36, 48, 54, 57*
*យ៉ូសែប ស្ម៊ីធ, 8, 73, 81*
*ព្រះវិហារបរិសុទ្ធ, 24, 28, 46*
*ដង្វាយមួយភាគក្នុងដប់, 24*
*ប្រពៃណី, 10*
*សាមគ្គីភាព, 58*
*ការបង្រៀនសួរសុខទុក្ខ, 7*



ដោយ ប្រធាន
ថូម៉ាស អេស ម៉នសុន

# ការរកឃើញនូវ អារម្មណ៍នៃបុណ្យគ្រីស្ទម៉ាស់ សារជាថ្មី

ជាច្រើនឆ្នាំកន្លងទៅ ក្នុងនាមជាអែលឌើរវ័យក្មេងមួយរូប ខ្ញុំ និង អ្នកដទៃទៀតត្រូវបានហៅឱ្យទៅមន្ទីរពេទ្យមួយ នៅក្នុងទីក្រុងសលត៍លេក ដើម្បីផ្ដល់ការប្រសិទ្ធពរដល់កុមារឈឺ ។ ពេលចូលទៅដល់ យើងបានកត់សំគាល់ឃើញមានដើមគ្រីស្ទម៉ាស់មួយ ដែលមានពន្លឺភ្លឺស្រស់ពព្រាយ ហើយបានឃើញមានកញ្ចប់ជាច្រើនដែលបានវេចខ្ចប់យ៉ាងល្អ ដាក់នៅតាមមែកឈើ ។ បន្ទាប់មក យើងដើរកាត់តាមសាល ដែលមានកុមារា និង កុមារីតូចៗជាច្រើន—កុមារមួយចំនួនមានប៉ង់ស៊ីម៉ង់នៅដៃ ឬ ជើង ហើយមួយចំនួនទៀតមានជម្ងឺដែលប្រហែលជាមិនអាចព្យាបាលបាន—ដែលបានស្វាគមន៍យើងដោយទឹកមុខញញឹម ។

មានកុមារាតូចម្នាក់ដែលឈឺធ្ងន់បានហៅខ្ញុំ ហើយសួរថា « តើអ្នកឈ្មោះអ្វី ? »

ខ្ញុំបានប្រាប់ឈ្មោះដល់គាត់ ហើយ គាត់បានសួរថា « តើអ្នកនឹងផ្ដល់ការប្រសិទ្ធពរដល់ខ្ញុំឬទេ ? »

ការប្រសិទ្ធពរត្រូវបានផ្ដល់ឱ្យគាត់ ហើយនៅពេលយើងងាកខ្លួនដើម្បីចេញពីគ្រែគេងរបស់គាត់ គាត់បាននិយាយថា « អរគុណខ្លាំងណាស់ » ។

ពេលយើងបានដើរចេញបានពីរបីជំហាន ខ្ញុំបានឮគាត់ហៅថា « អ៊ូ ! បងប្រុសម៉នសុន រីករាយបុណ្យគ្រីស្ទម៉ាស់ » ។ បន្ទាប់មក ស្នាមញញឹមដ៏ពព្រាយបានបង្ហាញនៅលើទឹកមុខរបស់គាត់ ។

កុមារានោះមានអារម្មណ៍នៃបុណ្យគ្រីស្ទម៉ាស់ អារម្មណ៍នៃបុណ្យគ្រីស្ទម៉ាស់គឺជាអ្វីមួយ ដែលខ្ញុំសង្ឃឹមថាយើងទាំងអស់គ្នានឹងមាននៅក្នុងដួងចិត្តរបស់យើង និង ជីវិតរស់នៅរបស់យើង—ដោយពុំគ្រាន់តែមាននៅក្នុងរដូវកាលពិសេសនេះទេ តែមានពេញមួយឆ្នាំផងដែរ ។

នៅពេលយើងមានអារម្មណ៍នៃបុណ្យគ្រីស្ទម៉ាស់ នោះយើងចងចាំអំពីទ្រង់ ដែលយើងប្រារព្ធរំឭកចាំពីការប្រសូត នៅក្នុងរដូវកាលនេះក្នុងឆ្នាំ ៖ « ត្បិតនៅថ្ងៃនេះ មានព្រះអង្គសង្គ្រោះមួយអង្គប្រសូតដល់អ្នករាល់គ្នានៅក្នុងក្រុងហ្លួងដាវីឌ គឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់ » (លូកា 2:11) ។

នៅក្នុងជំនាន់របស់យើង អារម្មណ៍នៃការឱ្យអំណោយបានដើរតួរយ៉ាងសំខាន់ នៅក្នុងការប្រារព្ធពិធីរំឭកក្នុងរដូវកាលបុណ្យគ្រីស្ទម៉ាស់ ។ ខ្ញុំឆ្ងល់ បើយើងនឹងទទួលបានប្រយោជន៍ ដោយការសួរខ្លួនយើងថា តើអំណោយអ្វី ដែលព្រះអម្ចាស់ចង់ឱ្យខ្ញុំថ្វាយទ្រង់ ឬ ឱ្យដល់អ្នកដទៃនៅក្នុងរដូវកាលដ៏ថ្លៃថ្លាក្នុងឆ្នាំនេះ ?

ខ្ញុំសូមឱ្យយោបល់ថា ព្រះវរបិតាសួគ៌របស់យើងនឹងចង់ឱ្យយើងម្នាក់ៗថ្វាយដល់ទ្រង់ និង ព្រះរាជបុត្រារបស់ទ្រង់នូវអំណោយនៃការគោរពប្រតិបត្តិ ។ ខ្ញុំក៏មានអារម្មណ៍ថា ទ្រង់នឹងសុំពីយើងឱ្យលះបង់ខ្លួនយើង ហើយពុំមានចិត្តកំណាញ់ ឬ អត្មានិយម ឬ មួរម៉ៅ ដូចជាព្រះរាជបុត្រាដ៏ថ្លាថ្លៃរបស់ទ្រង់ បានផ្ដល់យោបល់នៅក្នុងព្រះគម្ពីរមរមន ៖

« ត្បិតប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា អស់អ្នកណា ដែលមានវិញ្ញាណនៃការទាស់ទែងគ្នា គឺពុំមែនជារបស់ផងយើងទេ ប៉ុន្តែជារបស់ផងអារក្សវិញ ដែល... វាចាក់រុកចិត្តមនុស្សឱ្យមានកំហឹងទាស់ទែងនឹងគ្នាទៅវិញទៅមក ។

« មើលចុះ នេះពុំមែនជាគោលលទ្ធិរបស់យើងទេ ដែលចាក់រុកចិត្តមនុស្សឱ្យមានកំហឹងទាស់ទែងនឹងគ្នាទៅវិញទៅមក ប៉ុន្តែគោលលទ្ធិរបស់យើង គឺត្រូវលះបង់ការណ៍ទាំងនោះចោលវិញ » (នីហ្វៃទី 3 11:29–30) ។

នៅក្នុងគ្រាកាន់កាប់ត្រួតត្រានៃពេលពេញកំណត់ដ៏អស្ចារ្យនេះ ឱកាសរបស់យើងដើម្បីស្រឡាញ់ និង លះបង់ខ្លួយើង គឺគ្មានដែនកំណត់នោះទេ ប៉ុន្តែវាក៏ត្រូវបានពុកផុយទៅផងដែរ ។ នៅសព្វថ្ងៃនេះ មានដួងចិត្តជាច្រើនត្រូវការភាពរីករាយ, និយាយពាក្យល្អៗ, ធ្វើទង្វើរល្អ និង មានព្រលឹងជាច្រើនត្រូវការនូវការសង្គ្រោះ ។

មានមនុស្សម្នាក់ដែលមានអារម្មណ៍ទូញថ្ងូរនៅក្នុងអារម្មណ៍នៃបុណ្យគ្រីស្ទម៉ាស់បានសរសេរថា ៖



*ខ្ញុំគឺជាអារម្មណ៍នៃបុណ្យគ្រីស្ទម៉ាស់—*
*ខ្ញុំបានចូលទៅក្នុងផ្ទះនៃភាពទុរគតិ ធ្វើឱ្យកុមារដែលមានទឹកមុខស្លេកស្លាំងបើកភ្នែកធំៗ ដោយចិត្តរីករាយ ។*
*ខ្ញុំបានធ្វើឱ្យដៃរបស់មនុស្សកំណាញ់ បានលាតចេញផ្ដល់ឱ្យ ហើយធ្វើឱ្យព្រលឹងរបស់គាត់បានភ្លឺថ្លា ។*
*ខ្ញុំបានធ្វើឱ្យមនុស្សចាស់បានទឹកចាំពីយុវវ័យរបស់ពួកគេ ហើយសើចសប្បាយនៅក្នុងវ័យចំណាស់ដោយរីករាយ ។*
*ខ្ញុំរក្សាភាពផ្អែមល្ហែមឱ្យនៅរស់រវើកនៅក្នុងដួងចិត្តនៃកុមារភាព ហើយធ្វើឱ្យការទទួលទានដំណេកបានលង់លក់ក្នុងសុបិនល្អ ។*
*ខ្ញុំបានធ្វើឱ្យជនស្រេកឃ្លាន ជួយដល់អ្នកដែលខ្វះខាត ដោយទុកចោលដួងចិត្តដែលកោតសរសើរដល់សេចក្ដីល្អនៃលោកិយមួយអន្លើរ ។*
*ខ្ញុំធ្វើឱ្យកូនខ្ជះខ្ជាយបញ្ឈប់ភាពឃោរឃៅ និងភាពខ្ជះខ្ជាយរបស់វាមួយសន្ទុះ ហើយផ្ញើរអ្វីមួយដល់មនុស្សជាទីស្រឡាញ់ដោយអន្ទះសារ ដើម្បីជួយស្រាយទឹកភ្នែកដែលរីករាយឱ្យហូរចុះមក—ជាទឹកភ្នែកដែលលុបលាងនូវស្នាមនៃភាពសោកសៅ ។*
*ខ្ញុំបានចូលក្នុងគុកងងឹត រំឭកចាំពីមនុស្សមានភាពភ័យខ្លាចនឹងអ្វីដែលអាចនឹងកើតឡើង ហើយចង្អុលទៅកាន់ថ្ងៃល្អដែលមិនទាន់មកដល់ ។*
*ខ្ញុំបានមកដល់ផ្ទះនៃក្ដីឈឺចាប់ពណ៌សស្ងាត់ជ្រងំ ហើយបបូរមាត់ទន់ខ្សោយពុំអាចនិយាយ ដោយគ្រាន់តែញាប់ញ័រនៅក្នុងការដឹងគុណដោយស្ងប់ស្ងាត់ និង អានុភាព ។*
*ខ្ញុំបានធ្វើឱ្យពិភពលោកដែលនឿយហត់មើលទៅរកព្រះភ័ក្ត្ររបស់ព្រះ ហើយបំភ្លេចនូវរឿងដែលតូចតាច ហើយរងទុក្ខមួយសន្ទុះ បានតាមរាប់ពាន់វិធី ។*
*ខ្ញុំជាអារម្មណ៍នៃបុណ្យគ្រីស្ទម៉ាស់ ។*[1] ■

សូមឱ្យយើងម្នាក់ៗរកឃើញនូវអារម្មណ៍នៃបុណ្យគ្រីស្ទម៉ាស់សារជាថ្មី—ជាព្រះវិញ្ញាណនៃព្រះគ្រីស្ទ ។

**កំណត់ចំណាំ**

1. អ៊ី. ស៊ី. បេ៊ែត "Christmas Spirit" នៅក្នុង ជេម អេស. ហ៊ីវិត, បានបោះពុម្ពផ្សាយ *Illustrations Unlimited* (ឆ្នាំ 1988), 81 ។

**ការបង្រៀនចេញពីសារលិខិតនេះ**

នៅពេលអ្នកចែកចាយសារលិខិតរបស់ប្រធានម៉នសុន ជាមួយគ្រួសារ ចូរពិចារណាដោយគូសបញ្ជាក់ទៅលើសំណួរ ដែលគាត់បានដាក់ថា តើអំណោយអ្វីដែលព្រះអម្ចាស់ចង់ឱ្យយើងថ្វាយទ្រង់ ឬ ផ្ដល់ដល់អ្នកដទៃនៅក្នុងរដូវកាលនេះ ។ ចូរលើកទឹកចិត្តដល់សមាជិកគ្រួសារ ឱ្យកត់ត្រាគំនិត និង យោបល់របស់ពួកគេ (ឬ សម្រាប់កុមារតូចៗ ដើម្បីគូររូប) អំពីរបៀបដើម្បី « រកឃើញនូវអារម្មណ៍នៃបុណ្យគ្រីស្ទម៉ាស់សារជាថ្មី—ជាព្រះវិញ្ញាណនៃព្រះគ្រីស្ទ » ។

ព្រះគ្រីស្ទ និង អ្នកមានវ័យក្មេង, ដោយ ហែនរិច ហូហ្វម៉ែន រូបភាពចំលងរបស់ C. HARRISON CONROY CO.

យុវវ័យ

# យប់មុនបុណ្យគ្រីស្ទម៉ាស់ដ៏អស្ចារ្យ

ដោយ ជើរី អេស. យ៉ាកុប

នៅពេលខ្ញុំធំឡើង ចំណុចសំខាន់មួយនៃឆ្នាំនីមួយៗ គឺយប់មុនបុណ្យគ្រីស្ទម៉ាស់ ។ គ្រួសាររបស់ខ្ញុំ និង ខ្ញុំបានធ្វើនំភីស្សា ដើរចេញទៅច្រៀង បន្ទាប់មកជួបជុំគ្នា ដើម្បីមានការប្រជុំធម្មនិដ្ឋានបុណ្យគ្រីស្ទម៉ាស់ ។ យើងច្រៀងទំនុកដំកើងពុំស្រុះគ្នាទេ ហើយបានធ្វើឱ្យចម្រៀងសោះកក្រោះមិនពិរោះ ដោយសារតែឧបករណ៍តន្ត្រីរបស់យើងខុសប្លែកពីធម្មតា ។ ប៉ុន្តែងតែបញ្ចប់ល្ងាចនេះ ដោយគំនិតបុណ្យគ្រីស្ទម៉ាស់ ដែលបន្សល់ទុកឱ្យយើងនូវទឹកភ្នែកដ៏រីករាយ ។ ពុំមានជីវិតណាសប្បាយជាងនៅយប់មុនបុណ្យគ្រីស្ទម៉ាស់នោះ ទេ ។

នៅពេលខ្ញុំកាន់តែធំ ម្ដាយខ្ញុំបានចាប់ផ្ដើមមើលថែទាំក្មេងជិតខាងម្នាក់ ឈ្មោះ ខេលលី ។ ខេលលី បានមកផ្ទះរបស់យើងជារៀងរាល់ថ្ងៃ បន្ទាប់ពីសាលារៀន ខណៈដែលម្ដាយរបស់នាង ឈ្មោះ ផាទី នៅធ្វើការ ។ ខាលលី បានដើរតាមខ្ញុំដូចជាកូនឆ្កែតូចមួយក្បាល—ដែលនិយាយខ្លាំងៗ និង ឃ្លាន ។ វាតែងតែជាការសម្រាលទុក្ខ នៅពេល មីង ផាទី មកយកកូនរបស់គាត់ទៅវិញ ចេញពីផ្ទះរបស់ខ្ញុំ ហើយ គ្រួសាររបស់យើងមានភាពសុខសាន្ត ។

នៅខែធ្នូ ខ្ញុំរន្ធត់ចិត្ត នៅពេលម៉ាក់ អញ្ជើញមីង ផាទី និង ខាលលី មកចូលរួមនឹងយើងសម្រាប់យប់មុនបុណ្យគ្រីស្ទម៉ាស់ ។ យប់មុនបុណ្យគ្រីស្ទម៉ាស់របស់ខ្ញុំ ។ ម៉ាក់បានញញឹម ហើយអះអាងនឹងខ្ញុំថា « វានឹងមិនផ្លាស់ប្ដូរអ្វីនោះទេ » ។ ប៉ុន្តែខ្ញុំដឹងច្រើនជាង ។ ពួកគេនឹងបរិភោគភីស្សារបស់យើងទាំងអស់ហ្នឹង ។ ខាលលី នឹងសើចចំអកដល់ការច្រៀងរបស់យើង ។ ខ្ញុំបានត្រៀមខ្លួនចំពោះយប់មុនបុណ្យគ្រីស្ទម៉ាស់ដែលអាក្រក់បំផុត ។

នៅពេលល្ងាចនោះមកដល់ មីង ផាទី និង ខាលលី បានមកចូលរួមនឹងយើង ហើយយើងបាននិយាយគ្នា បានសើច និង ច្រៀងជាមួយគ្នា ។ ម្ដាយរបស់ខ្ញុំពិតជានិយាយត្រូវមែន ។ វា គឺជា ពេលដ៏ល្អ ។ ដល់យប់ពាក់កណ្ដាលអធ្រាត ពួកគាត់បានអរគុណពួកយើង ហើយបានចាកចេញទៅដោយចិត្តស្ទាក់ស្ទើរ ។ ខ្ញុំបានចូលទៅដេកដោយដួងចិត្តរីករាយ ។ ខ្ញុំបានរកឃើញថា អំណោយនៃបុណ្យគ្រីស្ទម៉ាស់ដ៏មានតម្លៃពិត គឺពុំបាត់បង់នៅពេលចែកចាយនោះទេ ។ ផ្ទុយទៅវិញ វាមានភាពផ្អែមល្ហែម ហើយរីកដុះដាលឡើង នៅពេលយើងផ្ដល់ទៅឱ្យអ្នកដទៃ ។

កុមារ

# អំណោយទានបុណ្យគ្រីស្ទម៉ាស់ចំនួនប្រាំយ៉ាង

ប្រធានម៉នសុន បានមានប្រសាសន៍ថា យើងអាចនឹងគិតថា អំណោយអ្វីដែលព្រះអម្ចាស់ចង់ឱ្យយើងថ្វាយដល់ទ្រង់ ឬ ផ្ដល់ទៅឱ្យអ្នកដទៃ ។

ចូរគូសរង្វង់កុមារប្រាំនាក់នៅក្នុងរូបភាព ដែលកំពុងបម្រើដល់អ្នកដទៃ ។ តើអំណោយជាសកម្មភាពរបស់ពួកគេ ថ្វាយដល់ព្រះយេស៊ូវដោយរបៀបណា ?



*សូមសិក្សាឯកសារនេះ ហើយបើអាចធ្វើទៅបាន សូមពិភាក្សាវាជាមួយនឹងបងប្អូនស្ត្រីដែលអ្នកចុះទៅសួរសុខទុក្ខ ។ សូមប្រើសំណួរទាំងឡាយដើម្បីជួយអ្នកពង្រឹងដល់បងប្អូនស្ត្រីរបស់អ្នក និងធ្វើឱ្យសមាគមសង្គ្រោះក្លាយទៅជាផ្នែកមួយដ៏សកម្មនៅក្នុងជីវិតផ្ទាល់របស់អ្នក ។*

សេចក្ដីជំនឿ, ក្រុមគ្រួសារ, ការសង្គ្រោះ

# ការបង្រៀនសួរសុខទុក្ខ, កិច្ចការនៃសេចក្ដីសង្គ្រោះ



ការបង្រៀនសួរសុខទុក្ខបានផ្ដល់ឱកាសដល់ស្ត្រីដើម្បីមើលថែ, ពង្រឹង និង បង្រៀនដល់គ្នាទៅវិញទៅមក—វាគឺពិតជាកិច្ចការនៃសេចក្ដីសង្គ្រោះ ។ តាមរយៈការបង្រៀនសួរសុខទុក្ខ នោះបងប្អូនស្ត្រីធ្វើការបម្រើតំណាងឱ្យព្រះអង្គសង្គ្រោះ ហើយជួយរៀបចំស្ត្រីសម្រាប់ពរជ័យនៃជីវិតដ៏អស់កល្បជានិច្ច ។

ប្រធាន ស្ពែនស៊ើរ ដបុលយូ.ឃីមបឹល បានមានប្រសាសន៍ថា « យើង ‹ ត្រូវព្រមាន, ពន្យល់, ទូន្មាន និង បង្រៀន ហើយអញ្ជើញមនុស្ស [ដទៃទៀត] ឱ្យមករកព្រះគ្រីស្ទ › (គ. និង ស. 20:59), ដូចជាព្រះអម្ចាស់ មានបន្ទូលនៅក្នុងវិវរណៈរបស់ទ្រង់ » (ឆ្នាំ 1895–1985) ។ លើសពីនោះ លោកបានមានប្រសាសន៍ថា « ទីបន្ទាល់របស់អ្នក គឺមធ្យោបាយមួយដ៏ពូកែ » ។[1]

ក្នុងនាមជាគ្រូបង្រៀនសួរសុខទុក្ខ នៅពេលយើងបង្កើនចំណេះដឹងរបស់យើងអំពីសេចក្ដីពិតនៃដំណឹងល្អ នោះទីបន្ទាល់របស់យើងពង្រឹង ហើយគាំទ្រដល់បងប្អូនស្ត្រី ដែលកំពុងរៀបចំដើម្បីទទួលបុណ្យជ្រមុជទឹក និង ពិធីបញ្ជាក់ ។ យើងជួយដល់សមាជិកថ្មីឱ្យបានរឹងមាំនៅក្នុងដំណឹងល្អ ។ ការសួរសុខទុក្ខ និង ក្ដីស្រឡាញ់របស់យើង ជួយ « នាំអ្នកទាំងឡាយដែលវង្វេងឱ្យត្រឡប់មកវិញដោយជោគជ័យ [ហើយ] ធ្វើឱ្យដួងចិត្តរបស់អ្នកទាំងឡាយនោះដែលរងារនៅក្នុងដំណឹងល្អ បានកក់ក្ដៅឡើងវិញ » ។[2] ហើយយើងលើកទឹកចិត្តបងប្អូនស្ត្រី ឱ្យមករកព្រះគ្រីស្ទ តាមរយៈការចូលរួមក្នុងព្រះវិហារបរិសុទ្ធ ។

ប្រធាន ឃីមបឹល បានមានប្រសាសន៍ទៅកាន់គ្រូបង្រៀនសួរសុខទុក្ខថា « អ្នកកំពុងតែចេញទៅសង្គ្រោះដល់ព្រលឹងទាំងឡាយ ហើយតើនរណាទៅដឹង ថាមានសមាជិកសកម្មល្អជាច្រើននៅក្នុងសាសនាចក្រសព្វថ្ងៃនេះ នៅតែសកម្ម ដោយសារតែអ្នកចូលទៅក្នុងផ្ទះរបស់ពួកគេ ហើយបានផ្ដល់នូវទិដ្ឋភាពថ្មីមួយ, ទស្សនៈថ្មីមួយដល់ពួកគេនោះ ។ អ្នកបានទាញវាំងននចេញ ។ អ្នកបានពង្រីកទស្សនៈវិស័យរបស់ពួកគេ ។ ...

« អ្នកមើលឃើញទេ អ្នកពុំគ្រាន់តែសង្គ្រោះបងប្អូនស្ត្រីទាំងនេះប៉ុណ្ណោះទេ ប៉ុន្តែប្រហែលជាសង្គ្រោះដល់ស្វាមី និង គេហដ្ឋានរបស់ពួកគេផងដែរ » ។[3]

## ចេញពីព្រះគម្ពីរ

គោលលទ្ធិ និង សេចក្ដីសញ្ញា 20:59; 84:106; 138:56

## តើខ្ញុំអាចធ្វើអ្វីបាន ?

1. តើសមាគមសង្គ្រោះ រៀបចំខ្ញុំសម្រាប់ពរជ័យនៃជីវិតដ៏អស់កល្បជានិច្ចដោយរបៀបណា ?

2. តើខ្ញុំអាចធ្វើអ្វីខ្លះ ដើម្បីបង្កើនសេចក្ដីជំនឿរបស់អ្នកទាំងឡាយ ដែលខ្ញុំមើលថែ ?

រចនារូបថតដោយ រ៉ូប៊ឺត កាស៊ី

## ចេញពីប្រវត្តិសាស្ត្ររបស់យើង

នៅពេលព្យាការីយ៉ូសែប ស្ម៊ីធ បានរៀបចំសមាគមសង្គ្រោះ លោកបានមានប្រសាសន៍ថា ស្ត្រី គឺពុំគ្រាន់តែមើលថែដល់ជនក្រីក្រប៉ុណ្ណោះទេ គឺថែមទាំងសង្គ្រោះដល់ព្រលឹងទាំងឡាយទៀតផង ។ លោកក៏បានបង្រៀនផងដែរថា ស្ត្រីនៅក្នុងសាសនាចក្រ ដើរតួរយ៉ាងសំខាន់នៅក្នុងផែនការនៃសេចក្ដីសង្គ្រោះរបស់ព្រះវរបិតាសួគ៌ ។[4] បានដឹកនាំដោយគោលការណ៍ទាំងឡាយ ដែលបានបង្រៀនដោយព្យាការីយ៉ូសែប ស្ម៊ីធ យើងជាបងប្អូនស្ត្រីក្នុងសមាគមសង្គ្រោះ អាចធ្វើការជាមួយគ្នាដើម្បីរៀបចំស្ត្រី និង ក្រុមគ្រួសាររបស់ពួកគេ សម្រាប់ពរជ័យដ៏មហិមាបំផុតរបស់ព្រះ ។

ប្រធានព្រីកហាំ យ៉ង់ (ឆ្នាំ 1801–77) បានមានប្រសាសន៍ថា « ចូរយើងមានក្ដីមេត្តាករុណាចំពោះគ្នាទៅវិញទៅមក ហើយចូរឱ្យ [អ្នកទាំងឡាយដែល] រឹងមាំដោយទន់ភ្លន់ មើលថែដល់មនុស្សទន់ខ្សោយឱ្យទៅជាខ្លាំង ហើយចូរឱ្យអ្នកទាំងឡាយដែលអាចមើលឃើញ នាំផ្លូវមនុស្សខ្វាក់ រហូតដល់ពួកគេអាចមើលឃើញផ្លូវសម្រាប់ខ្លួនពួកគេ » ។[5]

**កំណត់ចំណាំ**

1. ស្ពែនស៊ើរ ដបុលយូ. ឃីមបឹល, នៅក្នុង *Daughters in My Kingdom: The History and Work of Relief Society* ឆ្នាំ 2011), 116 ។
2. អ៊ីឡៃស្សា អរ ស្នូ នៅក្នុង *Daughters in My Kingdom,* ទំព័រ 83 ។
3. ស្ពែនស៊ើរ ដបុលយូ. ឃីមបឹល, នៅក្នុង *Daughters in My Kingdom,* 117 ។
4. សូមមើល យ៉ូសែប ស្ម៊ីធ នៅក្នុង *Daughters in My Kingdom,* 171–72 ។
5. ព្រិកហាំ យ៉ង់ នៅក្នុង *Daughters in My Kingdom,* 107 ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ www.reliefsociety.lds.org ។

# ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទត្រូវបានស្តារឡើងវិញតាមរយៈ ព្យាការី យ៉ូសែប ស្ម៊ីធ

បន្ទាប់ពីការឆ្កាងរបស់ព្រះអង្គសង្គ្រោះ និង ការស្លាប់របស់ពួកសាវករបស់ទ្រង់ មនុស្សបានផ្លាស់ប្តូរគោលលទ្ធិ និង ពិធីបរិសុទ្ធមួយចំនួនរបស់ដំណឹងល្អ ។ ទោះជាមនុស្សល្អជាច្រើនបានជឿទៅលើព្រះយេស៊ូវគ្រីស្ទ ហើយបានព្យាយាមដើម្បីយល់ និង បង្រៀនដំណឹងល្អរបស់ទ្រង់ក្តី ក៏ភាពពេញលេញនៃដំណឹងល្អ លែងមានតទៅទៀតដែរ ។ ជាលទ្ធផលនាំឱ្យមានការផ្លាស់ប្តូរទៅរកការក្បត់សាសនានៅក្នុងចំណោមពួកគ្រីស្ទានដែលនៅរស់ ។ ខណៈដែលពួកគេមានសេចក្តីពិតជាច្រើន នោះគ្មាននរណាម្នាក់ក្នុងចំណោមពួកគេ មានគោលលទ្ធិ, ពិធីបរិសុទ្ធ ឬ បព្វជិតភាពរបស់ព្រះគ្រីស្ទពេញលេញទេ ។

ព្រះវរបិតាសួគ៌របស់យើងបានដឹងថា ការបាត់បង់សេចក្តីពិតជាលំដាប់នេះនឹងកើតមានឡើង ដូច្នេះ ទ្រង់បានរក្សាសេចក្តីពិតភាពពេញលេញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ នៅក្នុងគម្ពីរបុរាណមួយ ប្រៀបបានទៅនឹងព្រះគម្ពីរប៊ីប ។ នៅដើមឆ្នាំ 1800 សារទូតសួគ៌មួយអង្គ ព្រះនាមម៉ូរ៉ូណៃ បានដឹកនាំយ៉ូសែប ស្ម៊ីធទៅកាន់កន្លែងដែលលាក់គម្ពីរបរិសុទ្ធនេះ អស់រយៈពេលជាច្រើនសតវត្សន៍ហើយនោះ ។ កំណត់ត្រានេះ បានឆ្លាក់ត្រានៅលើផ្ទាំងមាស មាននូវការសរសេររបស់ពួកព្យាការី ដែលប្រាប់អំពីការទាក់ទងរបស់ព្រះជាមួយនឹងប្រជាជនបុរាណមួយចំនួននៅក្នុងទ្វីបអាមេរិក ។ ព្យាការីយ៉ូសែប ស្ម៊ីធ បានបកប្រែការសរសេរនៅលើផ្ទាំងទាំងនេះ ដោយអំណោយទាន និង ព្រះចេស្តានៃព្រះ ។ កំណត់ត្រានេះ គឺជាព្រះគម្ពីរមរមន ៖ សក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ ។

ដំណើរការនៃការបកប្រែព្រះគម្ពីរមរមនបានផ្តល់ដល់យ៉ូសែប ស្ម៊ីធ នូវការអប់រំមួយនៅក្នុងគោលលទ្ធិរបស់ព្រះ—ព្រះវិញ្ញាណគឺជាគ្រូបង្រៀនរបស់លោក ហើយព្រះគម្ពីរមរមន គឺជាអត្ថបទរបស់លោក ។ នៅពេលយ៉ូសែប ស្ម៊ីធ មានសំណួរមួយ លោកបានទៅរកព្រះនៅក្នុងការអធិស្ឋាន ហើយព្រះបានបើកសម្តែងចម្លើយដល់លោក ។ ដំណើរការនេះបានបង្រៀនយ៉ូសែប ស្ម៊ីធ ដែលជាយុវជនពុំបានរៀនសូត្រនូវសេចក្តីពិតដ៏សំខាន់ដែលមានតម្លៃចំពោះការហៅបម្រើរបស់លោក ក្នុងនាមជាព្យាការីនៃការស្តារឡើងវិញ ។ ■

សម្រាប់ព័ត៌មានបន្ថែម សូមមើល *គោលការណ៍ដំណឹងល្អ* (ឆ្នាំ 2009), 87–93, 95–100; *ពិតចំពោះសេចក្តីជំនឿ* (ឆ្នាំ 2004), 124–28, 135–39, 170–74; និង ហ្គារី ជេ. ខូលមែន « ព្រះយេស៊ូវគ្រីស្ទ គឺជាចំណុចសំខាន់នៃការស្តារឡើងវិញនៃដំណឹងល្អ » *Ensign,* ខែ វិច្ឆិកា ឆ្នាំ 1992, 43 ។

*ខណៈដែលយើងជឿ លើយ៉ូសែប ស្ម៊ីធ គឺជាព្យាការីម្នាក់របស់ព្រះ នោះយើងថ្វាយបង្គំព្រះវរបិតាសួគ៌ និង ព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ។*



## ព្យាការីយ៉ូសែប ស្ម៊ីធ ថ្លែងទីបន្ទាល់

1. « ខ្ញុំពិតជាបានឃើញពន្លឺមែន ហើយនៅកណ្ដាលពន្លឺនោះ ខ្ញុំបានឃើញតួអង្គពីរ ហើយតួអង្គនោះបានមានព្រះបន្ទូលមកខ្ញុំជាពិតប្រាកដ ហើយទោះជាខ្ញុំត្រូវគេស្អប់ ហើយបៀតបៀនមកពីថាខ្ញុំបានឃើញការនិមិត្តក្ដី គង់តែការនោះពិត... ខ្ញុំដឹងថាខ្ញុំបានឃើញការនិមិត្ត ហើយខ្ញុំដឹងថាព្រះទ្រង់ក៏ដឹងថាខ្ញុំបានឃើញការនិមិត្ត ហើយខ្ញុំពុំអាចបដិសេធរឿងនេះ ឬក៏ហ៊ានធ្វើដូច្នោះបានឡើយ » ។[1]



2. « ដោយអំណាចនៃព្រះ ខ្ញុំបានបកប្រែព្រះគម្ពីរមរមនពីវត្ថុលេខនា ជាចំណេះវិជ្ជាដែលត្រូវបានបាត់បង់នៅក្នុងពិភពលោកដែលខ្ញុំបានឈរនៅក្នុងហេតុការណ៍ដ៏អស្ចារ្យតែម្នាក់ឯង ជាយុវជនដែលពុំមានចំណេះដឹងជ្រៅជ្រះដើម្បីទប់ទល់នឹងប្រាជ្ញារបស់ពិភពលោក និង ការអវិជ្ជាជាច្រើននៅក្នុងសតវត្សរ៍ទីដប់ប្រាំបីចំពោះវិវរណៈថ្មីនេះ ។[2]



3. « ខ្ញុំបានប្រាប់បងប្អូនទាំងឡាយថា ព្រះគម្ពីរមរមន គឺជាគម្ពីរដ៏ត្រឹមត្រូវបំផុតជាងគម្ពីរនានាទាំងអស់នៅលើផែនដីនេះ ហើយជាមូលដ្ឋាននៃសាសនាចក្ររបស់យើង ហើយបុគ្គលម្នាក់ៗអាចចូលទៅជិតព្រះបាន ដោយសារធ្វើតាមសិក្ខាបទទាំងឡាយនៃគម្ពីរនេះ ជាជាងគម្ពីរដទៃទាំងអស់ » ។[3]





4. « ខ្ញុំ ... កាន់កូនសោនៃនគរចុងក្រោយ គឺជាគ្រាកាន់កាប់ត្រួតត្រានៃពេលពេញកំណត់នៃរឿងគ្រប់យ៉ាង ដែលបាននិយាយដោយមាត់របស់ព្យាការីបរិសុទ្ធទាំងអស់ ចាប់តាំងពីពិភពលោកបានចាប់ផ្ដើម នៅក្រោមអំណាចនៃការស្ដារភ្ជាប់នៃបព្វជិតភាពមិលគីស្សាដែក » ។[4] (សូមមើល គ. និង ស. 27:12–13) ។



5. « សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយត្រូវបានសង់នៅលើគ្រឹះនៃវិវរណៈផ្ទាល់ៗ ដូចជាសាសនាចក្រពិតប្រាកដរបស់ព្រះដែលមានពីមុន ... ហើយតាមរយៈព្រះឆន្ទៈ និង ពរជ័យរបស់ព្រះ ខ្ញុំបានក្លាយជាឧបករណ៍នៅក្នុងព្រះហស្តរបស់ទ្រង់ ហេតុដូច្នោះហើយ ត្រូវឈានទៅមុខសម្រាប់បុព្វហេតុរបស់ស៊ីយ៉ូន » ។[5]



6. « [ព្រះគម្ពីរមរមន] ប្រាប់យើងថាព្រះអង្គសង្គ្រោះបានធ្វើការសម្ដែងរូបអង្គទ្រង់នៅលើទ្វីប [អាមេរិក] នេះ បន្ទាប់ពីទ្រង់បានមានព្រះជន្មរស់ឡើងវិញ ទ្រង់បានដាក់ដំណឹងល្អនៅទីនេះនៅក្នុងភាពពេញលេញ, បរិបូរណ៍, និង ដាក់អំណាច ព្រមទាំងពរជ័យផងដែរ » ។[6]

**កំណត់ចំណាំ**

1. (យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1:25)។
2. *Teachings of Presidents of the Church: Joseph Smith* (2007 ឆ្នាំ) ទំព័រ 60 ។
3. *Teachings: Joseph Smith,* ទំព័រ 64 ។
4. *Teachings: Joseph Smith,* ទំព័រ 511 ។
5. *Teachings: Joseph Smith,* ទំព័រ 195 ។
6. *Teachings: Joseph Smith,* ទំព័រ 64 ។



ខាងឆ្វេង ៖ *សរសើរដល់លោក* ដោយ ចូន ម៉ាក់ណាត់តុន; *ការនិមិត្តដំបូងរបស់យ៉ូសែប ស្ម៊ីធ,* ដោយ ហ្គ្រេក អូលសុន, ហាមថតចម្លង *យ៉ូសែប ស្ម៊ីធ កំពុងបកប្រែព្រះគម្ពីរមរមន,* ដោយ ដេល ផាសុន © 1996; *ព្យាការីនៃព្រះអម្ចាស់* ដោយ ដេវីឌ លីនស៊ី ហាមថតចម្លង; រូបមកពី *ការស្ដារឡើងវិញនៃបព្វជិតភាពមិលគីស្សាដែក,* ដោយ លីស្ស លីម៉ុន ស្វីនដល ហាមថតចម្លង; *សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទត្រូវបានរៀបចំឡើងវិញ, ឆ្នាំ 1830,* ដោយ យ៉ូសែប ប្រ៊ីកឃី ហាមថតចម្លង *មើលទ៍ កូនតូចៗរបស់អ្នក,* ដោយដេវីឌ លីនស៊ី © 1983

ត្រូវប្រាកដថា អ្នកកំពុងបង្កើតបរិយាកាសដ៏ល្អមួយ ដែលគ្រួសាររបស់អ្នក អាចទន្ទឹងចាំគ្រាពិសេសៗក្នុងឆ្នាំ ជាពេលដែលប្រពៃណីជាច្រើនបាននាំឱ្យអ្នកជួបជុំគ្នា ជាអង្គភាពគ្រួសារដ៏អស់កល្បយ៉ាងអស្ចារ្យមួយ ។



ដោយអែលឌើរ
អិល ថមភើរី
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់



# ប្រពៃណីនៃពន្លឺ និង ទីបន្ទាល់

សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺពិតជាសាសនាចក្រជាសាកលមួយមែន ។ ទោះជាយ៉ាងណា វាសំខាន់ដើម្បីដឹងថា សាសនាចក្រពុំមានដូចសព្វថ្ងៃនេះទេ បើគ្មានកំណើតនៃជាតិសាសន៍ដ៏អស្ចារ្យមួយ ដែលជាសហរដ្ឋអាមេរិកនោះ ។ ព្រះអម្ចាស់បានរៀបចំដែនដីថ្មីមួយ ដើម្បីទាក់ទាញមនុស្សក្នុងពិភពលោក ដែលស្វែងរកសេរីភាព និង សេរីភាពខាងសាសនា ។ ដែនដីថ្មីនេះ ត្រូវបានប្រទានពរឱ្យមានអ្នកដឹកនាំខ្លាំងៗ ដែលមានកាតព្វកិច្ចជាប់ខ្លួន ដើម្បីស្ថាបនារដ្ឋាភិបាលមួយ ដែលអនុញ្ញាតឱ្យបុគ្គលម្នាក់ៗ ថ្វាយបង្គំស្របតាមមនសិការផ្ទាល់ខ្លួនរបស់ពួកគេ ។

មេដឹកនាំដែលចាប់ផ្ដើមបង្កើតសហរដ្ឋ បានជឿថា ជំនឿសាសនានានា គឺជាគ្រឹះនៃការស្ថាបនារដ្ឋាភិបាលរឹងមាំ ។ ទោះជាយ៉ាងណា ប្រជាជនជាច្រើនក្នុងពិភពលោក បានភ្លេចអំពីសារៈសំខាន់ជាចំបងអំពីជំនឿសាសនា នៅក្នុងការបង្កើតគោលនយោបាយ, បញ្ញត្តិ និង ច្បាប់នៃរដ្ឋាភិបាល ។ ជាឧទាហរណ៍ ជនជាតិអាមេរិកជាច្រើន ពុំយល់ថា មេដឹកនាំទាំងឡាយ បានជឿទៅលើតួនាទីខាងសាសនាថា សំខាន់នៅក្នុងជំនាន់របស់យើង ក៏ដូចជានៅក្នុងជំនាន់របស់ពួកគេនោះទេ ។ មេដឹកនាំ ពុំចាត់ទុកសាសនា និង សីលធម៌ គឺជាការអនុវត្តប្រកបដោយបញ្ញាមួយនោះទេ—ពួកគាត់បានប្រកាសដោយខ្លាំងក្លាថា វាគឺជាគ្រឿងផ្សំដ៏សំខាន់មួយនៃរដ្ឋាភិបាលល្អ និង សុភមង្គលរបស់មនុស្សជាតិ ។

ជំហរនេះ ត្រូវបានតាំងឡើងដោយប្រធាន សហរដ្ឋទីមួយ ឈ្មោះ ចច វ៉ាស៊ីនតោន នៅក្នុងប្រសាសន៍លាចុងក្រោយរបស់លោក ។ លោកបានមានប្រសាសន៍ថា ៖

« រាល់ចរិតលក្ខណៈ និង ទម្លាប់ទាំងអស់ ដែលដឹកនាំទៅរកភាពរីកចម្រើនខាងនយោបាយ នោះសាសនា និង សីលធម៌ គឺជាអ្នកគាំទ្រដោយខាងពុំបាន ។ ... ចូរយើង ប្រុងប្រយ័ត្នក្នុងការស្មានថា សីលធម៌អាចត្រូវបានរក្សាដោយគ្មានសាសនានោះ ។ ... មូលហេតុ និង បទពិសោធន៍ ទាំងពីរនេះហាមយើងកុំឱ្យរំពឹងថា សីលធម៌របស់ជាតិសាសន៍ អាចមានជោគជ័យដោយបដិសេធគោលការណ៍ខាងសាសនានោះឡើយ ។

« វាគឺជាការពិតយ៉ាងសំខាន់ថា គុណធម៌ ឬ សីលធម៌ គឺជាពន្លកដ៏សំខាន់មួយនៃរដ្ឋាភិបាលល្បីល្បាញ » ។[1]

សហរដ្ឋ គឺជាដែនដីដែលបានសន្យាទុកជាមុន នៅក្នុងព្រះគម្ពីរមរមន—ជាកន្លែងមួយ ដែលការណែនាំដ៏ទេវភាព បានដឹកនាំបុរសដ៏បំផុសគំនិតឱ្យបង្កើតលក្ខខណ្ឌដែលចាំបាច់ សម្រាប់ការស្ដារឡើងវិញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ វាគឺជាកំណើតសហរដ្ឋអាមេរិក ដែលបានចាប់ផ្ដើមបញ្ចប់ការក្បត់សាសនាដ៏ធំនោះ នៅពេលផែនដីត្រូវបានងងឹតដោយអវត្តមានរបស់ពួកព្យាការី និង ពន្លឺដែលបានបើកសម្ដែង ។ វាពុំមែនជារឿងចៃដន្យទេដែលព្រឹកគួរឱ្យស្រឡាញ់នៃការនិមិត្តដំបូង បានកើត

រចនារូបភាពដោយ ចន លូក © IRI



*តើខ្ញុំអាចរៀនអំពីរបៀបដើម្បីបង្កើតផែនការសម្រាប់ស្ថានភាពកើតឡើងដោយចៃដន្យ សម្រាប់សុវត្ថិភាពខាងវិញ្ញាណនៃគ្រួសារខ្ញុំនៅកន្លែងណាបាន ? ខ្ញុំបានមើលទៅសាសនាចក្រ——ជាវន្ទាដែលខ្ញុំអាចស្ថាបនាគ្រួសារដ៏អស់កល្បជានិច្ចមួយបាន ។*

ឡើងគ្រាន់តែរយៈពេលពីរបីទស្សវត្សរ៍ បន្ទាប់ពីការស្ថាបនាសហរដ្ឋឡើងនោះ ។

ការនិមិត្តដំបូងបានពន្លឿនជំនន់នៃសេចក្តីពិតបើកសម្តែងឡើង ។ ចំណេះដឹងត្រូវបានស្តារឡើងវិញ អំពីលក្ខណៈនៃក្រុមព្រះ ។ គម្ពីរដែលបានបកប្រែថ្មីមួយបានធ្វើជាសាក្សី និង ជាសក្ខីបទទីពីរ នៃព្រះយេស៊ូវគ្រីស្ទ ។ ការស្តារឡើងវិញនៃបព្វជិតភាព ផ្តល់ឱ្យមនុស្សលោកនូវអំណាច និង សិទ្ធិអំណាចដើម្បីធ្វើសកម្មភាព និង ជាតំណាងឱ្យព្រះនៅក្នុងការធ្វើពិធីបរិសុទ្ធនៃបព្វជិតភាពសារជាថ្មី និង នៅក្នុងការស្ថាបនាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៅលើផែនដីឡើងវិញ ។ យើងត្រូវបានប្រទានពរឱ្យធ្វើជាសមាជិកនៃសាសនាចក្រដែលបានស្តារឡើងវិញ ។

## ផែនការមួយសម្រាប់សុវត្ថិភាពខាងវិញ្ញាណ

ពរជ័យមួយនៃសាសនាចក្រដែលបានស្តារឡើងវិញ គឺការមានពួកព្យាការីនៅរស់ ។ ប្រធាន ហារ៉ូល ប៊ី. លី (ឆ្នាំ 1899–1973) មានការយល់ដឹងយ៉ាងច្បាស់អំពីអាទិភាព ។ លោកបានបង្រៀនថា « អ្វីជាច្រើនដែលយើងធ្វើការរៀបចំ [នៅក្នុងសាសនាចក្រ] ... គឺជាការសង់រន្ទា នៅពេលយើងព្យាយាមស្ថាបនាបុគ្គលម្នាក់ៗ ហើយយើងមិនត្រូវភ្លេចសង់រន្ទាសម្រាប់ព្រលឹងនោះទេ » ។[2]

ប្រធាន លី ពុំបានបង្រួមតួនាទីរបស់សាសនាចក្រនៅក្នុងសេចក្តីសង្គ្រោះរបស់បុរស ស្ត្រី និង ក្រុមគ្រួសារឱ្យទៅតូចបំផុតនោះទេ ។ ប៉ុន្តែលោកបានបង្រៀនប្រកបដោយអំណាចថា ខ្លឹមនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ គឺបុគ្គលម្នាក់ៗ, ក្រុមគ្រួសារ និង គេហដ្ឋាន ដែលសាសនាចក្រមានតួនាទីជួយគាំទ្រ ។[3] ហេតុដូច្នោះហើយ សាសនាចក្រកំពុងតែសង់រន្ទា ដើម្បីយើងស្ថាបនាក្រុមគ្រួសារដ៏អស់កល្បជានិច្ច ។

ខ្ញុំជាសមាជិកនៃមែកមួយរបស់ដើមឈើគ្រួសារ វីង ។ សមាជិកនៃគ្រួសារ វីង នៅតែជាម្ចាស់របស់គេហដ្ឋានដ៏ចំណាស់មួយ នៅញូវអង់គ្លេស ដែលនៅតែមានគ្រួសារដដែលរស់នៅ ។ ផ្ទះនោះត្រូវបានហៅថា អូលហ្វតហោស៍ (ផ្ទះបន្ទាយចាស់) ។ វាគឺជាផ្ទះរបស់ស្ទីហ្វិន វីង និង គ្រួសាររបស់គាត់ បន្ទាប់ពីពួកគេបានមកដល់អាមេរិក ប្រហែលជាឆ្នាំ 1635 ។

បេះដូងនៃផ្ទះ ត្រូវបានសាងសង់ឡើងសម្រាប់ជាការការពារ ។ ជញ្ជាំងរបស់វាមានកម្រាស់ពីរហ្វីត (0.6 ម) ដែលធ្វើពីដើមឈើអុក ដែលចាក់បុកទៅក្នុងដីដើម្បីបង្កើតជាបែបផែនសំណង់នៃយោធភូមិញូវអង់គ្លេស ។ វាមានជញ្ជាំងពីរផ្សេងគ្នា ។ ចន្លោះកណ្តាលជញ្ជាំងទាំងពីរ គឺមានដាក់បំពេញដោយខ្សាច់សម្រាប់ជាការការពារនឹងព្រួញ ហើយនឹងគ្រាប់កាំភ្លើង ។ បន្ទាយគឺនៅកណ្តាលផ្ទះនោះ ។ នៅពេលគ្រួសារ វីង កាន់តែធំឡើង នោះវាបានបន្ថែមទំហំផ្ទះបន្ទាយដើមធំជាងមុន ។ ប៉ុន្តែបន្ទាយនោះនៅតែជាបន្ទាយការពាររបស់ពួកគេ ជាជម្រកសុវត្ថិភាពរបស់ពួកគេ ។

យើងម្នាក់ៗ គួរតែពិចារណាអំពីការស្ថាបនារចនាសម្ព័ន្ធសម្រាប់សុវត្ថិភាពខាងវិញ្ញាណរបស់យើង ដើម្បីយើងមានសេរីភាពពីឥទ្ធិពលរបស់លោកិយ——ជាកន្លែងដែលយើងអាចការពារ និង បង្រៀនសមាជិកគ្រួសារអំពីរបៀបដើម្បីប្រឈមមុខនឹងឧបសគ្គទាំងឡាយនៃលោកិយ ដែលតែងតែគំរាមគំហែងដល់ស្តូលគុណធម៌នៃដំណឹងល្អ ។ ខ្ញុំសំដៅលើគំនិតសុទិដ្ឋិនិយម ដូច្នេះខ្ញុំបន្តមានក្តីសង្ឃឹមចំពោះការផ្លាស់ប្តូរវិជ្ជមាននៅក្នុងពិភពលោក ។ ប៉ុន្តែខ្ញុំក៏ជាមនុស្សប្រាកដនិយមផងដែរ ដូច្នេះខ្ញុំបង្កើតផែនការសម្រាប់ស្ថានភាពកើតឡើងដោយចៃដន្យ ក្នុងករណីការផ្លាស់ប្តូរវិជ្ជមានពុំកើតមានឡើង ។ ផែនការសម្រាប់ស្ថានភាពកើតឡើងដោយចៃដន្យរបស់ខ្ញុំសម្រាប់សុវត្ថិភាពខាងវិញ្ញាណ ត្រូវតែទទួលខុសត្រូវចំពោះរាល់មាតិកា——ទាំង

រចនារូបភាពដោយ ដាន ប៊ឺ

សេចក្ដីល្អ និង សេចក្ដីអាក្រក់ ដែលកំពុងតែត្រូវបានជម្រុញតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា ។ តើខ្ញុំអាចរៀនអំពីរបៀបដើម្បីបង្កើតផែនការសម្រាប់ស្ថានភាពកើតឡើងដោយចៃហេតុ សម្រាប់សុវត្ថិភាពខាងវិញ្ញាណនៃគ្រួសារខ្ញុំនៅកន្លែងណាបាន ? ខ្ញុំបានមើលទៅសាសនាចក្រ—ជារន្ទាដែលខ្ញុំអាចស្ថាបនាគ្រួសារដ៏អស់កល្បជានិច្ចមួយបាន ។

មានមូលហេតុចំបងពីរ ដែលខ្ញុំថ្លែងអំណរគុណចំពោះពាក្យប្រៀបធៀបរបស់ប្រធានលី ដែលថា សាសនាចក្រប្រៀបដូចជារន្ទាសម្រាប់សង់គ្រួសារដ៏អស់កល្បជានិច្ចរបស់យើង ។ ទីមួយ វាជួយខ្ញុំឱ្យយល់ថាសាសនាចក្រជាអ្វី ។ ទីពីរ ហើយមានសារៈសំខាន់ស្មើគ្នា ខ្ញុំដឹងនូវអ្វីដែលសាសនាចក្រពុំមានធ្វើ ។

សាសនាចក្រប្រៀបបាននឹងរន្ទា គឺជាតំណាងដ៏ល្អបំផុត ដែលបានថ្លែងដោយព្យាការី យ៉ូសែប ស្ម៊ីធ អំពីតួនាទីរបស់លោក ក្នុងនាមជាអ្នកដឹកនាំនៃសាសនាចក្រ ។ គាត់មានប្រសាសន៍ថា « ខ្ញុំបង្រៀនពួកគេនូវគោលការណ៍ត្រឹមត្រូវ ហើយពួកគេគ្រប់គ្រងខ្លួនគេ » ។[4] គោលការណ៍ដ៏អស់កល្បជានិច្ច គឺជារន្ទាដែលសាសនាចក្រផ្ដល់ឱ្យ ។ គោលការណ៍ដ៏អស់កល្បជានិច្ចទាំងនេះត្រូវបានបង្កប់នៅក្នុងគោលលទ្ធិនៃទេវព្រះ ហើយត្រូវបានឆ្លុះបញ្ចាំងនៅក្នុងផែនការនៃសុភមង្គលដ៏អស់កល្បជានិច្ចរបស់ទ្រង់ ។ យើងជួបជុំគ្នា ជាសមាជិកនៃសាសនាចក្រដើម្បីបង្រៀន និង រៀនពីគ្នាទៅវិញទៅមកនូវគោលការណ៍ទាំងឡាយនៃសេចក្ដីសុចរិត និង ដើម្បីទទួលពិធីបរិសុទ្ធនៃការសង្គ្រោះ ដូច្នេះរន្ទា មានភាពនឹងនរ ហើយស្ថិតស្ថេរ នៅពេលយើងស្ថាបនាគ្រួសារអស់កល្បជានិច្ចរបស់យើង ។

ចូរកត់ចំណាំថា សាសនាចក្រមិនធ្វើកិច្ចការរបស់ឪពុកម្ដាយនោះទេ ផ្ទុយទៅវិញ សាសនាចក្រណែនាំអំពីកិច្ចការរបស់ឪពុកម្ដាយ ។ សាសនាចក្រផ្ដល់ឱ្យនូវទម្រង់ដ៏អស់កល្បជានិច្ចមួយ ។ ក្នុងនាមជាអ្នកស្ថាបនាក្រុមគ្រួសារដ៏អស់កល្បជានិច្ច យើងត្រូវបានអះអាងដោយការសន្យាជាច្រើនថា បើយើងស្ថាបនាស្របទៅតាមទម្រង់ដ៏អស់កល្បជានិច្ចនេះ នោះកិច្ចខិតខំរបស់យើង អាចផ្ដល់នូវសុវត្ថិភាព និង ការការពារ ដែលយើងស្វែងរកសម្រាប់អ្នកទាំងឡាយ ដែលយើងស្រឡាញ់បំផុតនោះ ។

ឧបសគ្គរបស់យើង គឺត្រូវប្រើសាសនាចក្រជារន្ទាដើម្បីស្ថាបនាគ្រួសារមួយ ដែលមានភាពរឹងមាំខាងវិញ្ញាណ ឬ កាន់តែមានភាពរឹងមាំជាង អូលហ្វូតហោស៍ ដែលរឹងមាំខាងរូបកាយ ។ តើយើងធ្វើកិច្ចការនេះដោយរបៀបណា ?

**សារៈសំខាន់នៃទំនៀមទំលាប់**

ខ្ញុំជឿលើទំនៀមទំលាប់គ្រួសារ គឺដូចជាដើមឈើអូកដែលចាក់បុកទៅក្នុងដីដើម្បីបង្កើតជាអូលហ្វូតហោស៍ ។ ចូរធ្វើការគោរពទំនៀមទំលាប់គ្រួសារដូចជា—ទំនៀមទំលាប់ថ្ងៃឈប់សម្រាក, ទំនៀមទំលាប់ថ្ងៃខួបកំណើត, ទំនៀមទំលាប់ថ្ងៃអាទិត្យ, ទំនៀមទំលាប់អាហារពេលល្ងាច—និង ការបង្កើតទំនៀមទំលាប់ថ្មីមួយ ដែលមានអាទិភាពនៅក្នុងជីវិតរស់នៅរបស់អ្នក ។ ចូរគោរពដល់ទំនៀមទំលាប់នោះ ចូរសរសេរវាទុក ហើយត្រូវប្រាកដថាអ្នកធ្វើតាម ។ តាមការសិក្សាបង្ហាញថា មូលហេតុដែលមនុស្សវ័យក្មេងចូលរួមក្នុងក្រុមមនុស្សពាល គឺពីព្រោះតែទំនៀមទំលាប់ និង ពិធីនៃការធ្វើជាកម្មសិទ្ធិចំពោះអ្វីមួយ មានភាពអស្ចារ្យជាងខ្លួនគេ ។ នោះគឺជាអ្វីដែលគ្រួសារមួយគួរតែមាន ។ ត្រូវប្រាកដថា អ្នកកំពុងតែបង្កើតនូវបរិយាកាស ដ៏ល្អមួយ ដែលគ្រួសារអ្នកអាចទន្ទឹងចាំគ្រាពិសេសៗក្នុងមួយឆ្នាំៗ ជាពេលដែលទំនៀមទំលាប់ទាំងឡាយ នាំឱ្យអ្នកមកជួបជុំគ្នា ជាអង្គភាពគ្រួសារដ៏អស់កល្បជានិច្ចធំមួយ ។

ចូរយល់ថា នេះគឺពុំមែនជារឿងងាយស្រួល ឬ ក៏ជាដំណោះស្រាយងាយស្រួលនោះឡើយ ។ ក៏ដូចជាទីក្រុងរ៉ូមពុំមែនសង់ឡើងក្នុងមួយថ្ងៃនោះទេ ឯទំនៀមទំលាប់គ្រួសារក៏ដូច្នោះដែរ ។ ទំនៀមទំលាប់គ្រួសារ អាចផ្ដល់នូវការគាំទ្រជាមូលដ្ឋាន និង យូរអង្វែង ប៉ុន្តែត្រូវមានអ្វីៗជាច្រើនដែលត្រូវស្ថាបនានៅជុំវិញនោះ ។ ប្រហែលជាទំនៀមទំលាប់គ្រួសារដំណើរការល្អ តែនៅពេលពួកគេបង្កើតតួនាទីមួយ សម្រាប់សមាជិកគ្រប់រូបក្នុងគ្រួសារ និង នៅពេលមានការខិតខំរួមគ្នាដើម្បីបង្កើតទំនៀមទំលាប់ឡើងតែប៉ុណ្ណោះ ។ នេះមានន័យថា សមាជិកគ្រួសារ ចាំបាច់ត្រូវចំណាយពេលជាមួយគ្នា ហើយរៀនអំពីរបៀបធ្វើការជាមួយគ្នា ។ នៅពេលវាកើតមានក្នុងក្រុមគ្រួសារ នោះគ្មានពេលវេលាមានតម្លៃណាកើតឡើងដោយពុំតម្រូវឱ្យមានចំនួនពេលជាក់លាក់នោះទេ ។

ឧទាហរណ៍ នៅពេលអ្នកពិចារណាអំពីការងារ ចូរឆ្លុះបញ្ចាំងអំពីចំនួនពេលវេលាដែលការងារមួយ ត្រូវការពីអ្នកជារៀងរាល់ថ្ងៃ ។ តើវាជាការងារមួយ ដែលនឹងតម្រូវអ្នកឱ្យធ្វើការ 14 ម៉ោងក្នុងមួយថ្ងៃ ហើយរារាំងអ្នកមិនឱ្យត្រឡប់ទៅផ្ទះ រហូតដល់កូនៗរបស់អ្នកចូលដំណេកអស់ឬ ? ខ្ញុំពុំឱ្យយោបល់ថា ឱកាសការងារដូច្នោះ គឺនៅក្រៅព្រំដែននោះទេ ប៉ុន្តែបើអ្នកជ្រើសរើសយកវា អ្នកត្រូវតែរកវិធីឆ្នៃប្រឌិត ដើម្បីរក្សាទំនាក់ទំនងចំពោះគ្រួសាររបស់អ្នក ។ រន្ទារបស់សាសនាចក្រនឹងជួយរំឭកអ្នកអំពីអាទិភាពដ៏



*ទំនៀមទំលាប់គ្រួសារដំណើរការល្អបាន តែនៅពេលពួកគេបង្កើតតួនាទីមួយ សម្រាប់សមាជិកគ្រប់រូបក្នុងគ្រួសារ និង នៅពេលមានការខិតខំរួមគ្នាដើម្បីបង្កើតទំនៀទំលាប់ឡើងតែប៉ុណ្ណោះ ។ នេះមានន័យថា សមាជិកគ្រួសារចាំបាច់ត្រូវចំណាយពេលជាមួយគ្នា ហើយរៀនអំពីរបៀបធ្វើការជាមួយគ្នា ។*

*យើងត្រូវតែអង់អាចនៅក្នុងការប្រកាស និង ទីបន្ទាល់របស់យើងអំពីភាពជាព្រះរបស់ព្រះយេស៊ូវគ្រីស្ទ ។ យើងចង់ឱ្យអ្នកដទៃដឹងថា យើងជឿថា ទ្រង់គឺជាតួអង្គដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សលោកគ្រប់គ្នា ។*

អស់កល្បជានិច្ចរបស់អ្នក ។

សម្រាប់អាជីពរបស់ខ្ញុំ ខ្ញុំបានជ្រើសរើសអាជីវកម្មលក់រាយ ។ ហាងរបស់យើង បើកប្រាំមួយថ្ងៃក្នុងមួយសប្តាហ៍ ចាប់ពីម៉ោង 10 ព្រឹក ដល់ម៉ោង 10 យប់ ។ កិច្ចការធម្មតាប្រចាំថ្ងៃរបស់ខ្ញុំ គឺមានយ៉ាងហោចណាស់ 10 ម៉ោង ពេលខ្លះ 12 ម៉ោង ទៅ 15 ម៉ោង ។ ខ្ញុំត្រូវតែប្រយ័ត្នបំផុតដើម្បីមានពេលសម្រាប់កូនៗរបស់ខ្ញុំ ហើយខ្ញុំជឿថា ការមើលទៅសាសនាចក្រ ជាវន្ទា បានរំឭកខ្ញុំជាបន្តបន្ទាប់អំពីអាទិភាពដ៏អស់កល្បជានិច្ចរបស់ខ្ញុំ ។

ឧទាហរណ៍ ខ្ញុំឱ្យកូនៗរបស់ខ្ញុំទាំងអស់មានការងារក្រៅម៉ោងក្នុងហាងរបស់យើង ។ កូនស្រីច្បងរបស់ខ្ញុំ ធ្លាប់មកក្នុងហាង ហើយធ្វើបច្ចុប្បន្នភាពលើចំនួននៃការលក់ ដើម្បីឱ្យរបាយការណ៍របស់ខ្ញុំមានសុពលភាពជានិច្ច ហើយ ខ្ញុំអាចធ្វើការប្រៀបធៀបពីមួយឆ្នាំទៅមួយឆ្នាំបាន ។ ខ្ញុំឱ្យកូនប្រុសរបស់ខ្ញុំធ្វើការនៅផ្នែកគណនីបំណុលអំឡុងពេលរដូវក្តៅ ។ ខ្ញុំបានបង្រៀនកូនស្រីពៅរបស់ខ្ញុំអំពីរបៀបប្រើម៉ាស៊ីនគិតលុយ ដូច្នេះនាងអាចធ្វើការងារជាអ្នកគិតលុយក្រៅម៉ោងបាន ។ នេះ បានផ្តល់ជាឱកាសដល់យើង ដើម្បីជួបគ្នាអំឡុងពេលថ្ងៃ បរិភោគអាហារថ្ងៃត្រង់ជាមួយគ្នាច្រើនថ្ងៃក្នុងមួយសប្តាហ៍ ហើយចំណាយពេលមានតម្លៃជាមួយគ្នាម្នាក់ទល់នឹងម្នាក់ ។ ពេលល្អបំផុតនៅជាមួយគ្នា គឺអំឡុងពេលធ្វើដំណើរប្រចាំថ្ងៃទៅកន្លែងធ្វើការ និង មកពីកន្លែងធ្វើការ ។

## វន្ទាសម្រាប់ជីវិតខាងវិញ្ញាណរបស់យើង

ខ្ញុំក៏ជឿផងដែរថា សាសនាចក្រអាចផ្តល់វន្ទាសម្រាប់ជីវិតខាងវិញ្ញាណរបស់យើង ។ ក្នុងនាមជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ យើងតំណាងឱ្យព្រះអង្គសង្គ្រោះ និង សាសនាចក្ររបស់ទ្រង់ ។ សម្រាប់យើងទាំងអស់គ្នា ការធ្វើជាមនុស្សម្នាក់ល្អដូចជាអ្នកដទៃទៀតដែលមកពីព្រះវិហារដទៃទៀត គឺពុំល្អគ្រប់គ្រាន់ទេ ។ ប្រធាន ចច អាល់បើត ស្ម៊ីធ (ឆ្នាំ 1870–1951) បានបង្រៀនមេរៀននេះ នៅពេលលោកមានប្រសាសន៍ថា ៖

« នៅអំឡុងឆ្នាំមុន ខ្ញុំមានឯកសិទ្ធិចូលរួមការប្រជុំ និង សន្ទនាអំពីដំណឹងល្អ ជាមួយបុរសមួយចំនួន ដែលរស់នៅក្នុងសហគមន៍នេះ [ទីក្រុង សលត៍ លេក] ពុំមែនជាសមាជិកនៃសាសនាចក្ររបស់យើងទេ ។ មានបុរសម្នាក់បានរស់នៅទីនេះអស់រយៈពេលម្ភៃឆ្នាំហើយ ជាបុរសម្នាក់ដែលពុំអាចរិះគន់បានជាពលរដ្ឋល្អ ជាអ្នកអាជីវកម្មដ៏ល្បី ជាបុរសដែលមានអារម្មណ៍ល្អមកកាន់ប្រជាជនយើង ។ គាត់បានប្រាប់ខ្ញុំថា គាត់ ... បានសន្និដ្ឋានថា យើងល្អដូចជាអ្នកជិតខាងរបស់គាត់ ដែលជាសមាជិកនៃព្រះវិហារដទៃដែរ គាត់ពុំឃើញមានអ្វីខុសប្លែកនៅក្នុងចំណោមពួកយើងទេ ។

« បងប្អូនប្រុសស្រីរបស់ខ្ញុំអើយ ខ្ញុំចង់និយាយទៅកាន់អ្នករាល់គ្នា ថានោះពុំមែនជាការសរសើរចំពោះខ្ញុំទេ ។ បើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទពុំធ្វើឱ្យខ្ញុំក្លាយជាមនុស្សល្អប្រសើរម្នាក់ទេ នោះខ្ញុំពុំបានរីកចម្រើន ដូចដែលខ្ញុំគួរតែរីកចម្រើននោះទេ ហើយបើអ្នកជិតខាងយើង ដែលពុំនៅក្នុងសាសនាចក្រនេះ អាចរស់នៅក្នុងចំណោមយើងជាច្រើនឆ្នាំមក ពុំមើលឃើញនូវភស្តុតាងនៃអត្ថប្រយោជន៍ ដែលកើតមានមកពីការរក្សាបទបញ្ញត្តិរបស់ព្រះនៅក្នុងជីវិតរស់នៅរបស់យើងទេនោះ នោះមានអ្វីដែលត្រូវការកែតម្រង់នៅក្នុងអ៊ីស្រាអែលហើយ » ។[5]



ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ដោយ ដែល ផាសុន, © 1983 IRI; រូបថតពីអម © IRI

សមាជិកនៃសាសនាចក្រម្នាក់ៗ ដែលមានភាពសក្តិសមទទួលបណ្ណចូលព្រះវិហារបរិសុទ្ធ គួរតែល្អលេចធ្លោនៅក្នុងរង្វង់វិជ្ជាជីវៈអ្វីក៏ដោយ ដែលគាត់ ឬ នាងស្ថិតនៅ ។ ចូរហានធ្វើជាមនុស្សខុសប្លែកពីគេ ។ ចូរកុំបារម្ភអំពីការធ្វើឱ្យអ្នកដទៃអន់ចិត្ត ដោយសារការរស់នៅតាមបទដ្ឋាននៃសាសនាចក្រនោះឡើយ ។ ខ្ញុំសន្យានឹងអ្នកថា ការរស់នៅតាមបទដ្ឋានបណ្ណចូលព្រះវិហារបរិសុទ្ធ នឹងប្រទានពរ ហើយនឹងពុំដែលធ្វើឱ្យអ្នកឈឺចាប់នៅក្នុងស្ថានភាពណាមួយ ដែលអ្នកឃើញថាខ្លួនអ្នកស្ថិតនៅនោះឡើយ ។

**ការឆ្លុះបញ្ចាំងពន្លឺរបស់ព្រះអង្គសង្គ្រោះ**

នៅពេលខ្ញុំ អាន និង មើលសារព័ត៌មានរាល់ថ្ងៃ ខ្ញុំរន្ធត់ចិត្តចំពោះការលំបាកដែលយើងកំពុងតែបង្កើតសម្រាប់ខ្លួនយើង ។ ក្នុងកាលដែលពេលវេលា និង ស្ថានភាពផ្លាស់ប្តូរ ហើយកាន់តែស្មុគស្មាញ នោះហាក់បីដូចជាមានមនុស្សពីរបីនាក់ ដែលមានសមត្ថភាពក្នុងការទទួលយកការទទួលខុសត្រូវនៃការដឹកនាំទៅរកការផ្លាស់ប្តូរជាវិជ្ជមាន ។ ខ្ញុំសូមផ្តល់នូវសំណូមពរមួយដល់អ្នកដែលជាអ្នកដឹកនាំ និង អ្នកដែលអនាគតជាអ្នកដឹកនាំ ឱ្យទទួលស្គាល់ថា ពិភពលោកកំពុងតែផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ។ មានតម្រូវការបន្ទាន់មួយសម្រាប់អ្នកដឹកនាំ ដែលមានសមត្ថភាព និងអង់អាចល្មមគ្រប់គ្រាន់ ដើម្បីទទួលយកនូវឧបសគ្គដ៏ធំដែលប្រឈមមុខនឹងយើងសព្វថ្ងៃនេះ ។

គ្រឹះសីលធម៌ នៃទំនៀមទំលាប់ដ៏ខ្ជាប់ខ្ជួនមួយនៃពួកគ្រីស្ទានជូឌីអូបង្ហាញឱ្យឃើញនូវការសឹករិចរិលនៅក្នុងសហរដ្ឋ និង នៅក្នុងជាតិសាសន៍ដទៃទៀត ។ ទំនៀមទំលាប់នេះ ផ្តោតទៅលើយុត្តិធម៌, ក្តីមេត្តាករុណា និង ការគោរពចំពោះសេចក្តីថ្លៃថ្នូរបស់មនុស្សជាតិ ។ វាពុំផ្តោតទៅលើច្បាប់ និងបញ្ញត្តិច្បាប់ទេ ប៉ុន្តែផ្តោតទៅលើពន្លឺនៃព្រះគ្រីស្ទ នៅក្នុងពលរដ្ឋល្អ និង ត្រឹមត្រូវគ្រប់រូប ។

មនុស្សមួយចំនួន ដែលបានចូលទៅក្នុងជំនឿ និងតម្លៃទាំងនេះ កំពុងមានចំនួនថយចុះ ប៉ុន្តែអ្នក និង ខ្ញុំបន្តនៅស្មោះត្រង់ ។ យើងបានចុះសេចក្តីសញ្ញាជាមួយនឹងព្រះអង្គសង្គ្រោះ ដើម្បីធ្វើជាតំណាងឱ្យទ្រង់ ។ តាមរយៈការធ្វើជាតំណាងរបស់ព្រះយេស៊ូវគ្រីស្ទ និង ការឆ្លុះបញ្ចាំងនូវពន្លឺនៃព្រះគ្រីស្ទនៅក្នុងជីវិតរស់នៅរបស់យើង នោះយើងអាចជួយបងប្អូនប្រុសស្រីរបស់យើងជាច្រើនឱ្យចងចាំអំពីទំនៀមទម្លាប់និង កេមរតកគ្រីស្ទាន ជូឌីអូ របស់ពួកគេ ។

យើងត្រូវតែអង់អាចនៅក្នុងការប្រកាស និងទីបន្ទាល់របស់យើងអំពីភាពជាព្រះរបស់ព្រះយេស៊ូវគ្រីស្ទ ។ យើងចង់ឱ្យអ្នកដទៃដឹងថា យើងជឿថា ទ្រង់គឺជាតួអង្គដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សលោកគ្រប់គ្នា ។ ជីវិត និង ការបង្រៀនរបស់ទ្រង់ គឺជាបេះដូងនៃគម្ពីរប៊ីប និងគម្ពីរដទៃទៀត ដែលយើងចាត់ទុកជាគម្ពីរបរិសុទ្ធ ។ គម្ពីរសញ្ញាចាស់ រៀបចំផ្លូវសម្រាប់ការបម្រើក្នុងជីវិតរមែងស្លាប់របស់ព្រះគ្រីស្ទ ។ គម្ពីរសញ្ញាថ្មីពិពណ៌នាអំពីការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ ។ ព្រះគម្ពីរមរមនធ្វើជាសាក្សីទីពីរដល់យើងអំពីការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ ។ ទ្រង់បានយាងមកផែនដី ដើម្បីប្រកាសដំណឹងល្អរបស់ទ្រង់ ទុកជាគ្រឹះមួយសម្រាប់មនុស្សលោកទាំងអស់គ្នា ដូច្នេះកូនចៅទាំងអស់របស់ព្រះ អាចរៀនអំពីទ្រង់ និង ការបង្រៀនរបស់ទ្រង់ ។ បន្ទាប់មកទ្រង់បានប្រទានជីវិតរបស់ទ្រង់ ដើម្បីធ្វើជាព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះរបស់យើង ។ មានតែតាមរយៈព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ ទើបមានសេចក្តីសង្គ្រោះកើតឡើងបាន ។ នេះគឺជាមូលហេតុដែលយើងជឿថា ទ្រង់គឺជាតួអង្គដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សលោកគ្រប់ៗគ្នា ។ ជោគវាសនាដ៏អស់កល្បជានិច្ចរបស់យើង គឺនៅក្នុងព្រះហស្តរបស់ទ្រង់ជានិច្ច ។ វាគឺជារឿងដ៏រុងរឿងមួយ ដើម្បីជឿទៅលើទ្រង់ និង ទទួលទ្រង់ជាព្រះអង្គសង្គ្រោះរបស់យើង, ព្រះអម្ចាស់របស់យើង និង ជាចៅហ្វាយរបស់យើង ។

ចូរចងចាំថា អ្វីទាំងអស់ដែលសាសនាចក្របានធ្វើ, កំពុងធ្វើ ហើយអាចធ្វើ គឺសម្រាប់អ្នក និង គ្រួសាររបស់អ្នក ។ ហើយសូមចងចាំថា នេះពុំមែនដូចជាព្រះវិហារដទៃទៀតនោះទេ វាគឺជាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទដែលបានស្តារឡើងវិញ ។ ■

*ចេញមកពីសុន្ទរកថាការប្រជុំធម្មនិដ្ឋាន ដែលបានផ្តល់ឱ្យនៅថ្ងៃទី 24 ខែមករា ឆ្នាំ 2012 នៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់—អៃដាហូ ។ សម្រាប់អត្ថបទពេញលេញជាភាសាអង់គ្លេស សូមចូលទៅកាន់ web.byui.edu/devotionalsandspeeches ។*



*ចូរចងចាំថា អ្វីទាំងអស់ដែលសាសនាចក្របានធ្វើ, កំពុងធ្វើ ហើយអាចធ្វើ គឺសម្រាប់អ្នក និង គ្រួសាររបស់អ្នក ។ ហើយសូមចងចាំថា នេះពុំមែនដូចជាព្រះវិហារដទៃទៀតនោះទេ វាគឺជាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទដែលបានស្តារឡើងវិញ ។*

**កំណត់ចំណាំ**

1. *Washington’s Farewell Address,* បានបោះពុម្ពដោយ ថូម៉ាស អាយល ក្លាក (ឆ្នាំ 1908), ទំព័រ 14 ។
2. *Teachings of Presidents of the Church: Harold B. Lee* ឆ្នាំ 2000), ទំព័រ 148 ។
3. សូមមើល *Teachings: Harold B. Lee,* ទំព័រ 148–49 ។
4. *Teachings of Presidents of the Church: Joseph Smith* ឆ្នាំ 2007), ទំព័រ 284 ។
5. *Teachings of Presidents of the Church: George Albert Smith* (ឆ្នាំ 2011), ទំព័រ7–8 ។



ដោយ អែលឌើរ ដេវីឌ អេស. ប៉ាកស្ទើរ
នៃពួកចិតសិបនាក់

# ការទុកចោលនូវ ភាពមិនអនុគ្រោះ ចោលមួយអន្លើរ

*ពេលវេលានឹងមកដល់ជាពេលដែលយើងអាចទុកនូវភាពមិនអនុគ្រោះចោលមួយអន្លើរ ដោយមានជំនួយរបស់ព្រះអម្ចាស់ ហើយងើបចេញពីភាពងងឹតទៅកាន់ពន្លឺដ៏លើសលប់ ។*

ទំនុកដំកើងដ៏អស្ចារ្យមួយនៃការស្ដារឡើងវិញ បានទិពន្ធដោយ ប៉ាលី ភី ប្រាត្ត បាននិយាយអំពីរបៀបដែលវាំងននសេចក្ដីងងឹតនៃការក្បត់សាសនា បានបើកឡើងទៅរកពន្លឺដ៏រុងរឿងនៃសេចក្ដីពិតដែលបានស្ដារឡើងវិញ ៖

*ថ្ងៃរះឡើងហើយស្បៃងងឹតឃ្លាត*
*មើលទង់ស៊ីយ៉ូនត្រដាងលាលាត*
*ព្រលឹមស្រាងៗនៃថ្ងៃរះថ្មី*
*ព្រះចេស្ដាទ្រង់រះលើផែនដី ។*
*ពពកខ្មៅងងឹតរសាត់បាត់*
*ចេញពីមុខរស្មីនៃក្ដីពិត...*
*សិរីរុងរឿងចែងចាំពីឆ្ងាយ*
*មិនយូរនឹងរះលើសាសន៍ទាំងពួង ។*[1]

គួរឱ្យអស្ចារ្យណាស់ សាវកប៉ុល ក៏បានប្រើសទិសន័យអំពីពន្លឺនៅក្នុងការពន្យល់អំពីរបៀបដែលគាត់អាចថ្លែងទីបន្ទាល់ថា « ដែលយើងខ្ញុំត្រូវគេសង្កត់សង្កិនគ្រប់ជំពូក តែមិនទ័លផ្លូវឡើយ មានសេចក្ដីវិលវល់ តែមិនទ័លគំនិតទេ មានគេធ្វើទុក្ខ តែមិនមែនត្រូវចោលនៅម្នាក់ឯងទេ ត្រូវគេវាយដួលស្ដូក តែមិនស្លាប់ទេ » (កូរិនថូសទី 2 4:8–9) ។

គាត់បានពន្យល់អំពីការរត់គេចរបស់គាត់ចេញពីចំណុចនេះមកដល់ពេលនេះថា ៖ « ត្បិតគឺជាព្រះ ដែលមានបន្ទូលបង្គាប់ឱ្យមានពន្លឺភ្លឺចេញពីសេចក្ដីងងឹត ទ្រង់បានបំភ្លឺមកក្នុងចិត្តយើងខ្ញុំ ឱ្យយើងខ្ញុំមានរស្មីពន្លឺនៃដំណើរស្គាល់សិរីល្អរបស់ព្រះ ដែលនៅព្រះភក្ត្រនៃព្រះយេស៊ូវគ្រីស្ទ » ។ (កូរិនថូសទី 2 4:6) ។

យើងរាល់គ្នាភាគច្រើន នៅពេលខ្លះក្នុងជីវិតរស់នៅរបស់យើងមានអារម្មណ៍ដឹងអំពីខ្យល់គ្រសៀកៗនៃភាពមិនអនុគ្រោះ ។ ព្យុះកើតឡើង ខ្យល់បក់បោក ភ្លៀងធ្លាក់ចុះ ហើយទឹកជន់ឡើង ។ វាហាក់ដូចជាគ្មានចុងបញ្ចប់ទេ ថាយើងប្រឈមមុខនឹងអនាគតជាមួយនឹងភាពមិនពិតប្រាកដ និង ភាពសង្ស័យ, ការសាកល្បង និង ទុក្ខព្រួយ ។

ក៏ជួបប្រទះនឹងព្យុះសង្ឃរាម្ដងម្កាលផងដែរ យើងអាចជួបប្រទះនឹងខ្យល់ព្យុះដ៏រន្ធត់ និង ព្យុះនៃភាពចលាចល ដែលអាចបំផ្លាញទំនុកចិត្តរបស់យើង ហើយអង្រួនអារម្មណ៍នៃតម្លៃផ្ទាល់ខ្លួនរបស់យើង ។ អ្វីគ្រប់យ៉ាងដែលយើងស្រឡាញ់ អាចនឹងរបូតទៅមួយ



រំពេចភ្នែក របូតចេញពីដៃរបស់យើង ។ ការផ្លាស់ប្ដូរចំបងក្នុងជីវិត អាចធ្វើឱ្យយើង បាត់តុល្យភាព ដែលរំខានដល់លំនឹងនៃវិញ្ញាណរបស់យើង ។

ប្រហែលជាការបញ្ឈប់ពីការងារដោយពុំបានរំពឹងទុក នាំទៅរកការអត់ការងារធ្វើរយះពេលយូរ ខ្វះសេរីភាពខាងហិរញ្ញវត្ថុ បានកាត់បន្ថយជម្រើស ឬ វិបត្តិប្រាក់បញ្ចាំ បានបន្សល់ឱ្យយើងមាននូវបញ្ហាហិរញ្ញវត្ថុ ។ ប្រហែលជាចូលនិវត្តន៍បន្ទាប់ពីធ្វើការរយះពេលយូរ, ជាប់រវល់ និង ចម្រុងចម្រើន បាននាំមកនូវអារម្មណ៍នៃការបរាជ័យ ។ ប្រហែលជាការឈឺ ឬ អសមត្ថភាពភ្លាមៗ បន្សល់ទុកឱ្យយើងនូវអារម្មណ៍ « ជាប់ឃុំ » គ្មានប្រយោជន៍, គ្មានក្ដីសង្ឃឹម និង ពុំពិតប្រាកដ ។ នៅក្នុងកាលៈទេសៈដូច្នេះ ភាពភ័យខ្លាចអាចនឹងកើតមានយ៉ាងងាយ ខណៈដែលសេចក្ដីជំនឿអាចនឹងពិបាកដើម្បីទទួល ។

ខ្ញុំដឹងរឿងទាំងអស់នេះដោយខ្លួនឯង ។ ខណៈដែលជាសះស្បើយពីការវះកាត់ដើម្បីយកសាច់ដុះពីរដុំធំក្នុងខួរក្បាលចេញ ខ្ញុំបានជួបបទពិសោធន៍ស្រងេះស្រងោចហើយស្រងាកចិត្តមួយរយះដោយសារការប៉ះទង្គិចដល់អារម្មណ៍ និង ខួរក្បាលអំពីរឿងទាំងអស់នោះ ។ ខ្ញុំបានរកឃើញថា ខ្ញុំពុំមែនមិនអាចទប់ទល់បាន ដូចដែលខ្ញុំបានគិតនោះទេ ។ ថ្នាំពុំបានជួយនោះទេ ហើយការលាប់ជម្ងឺម្ដង ឬ ពីរដងឡើងវិញ បាននាំមកនូវការអស់សង្ឃឹមបន្ថែមទៀត ។ ខ្ញុំបានចាប់ផ្ដើមមានអារម្មណ៍សោកស្ដាយចំពោះខ្លួនខ្ញុំ ។

## ចូរសម្រេចចិត្តថាសប្បាយរីករាយ

នោះមានរឿងល្អៗមួយចំនួនចាប់ផ្ដើមកើតមានឡើង ។ មិត្តល្អ និង អ្នកដឹកនាំសាសនាចក្រដែលគួរទុកចិត្ត ផ្ដល់នូវការគាំទ្រ និង ការយល់ចិត្តរបស់ពួកគាត់ ហើយខ្ញុំបានចាប់ផ្ដើមស្ដាប់តាមដំបូន្មាន ហើយទទួលយកការលើកទឹកចិត្តរបស់ពួកគាត់ ។ នាយប់ជ្រៅមួយ នៅពេលខ្ញុំបានចែកចាយអារម្មណ៍សោកសៅរបស់ខ្ញុំជាមួយនឹងកូនប្រុសពៅរបស់យើង គាត់បាននិយាយថា « មែនហើយ លោកប៉ា ខ្ញុំតែងតែគិតថា សុភមង្គលគឺជាការសម្រេចចិត្តមួយ » ។ គាត់និយាយត្រូវ ។

ខ្ញុំបានរកឃើញថា ខ្លួនខ្ញុំបង្កើននូវការដឹងគុណចំពោះគ្រប់ពរជ័យទាំងអស់ ដែលខ្ញុំនៅតែរីករាយ ។ ខ្ញុំបានរកឃើញដោយខ្លួនឯងថា « [ការសាកល្បង] បែបយ៉ាងនេះ វាចេញទៅដោយសារតែការអធិស្ឋាន ហើយនឹងតមអត់ប៉ុណ្ណោះ » (ម៉ាថាយ 17:21) ។

ខ្ញុំមានអារម្មណ៍ទទួលកម្លាំង ទទួលអំណាចធ្វើឱ្យស្រស់ថ្លា និង ទទួលក្ដីស្រឡាញ់របស់ព្រះអង្គសង្គ្រោះ ។ ខ្ញុំបានរីករាយជាមួយប៉ុលនូវចំណេះដឹងដែលថា សេចក្ដីទុក្ខលំបាក, សេចក្ដីវេទនា, សេចក្ដីបៀតបៀន ពុំអាចបំបែកខ្ញុំចេញពីសេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទទេ (សូមមើលរ៉ូម 8:35) ។

ជាកុសលល្អ សេចក្ដីពិតប្រកបដោយក្ដីសង្ឃឹម និង ភាពជឿជាក់ មិនថាមានរឿងអ្វីនោះទេ យើងអាចរកបានកម្លាំង និង ការលើកទឹកចិត្ត ។ បន្ទុករបស់យើង អាចបាន

*ជួនកាល ទោះបីជាជំនឿរបស់យើងមើលទៅពុំធំជាងគ្រាប់ពូជមួយគ្រាប់ក្ដី នៅពេលយើងឆ្ពោះទៅមុខ នោះការដឹកនាំពីព្រះ នឹងទៅជាមួយយើងឆ្ពោះទៅមុខ ។ បើយើងស្វែងរកជំនួយពីស្ថានសួគ៌ នោះយើងនឹងបានទទួល—ប្រហែលជាមកតាមរបៀបដែលពុំបានរំពឹងទុក ។*

សម្រាល ទោះបីជាវាពុំរលត់បាត់ទៅភ្លាមៗក្ដី ។ យើងអាចងើបចេញពីជម្រៅនៃភាពងងឹតបំផុតបាន ដោយប្ដេជ្ញាចិត្តកាន់តែរឹងមាំ ហើយកាន់តែខ្លាំងដើម្បីធ្វើនូវអ្វីដែលត្រូវ ប្រែក្លាយជាបុរស និង ស្ត្រីកាន់តែល្អ ។

យើងនឹងបានបណ្ដុះចរិតលក្ខណៈមួយ ដែលអាចជួយយើងប្រឈមមុខ និង ទប់ទល់នឹងការសាកល្បងនាពេលអនាគត ដោយសារការពិសោធន៍បញ្ជាក់នៅក្នុងភ្លើងបន្សុតនៃការលំបាក ។ ជាលទ្ធផល យើងអាចប្រើបទពិសោធន៍របស់យើង ដើម្បីលើកដំកើង និង ចេះយល់ចិត្តអ្នកដទៃ ។ គំរូនៃការអត់ធ្មត់ផ្ទាល់ខ្លួនរបស់យើង អាចផ្ដល់ក្ដីសង្ឃឹមដល់អ្នកដទៃ ហើយបំផុសគំនិតដល់គ្រួសាររបស់យើង ។ យើងក្លាយខ្លួនកាន់តែសមនឹងអនាគត ។

ខណៈដែលភាពមិនអនុគ្រោះ អាចនឹងមិនងាយចាកចេញពីយើង *នោះយើងអាចជ្រើសរើស* ដើម្បីចាកចេញពីវានៅគ្រប់ពេល ។ ការសន្យារបស់ព្រះអម្ចាស់ចំពោះយើង គឺដូចជាការសន្យារបស់ទ្រង់ចំពោះអាលម៉ា និង រាស្ត្ររបស់គាត់ នៅក្នុងកណ្ដាលការបៀតបៀនដែលគួរឱ្យញញើត ៖

« ចូរងើបក្បាលឡើង ហើយចូរក្សាន្តចិត្តចុះ ព្រោះយើងដឹងនូវសេចក្ដីសញ្ញា ដែលអ្នករាល់គ្នាបានធ្វើជាមួយនឹងយើង ហើយយើងនឹងធ្វើសេចក្ដីសញ្ញាជាមួយនឹងរាស្ត្រយើង ហើយនឹងដោះពួកគេឱ្យរួចផុតពីសេវកភាព ។

« យើងនឹងសម្រាលបន្ទុកទាំងឡាយដែលដាក់នៅលើស្មាអ្នកផង ហើយសូម្បីតែរូបអ្នកក៏នឹងមិនអាចចាប់អារម្មណ៍ថា មានបន្ទុកទាំងនោះនៅលើខ្នងអ្នកឡើយ » (ម៉ូសាយ 24:13–14) ។

បន្ថែមពីលើនោះទៀត ព្រះអម្ចាស់បានបញ្ជាក់ថា « ខ្ញុំមិនចោលអ្នករាល់គ្នាឱ្យនៅកំព្រាទេ ខ្ញុំនឹងមកឯអ្នករាល់គ្នាវិញ » (យ៉ូហាន 14:18) ។

## ស្វែងរកជំនួយពីសួគ៌ា

ជំនួយពីសួគ៌ា ពុំអាចមើលឃើញនឹងភ្នែកដាក់ស្ដែងទេ ។ យើងពុំអាចមើលឃើញ ឬ ដឹងភ្លាមថា បន្ទុកដទៃទៀតមួយចំនួន ដែលបានកើតមានមកលើយើង ត្រូវបានសម្រាល និង បានបង្វែរចេញពីមាត់ច្រកយើងនោះទេ ។

ព្រះអម្ចាស់បានអះអាងថា ៖ « មើលចុះ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា ព្រះនេត្ររបស់យើងកំពុងទតមើលមកលើអ្នក ។ យើងនៅកណ្ដាលពួកអ្នក ហើយអ្នករាល់គ្នាពុំអាចមើលយើងឃើញទេ » (គ. និង ស. 38:7) ។

ប្រាកដណាស់ យើងអាចនឹងចាំបាច់ត្រូវអត់ធ្មត់យ៉ាងខ្លាំងជាមួយនឹងអ្នកដទៃ និង ខ្លួនយើង ជាញឹកញាប់វាត្រូវការពេលវេលាដើម្បីឱ្យអ្វីៗគ្រប់យ៉ាងបានដោះស្រាយ ។ ជួនកាល ទោះបីជាជំនឿរបស់យើងមើលទៅពុំធំជាងគ្រាប់ពូជមួយគ្រាប់ក្ដី នៅពេលយើងឆ្ពោះទៅមុខ នោះការដឹកនាំពីព្រះនឹងទៅជាមួយយើងឆ្ពោះទៅមុខ ។ បើយើងស្វែងរកជំនួយពីស្ថានសួគ៌ នោះយើងនឹងបានទទួល—ប្រហែលជាមកតាមរបៀបដែលពុំបានរំពឹងទុក ។

យើងអាចរកឃើញថា មានលទ្ធភាពថ្លែងអរគុណចំពោះអ្វីដែលយើងមាន ជាជាងទួញសោកចំពោះអ្វីដែលយើងបានបាត់បង់ ។ គួរឱ្យចាប់អារម្មណ៍ណាស់ ជាញឹកញាប់យើងស្ដាប់ឮគំនិតដូចគ្នាដែលបានបង្ហាញ មកពីអ្នកទាំងឡាយដែលបានបាត់បង់នូវទ្រព្យសម្បត្តិខាងលោកិយរបស់ពួកគេទាំងអស់ នៅក្នុងគ្រោះធម្មជាតិ ដូចជាភ្លើងឆេះព្រៃ, ទឹកជំនន់ និង ខ្យល់ព្យុះជាដើម ។ ស្ទើរតែនៅក្នុងគ្រប់ករណីទាំងអស់ ពួកគេនិយាយថា « យ៉ាងហោចណាស់ យើងនៅមានអ្វីដែលសំខាន់ពិតប្រាកដ » ។

ទីបន្ទាល់របស់ប៉ុល គឺជាការលើកទឹកចិត្តថា ៖

« ខ្ញុំបានរៀនឱ្យសេចក្ដីសន្ដោសក្នុងសណ្ឋានគ្រប់យ៉ាង ។

« ខ្ញុំធ្លាប់ទ្រាំឱ្យមានសេចក្ដីចង្អៀតចង្អល់ ហើយក៏ធ្លាប់មានសេចក្ដីរីករាយដែរ ខ្ញុំធ្លាប់ទាំងឆ្អែត ទាំងឃ្លាន ទាំងមាន ទាំងខ្វះក្នុងសារពើទាំងអស់ហើយ ។

« ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បាន ដោយសារព្រះគ្រីស្ទដែលទ្រង់ចម្រើនកម្លាំងដល់ខ្ញុំ » (ភីលីព 4: 4:11–13).

ដូចដែលបានសរសេរថា « រាល់រឿងដែលពុំយុត្តិធម៌ទាំងអស់ក្នុងជីវិត អាចត្រូវបានធ្វើឱ្យទៅជាយុត្តិធម៌ តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ » ។[2]

មិនថាកាលៈទេសៈរបស់យើងយ៉ាងណាទេ នោះនឹងមានពេលមួយ ដែលយើងអាចទុកចោលនូវភាពមិនអនុគ្រោះមួយអន្លើរ ហើយដោយមានជំនួយរបស់ព្រះអម្ចាស់ នោះយើងអាចងើបចេញពីភាពងងឹតទៅរកពន្លឺដ៏លើសលប់ ។ ■

**កំណត់ចំណាំ**

1. "The Morning Breaks," *Hymns,* ទំព័រ. 1 ។
2. *ផ្សាយដំណឹងល្អរបស់យើង ៖ សៀវភៅណែនាំសម្រាប់ការបម្រើផ្សព្វផ្សាយសាសនា* (ឆ្នាំ 2004),ទំព័រ 52 ។

# ពុំនៅម្នាក់ឯងឡើយ

ដោយអានទ្រៀ ដានី គ្វីលឡា-ស្វូឡេតា

កាលពីបីឆ្នាំមុន ខ្ញុំបានមានឱកាសដើម្បីសាកល្បង ។ ខ្ញុំបានដឹងថា មិនថាអ្នកឆ្លងកាត់អ្វីខ្លះនោះទេ ជាមួយនឹងព្រះ អ្នកពុំត្រូវបានទុកចោលឱ្យធ្វើកិច្ចការនោះតែម្នាក់ឯងឡើយ ។

មិនយូរប៉ុន្មាន បន្ទាប់ពីខួបកំណើត 16 ឆ្នាំរបស់ខ្ញុំ ខ្ញុំបានរកឃើញថា ខ្ញុំមានជម្ងឺតាអក ។ វាពិបាកណាស់ ដែលរាល់ព្រឹក ខ្ញុំត្រូវមើលទៅក្នុងកញ្ចក់ ហើយមើលឃើញស្នាមកន្ទួលដែលមាននៅលើរូបរាងកាយខ្ញុំនោះ ។ ខ្ញុំបានប្រាប់ខ្លួនឯងឱ្យមើលទៅរឿងនេះ ជាឱកាសមួយដើម្បីទទួលការសាកល្បង ។ ជំនួសឱ្យអារម្មណ៍សោកសៅចំពោះខ្លួនខ្ញុំ នោះខ្ញុំបានព្យាយាមធ្វើនូវអ្វីដែលគ្រូបង្រៀនយុវនារីរបស់ខ្ញុំបានបង្រៀនខ្ញុំថា ៖ ចូររាប់ពរជ័យរបស់ខ្ញុំរាល់ថ្ងៃ ដោយពុំគិតពីការសាកល្បងរបស់ខ្ញុំ ។ ទោះជាខ្ញុំពុំមានស្បែកជ្រះស្អាតនាពេលនេះក្ដី ក៏ខ្ញុំមានអំណរគុណចំពោះគ្រួសារ និងមិត្តភក្ដិរបស់ខ្ញុំ និង ទេពកោសល្យខាងតន្ត្រីរបស់ខ្ញុំដែរ ។ ខ្ញុំមានអំណរគុណចំពោះជើងពីរ, ដៃជើងពីរ, ភ្នែកដើម្បីមើល និង ត្រចៀកដើម្បីស្ដាប់ ។ ខ្ញុំដឹងថា ភាពស្រស់ស្អាតពិតគឺស្ថិតនៅក្នុងខ្លួនបុគ្គលនោះ ពុំមែនស្ថិតនៅផ្នែកខាងក្រៅនោះទេ ។

ប៉ុន្តែជម្ងឺតាអករបស់ខ្ញុំ បានចាប់ផ្ដើមមានឥទ្ធិពលមកលើអារម្មណ៍បន្តិចម្ដងៗ ។ ខ្ញុំឈប់មានភាពរួសរាយដូចពីមុន ហើយឈប់ញញឹម ។ វេជ្ជបណ្ឌិតជាច្រើន ដែលខ្ញុំបានទៅពិគ្រោះជាមួយ បានអះអាងថា ខ្ញុំនឹងបាន « ស្អាតជាសះស្បើយ » មុនពេលបុណ្យគ្រីស្ទម៉ាស់ ។ ប៉ុន្តែខ្ញុំពុំបានជាសះស្បើយទេ ។ ខ្ញុំបានអធិស្ឋានជារៀងរាល់ថ្ងៃ សុំកម្លាំងដើម្បីយកឈ្នះភាពខ្មាស់អៀន ចំពោះជម្ងឺសើស្បែករបស់ខ្ញុំនេះ ។

មនុស្សគ្រប់គ្នាបន្តប្រាប់ខ្ញុំឱ្យឈប់គិតអំពីស្ថានភាពលំបាករបស់ខ្ញុំទៅ ថាខ្ញុំគួរតែធ្វើតាមធម្មតា ហើយធ្វើដូចជាគ្មានអ្វីខុសប្លែកកើតឡើងនៅលើស្បែករបស់ខ្ញុំ ។ ប៉ុន្តែនេះពុំមែនជារឿងងាយស្រួលធ្វើនោះទេ ។ ម៉ាក់របស់ខ្ញុំបានអានរឿងគម្ពីរម្ដងហើយម្ដងទៀតដោយទន់ភ្លន់ ដោយសង្ឃឹមថា នឹងលួងលោម ហើយលើកទឹកចិត្តខ្ញុំ ។

គោលលទ្ធិ និង សេចក្ដីសញ្ញា 24:8 និយាយថា « ចូរមានចិត្តអត់ធន់ក្នុងការឈឺចាប់ ត្បិតអ្នកនឹងមានដ៏ច្រើន ប៉ុន្តែចូរទ្រាំទ្រចុះ ត្បិតមើលន៏ យើងនៅជាមួយនឹងអ្នក គឺដរាបដល់អស់មួយជីវិតរបស់អ្នក » ។ បទគម្ពីរនេះបានផ្ដល់នូវពាក្យសម្ដីឱ្យខ្ញុំរស់នៅតាម ។ ខ្ញុំបានសរសេរវាដាក់នៅលើវត្ថុស្បៀតចំណាំក្នុងសៀវភៅ, សរសេរនៅក្នុងសៀវភៅកំណត់ហេតុ និងដាក់វានៅក្នុងបន្ទប់របស់ខ្ញុំ ។ ឥឡូវវាជាខគម្ពីរមួយដែលខ្ញុំពេញចិត្ត សម្រាប់លើកទឹកចិត្តខ្ញុំឱ្យខិតខំអស់ពីលទ្ធភាព ដោយពុំគិតអំពីការសាកល្បងរបស់ខ្ញុំ ។



កូនចៀមដែលបាត់ ដោយ ដេល ផាសុន

ការស៊ូទ្រាំនឹងការសាកល្បងនេះ គឺជាការលំបាក ប៉ុន្តែឥឡូវខ្ញុំបានរៀបចំខ្លួនកាន់តែប្រសើរសម្រាប់ការសាកល្បងនាពេលខាងមុខ ។ ព្រះវរបិតាសួគ៌បានរៀបចំខ្ញុំ ដើម្បីខ្ញុំអាចគ្រប់គ្រងនូវឧបសគ្គនានាដែលនឹងកើតមាន ។ ឥឡូវខ្ញុំដឹងថា មិនថាខ្ញុំឆ្លងកាត់រឿងអ្វីនោះទេ ខ្ញុំពុំត្រូវធ្វើវាតែម្នាក់ឯងឡើយ ។ ■

ដោយ ឡូរ៉ា អែហ្វ. វិលលីស

# ពួកព្យាការីនៅរដូវបុណ្យគ្រីស្ទម៉ាស់



ជីវិតរស់នៅរបស់ពួកព្យាការីថ្ងៃចុងក្រោយចំនួន 16 នាក់របស់យើង បានធ្វើជាគំរូនៃអារម្មណ៍បុណ្យគ្រីស្ទម៉ាស់ រំឭកដល់យើងអំពីព្រឹត្តការណ៍ដែលពុំអាចប្រៀបផ្ទឹមបាន ដែលបានកើតឡើងនៅក្នុងស្នូកនៅភូមិបេថ្លេហិម កាលពីជាង 20 សតវត្សន៍កន្លងទៅ ៖ កំណើតនៃព្រះអង្គសង្គ្រោះរបស់យើង គឺព្រះយេស៊ូវគ្រីស្ទ ។ យើងពុំដើរខុសផ្លូវទេ បើយើងធ្វើតាមគំរូរបស់ពួកគាត់—ជាពិសេសនៅបុណ្យគ្រីស្ទម៉ាស់ ។

### អំណោយនៃក្ដីស្រឡាញ់

ការផ្ដល់អំណោយនៃក្ដីស្រឡាញ់ និង ការបម្រើ ដល់អ្នកទាំងឡាយដែលពុំសូវមានសំណាង បានធ្វើជាសញ្ញាមួយនៃបទពិសោធន៍បុណ្យគ្រីស្ទម៉ាស់របស់ព្យាការី ។ នៅឆ្នាំ 1931 អំឡុងពេលវិបត្តិធ្ងន់ធ្ងរ ប្រធាន ហារ៉ូល ប៊ី. លី គឺជាប្រធានស្តេកធំមួយ នៅក្នុងទីក្រុងសលត៍ ឡេក រដ្ឋយូថាហ៍ ។ ប្រធាន លី បានប្ដេជ្ញាចិត្តថា គាត់ត្រូវដឹងអំពីសេចក្ដីត្រូវការរបស់សមាជិកស្តេករបស់គាត់ ហើយធ្វើអ្វីគ្រប់យ៉ាង ដែលគាត់អាចធ្វើដើម្បីសម្រាលតម្រូវការរបស់ពួកគេ ។ តាមរយៈការស្ទង់មតិ គាត់បានដឹងថា មានមនុស្សច្រើនជាងពាក់កណ្ដាលនៅក្នុងស្តេករបស់គាត់ ជិត 5,000 នាក់ បានពឹងផ្អែកលើគ្នាទៅវិញទៅមកសម្រាប់ជំនួយ រួមមានទាំងកុមារជាង 1000 នាក់ ដែលមានអាយុក្រោម 10 ឆ្នាំ ។ គាត់បានចល័តសមាជិកឱ្យប្រមូលសម្ភារក្មេងលេង ហើយបានរៀបចំរោងជាង ដើម្បីជួសជុល, លាបពណ៌ និង សម្អាតសម្ភារក្មេងលេងចាស់ៗ ឬធ្វើសម្ភារក្មេងលេងថ្មី ដើម្បីឱ្យកុមារគ្រប់រូបទទួលបានមួយសម្រាប់បុណ្យគ្រីស្ទម៉ាស់ ។ គាត់បានសម្រេចចិត្តថា គ្រប់គ្រួសារនៅក្នុងស្តេក គួរមានអាហារពេលល្ងាចសម្រាប់បុណ្យគ្រីស្ទម៉ាស់ ហើយបានសុំការបរិច្ចាគអាហារ ដើម្បីធ្វើឱ្យរឿងនោះកើតឡើងបាន ។[1] ក្រោយមក ក្នុងនាមជាសាវកមួយរូប អែលឌើរ លី ត្រូវបានគេសុំឱ្យរៀបចំកម្មវិធីសុខុមាលភាពរបស់សាសនាចក្រ ដែលផ្ដោតទៅលើគោលការណ៍នៃការបម្រើ, ការលះបង់ និង កិច្ចការស្រដៀងគ្នានេះ ។

ក្នុងនាមជាក្មេងប្រុសម្នាក់ ប្រធាន ថូម៉ាស អេស. ម៉នសុន បានធ្វើពិធីបុណ្យគ្រីស្ទម៉ាស់ នោះមិត្តរបស់លោក បានសួរសំណួរមួយគួរឱ្យភ្ញាក់ផ្អើលថា « តើមាន់



បារាំងដុតមានរសជាតិយ៉ាងម៉េចដែរ ? » គាត់បានឆ្លើយថា វាមានរសជាតិដូចជាសាច់មាន់ ប៉ុន្តែបន្ទាប់មក លោកបានដឹងថា មិត្តអភ័ព្វរបស់គាត់ ពុំដែលបានភ្លក់រសជាតិវាទេ ។ មិនតែប៉ុណ្ណោះសោត ផ្ទះរបស់មិត្តគាត់ គឺគ្មានអ្វីសោះ ដើម្បីរៀបចំសម្រាប់អាហារបុណ្យគ្រីស្ទម៉ាស់ ។ ប្រធាន ម៉នសុន បានមានប្រសាសន៍ថា « ខ្ញុំបានគិតអំពីដំណោះស្រាយមួយ » ។ « ខ្ញុំគ្មានមាន់បារាំង, គ្មានមាន់, គ្មានលុយទេ ។ បន្ទាប់មក ខ្ញុំចាំថា ខ្ញុំមានចិញ្ចឹមសត្វទន្សាយពីរក្បាល ។ ភ្លាមនោះ ខ្ញុំដឹកដៃមិត្តរបស់ខ្ញុំ ហើយរត់ទៅកាន់ទ្រុងទន្សាយ រួចបានចាប់ទន្សាយដាក់ក្នុងប្រអប់មួយ ហើយបានហុចប្រអប់នោះទៅឱ្យគាត់ជាមួយនឹងពាក្យថា ‹ នេះ យកសត្វទន្សាយពីរនេះទៅ ។ វាល្អដើម្បីបរិភោគ—ដូចជាសត្វមាន់ដែរ ។ › ... ទឹកភ្នែកខ្ញុំបានស្រក់ហូរចុះមក នៅពេលខ្ញុំបានបិទទ្វារទ្រុងទន្សាយដែលនៅទទេរនោះ ។ ប៉ុន្តែខ្ញុំពុំសោកស្ដាយទេ ។ អារម្មណ៍កក់ក្ដៅ អារម្មណ៍នៃក្ដីអំណរដ៏អស្ចារ្យ បានមានពេញក្នុងដួងចិត្តខ្ញុំ ។ វាគឺជាបុណ្យគ្រីស្ទម៉ាស់ដែលគួរឱ្យចងចាំមួយ » ។[2]

## ការខិតមកជិតគ្នាជាគ្រួសារមួយ

នៅបុណ្យគ្រីស្ទម៉ាស់ដ៏ផ្អែមល្ហែមមួយ ប្រធាន អែសរ៉ា ថាហ្វ បែនសឹន បានទឹកចាំថា វាបានកើតឡើងនៅក្នុងឆ្នាំ 1923 នៅពេលលោកបានត្រឡប់មកផ្ទះនៅថ្ងៃយប់មុនបុណ្យគ្រីស្ទម៉ាស់ ទៅកាន់ចម្ការគ្រួសារនៅ វីតនី រដ្ឋអៃដាហូ សហរដ្ឋ បន្ទាប់ពីបេសកកម្មពីរឆ្នាំកន្លះទៅកាន់ប្រទេសអង់គ្លេស ។ ការជួបជុំគ្នាជាមួយនឹងឪពុកម្ដាយ និង បងប្អូនប្រុសស្រី 10 នាក់របស់លោកប្រកបដោយអំណរនេះ គឺពោរពេញទៅដោយការរំភើបចិត្ត និង ចិត្តសោមនស្សផងដែរសម្រាប់គ្រីស្ទម៉ាស់ ។ ជាការផ្ដល់ឱកាសពិសេស ឪពុកម្ដាយរបស់លោក បានអនុញ្ញាតឱ្យលោកនៅជួយក្នុងការរៀបចំបុណ្យគ្រីស្ទម៉ាស់ បន្ទាប់ពីកូនៗផ្សេងទៀត ចូលទទួលដំណេកអស់ ។ នៅពេលលោកធ្វើការជាមួយនឹងឪពុកម្ដាយរបស់លោក នោះលោកបានចែកចាយបទពិសោធន៍បេសកកម្មរបស់លោកដោយស្ងាត់ស្ងៀម ។ លោកពុំអាចទប់ទឹកភ្នែក អំឡុងពេល « ល្ងាចដ៏ជម្រើស » នេះ នៅក្នុងគេហដ្ឋានពីកុមារភាពរបស់លោកទេ ។[3]

ជីវិតរបស់ពួកព្យាការី លើកទឹកចិត្តយើងឱ្យខិតទៅជិតនឹងក្រុមគ្រួសាររបស់យើងនៅក្នុងរដូវបុណ្យគ្រីស្ទម៉ាស់ ។ ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ បានទឹកចាំពីបុណ្យគ្រីស្ទម៉ាស់មួយ កាលពីនៅជាឪពុកវ័យក្មេង ជាពេលដែលលោកគ្មានប្រាក់សោះ—គ្មានសូម្បីតែមួយសេន—ដើម្បីទិញអំណោយសម្រាប់កូនៗរបស់លោក ។ មុនពេលបុណ្យគ្រីស្ទម៉ាស់ លោកបានដើរពីផ្ទះ នៅតាមដងផ្លូវ មើលទៅកាន់វត្ថុស្រស់ស្អាតទាំងអស់ដាក់តាំងនៅតាមមាត់បង្អួចហាង ប៉ុន្តែលោកបានដឹងថា លោកពុំអាចទិញអ្វីបានទេ ។ លោកស្ទើរតែអស់សង្ឃឹមទៅហើយ លោកបានទៅកន្លែងស្ងាត់មួយ ហើយបាន « យំដូចជាកូនក្មេង » ដើម្បីរំសាយភាពឈឺចាប់ក្នុងដួងចិត្តរបស់លោក ។ ប៉ុន្តែលោកបានជូតទឹកភ្នែក ហើយដើរទៅផ្ទះ លេងជាមួយនឹងកូនៗរបស់លោកពេញមួយថ្ងៃ « មានតែការដឹងគុណ និង ក្ដីរីករាយសម្រាប់ ពួកគេតែប៉ុណ្ណោះ » ។[4] ដោយមិនគិតពីការអសមត្ថភាពរបស់លោក ក្នុងការផ្ដល់សម្ភារបុណ្យគ្រីស្ទម៉ាស់ដល់កូនៗរបស់លោក នោះលោកបានផ្ដល់នូវអំណោយដ៏អស្ចារ្យបំផុត ដែលឪពុកគ្រប់រូបអាចផ្ដល់ឱ្យគឺ—ក្ដីស្រឡាញ់ និង ពេលវេលារបស់លោក ។

ព្យាការី យ៉ូសែប ស្ម៊ីធ បានចំណាយពេលបុណ្យគ្រីស្ទម៉ាស់ ឆ្នាំ 1838 ជាប់ឃុំឃាំងនៅក្នុងគុកលីប៊ីធី រដ្ឋមីសសួរី ។ លោក និង ដៃគូមួយចំនួនទៀត ត្រូវបានគេដាក់ឃុំនៅក្នុងគុកក្រោមដីតូចមួយ ដែលត្រជាក់, កខ្វក់ ហើយមានពេញដោយផ្សែងមកពីភ្នក់ភ្លើងដែលពួកលោកបង្ខំចិត្តត្រូវប្រើ ។ ពិដានទាបពេក ដែលពួកលោកពុំអាចឈរត្រង់ខ្លួនបានទេ ។ ប៉ុន្តែមានគ្រាល្អមួយនៅរដូវកាលបុណ្យគ្រីស្ទម៉ាស់នោះ ។ ភរិយារបស់ព្យាការី ឈ្មោះ អិមម៉ា អាចមកសួរសុខទុក្ខយ៉ូសែប ក្នុងរយៈពេលខ្លី មុនពេលបុណ្យគ្រីស្ទម៉ាស់ បានពីរបីថ្ងៃ ។ លើសពីនោះ គាត់បាននាំកូនប្រុសរបស់ពួកគាត់មក ឈ្មោះ យ៉ូសែប ស្ម៊ីធ III ។ ដោយសារអារម្មណ៍នៃក្ដីស្រឡាញ់របស់គ្រួសារលោក នោះយ៉ូសែប បានសរសេរពាក្យលើកទឹកចិត្តដល់ពួកបរិសុទ្ធពីក្នុងគុកថា ៖ « យើងមានសិរីល្អនៅក្នុងទុក្ខវេទនារបស់យើង ដោយសារយើងដឹងថា ព្រះគង់នៅជាមួយយើង » ។[5]

នៅក្នុងឆ្នាំ 1937 ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានសម្រុបខ្លួនទៅនឹងជីវិតដែលរស់នៅដោយគ្មានភរិយាជាទីស្រឡាញ់របស់លោក អ៊ីថែល ដែលបានទទួលមរណកាលក្នុងពេលថ្មីៗ ។ អ៊ីថែល បានសុំឱ្យ ចេសស៊ី អ៊ីវ៉ាន ដែលជាស្ត្រីនៅលីវមានសម្លេងពិរោះរន្ធំ ច្រៀងនៅក្នុងពិធីបុណ្យសពរបស់គាត់ ។ តាមរយៈការជួបនោះ ចេសស៊ី អ៊ីវ៉ាន និង យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានស្គាល់គ្នាកាន់តែច្រើន ហើយទាក់ចិត្តគ្នាទៅវិញទៅមករបស់ពួកគាត់ បានរីកស្គុះស្គាយនៅក្នុងក្ដីស្រឡាញ់ ។ គាត់បានទទួលយកការស្នើសុំរៀបការរបស់លោក មិនយូរប៉ុន្មានបន្ទាប់ពីបុណ្យគ្រីស្ទម៉ាស់ ។ ពេលសញ្ជឹងគិតអំពីអំណោយដែលលោកបានទទួលនៅបុណ្យគ្រីស្ទម៉ាស់ ឆ្នាំ 1937 ប្រធានស្ម៊ីធ បានសរសេរថា « ខ្ញុំបានទទួល [ចេសស៊ី] ជា

រូបថត ដោយ ប្រេនដេន ស៊ី អាន់ឌើសុន



អំណោយបុណ្យគ្រីស្ទម៉ាស់ ដែលខ្ញុំមានអំណរគុណយ៉ាងខ្លាំង » ។[6] ពួកគេបានរៀបការ នៅខែមេសាក្រោយមក ។

ទំនៀមទំលាប់គ្រួសារប្រចាំឆ្នាំមួយរបស់ប្រធាន ដេវីឌ អូ. មិកឃេ គឺជាការនាំចៅៗជិះគារទឹកកក ដែលអូសដោយសេះល្អៗមួយហ្វូង « កន្ដឹងឮរីងៗ » ។ ការជិះគារ គឺជាទំនៀមទំលាប់ដ៏រីករាយមួយរបស់ពួកគាត់ ។ ប្រធាន មិកឃេ បានបន្តធ្វើវារហូតដល់លោកមានអាយុ 80 ឆ្នាំ ។ ដើម្បីឱ្យកក់ក្ដៅ ប្រធាន មិកឃេ បានពាក់អាវរងារោមសត្វវែងក្រាស់ និង ពាក់ស្រោមដៃធំ ។ ចៅតូចៗ ជិះនៅលើគារ ប៉ុន្តែចៅធំៗ « មកតាមពីក្រោយជិះលើគាររបស់ពួកគេរៀងៗខ្លួន » បានព្យាយាមទៅតាមក្រោយគាររបស់កុមារតូចៗនោះ ។ ការធ្វើបុណ្យគ្រីស្ទម៉ាស់ដែលគួរចងចាំយូរអង្វែងទាំងនេះ ពេលខ្លះបញ្ចប់ដោយការច្រៀងចម្រៀងនៅជុំវិញព្យាណូ ហើយច្រៀងបទ « ក្ដីស្រឡាញ់នៅក្នុងផ្ទះ » ។[7]

## ទីបន្ទាល់មួយអំពីព្រះយេស៊ូវ គ្រីស្ទ

អ្វីដែលសំខាន់បំផុតនោះ បទពិសោធន៍បុណ្យគ្រីស្ទម៉ាស់អំពីពួកព្យាការីបង្រៀនយើងឱ្យបង្កើនទីបន្ទាល់របស់យើងអំពីព្រះយេស៊ូវគ្រីស្ទ នៅពេលយើងដាក់ទ្រង់ជាចំបងនៅក្នុងការធ្វើពិធីបុណ្យគ្រីស្ទម៉ាស់របស់យើង ។ នៅក្នុងឆ្នាំ 1876 ព្រះវិហារបរិសុទ្ធសេន ចច យូថាហ៍ ជិតសាងសង់ចប់ហើយ ។ ពិធីឧទ្ទិសឆ្លងបន្ទប់ជាន់ក្រោមដី, បន្ទប់ធំ និង បន្ទប់ផ្សាភ្ជាប់ ត្រូវបានដាក់កាលវិភាគថ្ងៃទី 1 ខែមករា ឆ្នាំ 1877 ។[8] នៅបុណ្យគ្រីស្ទម៉ាសគ្រាន់តែរយៈពេលប្រាំពីរថ្ងៃ មុនការឧទ្ទិសឆ្លង មនុស្សជាច្រើននៅទីក្រុង សេន ចច បានធ្វើការយ៉ាងរំភើបចិត្ត ដើម្បីជួយធ្វើយ៉ាងណាឱ្យប្រាកដថាព្រះវិហារបរិសុទ្ធបានបញ្ចប់ទាន់ពេល ។

ប្រធាន វិលហ្វូឌ វូឌរុហ្វ ដែលបានបម្រើជាប្រធានព្រះវិហារបរិសុទ្ធទីមួយ បានកត់ត្រានៅក្នុងកំណត់ហេតុរបស់គាត់ថា នៅថ្ងៃបុណ្យគ្រីស្ទម៉ាស់ បុរសៗបានធ្វើការយ៉ាងមមាញឹកក្នុងការអារឈើ ហើយមានស្ត្រី 40 នាក់បានចំណាយពេលពេញមួយថ្ងៃនៅក្នុងព្រះវិហារបរិសុទ្ធដេរកំរាលព្រំ ។ ពួកគេបានក្រាលកំរាលព្រំ ហើយបានដាក់វាំងនន ។[9]

ថ្វីត្បិតតែពួកគេហៀបនឹងបានបញ្ចប់តាមពេល នោះអំណោយដែលពួកគេឱ្យនៅក្នុងរដូវកាលបុណ្យគ្រីស្ទម៉ាស់នោះពិតជាមានតម្លៃ ។ កិច្ចការនេះ គឺជាការប្រារព្ធបុណ្យគ្រីស្ទម៉ាស់របស់ពួកគេ ។ មានមនុស្ស 2000 នាក់មានវត្តមាននៅថ្ងៃទី 1 ខែមករា ប្រធាន វូឌរុហ្វ បានផ្ដល់ការអធិស្ឋានឧទ្ទិសឆ្លងនូវផ្នែកខ្លះនៃព្រះវិហារបរិសុទ្ធ—រយៈពេលជាង 30 ឆ្នាំ បន្ទាប់ពីពួកបរិសុទ្ធថ្ងៃចុងក្រោយ ត្រូវបានគេបង្ខំឱ្យបោះបង់ព្រះវិហារបរិសុទ្ធណៅវូចោល ។

អំឡុងសង្គ្រាមលោកលើកទី II មានទីក្រុងជាច្រើននៅសហរដ្ឋ បានបង្គាប់ឱ្យបិទភ្លើងពេលយប់ ដើម្បីសន្សំប្រេង ។ នៅក្នុងទីក្រុងសលត៍ លេក ភ្លើងបំភ្លឺនៅលើព្រះវិហារបរិសុទ្ធសលត៍ លេក ត្រូវបានបិទ ។ ព្រះវិហារបរិសុទ្ធឈរនៅក្នុងទីងងឹត ក្នុងទីក្រុងងងឹតអស់រយៈពេលជាច្រើនឆ្នាំ ។ នៅពេលការបញ្ឈប់បាញ់គ្នា ត្រូវបានប្រកាសឡើងនៅក្នុងទ្វីបអឺរ៉ុប នោះប្រធាន ហ៊ីប៊ើរ ចេ គ្រាន្ត បានបង្គាប់ឱ្យភ្លើងបំភ្លឺព្រះវិហារបរិសុទ្ធបើកឡើងវិញ ។



សម្រាប់បុណ្យគ្រីស្ទម៉ាស់ ឆ្នាំ 1945 ប្រធាន ចច អ័លប៊ើត ស្មីធ បានរៀបចំកាតបុណ្យគ្រីស្ទម៉ាស់ដ៏បំផុសគំនិត និង ប្រកបដោយអត្ថន័យ ។ នៅខាងមុខរូបថតនៃកំពូលបីប៉ែកខាងកើតនៃព្រះវិហារបរិសុទ្ធសលត៍ លេកដ៏ស្រស់ស្អាត លេចជាមួយនឹងពណ៌ខៀវចាស់នៅផ្ទៃខាងក្រោយ ដោយមានរូបសំណាកទេវតាមូរ៉ូណៃឈរនៅខាងលើ ។ នៅខាងក្រោមមានពាក្យថា « បុណ្យគ្រីស្ទម៉ាស់—1945 » និង សារ « ពន្លឺត្រឡប់មកជាថ្មី » ។[10] គ្មានអ្វីអាចឆ្លុះបញ្ចាំងពីអារម្មណ៍អំណរល្អដែលមនុស្សគ្រប់រូបមាន បន្ទាប់ពីរយៈពេលជាច្រើនឆ្នាំនៃការស្លាប់ និង ការបំផ្លិចបំផ្លាញនោះទេ ។

ប៉ុន្តែកាតបុណ្យគ្រីស្ទម៉ាស់ដ៏ស្រស់ស្អាតនេះ គឺជារបៀបដែលប្រធាន ស្មីធ ថ្លែងទីបន្ទាល់របស់គាត់អំពីព្រះយេស៊ូវគ្រីស្ទ និង ការស្តារឡើងវិញនៃដំណឹងល្អផងដែរ ។ ដូចជាការបញ្ចប់នៃសង្គ្រាម បាននាំមកនូវភាពសុខសាន្ត និង ពន្លឺនៅក្នុងទីងងឹតវិញ នោះការស្តារឡើងវិញនៃដំណឹងល្អ បន្ទាប់ពីការក្បត់សាសនាអស់រយៈពេលជាច្រើនសតវត្សរ៍ បាននាំពន្លឺនៃសេចក្តីពិត « មកម្តងទៀត » សម្រាប់មនុស្សទាំងអស់ក្នុងពិភពលោក ។

គំរូរបស់ពួកព្យាការីថ្ងៃចុងក្រោយរបស់យើង អំពីសេចក្តីស្រឡាញ់, ការបម្រើ, សេចក្តីជំនឿ និង ការពលិកម្ម ថ្លែងជាទីបន្ទាល់ថា ក្តីអំណរពិតអំឡុងពេលរដូវកាលបុណ្យគ្រីស្ទម៉ាស់ កើតចេញមកតាមរយៈការរស់នៅដូចជាព្រះគ្រីស្ទបានរស់នៅ ។ ដូចជាប្រធាន ហារ៉ើដ ដបុលយូ ហឺនធើរ បានមានប្រសាសន៍ « បុណ្យគ្រីស្ទម៉ាស់ពិត កើតមានដល់គាត់ ដែលយកព្រះគ្រីស្ទដាក់ក្នុងជីវិតរបស់ខ្លួន ជាកម្លាំងចលករ, ថាមពល និង គ្រឿងភ្លា ។ អារម្មណ៍ពិតនៃបុណ្យគ្រីស្ទម៉ាស់ ស្ថិតនៅក្នុងជីវិត និង បេសសកម្មនៃលោកចៅហ្វាយ » ។[11] ■


**កំណត់ចំណាំ**

1. សូមមើល ឡែរី ស៊ី. ផតទើរ "Remembering Christmas Past," *BYU Studies,* វ៉ុលទី 40, លេខ. 3 (ឆ្នាំ 2001)៖ 94–96 ។
2. ថូម៉ាស អេស. ម៉នសុន "Christmas Gifts, Christmas Blessings," *New Era,* ខែ ធ្នូ ឆ្នាំ 1986, ទំព័រ 7 ។
3. សូមមើល ផតទើរ "Remembering Christmas Past," ទំព័រ 104–5 ។
4. យ៉ូសែប អែហ្វ. ស្មីធ "Christmas and New Year» *Improvement Era,* ខែមករា ឆ្នាំ 1919, ទំព័រ 267 ។
5. យ៉ូសែប ស្មីធ នៅក្នុងផតទើរ "Remembering Christmas Past" ទំព័រ 53 ។
6. យ៉ូសែប ហ្វីលឌីង ស្មីធ នៅក្នុងយ៉ូសែប ហ្វីលឌីង ស្មីធ ជុញ្ញ័រ ។ និង ចន ជេ. ស្តូរើត The Life of Joseph Fielding Smith (ឆ្នាំ 1972) ទំព័រ 255 ។
7. សូមមើល ដារីឌ ឡូរិន ម៉ាក់ឃេ *My Father, David O. McKay* (ឆ្នាំ 1989) ទំព័រ 70–71 ។
8. ការឧទ្ទិសឆ្លងចុងក្រោយនៃការសាងសង់ព្រះវិហារបរិសុទ្ធសេន. ចច យូថាហ៍បញ្ចប់ ត្រូវបានធ្វើឡើងនៅរយៈពេលបួនខែក្រោយមក នៅថ្ងៃទី 6–8 ខែ មេសា ឆ្នាំ 1877 ។
9. សូមមើល *Wilford Woodruff's Journal,* បានបោះពុម្ពដោយ ស្កត ជី. ខែននី, វ៉ុល 9 ។ (ឆ្នាំ 1983–85), 7:297 ។
10. សូមមើល អាល់ប៊ើត អិល. ហ្សប៊ែល ជុញ្ញ័រ., "It Being Christmas," *Improvement Era,* ខែ ធ្នូ ឆ្នាំ 1949, ទំព័រ 826–27 ។
11. *The Teachings of Howard W. Hunter,* បានបោះពុម្ពដោយ ក្លេដ ជេ. វិល្លាម (ឆ្នាំ 1997),ទំព័រ 269 ។




**ដោយ អេរីរ៉ុន អិល. វេស្ទ**
ផ្នែកសេវាកម្មបោះពុម្ពផ្សាយរបស់សាសនាចក្រ

# ការផ្លាស់ប្ដូរដ៏ពិសិដ្ឋ

*ព្រះវិហារបរិសុទ្ធ សាន់ សាលវ៉ាឌ័រ អេល សាល់វ៉ាឌ័រ បានធ្វើដំណើរការលើសពីការគ្រាន់តែផ្លាស់ប្ដូរទេសភាព អនុភាពនៃព្រះវិហារបរិសុទ្ធនេះ កំពុងតែផ្លាស់ប្ដូរដួងចិត្ត ក្រុមគ្រួសារ ហើយនឹងប្រទេសជាតិទាំងមូល ។*

**ការផ្លាស់ប្ដូរភ្នំតូចមួយ**

នៅថ្ងៃទី 20 ខែកញ្ញា ឆ្នាំ 2008 មានពួកបរិសុទ្ធថ្ងៃចុងក្រោយប្រមាណ 600 នាក់បានជួបជុំគ្នា នៅលើ ភ្នំតូចមួយ ដែលខ្លួនទទឹកជោគទៅដោយទឹកភ្លៀង នៅក្នុងក្រុងសាន់ សាល់វ៉ាឌ័រ ប្រទេសអេល សាល់វ៉ាឌ័រ ។ ពួកគេបានឈរនៅលើដី ដែលបានប្រើសម្រាប់ដាំដំណាំជាច្រើនឆ្នាំ ។ ក្រោមការដឹកនាំរបស់គណៈប្រធានតំបន់អាមេរិកកណ្ដាល ពួកគេបានអធិស្ឋានរួមគ្នា ហើយបានចែកចាយទីបន្ទាល់។ ពួកគេខ្លះបានយកប៉ែលថ្មីជីកទឹកដីបុរាណ ដោយរំពឹងថានឹងមាននូវការផ្លាស់ប្ដូរមកដល់យ៉ាងឆាប់ៗ ចំពោះទីកន្លែងដ៏ជម្រើសនោះ។

នៅថ្ងៃទី 21 ខែសីហា ឆ្នាំ 2011 ពួកបរិសុទ្ធថ្ងៃចុងក្រោយរាប់ពាន់នាក់ បានស្វាគមន៍គ្នាយ៉ាងរីករាយនៅលើភ្នំតូចដដែលនោះ ។ ទីនោះត្រូវបានកែប្រែទៅជាទីកន្លែងដ៏ពិសិដ្ឋបំផុតនៅក្នុងប្រទេស អេល សាល់វ៉ាឌ័រ ពុំមែនជាចំការដំណាំទៀតឡើយ ។ ពួកបរិសុទ្ធបានជួបជុំគ្នាជុំវិញព្រះវិហារបរិសុទ្ធមួយ ។ ពួកគេបានរង់ចាំដោយអន្ទះសារនូវការមកដល់របស់ព្យាការី ព្យាការី ហិនរី ប៊ី អាវរិងនៃគណៈប្រធាន



*ការជីកបំបែកដីសម្រាប់ព្រះវិហារបរិសុទ្ធ អេល សាលវ៉ាឌ័រ សាន់ សាលវ៉ាឌ័រ គូសជាគំនូសនៃការចាប់ផ្ដើមនូវ ការផ្លាស់ប្ដូរដ៏ពិសិដ្ឋចំពោះតំបន់ ។*

*ជីវិតរបស់នៅរបស់អាម៉ាដូ និង អេវេលិន វិដិល ត្រូវបានផ្លាស់ប្រែ ដោយសារដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទ ដូចជាដែនដីដែលបានផ្លាស់ប្រែដើម្បីសាងសង់ព្រះវិហារបរិសុទ្ធសាន សាលវ៉ាឌ័រ អេល សាលវ៉ាឌ័រ ដូច្នោះដែរ។*

ទីមួយ ដែលបានឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធនោះថ្វាយដល់ព្រះអម្ចាស់។ សមាជិកចាស់ម្នាក់នៃសាសនាចក្រ និយាយស្ទើរតែជាសម្លេងខ្សិបថា ទីកន្លែងនោះ ខុសប្លែកពីទីកន្លែងដែលជុំវិញនោះជា—« ផ្នែកដ៏តូចនៃស្ថានសួគ៌ស្ថិតនៅលើផែនដី » ។

## ការផ្លាស់ប្តូរនៃក្រុមគ្រួសារមួយ

នៅខែមេសា ឆ្នាំ 2010 អេវេលិន វិដិលមានទុក្ខកង្វល់ ដែលស្វាមីរបស់គាត់ អាម៉ាដូ កំពុងតែបាត់បង់សេចក្តីជំនឿរបស់ខ្លួន ។ គាត់មិនបានទៅព្រះវិហារណាមួយអស់រយៈពេល 11 ឆ្នាំមកហើយ ដោយបានធ្វើការសន្និដ្ឋានថាសាសនាចក្រពិត ពុំមានទៀតឡើយ ។ តែខណៈពេលនោះ អេវេលិន មិនដែលឈប់ជឿលើព្រះឡើយ ហើយគាត់បានចេញពីព្រះវិហារមួយ ទៅព្រះវិហារមួយទៀត ប្រុងប្រៀបនឹងស្តាប់ព្រះបន្ទូលរបស់ទ្រង់ ប៉ុន្តែមិនដែលពេញចិត្តនឹងអ្វីដែលគាត់បានឮសោះ។ មានព្រឹកខ្លះ គាត់បានក្រោកឡើងពីដំណេកដោយសម្រក់ទឹកភ្នែក ។ ក្នុងបណ្តាថ្ងៃបែបនោះ គាត់បានទទូចអង្វរសុំការដឹកនាំពីព្រះវរបិតាសួគ៌របស់គាត់ ។ គាត់បានទូលសួរទ្រង់អំពីមូលហេតុដែលគាត់ពុំមានអារម្មណ៍ត្រឹមត្រូវ នៅក្នុងព្រះវិហារណាមួយដែលគាត់ចូលរួម ទោះជាគាត់ពិតជាចង់រៀនអំពីទ្រង់ក្តី ។ គាត់ក៏បានអធិស្ឋានសុំឱ្យក្រុមគ្រួសាររបស់គាត់ នៅថ្ងៃណាមួយនឹងរកឃើញព្រះវិហារត្រឹមត្រូវមួយ ។

នៅថ្ងៃទី 23 ខែសីហា ឆ្នាំ 2011 អាម៉ាដូ និងអេវេលិន វិដិល បានមានបទពិសោធន៍នៃការផ្លាស់ប្តូរមួយ មិនដូចជាការផ្លាស់ប្តូរ ដែលបានកើតឡើងនៅលើទីទួលមួយ នៅក្នុងរដ្ឋធានីរបស់គេឡើយ ។ ស្លៀកពាក់ក្នុងសម្លៀកបំពាក់ពណ៌សពួកគេបានចូលទៅក្នុងបន្ទប់ផ្សារភ្ជាប់ជាមួយកូនស្រីអាយុប្រាំបួន ឆ្នាំរបស់គេឈ្មោះ មីស្ហែល និងកូនប្រុសអាយុបីឆ្នាំរបស់ពួកគាត់ឈ្មោះ គ្រីស្ទាន ។ ពួកគេគឺជាក្រុមគ្រួសារដំបូង ដែលបានផ្សារភ្ជាប់សម្រាប់ពេលនេះ និង ពេលដ៏អស់កល្បជានិច្ច នៅក្នុងព្រះវិហារបរិសុទ្ធសាន់ សាលវ៉ាឌ័រ អេល សាលវ៉ាឌ័រ ។ ដូចជាព្រះវិហារបរិសុទ្ធដែលពួកគេបានចូល ដែលត្រូវបានឧទ្ទិសឆ្លងថ្មីៗសម្រាប់ជាការបម្រើដល់ព្រះអម្ចាស់ នោះពួកគេមានចិត្តតែមួយក្នុងការតាំងចិត្តរបស់ពួកគេ ។

## រឿងរបស់វីដីល

អាម៉ាដូរំឭកឡើងថា « រឿងរបស់យើងបានចាប់ផ្តើមនៅពេលយើងរកឃើញពួកអែលឌើរ—ហើយ ពួកគេក៏បានរកឃើញយើងវិញដែរ » ។ យើងកំពុងតែចាកចេញពីផ្ទះឪពុកម្តាយរបស់អេវេលិន ហើយយើងកំពុងតែកាន់ស្បោងទំនិញខ្លះៗ ។ យើងបានសង្កេតឃើញពួកអែលឌើរ មើលមកយើង ហើយកំពុងតែដើរឆ្លងថ្នល់មកកាន់យើង។ ពួកគេបានសួរដោយរាក់ទាក់ថាប្រសិនបើពួកគេអាចជួយយើងបាទ។

« ពួកគេក៏បានសួរ ប្រសិនបើយើងអាចអនុញ្ញាតឱ្យពួកគេមកជួបនឹងយើង ។ ខ្ញុំឆ្លើយថា បាទ ដោយសារតែការចង់ដឹងបន្ថែម។ រហូតមកដល់ពេលនេះ ខ្ញុំមិនសូវដឹងច្រើនអំពីសាសនាចក្រឡើយ—គ្រាន់តែឮគេនិយាយបន្តិចបន្តួច ប៉ុណ្ណោះ ។

« បន្ទាប់មកខ្ញុំបានយល់ព្រមនឹងអនុញ្ញាតឱ្យពួកអែលឌើរមកជួបយើងនៅផ្ទះ ខ្ញុំបានប្រាប់ប្រពន្ធខ្ញុំថា ‹ កុំទាន់ ត្រេកអរខ្លាំងពេកចំពោះរឿងនេះ ។ កុំយល់ខុសចំពោះខ្ញុំ អំពីការចូលរួមក្នុងសាសនាចក្រឱ្យសោះ ។ ខ្ញុំគ្រាន់តែចង់ដឹងអំពីអ្វីដែលពួកគេនឹងនិយាយតែប៉ុណ្ណោះ ។ ›

« ពួកអែលឌើរបានចាប់ផ្តើមមកជួបយើង ។ ខ្ញុំបានសម្រេចចិត្តនឹងប្រាប់ពួកគេចេញទៅវិញដោយគួរសម ប្រសិនបើពួកគេនិយាយអ្វីដែលមិនត្រឹមត្រូវមកកាន់ខ្ញុំ ។ ប៉ុន្តែពួកគេមានចិត្តទូលាយណាស់ ហើយខ្ញុំបានស្ញប់ស្ញែងក្នុងចិត្ត ដែលពួកគេមិនបាននិយាយអ្វីអាក្រក់អំពី សាសនាចក្រឯទៀតសោះ ។ ពួកគេបានបង្រៀនជាមួយសេចក្តីស្រឡាញ់ និងការព្យាយាម ហើយពួកគេមានអំណត់នៅពេលខ្ញុំបាន សួរសំណួរជាច្រើន ។ ពួកគេបានឆ្លើយតបដោយចិត្តរាក់ទាក់ស្រឡាញ់ចំពោះយើង » ។

បន្តិចម្តងៗ អាម៉ាដូ និង អេវេលិនបានរៀបចំខ្លួនដើម្បីទទួលបុណ្យជ្រមុជទឹក ហើយនឹងពិធីការបញ្ជាក់ជា សមាជិកនៃ សាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ការប្រឈមដ៏ធំបំផុតរបស់អេវេលិនគឺជាពាក្យគតិបណ្ឌិត ។ គាត់សោកស្តាយ ដោយសារត្រូវបោះបង់ចោលចំណង់ផឹកកាហ្វេ ។ អាម៉ាដូ មិនចាំបាច់បោះបង់ចោលទម្លាប់អាក្រក់ណាមួយឡើយ គាត់គ្រាន់តែរៀនតោងជាប់ទៅនឹងសេចក្តីពិតប៉ុណ្ណោះ ។ គាត់បានជឿនូវអ្វីដែលពួកអ្នកផ្សព្វផ្សាយសាសនាកំពុងបង្រៀន ហើយគាត់ព្រមទាំងបានស្គាល់នូវគោលលទ្ធិ និង ការគោរពប្រតិបត្តិទានា ដែលគាត់និង ភរិយាបានមានអារម្មណ៍ដឹងនូវអ្វីដែលបាត់បង់ពីសាសនាចក្រទាំងឡាយឯទៀតដូចជាគ្រួសារដ៏អស់កល្ប បុណ្យជ្រមុជទឹកសម្រាប់អ្នកស្លាប់ ការរាប់អានទិងការរៀបចំនៅក្នុងសាសនាចក្រ ។ ប៉ុន្តែគាត់រុញរានឹងសម្រេចចិត្តទទួលបុណ្យជ្រមុជទឹក ។ គាត់ព្រួយបារម្ភថា គាត់នឹងចូលរួមក្នុងសាសនា ដើម្បីគ្រាន់តែឃើញថាគាត់បានធ្វើការសម្រេចចិត្តខុសប៉ុណ្ណោះ ។

កង្វល់ទាំងនេះមិនយូរប៉ុន្មានបានរសាយចេញទៅ ។ អេវេលិន បានអធិស្ឋានសុំជំនួយ ហើយបានយកឈ្នះលើទម្លាប់ផឹកកាហ្វេរបស់នាង ដោយនិយាយថា « ខ្ញុំ នឹងមិនបណ្តោយឱ្យវា រារាំងខ្ញុំពីការទទួលពរជ័យឡើយ » ។ ក្រោយពីប្រហែលជាពីរខែនៃការមិនសម្រេចចិត្ត អាម៉ាដូ បានសម្រេចចិត្តទទួលបុណ្យជ្រមុជទឹក ។ ឥឡូវនេះ ស្របតាមពាក្យសំដីរបស់ អេវេលិន គាត់និយាយជាញយៗថា « យើងគប្បីឱបក្រសោបគោលលទ្ធិ » ។

*ព្រះវិហារបរិសុទ្ធ នឹងបន្តផ្លាស់ប្តូរជីវិត និង ដួងចិត្តរបស់ ប្រជាជនសាន សាល់វ៉ាឌ័រ ។*



**ការផ្លាស់ប្តូរ និង ពរជ័យទាំងឡាយ**

អាម៉ា,ដូ អេវេលិន និងមីស្វែល បានទទួលបុណ្យជ្រមុជទឹកនិង ពិធីបញ្ជាក់ នៅដើមខែមិថុនា ឆ្នាំ 2011 ។ អេវេលិន និយាយថា « ចាប់តាំងពីពេលដែលយើងបានទទួលបុណ្យជ្រមុជទឹក » « ខ្ញុំអាចមានអារម្មណ៍ថាអ្វីៗទាំងអស់ ចាប់ផ្តើមផ្លាស់ប្តូរ ។ ក្រុមគ្រួសាររបស់ខ្ញុំគឺរួបរួមសាមគ្គីគ្នា នៅក្នុងសាសនាចក្រ ។ យើងបានរកឃើញដំណឹងល្អដែលបានស្តារឡើងវិញ ។ យើងបានមានសេចក្តីល្បួង និងការឈឺស្កាត់នានាតាំងពីពេលនោះមក តែព្រះវរបិតាសួគ៌របស់យើង បានចាក់ព្រះពរជាច្រើនមកលើយើង » ។

អាម៉ាដូ សង្កេតឃើញថា ៖ « ការផ្លាស់ប្តូរដំបូងដែលខ្ញុំសង្កេតឃើញគឺសាមគ្គីភាពនៅក្នុងក្រុមគ្រួសាររបស់ខ្ញុំ ។ គឺពុំមានវិបត្តិដូចមុននោះទេ ប៉ុន្តែយើងចាប់ផ្តើមរួបរួមគ្នាថែមទៀត ។ គោលលទ្ធិនៃដំណឹងល្អបានជួយយើង ។ កាលដែលអ្នកដឹកនាំសាសនាចក្របានបង្រៀនយើង អំពីភាពពិសិដ្ឋនៃក្រុមគ្រួសារ យើងបានគិតបន្ថែមទៀតអំពី គុណតម្លៃដែលយើងផ្តោតទៅលើក្រុមគ្រួសាររបស់យើង » ។

ប៊ីស្សពរបស់ វីជីល សេសា អូរេយ៉ាណា ក៏បានមើលឃើញការផ្លាស់ប្តូរនៅក្នុងជីវិតរបស់គេដែរ ។ ប៉ុន្តែក្រោមពីបុណ្យជ្រមុជទឹករបស់គេ អាម៉ាដូ បានចូលទៅជួបនឹងប៊ីស្សព អូរេយ៉ាណា ហើយនិយាយថា « យើងចង់ថ្វាយដង្វាយមួយភាគក្នុងដប់ ប៉ុន្តែយើងមិនដឹងថាត្រូវថ្វាយធ្វើដូចម្តេចទេ » ។

ប៊ីស្សពអូរេយ៉ាណា បានពន្យល់ថា ដង្វាយមួយភាគក្នុងដប់គឺជា 10 ភាគរយនៃប្រាក់ចំណូលរបស់គេ ។ អាម៉ាដូ មានកង្វល់ខ្លះៗ ។ ក្នុងពេលនោះ អេវេលិន មានការងារមួយ ប៉ុន្តែគាត់គ្មានការងារធ្វើទេ។ « យើងតែងតែខ្វះមុខខ្វះក្រោយ » អាម៉ាដូ បានពន្យល់ដល់ប៊ីស្សពរបស់គាត់ថា « ប៉ុន្តែយើងចង់ថ្វាយដង្វាយមួយភាគក្នុងដប់ » ។

ប៊ីស្សព អូរេយ៉ាណា បានឆ្លើយតបថា « បងប្រុសអើយ ព្រះអម្ចាស់បានធ្វើសេចក្តីសន្យាជាច្រើន » ។ ពួកគេបានអានព្រះគម្ពីរជាមួយគ្នាអំពីពរជ័យដែលបានមកពីការថ្វាយដង្វាយមួយភាគក្នុងដប់ ដោយចិត្តស្មោះ នៅក្នុងព្រះបន្ទូលរបស់ព្រះអម្ចាស់ តាមរយៈព្យាការីម៉ាឡាគីថា ៖ «ចូរនាំយកដង្វាយ 1 ភាគក្នុង 10 ទាំងអស់មកដាក់ក្នុងឃ្លាំងចុះ, ... ហើយល្បងលអញឥឡូវ បើអញមិនបើកទ្វារស្ថានសួគ៌ ដើម្បីចាក់ ព្រះពរមកលើឯង ដែលនឹងគ្មានកន្លែងល្មមទុកបានទេ» (ម៉ាឡាគី 3:10) ។

បន្ទាប់ពីការអានវគ្គគម្ពីរទាំងនេះជាមួយគ្នា ប៊ីស្សព អូរេយ៉ាណា បានសម្លឹងមុខអ្នកប្រែចិត្តជឿថ្មី ហើយបាននិយាយថា « ប្រសិនបើថ្វាយដង្វាយមួយក្នុងដប់មានន័យថា អ្នកមិនអាចបង់ថ្លៃទឹក និង ថ្លៃភ្លើង ចូរថ្វាយដង្វាយមួយភាគក្នុងដប់ ។ បើថ្វាយដង្វាយមួយភាគក្នុងដប់មានន័យថា អ្នកមិនអាចបង់ថ្លៃផ្ទះឈ្នួល ចូរថ្វាយដង្វាយមួយភាគក្នុងដប់ ។ បើថ្វាយដង្វាយមួយភាគក្នុងដប់មានន័យថា អ្នកគ្មានលុយគ្រប់គ្រាន់ដើម្បីនឹងផ្តល់អាហារដល់ក្រុមគ្រួសាររបស់អ្នក ចូរថ្វាយដង្វាយមួយភាគក្នុងដប់ ។ ព្រះអម្ចាស់នឹងមិនបោះបង់ចោលអ្នកឡើយ » ។

ថ្ងៃអាទិត្យក្រោយ អាម៉ាដូ បានទៅជួបប៊ីស្សព អូរេយ៉ាណា ម្តងទៀត ។ លើកនេះគាត់មិនបានសួរសំណួរអ្វីឡើយ ។ គាត់បានហុចស្រោមសំបុត្រមួយដល់ប៊ីស្សពរបស់គាត់ហើយនិយាយថា « ប៊ីស្សព នេះគឺជាថ្វាយដង្វាយមួយភាគក្នុងដប់របស់យើង ។

ប៊ីស្សពអូរេយ៉ាណា និយាយដោយសញ្ជឹងគិតអំពីបទពិសោធន៍នេះថា « តាំងពីពេលនោះមក ពួកគេជាអ្នកថ្វាយដង្វាយមួយភាគក្នុងដប់យ៉ាងស្មោះត្រង់ » ។ ក្រុមគ្រួសារបានទទួលម្ហូបអាហារខ្លះពីឃ្លាំងប៊ីស្សព ក្នុងអំឡុងពេលគ្រាលំបាកខាងហិរញ្ញវត្ថុរបស់គេ ។ ក្រៅពីនោះ ព្រះអម្ចាស់បានប្រទានពរដល់ពួកគេ ដើម្បីធ្វើឱ្យពួកគេអាចថែទាំខ្លួនឯង ។ អេវេលិន បានទទួលការតម្លើងមុខតំណែងការងារ ហើយអាម៉ាដូ រកបានការងារល្អមួយ ។ អេវេលីន ក្រោយមកបានបាត់បង់ការងាររបស់នាង ប៉ុន្តែបានបន្តថ្វាយដង្វាយមួយភាគក្នុងដប់ដើម្បីទទួលពរជ័យខាងវិញ្ញាណនឹងលោកីយចំពោះសេចក្តីស្មោះត្រង់របស់ពួកគេ ។ គ្រាមួយប៊ីស្សព អូរេយ៉ាណា បានសួរអាម៉ាដូ ពីស្ថានភាពហិរញ្ញវត្ថុគ្រួសារ



*ក្រុមគ្រួសាររីជីល គឺជាក្រុមគ្រួសារទីមួយដែលត្រូវបានផ្សារភ្ជាប់ នៅក្នុងព្រះវិហារបរិសុទ្ធសាន់សាលវ៉ាឌ័រ អែល សាល់វាឌ័រ ក្នុងខែសីហា ឆ្នាំ 2011 ។*

យ៉ាងដូចម្ដេចដែរ ។ អាម៉ាដូ បានឆ្លើយតបថា « យើងពុំមានបញ្ហាអ្វីទេ ។ ពេលខ្លះ យើងពុំមានអាហារច្រើនសម្រាប់បរិភោគ ប៉ុន្ដែយើងមានល្មមគ្រប់គ្រាន់ ។ អ្វីដែលសំខាន់បំផុតនោះគឺ យើងទុកចិត្តលើព្រះអម្ចាស់។ »

បន្ទាប់ពីការថ្វាយដង្វាយមួយភាគក្នុងដប់ជាយូរមក អេវេលីន និង អាម៉ាដូ បាននិយាយជាមួយប៊ីស្សព អូរេយ៉ាណា អំពីពរដែលពួកគេបានទទួល ។ យោងទៅម៉ាឡាគី 3:10 ពួកគេបាននិយាយថា « យើងត្រូវបានល្បងលព្រះអម្ចាស់ » ។ ហើយជាការឆ្លើយតបដ៏ពិតចំពោះសេចក្ដីសន្យារបស់ អូរេយ៉ាណា ព្រះអម្ចាស់មិនបានបោះបង់គេឡើយ ។

## ទស្សនះថ្មី

អេវេលីន និងអាម៉ាដូ បាននិយាយដោយទន់ភ្លន់អំពីថ្ងៃដែលក្រុមគ្រួសាររបស់ពួកគេ បានជួបជុំគ្នាក្នុងបន្ទប់ ផ្សារភ្ជាប់ ។ ពួកគេបានព្រួយបារម្ភថា កូនៗរបស់ពួកគេនឹងនៅមិនស្ងៀម ប្រសិនបើពួកគេទទួលអំណោយទានពិសិដ្ឋ ហើយត្រៀមខ្លួនសម្រាប់ទទួលពិធីបរិសុទ្ធផ្សាភ្ជាប់ក្នុងថ្ងៃតែមួយ ។ ពួកគេមានការបារម្ភជាពិសេសអំពីកូនដ៏រពឹសរបស់ពួកគេ ឈ្មោះគ្រីស្ទាន ដែលមានអាយុបីឆ្នាំនោះ ។ ប៉ុន្ដែកូនៗបានចូលទៅក្នុងបន្ទប់ផ្សារភ្ជាប់ដោយមានការវភាពដ៏សុខសាន្ត ដែលបង្ហាញថាពួកគេបានយល់អំពីមូលហេតុដែលពួកគេនៅទីនោះ ។ ហើយដល់ពេលកូនៗចូលរួមក្នុងពិធីផ្សារភ្ជាប់ ដោយមិនចាំបាច់ទទួលពាក្យណែនាំឬការប្រាប់ជាមុន គ្រីស្ទានបានដើរទៅអាសនៈ ហើយលុតជង្គង់ចុះក្បែរឪពុកម្ដាយរបស់គេ ។

អេវេលីន ចាំមើលរូបរបស់ក្រុមគ្រួសារនៅក្នុងកញ្ចក់ ។ អាម៉ាដូក៏និយាយអំពីការមើលឃើញ មិនត្រឹមតែនៅក្នុងព្រះវិហារបរិសុទ្ធប៉ុណ្ណោះទេ ប៉ុន្ដែនៅក្នុងជីវិតប្រចាំថ្ងៃផងដែរ ។ គាត់សម្ដែងនូវអំណរគុណចំពោះទស្សនះដ៏អស់កល្បជានិច្ចដែលឥឡូវនេះដឹកនាំជីវិតរបស់គាត់—ជាទស្សនះវិស័យដែល មីស្ហែល និងគ្រីស្ទាន ហាក់ដូចជាដឹងនៅពេលពួកគេនៅក្នុងដំណាក់របស់ព្រះ ។ ទស្សនះវិស័យនេះបានលាតត្រដាងកាន់តែច្បាស់តាំងពីពេលនោះមក ជាពិសេសក្នុងពេលដែល រីជីល បានស្វាគមន៍ [កូនស្រី] ថ្មីឱ្យចូលមកក្នុងក្រុមគ្រួសារ—[អាន់ទ្រៀ] ដែលបានកើតមកក្នុងសេចក្ដីសញ្ញា [ខែសីហា] ។

## ពន្លឺនៅលើភ្នំមួយ

ក្រុមគ្រួសាររីជីល នឹងត្រូវបានផ្លាស់ប្ដូរជានិរន្តតាមរយះពលិកម្មដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និង ឥទ្ធិពល នៃព្រះវិហារបរិសុទ្ធរបស់ទ្រង់នៅក្នុងទឹកដីរបស់ពួកគេ ។ ពីព្រោះតែដំណាំ បានប្រែក្លាយទៅជាទីធ្លាដ៏ពិសិដ្ឋ នោះផ្ទះពួករបស់គេបានក្លាយទៅជាទីកន្លែងកាន់តែ ពិសិដ្ឋដែរ ។

នៅក្នុងរបៀបជាច្រើន ពួកគេបានធ្វើជាតំណាងនៃសេចក្ដីសន្យារបស់ប្រទេសជាតិទាំងមូល ។ ប្រទេសអេល សាល់វ៉ាឌ័រ គឺជាគេហដ្ឋានដល់ប្រជាជនល្អ ស្មោះត្រង់រាប់លាននាក់ ដែលមានសំឡេងអុកឡុករំខាន រៀងរាល់ថ្ងៃដោយសម្លេង និង ភាពទាក់ទាញនៃលោកិយ៍។ ពួកបរិសុទ្ធសាល់វ៉ាឌ័រ ស្រឡាញ់មាតុភូមិរបស់ខ្លួន ហើយពួកគេបានរកឃើញសេចក្ដីសង្ឃឹមថ្មី ក្នុងពេលពួកគេបានឃើញព្រះវិហារបរិសុទ្ធរបស់ព្រះនៅទីនោះ ។ ពួកគេបានឃើញការបញ្ជាក់នៅក្នុងពាក្យពេជន៍ដូចខាងក្រោម ពីពាក្យអធិស្ឋានឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ ផ្ដល់ដោយប្រធានអារវិង ៖

« យើងអធិស្ឋានសុំឱ្យព្រះប្រទានពរទ្រង់ មកលើប្រទេសជាតិនៃប្រទេសអេល សាល់វ៉ាឌ័រនេះ ។ សូមស្រឡាញ់អស់អ្នកដែលកាន់កាប់ត្រួតត្រា ដើម្បីប្រជាជននឹងពរ ដោយការមានសេរីភាព និងឱកាស ។ សូមឱ្យសន្តិភាពកើតមាននៅលើដែនដី ។

« សូមពង្រីកកិច្ចការរបស់ទ្រង់នៅលើដែនដីនេះ ។ សូមឱ្យសារដំណឹងល្អដក់ជាប់ក្នុងដួងចិត្តប្រជារាស្ត្រទូទាំងប្រទេសជាតិ ។ សូមឱ្យពួកគេចូលទៅក្នុងទឹកនៃពិធីបុណ្យជ្រមុជទឹក ហើយនៅតែស្មោះត្រង់ចំពោះទ្រង់ ។ ...

« ... ដោយមានដួងចិត្តពោរពេញដោយអំណរគុណ យើងសូមឆ្លង និងញែកសំណង់បរិសុទ្ធនេះ និងទីធ្លាជុំវិញនេះចំពោះការសម្រេចតាមព្រះឆន្ទះរបស់ទ្រង់ និងការបំពេញកិច្ចការដ៏អស់កល្បជានិច្ច របស់ទ្រង់ ។ យើងអធិស្ឋានសុំឱ្យអនុភាពរបស់អគារនេះ បានជ្រោតជ្រាបទូទាំងដែនដី ជាពន្លឺនៅលើភ្នំមួយ » ។[1]

អនុភាពជាច្រើននេះ គឺពិតជាបានទទួលអារម្មណ៍តាមរយះការបម្រើ និងគំរូនៃប្រជាជនដូចជា ក្រុម គ្រួសាររីជីល ។ ទាំងជូតទឹកភ្នែក ដោយក្ដុកក្ដួលក្នុងចិត្តនិយាយមិនចេញ អាម៉ាដូ រីជីល ឥឡូវនេះ និយាយដោយក្ដីស្រឡាញ់ ចំពោះពួកអ្នកផ្សព្វផ្សាយសាសនា ដែលបានជួយឱ្យគាត់ និងក្រុមគ្រួសារឱ្យមកឯព្រះគ្រីស្ទ និងដើម្បីទទួល ពរជ័យនៃព្រះវិហារបរិសុទ្ធ ។ គាត់និយាយថា « យើងគ្រាន់តែសង្ឃឹមថាកូនៗរបស់យើងនឹងបម្រើបេសកកម្មដើម្បីឱ្យពួកគេអាចផ្ដល់ពរជ័យដល់ក្រុមគ្រួសារឯទៀត ដូចដែលពួកយុវជនទាំងនោះបានផ្ដល់ពរជ័យដល់យើងផងដែរ » ។ ■

**កំណត់ចំណាំ**

1. “ ‘May Peace Reign in the Land’—Dedicatory Prayer for El Salvador Temple” *Church News* ថ្ងៃទី 27 ខែសីហា ឆ្នាំ 2011, ldschurchnews.com។



# ការផ្តោតទៅលើ គ្រួសារ ដ៏ជានិរន្តន៍

*ការមានព្រះវិហារបរិសុទ្ធ សង់នៅក្នុងប្រទេស អេល សាល់វ៉ាឌ័រ បានក្លាយទៅជាពរជ័យដ៏ធំ សម្រាប់បង ប្អូនដែល បានជួយឪពុកម្តាយរបស់ ពួកគេត្រឡប់មកព្រះវិហារវិញ ។*

**ដោយ មីនឌី រ៉េ ហ្វ្រិតមែន**
ទស្សនាវដ្ដីសាសនាចក្រ

យេរិន និងដែកគ្លិន អេស. ជាបងប្អូនប្រុសស្រីនៅក្នុងប្រទេសអេល សាល់វ៉ាឌ័រ គឺជាមិត្តដ៏ជិតស្និទ្ធ ហើយពួកគេ បានស្មោះស្ម័គ្រនៅជាមួយគ្នា ក្នុងអ្វីៗគ្រប់បែបយ៉ាង ។ ពួកគេមានសេចក្ដីស្រឡាញ់ដ៏ធំចំពោះដំណឹងល្អ និងចំពោះក្រុមគ្រួសាររបស់ពួកគេ ។ ពួកគេចង់ឱ្យក្រុមគ្រួសាររបស់គេនៅជាមួយគ្នាជានិរន្ដ ។

នៅពេលយេរិន និងដែកគ្លិន នៅក្មេង សមាជិកគ្រប់គ្នានៅក្នុងព្រះវិហារតែងតែសួរដល់ឪពុករបស់គេថា « តើពេលណាទើប ប៉ាទៅផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ? » ហើយគាត់នឹងឆ្លើយថា « នៅពេលមានព្រះវិហារបរិសុទ្ធនៅក្នុងប្រទេសអេល សាល់វ៉ាឌ័រ » ។

## ការអធិស្ឋានសម្រាប់ឪពុកម្ដាយរបស់ពួកគេ

ប៉ុន្តែ នៅពេលមានព្រះវិហារបរិសុទ្ធ សាន សាល់វ៉ាឌ័រ អេល សាល់វ៉ាឌ័រត្រូវបានប្រកាសនៅក្នុងឆ្នាំ 2007 ឪពុកម្ដាយរបស់យេរិន និងដែកគ្លិនបានឈប់ទៅព្រះវិហារ ។ ប៉ុន្តែយេរិន ឥឡូវនេះមានអាយុ 18 ឆ្នាំ និង ដែកគ្លិន មានអាយុ 15 ឆ្នាំ នៅតែបន្តទៅព្រះវិហារ ដោយអធិស្ឋានសុំថាថ្ងៃណាមួយ ឪពុកម្ដាយរបស់ពួកគេនឹងត្រឡប់មកវិញ ។

ដែកគ្លិននិយាយថា « ខ្ញុំមិនដែលឈប់អធិស្ឋានទូលសុំព្រះវរបិតាសួគ៌ ដើម្បីឱ្យពួកគាត់មកសកម្ម វិញនោះឡើយ » ។ « ខ្ញុំដឹងថាព្រះវរបិតាសួគ៌ សព្វព្រះទ័យចង់ឱ្យយើងបាននូវអ្វីដែលល្អបំផុត ហើយទ្រង់ចង់ឱ្យយើងក្លាយជាក្រុមគ្រួសារដ៏នៅអស់កល្បជានិច្ច » ។

ពួកគេក៏ខំប្រឹងប្រែងធ្វើជាគំរូល្អដល់ឪពុកម្ដាយរបស់ខ្លួនផងដែរ ។ យេរិននិយាយថា « ខ្ញុំមិនដែលបាត់បង់សេចក្ដីសង្ឃឹមឡើយ » ។ « ខ្ញុំតែងតែអានព្រះគម្ពីរ និងអធិស្ឋាន ហើយឪពុកម្ដាយតែងតែមើលឃើញខ្ញុំសិក្សាហើយចាកចេញទៅធ្វើការជាគ្រូបង្រៀនតាមផ្ទះ និងទៅចូលរួមនៅសកម្មភាពនានានៃសាសនាចក្រ ។ នៅពេលខ្ញុំបន្តរក្សាព្រះបញ្ញត្តិទាំងឡាយ និងដើម្បីលូតលាស់ឡើង ឪពុកម្ដាយរបស់ខ្ញុំបានឃើញគំរូរបស់ ខ្ញុំ » ។

## ការមានអារម្មណ៍ពីព្រះវិញ្ញាណនៃព្រះវិហារបរិសុទ្ធ ។

ការអធិស្ឋានរបស់យេរិន និងដែកគ្លិនសម្រាប់ឪពុកម្ដាយរបស់ពួកគេ បានចាប់ផ្ដើមទទួលចម្លើយតប កាលដែលព្រះវិហារបរិសុទ្ធ ធ្វើជិតរួច ។ យេរិននិយាយថា៖ « នៅពេលពួកអ្នកដឹកនាំរបស់យើងបានប្រកាសអំពីការឧទ្ទិសឆ្លង និងពិធីបុណ្យតាមវប្បធម៌ យើងបានអញ្ជើញឪពុកម្ដាយរបស់យើង » ។ « យើងបានប្រាប់ពួកគាត់អំពីឯកសិទ្ធិដែលយើងមាន ក្នុងពេលដែលយុវវ័យចូលរួម ហើយនេះបានទាក់ទាញចិត្តពួកគាត់យ៉ាងខ្លាំង ហើយបានជួយពួកគាត់ឱ្យរីកចម្រើនខាងវិញ្ញាណ » ។

បន្ថែមពីលើការចូលរួមក្នុងពិធីបុណ្យតាមវប្បធម៌ ក្រុមគ្រួសារនេះក៏អាចទៅចូលរួមនៅក្នុងការបើកសម្ពោធន៍ព្រះវិហារបរិសុទ្ធផងដែរ ។

យេរេននិយាយថា « ថ្វីបើឪពុកម្ដាយរបស់ខ្ញុំមិនបានទៅព្រះវិហារក៏ដោយ ពួកគាត់នៅតែមើលទៅ សាសនាចក្រ និងដំណឹងល្អ ទុកជារបស់ពិសិដ្ឋដែរ » ។ « នៅពេលយើងបានចូលក្នុងព្រះវិហារបរិសុទ្ធ ឪពុករបស់ខ្ញុំបានចាប់ផ្ដើមពន្យល់ដល់បងប្អូនស្រីរបស់ខ្ញុំ ថា នៅពេលយើងស្លៀកពាក់សម្លៀកបំពាក់ពណ៌ស ហើយថានេះជាទីកន្លែងដែលយើងធ្វើពិធីបរិសុទ្ធពិសិដ្ឋនានា » ។

យេរិន មានចិត្តស្ញប់ស្ញែងដែលប្អូនស្រីអាយុពីរឆ្នាំរបស់គាត់ ដែលតាមធម្មតារពឹស តែបែរជានៅស្ងៀមក្នុងពេលពួកគេនៅក្នុងព្រះវិហារបរិសុទ្ធ ហើយពួកគេបានសង្កេតឃើញម្ដាយរបស់ពួកគេ ស្រក់ទឹកភ្នែក ក្នុងពេលដែលគាត់បានមើលក្នុងបន្ទប់និងរូបគំនូផ្សេងៗ ។ នៅពេលក្រុមគ្រួសារបានចូលក្នុងបន្ទប់ផ្សារភ្ជាប់ អ្នកទទួលភ្ញៀវស្ម័គ្រចិត្តបានពន្យល់ដល់ពួកគេថា នេះគឺជាទីកន្លែងដែលក្រុមគ្រួសារត្រូវបានផ្សារភ្ជាប់នឹងគ្នាជានិរន្ដ។

ដែកគ្លិននិយាយថា « រួចហើយ ប្អូនស្រីរបស់យើងបានចាប់ផ្ដើមកេះយើងម្នាក់ៗ ហើយនិយាយថា ‹ ម៉ាក់ ប៉ាខ្ញុំ បងយេរិនរបស់ខ្ញុំ បងដែកគ្លិនរបស់ខ្ញុំ ›» ។ « គឺហាក់ដូចជាព្រះវរបិតាសួគ៌បានមានបន្ទូលតាមរយៈនាង ដើម្បីប្រាប់យើងថា យើងជារបស់ផង នាង » ។



យេរិននិយាយថា « រួចហើយ នាងបានឱបយើងហើយចាប់ផ្ដើមថើបយើង ហើយចង្អុលទៅមើលក្នុងកញ្ចក់ » ។ « យើងបានមើលខ្លួនយើងទាំងអស់គ្នានៅក្នុងកញ្ចក់ទាំងនោះ ហើយវាគួរឱ្យអស្ចារ្យក្រៃលែង ។ នៅពេលយើងបានចាកចេញពីបន្ទប់ផ្សារភ្ជាប់ថ្ងៃនោះ យើងបានដាក់គោលដៅ ដើម្បីនឹងត្រឡប់មកវិញម្ដងទៀត ។



រូបថត © IRI



## គោលដៅដ៏សំខាន់បំផុត

«បើអ្នកមិនទាន់បានទៅព្រះវិហារបរិសុទ្ធ ឬ បើអ្នក *បានទៅ* ប៉ុន្តែថ្មីៗនេះ គ្មានភាពសក្តិសមកាន់ប័ណ្ណចូលព្រះវិហារបរិសុទ្ធគោលដៅសំខាន់បំផុតរបស់អ្នក គឺត្រូវខិតខំដើម្បីមានភាពសក្តិសមទៅព្រះវិហារបរិសុទ្ធ ។ ... ពរជ័យដ៏សំខាន់ និងខ្ពស់បំផុតក្នុងនាមជាសមាជិកក្នុងសាសនាចក្រ គឺជាពរជ័យទាំងឡាយដែលយើងទទួលនៅក្នុងព្រះវិហារបរិសុទ្ធនៃព្រះ » ។

**សូមមើលប្រធាន ថូម៉ាស អេស ម៉នសុន “The Holy Temple—a Beacon to the World” *លីអាហូណា* ខែ ឧសភា ឆ្នាំ 2011 ទំព័រ 93 ។**

### ការទទួលបានទស្សនៈវិស័យសារជាថ្មី

បន្ទាប់ពីការចូលរួមក្នុងពិធីបើកសម្ពោធន៍ទទួលសាធារណៈជនក្នុងព្រះវិហារបរិសុទ្ធ ក្រុមគ្រួសារបានចាប់ផ្តើមធ្វើការផ្លាស់ប្តូរជាច្រើន ។ យេរិននិយាយថា « ចាប់តាំងពីយើងបានទៅព្រះវិហារបរិសុទ្ធ ក្រុមគ្រួសាររបស់យើងបានទទួលបានទស្សនៈថ្មីៗជាច្រើន » ។ « ចាប់តាំងពីពេលនោះមក យើងបានធ្វើរាត្រីជួបជុំក្រុមគ្រួសារ ហើយឪពុកម្តាយរបស់យើងកំពុងតែនាំយើង ទៅព្រះវិហារ ហើយអង្គុយជាមួយយើង នៅជួរខាងមុខក្នុងព្រះវិហារ » ។

នៅក្នុងខែសីហា ឆ្នាំ 2011 យេរិន និងដែកគ្លិន មានអារម្មណ៍ថាមានពរជ័យណាស់ ដែលអង្គុយជាមួយឪពុកម្តាយពួកគេនៅក្នុងមជ្ឈមណ្ឌលស្តេក នៅពេលពួកគេមើលការចាក់ផ្សាយការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ ។

យេរិននិយាយថា « នៅពេលព្រះវិហារត្រូវបានប្រកាសប្រាប់នៅក្នុងឆ្នាំ 2007 ឪពុកម្តាយខ្ញុំពុំសូវសកម្ម ទេ ហើយខ្ញុំបានគិតថាខ្ញុំនឹងគ្មានឱកាសដើម្បីនឹងនៅជាមួយពួកគាត់នៅឯការឧទ្ទិសឆ្លងឡើយ » ។ « នៅពេលពួកគាត់កំពុងតែអង្គុយជាមួយខ្ញុំ ខ្ញុំពិតជាមានអារម្មណ៍ថាព្រះវរបិតាសួគ៌បានឆ្លើយនឹងការអធិស្ឋានរបស់ខ្ញុំ ។ ដើម្បីនៅទីនោះជាមួយក្រុមគ្រួសាររបស់ខ្ញុំ នោះគឺជាពរដ៏ធំបំផុតដែលខ្ញុំមាននៅក្នុងជីវិតរបស់ខ្ញុំ » ។

ដែកគ្លីននិយាយ « បទពិសោធន៍នៃព្រះវិហារបរិសុទ្ធនេះបានជួយពង្រឹងខ្ញុំ » ។ « អ្វីដែលបានជួយពង្រឹងខ្ញុំជាងអ្វីៗទាំងអស់នោះគឺជាការមើលឃើញថាព្រះវិហារបរិសុទ្ធ បានផ្លាស់ប្តូរជីវិតមនុស្សជាច្រើន ពីព្រោះវាបានជួយឪពុកម្តាយខ្ញុំឱ្យសកម្មម្តងទៀតនៅក្នុងសាសនាចក្រ ។ ឥឡូវនេះ យើងបានដាក់គោលដៅថាយើងនឹងត្រូវផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ។ ខ្ញុំដឹងថាព្រះវរបិតា សព្វព្រះទ័យចង់ឱ្យយើងនូវអ្វីដែលល្អបំផុតសំរាប់យើង។ » ■



## នៅពេលមានសេចក្តីស្រឡាញ់ក្នុងផ្ទះ

យេរិន និងដែកគ្លិនគឺជាបងប្អូនដែលមានភាពជិតស្និទ្ធយ៉ាងខ្លាំង ហើយពួកគេបានរៀនដឹងថាចំណង រវាងបងប្អូនអាចជា ផ្នែកដ៏មានតម្លៃនៃជីវិត ។ នេះគឺជារបៀបដែលពួកគេគាំទ្រគ្នា ។

ដែកគ្លិននិយាយថា « បងប្រុសរបស់ខ្ញុំតែងតែជួយខ្ញុំ ធ្វើភារកិច្ចរបស់ខ្ញុំនៅក្នុងផ្ទះ និងនៅឯសាលារៀន ។ ខ្ញុំតែងតែមានការជួយគាំទ្រពីគាត់ ហើយខ្ញុំដឹងដោយគ្មានមន្ទិលសង្ស័យថា គាត់ស្រឡាញ់ខ្ញុំ និងជួយគាំ ទ្រខ្ញុំ រៀងរាល់ពេល ។ នៅពេលខ្ញុំមានកង្វល់ ឬអារម្មណ៍តូចចិត្តនឹងខ្លួនឯង គាត់នៅទីនោះដើម្បីលើកទឹកចិត្តខ្ញុំជានិច្ច » ។

យេរិននិយាយថា « នៅពេលខ្ញុំមានអារម្មណ៏ខកចិត្ត ប្អូនស្រីរបស់ខ្ញុំបានជួយគាំទ្រខ្ញុំ និងលើកទឹកចិត្តខ្ញុំ ។ នាងប្រាប់ខ្ញុំអំពីគុណសម្បត្តិវិជ្ជមានដែលខ្ញុំមាន ហើយវាធ្វើឱ្យខ្ញុំមានអារម្មណ៍ល្អប្រសើរច្រើន ។ ខ្ញុំបានរៀនច្រើនអំពីគំរូរបស់នាង ។ ពេលខ្លះ នៅពេលខ្ញុំចាប់ផ្តើមបោះបង់សេចក្តីជំនឿរបស់ខ្ញុំ នាងប្រាប់ខ្ញុំមិនឱ្យសង្ស័យ ហើយថាអ្វីៗ នឹង មានលទ្ធផលល្អប្រសើរជាងការសង្ឃឹមទុករបស់ខ្ញុំ » ។

យុវវ័យទាំងពីររូបនេះនិយាយថា ពួកគេរីករាយនឹងទំនាក់ទំនងរបស់គេ ហើយថាពួកគេមិនឈ្លោះគ្នា ដូចជាបងប្អូនឯទៀតៗឡើយ ។ យេរិននិយាយថា៖ « អ្នកអាចនិយាយថា យើងជាមនុស្សចម្លែក ប៉ុន្តែខ្ញុំសូមអរគុណព្រះវរបិតាសួគ៌ចំពោះ ទំនាក់ទំនងនេះជាមួយនឹងប្អូនស្រីខ្ញុំ » ។

# ការទទួលអារម្មណ៍ពីសេចក្ដីស្រឡាញ់របស់ទ្រង់តាមរយៈការបម្រើ

ដោយ ម៉ីស្សែល វ៉ាឌីន



## ការបម្រើសំខាន់ដ៏អស់កល្បជានិច្ច

« ប្រហែលជាគំរូដែលមនុស្សគ្រប់គ្នាស្គាល់ និងសំខាន់បំផុតនៃការបម្រើ និងការលះបង់ដោយចិត្តទូលាយ ដែលត្រូវបានធ្វើនៅក្នុងក្រុមគ្រួសាររបស់យើង ។ ម្ដាយទាំងឡាយ ពលិកម្មខ្លួនគាត់ ដើម្បីនឹងបីបាច់ថែទាំកូនៗរបស់គាត់ ។ ស្វាមីទាំងឡាយ បូជាខ្លួនរបស់គាត់ ដើម្បីជួយគាំទ្រដល់ភរិយា និងកូនៗរបស់ខ្លួន ។ ការលះបង់ទាំងឡាយ ដែលជាប់ទាក់ទងទៅនឹងការបម្រើដ៏សំខាន់អស់កល្បជានិច ចំពោះក្រុមគ្រួសារ របស់យើង គឺមានចំនួនច្រើនក្រៃលែង និង ជារឿងដដែលធ្លាប់ស្គាល់ ដែលចាំបាច់ត្រូវប្រកាស » ។

អែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « ការពលិកម្ម » *លីអាហូណា* ថ្ងៃទី 22 ខែ ឧសភា ឆ្នាំ 2012 ទំព័រ 17 ។

ទៅពីរសប្ដាហ៍មុនថ្ងៃគ្រីស្ទម៉ាស់ សម្ពាធនៃរដូវបុណ្យនេះបានធ្លាក់មកលើរូបខ្ញុំ ។ ខ្ញុំត្រូវការទិញអំណោយខ្លះ តុបតែងដើមឈើ និង ប្រគល់អំណោយឱ្យគេ ។

អស់រយៈពេលពីរបីខែ ខ្ញុំបានមានអារម្មណ៍ថាហ៊ុមព័ទ្ធទៅដោយកិច្ចការជាច្រើន ចំពោះភារកិច្ចប្រចាំថ្ងៃប្រឈមមុខជាម្ដាយ ដែលមានកូនប្រាំនាក់ ។ ខ្ញុំព្រមទាំងមានអារម្មណ៍ថាមិនសូវបានគិតគូរពីការចូលរួមក្នុងព្រះវិហារ ក្នុងពេលដែលខ្ញុំខំមើលថែទាំ កូនតូចៗនៅលើកៅអីវែង ។ ខ្ញុំចង់ឱ្យមានព្រះវិញ្ញាណ និងបទពិសោធន៍ខាងវិញ្ញាណនៅក្នុងជីវិតខ្ញុំកាន់តែច្រើន ។

ក្នុងពេលនេះ ប្អូនស្រីរបស់ខ្ញុំបានទិញផ្ទះថ្មី នៅក្នុងរដ្ឋក្បែរនោះ ហើយកំពុងតែខិតខំធ្វើអ្វីៗឱ្យបានរួចរាល់មុនថ្ងៃគ្រីស្ទម៉ាស់មកដល់ ។ នោះគឺជាការពិបាកណាស់ចំពោះក្រុមគ្រួសារមួយចំនួន ប៉ុន្តែចំពោះគាត់ វាគឺកាន់តែពិបាកថែមទៀត ។ ប្អូនស្រីរបស់ខ្ញុំមានផ្ទៃពោះប្រាំបីខែ ជាម្ដាយដែលមានកូនតូចៗពីរនាក់ ហើយជាអ្នកថែទាំប្ដីពិការថែមទៀត ។

ដោយដឹងពីការលំបាកដែលនាងកំពុងតែប្រឈមមុខ ខ្ញុំបានទូរស័ព្ទទៅនាង ដើម្បីសួរសុខទុក្ខ ។ នាងគិតសុទិដ្ឋិនិយមអំពីផ្លាស់លំនៅ និងសង្ឃឹមថា សមាជិកនៅវួដថ្មីរបស់នាងនឹងអាចជួយគាំទ្រ ។ បន្ទាប់ពីការសន្ទនារបស់យើងចប់ ខ្ញុំបានដាក់ទូរស័ព្ទចុះ ដោយជូនពរនាងឱ្យមានសំណាងល្អ ហើយសញ្ជឹងគិតអំពីរបៀបដែលខ្ញុំអាចជួយពីចម្ងាយ 400 ម៉ែល (650 គីឡូម៉ែត្រ) ដ៏ឆ្ងាយ ។

រាត្រីនោះខ្ញុំចេះតែគិតអំពីនាង ថាខ្ញុំត្រូវតែទៅទីនោះដើម្បីជួយ ។ ប៉ុន្តែខ្ញុំបានមើលកាលវិភាគរបស់ខ្ញុំ ខ្ញុំបានប្ដូរចិត្ត ហើយបានចូលទៅសម្រាកវិញ ។

នៅព្រឹកបន្ទាប់ខ្ញុំបានក្រោកឡើងដោយមានការបំផុសគំនិតដដែល ។ ខ្ញុំមានអារម្មណ៍នៃការបំផុសគំនិតយ៉ាងខ្លាំងក្នុងពេលនេះ ដែលខ្ញុំមិនអាចបដិសេធបាន ។ ខ្ញុំបានទូរស័ព្ទទៅស្វាមីខ្ញុំ ហើយបាននិយាយថា « ខ្ញុំត្រូវការទៅជួយប្អូនស្រីរបស់ខ្ញុំ » ។ ដោយគ្មានចិត្តស្ទាក់ស្ទើរ គាត់បានតបថា « បងបានគិតអញ្ចឹងដែរ » ។

ខ្ញុំបានទូរស័ព្ទទៅប្អូនស្រីខ្ញុំ ប្រាប់នាងអំពីគម្រោងរបស់ខ្ញុំ ហើយបានទិញសំបុត្រយន្តហោះនៅថ្ងៃរសៀលនោះ ។ ខ្ញុំបានរៀបចំអីវ៉ាន់ ថើបលាកូនៗរបស់ខ្ញុំ ហើយបានចេញដំណើរទៅព្រលានយន្តហោះ ។

ក្នុងអំឡុងពេលបីថ្ងៃក្រោយមក ខ្ញុំបានរើរបស់ចេញពីប្រអប់ រៀបចំបន្ទប់ ហើយបានជួយតុបតែងដើមឈើគ្រីស្ទម៉ាស់ ។ បន្ទាប់ពីបានរើឥវ៉ាន់ចេញពីឡាំង ខ្ញុំបានអង្គុយជាមួយប្អូនស្រី និងក្រុមគ្រួសាររបស់នាងសរសើរដើមឈើដ៏ស្អាតរបស់គេ ។ ក្មួយស្រីអាយុប្រាំឆ្នាំរបស់ខ្ញុំ រីករាយដែលក្រុមគ្រួសាររបស់នាងបានរៀបចំស្រេចបាច់សម្រាប់បុណ្យគ្រីស្ទម៉ាស ដោយបានស្រែកឡើងថា « នេះនឹងជាបុណ្យគ្រីស្ទម៉ាស់ដ៏អស្ចារ្យមួយ ! »

កាលដែលខ្ញុំបានជិះយន្តហោះមកផ្ទះវិញ ខ្ញុំបានដឹងថាខ្ញុំបានលះបង់ខ្លួនរបស់មួយចំណែកឱ្យទៅក្រុមគ្រួសារដ៏ផ្អែមល្ហែមនេះ ខ្ញុំបានទទួលអារម្មណ៍នៃព្រះវិញ្ញាណ ដែលខ្ញុំបានទន្ទឹងរង់ចាំជាយូរមកហើយ ។ ព្រះវិញ្ញាណបានមកពីព្រោះខ្ញុំបានបម្រើអ្នកដទៃ ។

វាជាការណ៍ងាយស្រួលនឹងនិយាយអំពីការបម្រើក្នុងរដូវគ្រីស្ទម៉ាស់ ដរាបណាការផ្ដល់ការបម្រើនោះសមនឹងកាលវិភាគរបស់យើង ហើយពុំសូវចុះលុយ ឬ ធ្វើអ្វីដែលយើងមិនស្រណុកចិត្ត។ ប៉ុន្តែដើម្បីទទួលអារម្មណ៍នៃវិញ្ញាណនៃបុណ្យគ្រីស្ទម៉ាស់ ពិតប្រាកដ យើងត្រូវតែខំឱ្យអស់ពីសមត្ថភាព របស់យើង ។ ការធ្វើបែបនេះ ជួយយើងឱ្យយល់ដឹងអំពីសេចក្ដីស្រឡាញ់របស់ព្រះសង្គ្រោះមានសម្រាប់យើងម្នាក់ៗ ។ ■

រូបថត ដោយ ខារេន ស៊ី. អាន់ឌើសិន



**ដោយ ប៊ីស្សព ហ្គេរី អ៊ី ស្ទីវិនសុន**
ប៊ីស្សពជាអធិបតី

# សុវត្ថិភាព និងសន្តិភាពនៃកាន់តាម ព្រះបញ្ញត្តិទាំងឡាយ

*គំរូ និងការពិតទាំងឡាយដែលមាននៅក្នុងព្រះគម្ពីរមរមន គឺច្បាស់លាស់ ហើយសម្រាប់ជាសេចក្ដីណែនាំ សេចក្ដីពិតច្បាស់ និងមានតម្លៃ ។ នៅពេលយើងចាប់ផ្ដើមជាមួយនឹងសុចរិតភាព និងការគោរព យើងនឹងទទួលពរជ័យ និងសេចក្ដីអំណរនៅទីបំផុត ។*

នៅក្នុងសម័យបច្ចេកវិទ្យាទំនើបរបស់យើង ព័ត៌មានហាក់ដូចជាផ្សព្វផ្សាយ 24 ម៉ោងក្នុងមួយថ្ងៃ ដែលការចាក់ផ្សាយនេះគឺមិនអាចជៀសផុសពីការផ្សព្វផ្សាយ ដែលធ្លាប់បានឮម្ដងហើយម្ដងទៀតនោះទេ ។ អ្នកសម្ដែងដែលដើរតួច្រើនតាមធម្មតា ទទួលបានភាពល្បីល្បាយដែលគេនិយម តាមរយៈទេពកោសល្យដ៏ល្អអនេក ជាអ្នកដើរតួ កីឡាករ អ្នកនយោបាយ ឬអ្នកដឹកនាំខាងជំនួញក្ដី ។ រយៈពេលនៃការអនុវត្តឬ ការបម្រើ និងពលិកម្ម—ជម្រុញទៅរកភាពជោគជ័យដ៏ខ្លាំងក្លា របស់គេនៅក្នុងវិជ្ជាជីវៈណាមួយ—ទាំងនោះត្រូវបានសាបរលាបបើមានរឿងអាស្រូវណាមួយ ។

ទីបញ្ចប់នៃសាច់រឿងរបស់តួអង្គ ជួនកាល គឺបន្សល់ទុកនូវរូបភាពដ៏ស្រងូតស្រងាត់ ធ្វើការទទូចអង្វរទាំងទឹកភ្នែកចំពោះចៅក្រម កូនហ៊ុន ឬភារប្បទាយី ឬចំពោះក្រុមគ្រួសារ មិត្តភក្ដិ ឬអ្នកគាំទ្រសុំនូវការអភ័យទោស ចំពោះសកម្មភាពខុសឆ្គងរបស់ពួកគេ ។ លទ្ធផល តាមធម្មតាទម្លាក់សំណាញ់យ៉ាងធំចំពោះលទ្ធផលអចេតនា—រួមជាមួយការឈឺចិត្ត ការអៀនខ្មាស់ ហើយនិងទុគ្គតិភាពគ្របដណ្ដប់លើពួកគេ អ្នកដែលគេស្រឡាញ់ និងសហការីរបស់ពួកគេ ។

នៅក្នុងពាក្យដ៏សាមញ្ញ តែមានអត្ថន័យរបស់ព្យាការីអាល់ម៉ាក្នុងព្រះគម្ពីរមរមន នៅក្នុងការទូន្មានចំពោះកូន ប្រុសរបស់គាត់ ហាក់ដូចជាពាក់ព័ន្ធទៅក្នុងសតវត្សទី 21 ដូចជាសភាពការណ៍ 2,000 ឆ្នាំកន្លងមកដែរ ៖ « សេចក្ដីទុច្ចរិតមិនដែលជាសុភមង្គលឡើយ » (អាល់ម៉ា 41:10) ។

តាមធម្មតានៅក្នុងរឿងអាស្រូវសព្វថ្ងៃនេះ ចំណេះដឹង និងការគោរពតាមបទបញ្ញត្តិដែលមានក្នុង ដំណឹងល្អដែលបានស្ដារឡើងវិញ នឹងជាការបង្វែរមហន្តរាយផ្ទាល់ខ្លួន និងមហន្តរាយខាងវិជ្ជាជីវៈចេញបាន ។

រចនារូបភាពដោយ ឌើរិន ម៉ាស្ស


ច្បាប់
សូមមើល នីហ្វៃទី 2
2:11–27 ។
សុភមង្គល
(សេចក្ដីអំណរ)
ការប្រសិទ្ធពរ
ការគោរពប្រតិបត្តិ
(សុចរិតភាព)
ការមិនគោរពប្រតិបត្តិ
(ទុច្ចរិតភាព)
ទារណ្ឌកម្ម
អពមង្គល
(ទុក្ខវេទនា)

## រូបមន្តដើម្បីទទួលបានសុភមង្គល

រូបមន្តដែលតំណាងនៅក្នុងដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទបានបើកបង្ហាញពីមាគ៌ាទៅកាន់សុភមង្គល ។ គឺជាសេចក្តីពិតច្បាស់ និងមានតម្លៃ ដែលអាចរកឃើញនៅពេញក្នុងព្រះគម្ពីរមរមន ។ វាត្រូវបានពណ៌នាយ៉ាងល្អិតល្អន់ជាពិសេស នៅក្នុងការបង្រៀនរបស់ព្យាការីលីហៃ ចំពោះកូនប្រុសៗ របស់គាត់មុននឹងទទួលមរណភាព ។ ក្នុងការនិយាយទៅកាន់កូនប្រុសរបស់គាត់យ៉ាកុប គាត់បានបង្រៀនថា « ត្បិតជាការចាំបាច់ ត្រូវតែមានការផ្ទុយចំពោះរឿងសព្វសារពើរ » (នីហ្វៃទី 2 2:11) ។ នៅក្នុងប៉ុន្មានវគ្គក្រោយមកលោក បានមានប្រសាសន៍ទៀតថា « មានមនុស្សលោក ដើម្បីឱ្យគេអាចមានសេចក្តីអំណរ » (នីហ្វៃទី 2 2:25) ។

ការបង្រៀនរបស់លីហៃនៅក្នុងទេសនកថានេះចំពោះយ៉ាកុប ដែលបានសង្ខេបដោយងាយស្រួលយល់ថា ៖ ការគោរពប្រតិបត្តិ និងសុចរិត្តភាពនាំទៅរកពរជ័យដែលនាំទៅរកសេចក្តីអំណរ ។ ផ្ទុយទៅវិញ ការមិនគោរពប្រតិបត្តិ និង ទុច្ចរិតភាពនាំទៅទារុណ្ឌកម្ម ដែលនាំទៅរកភាពទុក្ខសោក ។ ព្រះសង្គ្រោះគឺជាអង្គបង្កបង្កើតនៃមនុស្សលោកគ្រប់រូប និងជាអ្នកគាំទ្រនៃផ្លូវទៅកាន់សុភមង្គល ហើយជីវិតដ៏នៅអស់កល្បជានិច្ច ។ សាតាំងគឺជាបិតានៃការកុហក និងជាអ្នកគាំទ្រ ផ្លូវទៅកាន់ការជាប់ឃុំឃាំង និងសេចក្តីស្លាប់ ។

ពិតប្រាកដណាស់ បច្ឆាមិត្រយល់ថា យើងនឹងមិនជ្រើសយកការជាប់ឃុំឃាំង និងសេចក្តីស្លាប់ដោយចេតនាឡើយ ប៉ុន្តែវានឹងមានទុក្ខវេទនាជានិរន្ត ហើយធ្វើឱ្យមនុស្សលោកគ្រប់រូបមានទុក្ខវេទនាដូចវាដែរ (សូមមើល នីហ្វៃទី 2:27) ។ វាធ្វើបែបនេះដោយបំភាន់លទ្ធផលនានានៃអំពើបាប និងការឥតគោរពប្រតិបត្តិ ។ នោះគឺជាមូលហេតុមួយដែលវាត្រូវបានហៅថា បិតានៃការកុហក ។

ប្រធានស្ពែនស៊ើរ ដបុលយូ ឃឹមបឹល (ឆ្នាំ 1895–1985) បាននិយាយថា ៖ « អ្នករាល់គ្នា ... ដឹងហើយថា សាតាំងគឺជាបិតានៃការកុហក ។ អ្នកដឹងអំពីរបៀបដែលវាបង្វែរការពិតទៅជាការភូតកុហក ។ វាធ្វើឱ្យអំពើអាក្រក់មានរូបភាពស្អាត សមភ្នែក ងាយស្រួល ព្រមទាំងល្អទៀតផង » ។ [1]

សាតាំងនឹងធ្វើឱ្យយើងជឿថា រូបមន្តដើម្បីទទួលបានសុភមង្គលបានមកពីអំពើទុច្ចរិត ហើយអំពើបាប ។ យើងត្រូវបានព្រមានថា សេចក្តីល្បួងរបស់វាត្រូវបានលាក់បាំងយ៉ាងប៉ិនប្រសប់ ដែលជួនកាល វាក្លែងខ្លួនជា « ទេវតានៃពន្លឺ » (នីហ្វៃទី 2 9:9) ។ ព្រះម្ចាស់បានពិពណ៌នាអំពីការធ្លាក់ចុះ និងគោលដៅរបស់សាតាំងថា ៖

« ហេតុដូច្នេះហើយ មកពីសាតាំងបានបះបោរទាស់នឹងយើង ហើយខំរកបំផ្លាញសិទ្ធិជ្រើសរើសរបស់ មនុស្ស ដែលយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានប្រទានដល់មនុស្ស ហើយក៏មកពីបានចង់ឱ្យយើងប្រទានដល់វា នូវព្រះចេស្តារបស់យើងផ្ទាល់ គឺដោយសារព្រះចេស្តារ នៃព្រះរាជបុត្រាបង្កើតតែមួយរបស់យើង នោះយើងបានបណ្តាលឱ្យវាត្រូវបណ្តេញចុះ ។

« ហើយវាក្លាយទៅជាសាតាំង មែនហើយ គឺជាអារក្សជាបិតានៃអស់ទាំងការកុហក ដើម្បីបញ្ឆោត ហើយដើម្បីធ្វើឱ្យមនុស្សខ្វាក់ ហើយដើម្បីដឹកពួកគេយកទៅជាឈ្លើយតាមចិត្តរបស់វា » (ម៉ូសេ 4:3–4) ។

ផ្លូវទៅកាន់សុភមង្គលចាប់ផ្តើមជាមួយនឹងភាពសុចរិត តាមរយៈការគោរពប្រតិបត្តិចំពោះព្រះបញ្ញត្តិទាំងឡាយ ។ ព្រះបញ្ញត្តិទាំងឡាយត្រូវបានផ្តល់ដល់យើងជាត្រីវិស័យដ៏ទេវភាព ដើម្បីដឹកនាំយើងចេញពីភាពអន្តរាយនៃជីវិតរមែងស្លាប់។ ព្រះអម្ចាស់បានប្រកាសរឿងនេះ តាំងពីការចាប់ផ្តើមនៃការស្តារឡើយវិញថា ៖ « ហេតុដូច្នេះហើយ យើងជាព្រះអម្ចាស់ ដោយជ្រាបនូវគ្រោះដែលនឹងមានមកលើបណ្តាជនទាំងឡាយនៅលើផែនដីនោះនោះបាន ហៅយ៉ូសែបស្ម៊ីធជាអ្នកបំរើរបស់យើង ហើយបាននិយាយមកកាន់លោកពីលើស្ថានសួគ៌ *ហើយបានប្រទានព្រះព្រះបញ្ញត្តិទាំងឡាយដល់លោក* » (គោលលទ្ធិ និងសេចក្តីសញ្ញា 1:17 បន្ថែមសេចក្តីបញ្ជាក់) ។

## ការកាន់តាមព្រះព្រះបញ្ញត្តិ

អ្នកខ្លះបានយល់ឃើញថា វាជារឿងមិនសមហេតុផល ដែលព្រះបញ្ញត្តិទាំងឡាយជាប្រភពនៃផ្លូវទៅកាន់សុភមង្គល ជាជាងអ្វីដែលត្រូវអនុវត្តនៅតាមផ្លូវនោះ ។ រឿងខាងក្រោមដែលដកស្រង់ចេញពីការបម្រើរបស់ខ្ញុំជាប្រធានបេសកកម្មនៅក្នុងក្រុងណាហ្គូយ៉ា ប្រទេសជប៉ុន ជាច្រើនកន្លងមកគូរបង្ហាញបែបនេះ ។

ភរិយារបស់ខ្ញុំ លេសា និងខ្ញុំបានចាប់ផ្តើមស្គាល់យុវនារីម្នាក់ ក្រោយពីនាងបានមកព្រះវិហារ ដើម្បីមករៀនភាសាអង់គ្លេស ដែលបង្រៀនដោយពួកអ្នកផ្សព្វផ្សាយសាសនា ។ នាងមានចារឹកបួកពាក្លៀវក្លា ស្វាហាប់ ហើយចេះចាត់ចែងជីវិតរបស់នាងទៀតផង ដែលរួមជាមួយ ការងារល្អ និង មានសង្សារជាយូរមក ហើយនិងក្រុមគ្រួសាររបស់នាង ។ ទំនាក់ទំនងរបស់នាងជាមួយពួកអ្នកផ្សព្វផ្សាយសាសនា និងសមាជិក តាមរយៈថ្នាក់រៀនភាសាអង់គ្លេស បានធ្វើឱ្យនាងចាប់អារម្មណ៍ចំពោះសាសនាចក្រ ហើយនាងបានចាប់ផ្តើម ទទួលរៀនមេរៀនជាមួយអ្នកផ្សព្វផ្សាយសាសនា ។ ទីបន្ទាល់របស់នាងនៃភាពពេញលេញនៃដំណឹងល្អដែលបានស្តារឡើងវិញកាន់តែលូតលាស់ឡើងរៀងរាល់ថ្ងៃពេលនាងបានជួបពួកអ្នកផ្សព្វផ្សាយសាសនា ។ កាលដែលនាងអានព្រះគម្ពីរមរមន ហើយសញ្ជឹងគិត និងអធិស្ឋានអំពីព្រះគម្ពីរនោះ ហើយអ្វីៗ ដែលនាងកំពុងតែស្តាប់ឮ នាងបានដឹងថាវាពិត ។

នៅពេលពួកអ្នកផ្សព្វផ្សាយសាសនា បានចាប់ផ្តើមបង្រៀននាងនូវព្រះបញ្ញត្តិ នាងបានដឹងថា នាងត្រូវតែគោរពតាម ។ នាងបានផ្តាច់ទំនាក់ទំនងជាមួយសង្សាររបស់នាង ឈប់ពីការងាររបស់នាង ដែលនាងត្រូវធ្វើការក្នុងថ្ងៃអាទិត្យ ។ នាងបានចាប់ផ្តើមគោរពតាមពាក្យគតិបណ្ឌិត ហើយបានទទួលយកច្បាប់នៃដង្វាយមួយភាគក្នុងដប់ ។ សេចក្តីជំនឿរបស់នាងខ្លាំងក្រៃលែង ដែលនាងបានចាប់ផ្តើមកាន់តាមព្រះបញ្ញត្តិ មួយរំពេចក្នុងគ្រានាងបាន រៀនពីព្រះបញ្ញត្តិទាំងនោះ ។

នៅពេលនាងបានប្រកាសដល់ក្រុមគ្រួសារនាង នូវចំណាប់អារម្មណ៍របស់នាងចំពោះសាសនាចក្រ និង ការសិក្សានៃដំណឹងល្អដែលបានស្តារឡើងវិញ ឪពុកម្តាយ



របស់នាងបានប្រាប់នាងថា ទំនាក់ទំនងរបស់គ្រួសារនាងនឹងត្រូវបែកបាក់ ។ ក្នុងពីរបីសប្ដាហ៍នៃការទទួលព្រះបញ្ញត្តិ នាងបានរកឃើញថានាងពុំមានការងារ គ្មានផ្ទះឈ្នួល ឬការគាំទ្រពីក្រុមគ្រួសារឡើយ ។ ពិតប្រាកដណាស់ លទ្ធផលនៃការគោរពរបស់នាង បានមានឥទ្ធិពលមកលើជីវិតរបស់នាង នៅពេលអ្វីៗលេចឡើងជាសភាពមហន្តរាយ ។

ខ្ញុំបានព្រួយបារម្ភក្រៃលែងអំពីស្ថានភាពរបស់នាង ។ នារាត្រីមួយក្នុងពេលបញ្ចប់នៃថ្ងៃដ៏ចលាចល លេសា និងខ្ញុំបានចាកចេញពីគេហដ្ឋានបេសកកម្មទៅដើរលេង ដើម្បីស្វែងរកពេល ស្ងប់ស្ងាត់ជាមួយគ្នា ។ យើងមានការភ្ញាក់ផ្អើលណាស់ នៅពេលយើងបានមកដល់ផ្លូវបំបែកដ៏រវល់ តែក្នុងពេលដូចគ្នានេះ មានយុវនារីជាសាសនាគន់ការីដ៏ស្វាហាប់វ័យក្មេងម្នាក់បានជិះកង់របស់គាត់មកដល់ ។ នាងបានស្វាគមន៍យើងដោយទឹកមុខញញឹម និងការឱប ។ យើងបានសួរនាងថាតើនាងកំពុងតែធ្វើអ្វី ដោយសារមានការភ្ញាក់ផ្អើលពេលឃើញនាងដើរទាំងយប់អាធ្រាត ។

នាងបាននិយាយដោយរីករាយថា « ខ្ញុំកំពុងតែធ្វើដំណើរទៅធ្វើការងារថ្មីម៉ោងព្រឹក នៅឯភោជនីយដ្ឋានលក់អាហាររហ័សស្រាប់មួយ » ។

ការងារនេះជាផ្នែកដ៏ធំនៃចំណូលរបស់ខ្ញុំជាការទទួលខុសត្រូវ ហើយនិងការធ្វើការងារអស់ជាច្រើនម៉ោងរបស់នាង ។ ថ្វីបើមានឧបសគ្គដ៏ធំ ហើយមានរឿងរ៉ាវខាងសាច់ឈាមនៃជីវិតរបស់នាងក្ដី ក៏សុភមង្គលបានសម្ដែងចេញពីនាងដែរ ។ រួចហើយ នាងបានប្រកាសអំពីកាលបរិច្ឆេទនៃពិធីបុណ្យជ្រមុជទឹករបស់នាង បានណាត់ទុករួចហើយ ។ កាលយើងដើរត្រឡប់ទៅគេហដ្ឋានបេសកកម្មវិញ លេសា និងខ្ញុំមានចិត្តអស្ចារ្យដ៏អនេកអំពីរបៀប ដែលសេចក្ដីជំនឿ និងការគោរពរបស់នាង ចំពោះព្រះបញ្ញត្តិដែលបានរកឃើញថ្មី បាននាំនាងទៅកាន់ផ្លូវនៃសេចក្ដីអំណរ ។

ពីរបីអាទិត្យក្រោយមក នាងបានទទួលបុណ្យជ្រមុជទឹក ។ បន្ទាប់ពីពេលវេលាខ្លះបានកន្លងផុតទៅ នាងបានសម្រុះសម្រួលជាមួយក្រុមគ្រួសាររបស់នាង ហើយ រកបានការងារដ៏ល្អប្រសើរធ្វើ ។ ពីរបីឆ្នាំបន្ទាប់ពីបុណ្យជ្រមុជទឹករបស់នាង នាងបានផ្សាភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធតូក្យូ ប្រទេសជប៉ុន ទៅនឹងអតីតអ្នកផ្សព្វផ្សាយសាសនាម្នាក់ ដែលនាងបានជួបនៅឯសកម្មភាពមជ្ឈិមវ័យវ័យក្មេងនៅលីវមួយ ។ ឥឡូវនេះជាក្រុមគ្រួសារដ៏អស់កល្បជានិច្ច ពួកគេថ្មីៗនេះ ត្រូវបានប្រទានពរនូវទារកប្រុសដ៏ស្រស់ស្អាតម្នាក់ ។ នៅក្នុងទំនុកតម្កើងខ្លី និងផ្អែមល្ហែមមួយ បានពិពណ៌នាអំពីអ្វីដែលបានកើតឡើងនៅក្នុងជីវិតរបស់នាង មកពីផលនៃការគោរពព្រះបញ្ញត្តិទាំងឡាយ ។

*រក្សាព្រះបញ្ញត្តិ រក្សាព្រះបញ្ញត្តិ !*  
*ព្រះបញ្ញត្តិនេះធ្វើឱ្យមានសុវត្ថិភាព ព្រះបញ្ញត្តិនេះធ្វើឱ្យមានភាព*  
*សុខសាន្ត ។*  
*ទ្រង់នឹងប្រទានព្រះពរ ទ្រង់នឹងប្រទានព្រះពរ*  
*ជាពាក្យសំដីរបស់ព្យាការី ៖ ចូររក្សាព្រះបញ្ញត្តិ ។*  
*ព្រះបញ្ញត្តិនេះធ្វើឱ្យមានសុវត្ថិភាព និងភាពសុខសាន្ត ។*[2]

គំរូ និងសេចក្ដីពិតទាំងឡាយ ត្រូវបានរកឃើញនៅក្នុងព្រះគម្ពីរមរមន គឺជាសេចក្ដីពិតច្បាស់ និងមានតម្លៃ ។ នៅពេលយើងចាប់ផ្ដើមធ្វើដោយសេចក្ដីសុចរិត និង ការគោរពប្រតិបត្តិតាម នោះយើងបានទទួលពរជ័យ និង សេចក្ដីអំណរនៅទីបំផុត ។ ■

**កំណត់ចំណាំ**

1. ស្ពែនសឺរ ដបុលយូ឵ ឃីមបឹល "The Blessings and Responsibilities of Womanhood", *Ensign* ខែ មិនា ឆ្នាំ 1976 ទំព័រ 70 ។
2. "Keep the Commandments," *Children's Songbook,* 146–47 ។

***យើងមានការភ្ញាក់ផ្អើលណាស់ នៅពេលយើងបានមកដល់ផ្លូវបំបែកដ៏រវល់ តែក្នុងពេលដូចគ្នានេះ មានយុវនារីជាសាសនាគន់ការីដ៏ស្វាហាប់វ័យក្មេងម្នាក់បានជិះកង់របស់គាត់មកដល់ ។ ខ្ញុំមានចិត្តអស្ចារ្យដ៏អនេកអំពីរបៀប ដែលសេចក្ដីជំនឿ និងការគោរពរបស់នាង ចំពោះព្រះបញ្ញត្តិដែលបានរកឃើញថ្មី បាននាំនាងទៅកាន់ផ្លូវនៃសេចក្ដីអំណរ ។***

# តើយើងអាចផ្ដល់អាហារដល់ជនជាច្រើនបានយ៉ាងដូចម្ដេច ?

ក្នុងនាមជាប្រធានសមាគមសង្គ្រោះ ខ្ញុំបានមានអារម្មណ៍គ្រប់ដណ្ដប់ដោយសារសេចក្ដីត្រូវការ និង ការសាកល្បងដែលក្រុមគ្រួសារខ្លះនៅក្នុងសាខាតូចរបស់យើង កំពុងតែប្រឈមមុខ ។ គឺជាគ្រាលំបាកក្រៃលែង ហើយសមាជិករបស់យើងខ្លះ បានបាត់បង់ការងាររបស់គេ ។

នៅខាងក្រៅសាសនាចក្រ ការខកចិត្ត ទុក្ខព្រួយ និងការអស់សង្ឃឹមអាចមើលឃើញនឹងភ្នែកនៃជន ជាច្រើនរូបផ្ទាល់ ដែលកំពុងតែមានសេចក្ដីលំបាកក្នុងការផ្ដល់ដល់ក្រុមគ្រួសាររបស់គេ ។ កុមារ និងយុវវ័យទាំងឡាយក៏សម្ដែងនូវអារម្មណ៍នៃភាពមិនពិតប្រាកដ និងចលាចលផងដែរ ។

អ្នកដឹកនាំសាខាទាំងឡាយបានមានអារម្មណ៍ថា ត្រូវតែចែកចាយនូវសេចក្ដីសង្ឃឹម និងសេចក្ដីស្រឡាញ់ខ្លះ ដល់អ្នកដែលខ្វះខាតជាងគេបំផុត—នូវអ្វីដែលអាចជួយប្រជាជនក្នុងសហគមន៍របស់យើង ឱ្យដឹងថា ព្រះវរបិតាសួគ៌ជាទីស្រឡាញ់ ដឹងពីទុក្ខលំបាករបស់ពួកគេ ហើយកំពុងតែទតមកលើពួកគេ ។

ពេលរដូវគ្រីស្ទម៉ាស់ជិតមកដល់ យើងត្រូវបានប្រាប់ឱ្យអញ្ជើញកុមារក្រីក្របំផុតនៅក្នុងសហគមន៍របស់យើងមកបរិភោគអាហារពេលល្ងាច ។ សមាជិកសាខាទាំងឡាយបានរៀបកម្មវិធីដើម្បីប្រមូលមូលនិធិ ដើម្បីទិញម្ហូបអាហារពីបណ្ដាញលក់ម្ហូប អាហារដុំ ហើយរៀបចំទីប្រជុំរបស់យើង ដើម្បីនឹងទទួលភ្ញៀវ ។ សមាជិកគ្រប់រូបបានចូលរួម ជាមួយនឹងថ្នាក់អង្គការបឋមសិក្សា ថ្នាក់យុវនារី និង ថ្នាក់យុវជនផងដែរ ។

យើងបានរៀបចំសម្រាប់ម្ហូបអាហារ ដើម្បីផ្ដល់អាហារ ហើយយើងបានទំនាក់ទំនងទៅអ្នកធ្វើការផ្នែកសង្គមកិច្ច ឱ្យរកក្រុមគ្រួសារក្នុងមូលដ្ឋានដែលខ្វះខាតជាងគេ ។ អ្នកធ្វើការខាងសង្គមសិកច្ច បានឱ្យបញ្ជីឈ្មោះកុមារ ប្រមាណជា 100 នាក់ ដែលមានចំនួនហួសពីចំនួនដែលយើងគិតទុកមុន ។ យើងមិនបានបាក់ទឹកចិត្តឡើយ ប៉ុន្តែវាហាក់ដូចជាមិនអាចធ្វើទៅរួច ក្នុងការរកមូលនិធិគ្រប់គ្រាន់ ដើម្បីនឹងទិញម្ហូបអាហារសម្រាប់ក្មេងដ៏ច្រើនបែបនេះទេ ។

ថ្ងៃដែលត្រូវបរិភោគអាហារពេលល្ងាចបានមកដល់ ប្រធានសាខារបស់យើងរួមជាមួយនឹងឱកុនបីប្អូនទាក់ បានយកមូលនិធិដែលយើងបានប្រមូល ហើយបានចេញទៅភោជនីយដ្ឋាន ដោយការងឿងឆ្ងល់ ថាតើយើងនឹងអាចចំអែតក្មេងៗជាច្រើន ដោយមូលនិធិដ៏ស្ដួចស្ដើងរបស់យើងនោះបានដូចម្ដេចទៅ ។ ពួកគេបានអធិស្ឋានក្នុងពេលដែលពួកគេចេញទៅ ដោយគិតថាយើងគប្បីអញ្ជើញកុមារៗតូចជាងគេ ឱ្យចែកអាហារពាក់កណ្ដាលឬផ្អាកសកម្មភាពសិន ។

នៅពេលគេបានទៅដល់ភោជនីយដ្ឋាន ប្រធានសាខាបានដាក់លុយនៅលើតុគិតលុយ ។ ពេលនោះហើយ ដែលការអធិស្ឋានរបស់ពួកគេបានឆ្លើយតប ។

នាយកចាត់ចែងភោជនីយដ្ឋានបានសម្លឹងមើលពួកគេ ដោយញញឹមថា ភោជនីយដ្ឋានរីករាយនឹងផ្ដល់អាហារ ទៅតាមតម្រូវការ—ដោយមិនគិតលុយឡើយ ! ខ្ញុំមិនអាចបង្ហាញសេចក្ដីអំណរដែលយើងគ្រប់គ្នាមាន ក្នុងការដែលដឹងថានេះគឺជាទង្វើដ៏សប្បុរសដែល បានអនុញ្ញាតឱ្យយើងនាំមកនូវសេចក្ដីសោមនស្ស—នឹងអាហារគ្រប់គ្រាន់—ចំពោះក្រុមកុមារ ទាល់ក្រដ៏ច្រើននេះឡើយ ។

ដោយព្រោះតែសប្បុរសធម៌របស់ភោជនីយដ្ឋាន យើងអាចប្រើលុយកាក់ដែលយើងប្រមូលបាន ដើម្បីទិញអាហារ ហើយបានធ្វើកន្ត្រកអាហារជាច្រើនសម្រាប់ក្រុមគ្រួសារដែលទាល់ក្រជាងគេថែមទៀតផង ។

ដោយសារបទពិសោធន៍នេះ យើងបានដឹងថា គ្មានការប្រឹងប្រែងណាមួយដែលឥតប្រយោជន៍ឡើយ ប្រសិនបើយើង យកទេពកោសល្យ និងបំណងល្អរបស់យើង ដើម្បីធ្វើការបម្រើដល់អ្នកជិតខាងរបស់យើងនោះ ។ ទីបន្ទាល់របស់យើងត្រូវបានពង្រឹងឡើង ដែលព្រះអម្ចាស់បានប្រទានឱកាស បន្ទាប់ពីយើងខិតខំធ្វើអស់ពី សមត្ថភាពរបស់យើង ។ ■

ម៉ាតា ហ្វីរណាន់ដេស្ស-រេប្វយ៉ូស មកពីប្រទេសអេស្ប៉ាញ

*កាលដែលប្រធានសាខាបានដាក់លុយនៅលើតុគិតលុយ ការអធិស្ឋានរបស់គេត្រូវបានឆ្លើយតប ។*



# ខ្ញុំសង្ឃឹមថានឹងមាននរណាម្នាក់ស្រឡាញ់នាង

នៅពេលកូនប្រុសរបស់ខ្ញុំមានអាយុបីឆ្នាំ ហើយកូនស្រីរបស់ខ្ញុំមានអាយុបួនឆ្នាំ នោះពួកគេគឺជាផ្នែកនៃសហគមន៍កុមារមត្តេយ្យ ។ នារដូវរងារនោះ យើងរាល់គ្នាណាដែលដឹកនាំក្រុម បានសម្រេចចិត្តធ្វើគម្រោងពិធីគ្រីស្ទម៉ាស់ ដែលរួមបញ្ចូល កុមារម្នាក់ៗឱ្យបរិច្ចាកប្រដាប់ក្មេងលេងដល់ក្រុមគ្រួសារដែលខ្វះខាត ។

យើងបានបង្រៀនមេរៀនជាច្រើន ក្នុងប៉ុន្មានសប្ដាហ៍ក្រោយមក អំពីការវភាព និងការចែករំលែកជាមួយអ្នកដទៃ ធ្វើឱ្យយើងរីករាយ ។ ខ្ញុំបានប្រាប់កូនៗរបស់ខ្ញុំឱ្យចាប់ផ្ដើមគិតអំពី សម្ភារលេងណាដែលពួកគេចង់ឱ្យគេដែលចង់ឱ្យពួកគេ មានបទពិសោធន៍នៃការជ្រើសអ្វី ត្រូវផ្ដល់ឱ្យគេ ។ ហិរញ្ញវត្ថុក្រុមគ្រួសាររបស់យើងស្ដួចស្ដើង ហើយខ្ញុំបានឆ្ងល់ថាតើសម្ភារលេងណាខ្លះដែលពួកគេនឹងឱ្យ ។

នៅព្រលឹមថ្ងៃសៅរ៍មួយ ខ្ញុំបានប្រាប់កូនៗថា ដល់ពេលដែលត្រូវជ្រើសរើសរបស់សម្រាប់ការបរិច្ចាករបស់គេហើយ ។ ខ្ញុំបានជួយហ័នធើរ៍ ខ្ចប់កូនឡានដែលគេបានជ្រើស រួចហើយបានទៅមើលមីកែល ។ ទិដ្ឋភាពដែលខ្ញុំបានមើលឃើញពីច្រកទ្វានៃបន្ទប់របស់នាង ធ្វើឱ្យខ្ញុំសម្រក់ទឹកភ្នែក ។

មីកែល កំពុងតែកាន់កូនក្រមុំដែលនាងស្រឡាញ់បំផុត ស្លៀកសម្លៀកបំពាក់ឱ្យយ៉ាងល្អវិសេស ហើយនាងកំពុងតែច្រៀងដាក់កូនក្រមុំនោះ ។ រួចហើយនាងបានញាត់ភួយតូចមួយចូលទៅក្នុងថង់អំណោយ ។ នាងបានញញឹមដាក់កូនក្រមុំ ឱបថើបកូនក្រមុំ ហើយដាក់ដោយថ្នមៗទៅក្នុងថង់ ។ នាងបាននិយាយដោយសម្លឹងមើលមកខ្ញុំ ថា « មិឡា ខ្ចប់រួចហើយ ម៉ាក់។ ខ្ញុំសង្ឃឹមថានឹងមាននរណាម្នាក់ស្រឡាញ់នាង » ។

ការដឹងអំពីអារម្មណ៍របស់កូនស្រីខ្ញុំចំពោះកូនក្រមុំនេះ ខ្ញុំភ្ញាក់ផ្អើលដែលនាងសុខចិត្តឱ្យវាទៅគេ ។ ខ្ញុំស្ទើរតែចង់ប្រាប់មីកែលថា នាងពុំចាំបាច់ឱ្យកូនក្រមុំ



*នៅព្រលឹមថ្ងៃសៅរ៍មួយ ខ្ញុំបានប្រាប់កូនៗថា ដល់ពេលដែលត្រូវជ្រើសរើសរបស់សម្រាប់ធ្វើការបរិច្ចាករបស់គេហើយ ។ ទិដ្ឋភាពដែលខ្ញុំបានមើលឃើញពីច្រកទ្វានៃបន្ទប់របស់នាង ធ្វើឱ្យខ្ញុំស្រក់ទឹកភ្នែក ។*

ដែលនាងស្រឡាញ់បំផុតនោះដល់អ្នកដទៃឡើយ ប៉ុន្តែខ្ញុំបានប្ដូរគំនិតវិញ ។

ខ្ញុំបានគិតថា « នាងយល់អំពីការចេះផ្ដល់ឱ្យ » ។ « នាងកំពុងតែផ្ដល់របស់ដ៏ល្អវិសេសរបស់នាង » ។

ខ្ញុំស្រាប់តែភ្ញាក់ខ្លួនថាខ្ញុំត្រូវមានចំណែកដើម្បីផ្ដល់ឱ្យ និងចែករំលែក ប៉ុន្តែពុំមែនជាពលិកម្មផ្ទាល់ខ្លួនរបស់ខ្ញុំទេ ។ ខ្ញុំបានដាក់កម្រិតចំពោះសេចក្ដីសប្បុរសរបស់ខ្ញុំ ហើយខ្ញុំបានដឹងថាខ្ញុំគប្បីផ្លាស់ប្ដូរ ។

ខ្ញុំបានគិតអំពីរបៀបដែលព្រះវរបិតាសួគ៌បានប្រទានព្រះរាជបុត្រាដ៏ល្អឥតខ្ចោះតែមួយរបស់ទ្រង់ ហើយបានអនុញ្ញាតឱ្យទ្រង់រងទុក្ខ និង សុគតសម្រាប់ខ្ញុំ ។ ខ្ញុំបានស្រមៃឃើញនូវព្រះវរបិតាសួគ៌ជាទីស្រឡាញ់ ថើបព្រះរាជបុត្រាជាទីស្រឡាញ់របស់ទ្រង់ ហើយបានបញ្ជូនទ្រង់មកលើផែនដីជាទារក ដោយសង្ឃឹមថាយើងនឹងស្រឡាញ់និងដើរតាមទ្រង់ ។

ព្រះសង្គ្រោះទ្រង់ផ្ទាល់ មិនបានរុញរាឡើយ ទ្រង់បានប្រទានអ្វីៗទាំងអស់ដែលទ្រង់អាចគប្បីនឹងប្រទាន ។

ខ្ញុំបានសង្ស័យក្រែងមីកែល នឹងផ្លាស់ប្ដូរចិត្តនាង មុននឹងកម្មវិធីបុណ្យគ្រីស្ទម៉ាស់ នៅពេលសម្ភារលេងត្រូវបានដាក់ឱ្យសំរាប់ជាការបរិច្ចាក ប៉ុន្តែនាងមិនបានផ្លាស់ប្ដូរចិត្តទេ ។ ខ្ញុំសង្ស័យក្រែងនាងនឹងសោកស្ដាយពេលក្រោយ ចំពោះជម្រើសរបស់នាង ហើយមានអារម្មណ៍សោកសៅ ប៉ុន្តែនាងមិនបានសោកសៅឡើយ ។

ការមើលឃើញគំរូដូចព្រះគ្រីស្ទរបស់កូនស្រីខ្ញុំ ខ្ញុំបានសម្រេចចិត្តថា ប្រសិនបើខ្ញុំមានច្រើនឬតិចដើម្បីនឹងឱ្យគេ ខ្ញុំតែងតែឱ្យគេដោយចិត្តរីករាយ នូវរបស់ដ៏វិសេសបំផុត តាមដែលខ្ញុំមានឱកាសចែករំលែក ។ ■

ប្រ៊ីតនី ផាន មកពីរដ្ឋយូថាហ៍ សហរដ្ឋ អាមេរិក

# អ្នកបានច្រៀងចេញពីដួងចិត្ត

ក្នុងខែធ្នូ ឆ្នាំ 2000 ក្រុមចម្រៀងស្តេករបស់យើងកំពុងតែរៀបចំដើម្បីនឹងទទួលភ្ញៀវនៃពិធីបុណ្យ ក្រុមអ្នកចម្រៀង ។ ក្រុមចម្រៀងដ៏ល្បីល្បាញខ្លះ នៅក្នុងក្រុងប៉ូសាដាស អាចិនធីន បានបញ្ជាក់ថាពួកគេនឹងចូលរួម ហើយ មនុស្សច្រើននឹងចូលរួមផងដែរ ។ តាមរយៈការច្រៀងរបស់យើង យើងសង្ឃឹមថានឹងអាចចែកចាយទីបន្ទាល់របស់យើង អំពីការប្រសូត្រនៃ ព្រះសង្គ្រោះ ។

ក្នុងនាមជាអ្នកដឹកនាំក្រុមតន្ត្រី ខ្ញុំមានចិត្តរសាប់រសល់ខ្លះៗ ។ បន្ថែមទៅលើការរសាប់រសល់របស់ខ្ញុំ ខ្ញុំមានផ្ទៃពោះ ប្រាបីខែជាកូនភ្លោះ ។ ខ្ញុំបានដឹងនូវការឈឺចាប់ក្នុងអំឡុងពេលនៃការហាត់សមចុងក្រោយ មួយសប្តាហ៍មុននឹងការប្រគុំតន្ត្រី នោះត្រូវដឹកនាំអំពីរបៀបអង្គុយ ។

ដល់ពេលការហាត់សមបានចប់ហើយ ខ្ញុំមិនអាចឈរទៀតឡើយ ។ ប្តីរបស់ខ្ញុំ បងខាឡូស ហើយនិងឪពុករបស់ខ្ញុំបានផ្តល់ពរដល់ខ្ញុំ ។ រួចហើយ ខាឡូស បាននាំខ្ញុំទៅមន្ទីរពេទ្យ ដែលវេជ្ជបណ្ឌិតបានកំណត់ថា ទារកនឹងកើតថ្ងៃនោះ ។ ខ្ញុំបានភ័យខ្លាច ប៉ុន្តែខាឡូសបានប្រាប់ខ្ញុំឱ្យទុកចិត្តលើព្រះអម្ចាស់ ។

មិនយូរប៉ុន្មាន សំឡេងទារកបានយំបន្លឺឡើងក្នុងបន្ទប់នោះ ។ បេះដូងរបស់ខ្ញុំបានពោរពេញដោយអំណរចំពោះសំឡេងនោះ ប៉ុន្តែវេជ្ជបណ្ឌិតបានចូលមកជិតហើយនិយាយ « នោះគឺជាសម្លេងយំរបស់ យីវ៉ា ប៉ុន្តែអេប្រៀល ពុំបានយំទេ » ។

ខ្ញុំគ្មានពាក្យអ្វីពិពណ៌នានូវអារម្មណ៍ ដែលមានមកលើខ្ញុំឡើយ ។ មិនយូរប៉ុន្មាន គេបានយកខ្ញុំទៅបន្ទប់មួយទៀត ជាទីកន្លែងដែលប្តីរបស់ខ្ញុំកំពុងតែរង់ចាំខ្ញុំ ។ យើងបានឱបគ្នា ហើយយំ ។

ខាឡូស បាននិយាយថាៈ « ដាហ្វនី យើងមិនដឹងពីគោលបំណងរបស់ព្រះអម្ចាស់ ចំពោះការយកអេប្រៀលទៅឯទ្រង់ទេ » ។ « ប៉ុន្តែយើងត្រូវតែរឹងមាំទទួលយកឆន្ទៈរបស់ទ្រង់ ហើយបោះជំហានទៅមុខក្នុងសេចក្តីជំនឿ » ។

បន្តិចក្រោយមក ខាឡូស បានបីយីវ៉ា ដ៏តូចនោះ ហើយបានផ្តល់ពរដល់នាងឱ្យរស់នៅ ។ នាងបានរស់នៅ ប៉ុន្តែដោយព្រោះតែបញ្ហាបន្តិចបន្តួច នាងបានស្ថិតនៅក្នុងមន្ទីរពេទ្យអស់រយៈពេល 10 ថ្ងៃទៀត ។

ខ្ញុំបានចេញពីមន្ទីរពេទ្យនៅសប្តាហ៍បន្ទាប់ ។ ពីព្រោះតែការធ្វើដំណើរជាញយៗទៅមន្ទីរពេទ្យដើម្បីទៅមើលនិងបំបៅយីវ៉ា ខ្ញុំមិនបានគិតអំពីក្រុម ចម្រៀងឡើយ ។ រាត្រីមុននឹងពិធីបុណ្យ ឪពុករបស់ខ្ញុំបានសួរខ្ញុំប្រសិនបើខ្ញុំបានសម្រេចចិត្តនឹងដឹកនាំ ។ គាត់បាននិយាយថា « សូមអធិស្ឋានទៅ ដាហ្វនីហើយការសម្រេចចិត្តណាដែលកូននឹងធ្វើ នឹងជាការសម្រេចចិត្តត្រឹមត្រូវ » ។

ខ្ញុំបានគិតអំពីយីវ៉ា ដែលនៅតែស្នាក់នៅក្នុងមន្ទីរពេទ្យ ។ ខ្ញុំបានគិតអំពីសមាជិកក្រុមចម្រៀងដែលបានខំធ្វើការដើម្បីរៀបចំសម្រាប់ការប្រគុំតន្ត្រី ។ ខ្ញុំបានគិតអំពីព្រះអង្គសង្គ្រោះ និងការប្រសូត្រ អំពីជីវិតហើយនិងពលិកម្មរបស់ទ្រង់ ។ ខ្ញុំបានដឹងនូវអ្វីដែលខ្ញុំគប្បីនឹងធ្វើ ។

***រួចហើយ ក្នុងពេលដែលសំឡេងនៃតន្ត្រីប្រគុំបន្លឺឡើង ខ្ញុំត្រូវបានគ្របដណ្តប់ជាមួយនឹងអារម្មណ៍មួយថា ខ្ញុំស្ថិតនៅក្នុងកន្លែងដ៏ល្អមួយ ។***



ការបង្ហាញនូវសេចក្តីស្រឡាញ់ចំពោះក្រុមគ្រួសាររបស់យើង បានទទួលនារាត្រីបន្ទាប់ ពីសមាជិក ក្រុមចម្រៀងដែលបានប៉ះដល់ដួងចិត្តរបស់យើងយ៉ាងជ្រៅ ហើយវិញ្ញាណនៃសេចក្តីសុខសាន្តក្នុងចំណោមពួកគេបានបង្កើតនូវបំណងចេញពីដួងចិត្ត ដើម្បីនឹងប៉ះដល់ដួងចិត្តនៃអស់អ្នកដែលចូលរួម ។

ពីព្រោះយើងជាម្ចាស់កម្មវិធី នោះក្រុមចម្រៀងស្តេករបស់យើងជាអ្នកច្រៀងក្រោយគេ ។ នៅពេលដែលព្យាណូ និងវីយ៉ូឡុងបានលេងទំនុកផ្តើមនៃបទ « បុណ្យណូអែលដំបូង » ទឹកភ្នែកបាន ស្រក់មកលើថ្ពាល់របស់ខ្ញុំ ។ រួចហើយ ក្នុងពេលដែលសំឡេងនៃតន្ត្រីប្រគុំបន្លឺឡើង ខ្ញុំត្រូវបានគ្របដណ្តប់ជាមួយនឹងអារម្មណ៍មួយថា ខ្ញុំស្ថិតនៅក្នុងកន្លែងដ៏ល្អមួយ ។

នៅពេលយើងបញ្ចប់ ខ្ញុំបានបែរទៅមើលទស្សនិកជនដែលជាសមាជិកឃើញថាពួកគេបានស្រក់ទឹកភ្នែក ។ អស់អ្នកប្រហែលជាមិនដែលឮសារនៃដំណឹងល្អនៃភាពសុខសាន្ត និងសេចក្តីស្រឡាញ់ ដែលមាននៅក្នុងអារម្មណ៍របស់ពួកគេ តាមរយៈ ដួរតន្ត្រីដ៏ពិរោះ និងភាពអស្ចារ្យនៃកំណើតរបស់ព្រះរាជ បុត្ររបស់ព្រះ ។

បន្ទាប់មក អ្នកដឹកនាំភ្លេងនៃក្រុមចម្រៀងឯទៀតបាននិយាយមកកាន់យើងថា « យើងមានវិធីល្អ ប៉ុន្តែអ្នកបានច្រៀងពីដួងចិត្តរបស់អ្នក » ។

ក្នុងរាត្រីមុនថ្ងៃគ្រីស្ទម៉ាស់ ប្តីរបស់ខ្ញុំ និងខ្ញុំសូមអរគុណព្រះអម្ចាស់ ចំពោះការប្រទានឱ្យ យីវ៉ា កើតមកក្នុងផ្ទះរបស់ យើង និងចំពោះការបញ្ជូនព្រះរាជបុត្រារបស់ទ្រង់មកលើផែនដី ។ ពីព្រោះតែដង្វាយធួនរបស់ព្រះរាជបុត្រា និងការផ្សារភ្ជាប់របស់យើងនៅក្នុងព្រះវិហារបរិសុទ្ធ នោះយើងដឹងថាអេប្រៀល ថ្ងៃណាមួយនឹងជារបស់ផងយើងម្តងទៀត ។ ■

ដាហ្វនី អាណាលា រ៉ូម៉ូរ ដេ ថាវ មកពីមីស៊ីអុនស៍ រដ្ឋអាចិនធីនណា

# ពោតលីង ពួកអ្នកត្រួសត្រាយ និង សន្តិភាព

ម៉ាក់ បានដាក់ដុំឥដ្ឋជាច្រើននៅក្នុងឡដុត រួចហើយបានខ្ចប់វានៅក្នុងភួយ ដើម្បីជួយធ្វើឱ្យចុងជើងរបស់យើងកក់ក្ដៅ នៅពេលយើងបានធ្វើដំណើរនៅក្នុងរថយន្ដរបស់យើង ដែលគ្មានម៉ាស៊ីនកំដៅ ។ នាឆ្នាំ 1935 ហើយយើងកំពុងតែបើកឡានធ្វើដំណើរ 60-ម៉ៃ (96 គ.ម.) ពីសលត៍ ឡេក ស៊ីធី ទៅ ភេសុន រដ្ឋយូថាហ៍ ដើម្បីទៅសួរសុខទុក្ខលោកយាយរបស់យើងនៅដើមខែធ្នូ ។ ព្រិលកំពុងតែធ្លាក់ចុះតិចៗជុំវិញយើង ហើយបានខ្យល់គួច នៅលើថ្នល់ខាងមុខ ។ បងប្រុសរបស់ខ្ញុំ ហ្វ្រេដ និងខ្ញុំបានពាក់អាវរងាដ៏ធ្ងន់ និង ស្រោមជើងដ៏ក្រាស់ដែលធ្វើពីរោមចៀម និងកន្សែងបង់ក ។ ការបើកឡានហាក់ដូចជាមិនចេះចប់មិនចេះហើយឡើយ ចំពោះខ្ញុំ ដែលជាកុមារតូចអាយុប្រាំពីរឆ្នាំ ។

យើងបានធ្វើដំណើរនេះរៀងរាល់ខែធ្នូ ។ រដូវគ្រីស្ទម៉ាស់ពិតជាមិនទាន់ចាប់ផ្ដើមទេ ទាល់តែយើង បានអង្គុយនៅក្នុងផ្ទះបាយរបស់លោកយាយ និងលោកតាផែណ្ណី ដ៏កក់ក្ដៅ ធ្វើដុំពោតលីងសិន ។ លោកតាតែងតែធ្វើឱ្យភ្លើងឆេះឆ្អៅឡើយ ហើយលោកយាយតែងតែដាក់ពោតលីងក្នុងកន្ត្រកលួស ហើយអង្រួនក្រឡុកវា នៅលើភ្លើង រហូតដល់វាផ្ទុះរីក ទៅជាពណ៌ស ។ រួចហើយលោកយាយបានចាក់ទឹកបីរ៍ទឹកឃ្មុំក្ដៅ ទៅលើពោតលីងនៅក្នុងឆ្នាំងដែក ហើយដាក់ សណ្ដែកដីលាយចូល ។ នៅពេលការលាយគ្នាទុកត្រជាក់ហើយ យើងតែងតែដៃច្បាមចាប់ ហើយពូនជាដុំមូល ដើម្បីចែករំលែកជាមួយក្រុមគ្រួសារ និងមិត្តភក្ដិ ។

ប៉ុន្ដែ បុណ្យគ្រីស្ទម៉ាស់ ឆ្នាំនេះគឺខុសពីគេ ។ តាមធម្មតា ហ្វ្រេដ និងខ្ញុំ អង្គុយនៅកៅអីខាងក្រោម ប៉ុន្ដែឆ្នាំនេះយើងបានអង្គុយប្រជ្រៀតគ្នាជាមួយឪពុកម្ដាយរបស់ខ្ញុំនៅលើកៅអីវែងនៅខាងមុខវិញ ។ ក្ដារមឈូសតូចពណ៌ស ដែលដាក់សពប្អូនប្រុសអាយុមួយឆ្នាំរបស់ខ្ញុំ ដែរុលដ៍ បានដាក់លើកៅអី វែងខាងក្រោយ ។ គឺជាជំងឺកញ្ជ្រិលដែលបានក្លាយទៅជារោគរលាកសួតដ៏ធ្ងន់ធ្ងរ ហើយបានឆក់យកជីវិតដ៏ក្មេងរបស់គាត់ទៅ ។ មុននឹងបន្តិច ពួកយើងបានទៅកន្លែងបញ្ចុះសព ដើម្បីទៅយកក្ដារមឈូសតូចមួយ ។

ក្នុងពេលយើងបានធ្វើដំណើររយៈពេលពីរម៉ោងរួចហើយ នោះប៉ាបាននាំយើងចូលរួមក្នុងការច្រៀងចម្រៀងបុណ្យគ្រីស្ទម៉ាស់ ។ ប៉ា និងម៉ាក់បានយល់ចិត្តគ្នា ហើយភ្លេងដ៏ពិរោះបានលួងលោមយើង កាលដែលយើងបានទួញសោកចំពោះការបាត់បង់សមាជិកគ្រួសាររបស់យើង ។

នៅពេលយើងទៅដល់ផ្ទះរបស់លោកតា សេចក្ដីរីករាយធម្មតានៃហ្វូងក្រុមគ្រួសារ និងញាតិមិត្តកំពុងតែរង់ចាំភាពកក់ក្ដៅ ។ ក្ដារមឈូសត្រូវបានយកចេញពីកៅអីវែងខាងក្រោយ នាំចូលទៅបន្ទប់ទទួលភ្ញៀវដ៏ស្អាតរបស់លោកតា ។ ប៊ីស្សពរបស់លោកយាយលោកតាបាននិយាយពាក្យពេចន៍ដ៏ល្អខ្លះ រួចហើយពួកគេបានយកមឈូសចូលទៅក្នុងឡានវិញ ទៅទីបញ្ចុះសព ជាទីកន្លែងដែលយើងទួញយំ កាលដែលសពរបស់ក្មេងដ៏មានតម្លៃនេះ ដាក់បញ្ចុះចូលទៅក្នុងដីដ៏ត្រជាក់ ។

ថ្ងៃបុណ្យគ្រីស្ទម៉ាស់បានមក ។ ភ្លើងបានឆេះឆ្អៅឡើយ ពោតលីងបានផ្ទុះឡើង ហើយពិធីធ្វើពោតលីងទៅជាដុំមូលៗ ត្រូវបានដឹកដើរចែកនៅក្នុងរទេះអូសដោយសេះរបស់លោកតា ។ នៅក្នុងថ្ងៃនោះក៏មានទុក្ខសោកខ្លះដែរ ប៉ុន្ដែសន្តិភាពបានកើតមាន ខណៈពេលខ្ញុំស្ដាប់លោកយាយលោកតាដ៏ស្មោះត្រង់របស់យើង បានអានរឿងនៃការប្រសូតរបស់ព្រះគ្រីស្ទ ។

លោកយាយលោកតារបស់ខ្ញុំបានកើតមកពីឪពុកម្ដាយជាអ្នកត្រួសត្រាយ ដែលបានបញ្ចុះសពទារកជាច្រើនទៅក្នុងដី ។ កាលដែលក្រុមគ្រួសាររបស់យើងបានទួញសោកនូវការបាត់បង់របស់យើង យើងបានរំឭកពីទីកន្លែងដែលដូនតារបស់យើងរំឭក—ចំពោះព្រះរាជបុត្រារបស់ព្រះ និងព្រះបន្ទូលរបស់ទ្រង់ ។ ខ្ញុំបានចាំនូវរឿងបុណ្យគ្រីស្ទម៉ាស់ជាមួយនឹងដួងចិត្តខុសប្លែកគ្នានៅឆ្នាំនោះ ដ្បិតគឺដោយព្រោះតែព្រះទារកតូច ដែលបានប្រសូត្រក្នុងស្នូកសត្វ នោះធ្វើឱ្យទារកដែលយើងបានបញ្ចុះនៅក្នុងដី នឹងរស់ឡើងវិញហើយជារបស់ផងយើង ។

ជាច្រើនទសវត្ស បានកន្លងផុតទៅតាំងពីពេលនោះ ប៉ុន្ដែបុណ្យគ្រីស្ទម៉ាស់នីមួយ ៗខ្ញុំនៅតែចាក់បីរ៍ទឹកឃ្មុំ លើពោតលីង ពូនទៅជាដុំមូលៗ ហើយនៅតែចងចាំ ។ ■

ស្ទីលី ហីស្ដ ស្នេលស៍ មកពីរដ្ឋយូថា សហរដ្ឋអាមេរិក

***ក្នុងពេលយើងបានធ្វើដំណើររយៈពេលពីរម៉ោងរួចហើយ នោះប៉ាបាននាំយើងចូលរួមក្នុងការច្រៀងចម្រៀងបុណ្យគ្រីស្ទម៉ាស់ ។ ប៉ា និងម៉ាក់បានយល់ចិត្តគ្នា ហើយភ្លេងដ៏ពិរោះបានលួងលោមយើង កាលដែលយើងបានទួញសោកចំពោះការបាត់បង់សមាជិកគ្រួសាររបស់យើង ។***



គំនូរដោយ ដ៊ី ប្រ៊ូន ឆាក់គេនសុន



**ដោយអែលឌើរ**
**ជែហ្វ្រី អ័រ. ហូឡិន**
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# បុណ្យគ្រីស្ទម៉ាស់ នៅក្នុងខ្លួន អ្នករាល់គ្នា

*ការរក្សាសេចក្ដីជំនឿរបស់អ្នក សូមរកមើលអ្វីដែលល្អនៅក្នុងស្ថានភាពរបស់អ្នក ។ ចូរធ្វើអ្វីដែលល្អចំពោះអ្នកដទៃ ។ ស្វែងរកព្រះគ្រីស្ទ ដោយគ្មានក្រដាប់ខ្ចប់គុបតែងលំអរ ។*

ខ្ញុំជឿថា មនុស្សគ្រប់រូបចាំអំពីបុណ្យគ្រីស្ទម៉ាស់ដំបូងរបស់គេ ពេលនៅឆ្ងាយពីផ្ទះ ។ មូលហេតុនៃការនៅឆ្ងាយពីផ្ទះ គឺព្រោះតែបេសកកម្ម ឬការបម្រើយោធា ជីវិតជានិស្សិត ឬការងារ ។ ថ្វីបើជាមូលហេតុណាក៏ដោយ បុណ្យគ្រីស្ទម៉ាស់ដំបូងឆ្ងាយពីផ្ទះ គឺជាការចងចាំដ៏ក្តុកក្តួលចំពោះយើងគ្រប់រូប ។ ចំពោះអស់អ្នកដែលបាននៅឆ្ងាយពីផ្ទះ ក្នុងបុណ្យគ្រីស្ទម៉ាស់ ឬអ្នកដែលនៅឆ្ងាយពីផ្ទះឆ្នាំនេះ ខ្ញុំសូមឧទ្ទិសនូវការចងចាំនេះដល់អ្នក ។

ករណីយរបស់ខ្ញុំ គឺខ្ញុំបម្រើជាផ្សព្វផ្សាយសាសនាម្នាក់ ។ អស់រយៈពេល 19 ឆ្នាំ ដែលខ្ញុំបានរីករាយនឹងបុណ្យគ្រីស្ទម៉ាស់ ដែលមានទៅដោយក្រុម





រចនារូបភាពដោយ ប៊ុល មេន

គ្រួសារ និងមិត្តភក្តិជាច្រើន ។ ខ្ញុំជឿថា នៅក្នុងយុវវ័យខ្ញុំ គិតតែពីខ្លួនឯង ខ្ញុំមិនដែលគិតអំពីការចំណាយបុណ្យគ្រីស្ទម៉ាស់តាមរបៀបណាទៀតឡើយ ។

បន្ទាប់មក ក្នុងពេលរដូវបុណ្យណូអែលមកដល់ក្នុងឆ្នាំ 1960 ខ្ញុំបានដឹងខ្លួនថា ខ្ញុំនៅពាក់កណ្ដាលផែនដីឆ្ងាយពីបុណ្យគ្រីស្ទម៉ាស់បែបនោះ ។ ខ្ញុំបាននៅក្នុងប្រទេសអង់គ្លេស តិចជាងបីខែ ក្នុងខែធ្នូទីមួយ នៅពេលខ្ញុំត្រូវបានហៅឱ្យទៅបម្រើក្នុងការិយាល័យបេសកកម្ម ដើម្បីទៅជួយអែលឌើរ ផៃណ្ណី អិលឌុនស្ទីង ទើបតែមកដល់ពី ឆាមពៀន អាលបឺតា ប្រទេសកាណាដា—ជាដៃគូថ្មីដំបូងរបស់ខ្ញុំ ។ យើងត្រូវបានបញ្ជូនឱ្យបើកកិច្ចការការផ្សព្វផ្សាយសាសនា នៅក្នុងទីក្រុងអភិរក្សនៃហ្សេលហ្វ៊ដ នៅក្នុង តំបន់ ស្ស៊ីរ ជាតំបន់ដែលពុំដែលមានពួកអ្នកផ្សព្វផ្សាយសាសនាពីមុនមកឡើយ ហើយតាមការដឹងរបស់យើង គឺយើង មានសមាជិកតែម្នាក់គត់ដែលបានពួន នៅកន្លែងមាននៅក្នុងព្រំដែន ។ យើងនៅក្មេង គ្មានបទពិសោធន៍ ហើយមានសំពាធបន្តិចបន្តួច ប៉ុន្តែយើងពុំភ័យខ្លាចឡើយ ។

យើងបានចុះឈ្មោះជាមួយនឹងប៉ូលីស បានរៀបចំទីលំនៅ ហើយដំបូងមក មិនអាចរកឃើញសមាជិកណាម្នាក់នៃសាសនាចក្រទេ—តែយើងបានខិតខំយ៉ាងអស់ពីសមត្ថភាពរបស់យើង ដើរគោះទ្វាផ្ទះគេ ។ យើងបានគោះទ្វាពេលព្រឹក យើងបានគោះទ្វាពាក់កណ្ដាលថ្ងៃ យើងបានគោះទ្វានៅក្នុងពេល ថ្ងៃរសៀល ហើយយើងបានគោះទ្វាក្នុងពេលយប់ ។ យើងបានជិះកង់របស់យើងតាមផ្លូវទាំងនោះ ចំពោះយើងហាក់បីដូចជាស្ថិតនៅ ក្រោមធាតុអាកាសដែលមានភ្លៀងធ្លាក់ច្រើនជាងគេ នៃប្រវត្តិសាស្ត្រក្នុងប្រទេសប្រស៊ិល នាខែធ្នូ—។ យើងបានទទឹកជោគនៅពេលព្រឹក យើងបានទទឹកជោគនៅពេលថ្ងៃត្រង់ យើងបានទទឹកជោគនៅពេលរសៀល ហើយយើងបានទទឹកជោគនៅពេលយប់ តែយើងនៅតែដើរគោះទ្វាផ្ទះ ។ ហើយគ្មានអ្នកណាឱ្យយើងចូលផ្ទះគេសោះ ។

ដូច្នេះហូតដល់រាត្រីមុនថ្ងៃគ្រីស្ទម៉ាស់ នៅពេលដែលប្រជាជនមានចិត្តរីករូស មិនស្ដាប់ពួកអ្នកផ្សព្វផ្សាយសាសនាពីរនាក់ « មកពីបណ្ដាអាណានិគម » ។ នារាត្រីនោះ គឺជាថ្ងៃដែលនឿយហត់ តែពេញទៅដោយការប្ដេជ្ញាចិត្ត យើងបានចូលសម្រាកនៅក្នុងផ្ទះជួលរបស់យើង ហើយមានការប្រជុំធម្មទិដ្ឋានគ្រីស្ទម៉ាស់ ។ យើងបានច្រៀងទំនុកតម្កើងបុណ្យគ្រីស្ទម៉ាស់ រួចហើយផ្ដល់ការអធិស្ឋានបើក ។ យើងបានអានពីព្រះគម្ពីរ ហើយស្ដាប់កាសែតចម្រៀងមានចំណងជើងថា *The True Story of Christmas* ។ រួចហើយយើងបានច្រៀងទំនុកតម្កើងនៃរដូវកាលនោះ ហើយថ្លែងការអធិស្ឋានបញ្ចប់ រួចហើយចូលដំណេក ។ យើងបានអស់កម្លាំងយ៉ាងខ្លាំង ដើម្បីគិតអំពីការរាំឈ្មោះ ស៊ូហ៊ីផ្លាំស៍ នៅក្នុងក្បាលរបស់យើង ។

ព្រលឹមថ្ងៃគ្រីស្ទម៉ាស់ យើងបានរក្សាកាលវិភាគសិក្សាពេលព្រឹករបស់យើង ហើយបានបើកកញ្ចប់ការដូរីរឬមីដែលបានទាំយកមកជាមួយយើង នៅពេលដែលបានផ្លាស់ប្ដូរតំបន់។ រួចហើយ យើងបានចេញទៅគោះទ្វា ។ យើងបានគោះទ្វានៅក្នុងពេលព្រឹក យើងបានគោះទ្វាពេលថ្ងៃត្រង់ យើងបានគោះទ្វានៅក្នុងពេលរសៀល ហើយយើងបានគោះទ្វានៅពេលយប់ ។ គ្មាននរណាម្នាក់ឱ្យយើងចូលបង្រៀនគេឡើយ ។

ត្បិតគ្រីស្ទម៉ាស់ដ៏ឥតបានការ—ពិតជាធុញទ្រាន់ដែលខ្ញុំមិនដែលមានពីមុនមក ព្រោះថា—ថ្ងៃចម្លែកទាំងនេះក្នុងខែធ្នូក្នុងឆ្នាំ 1960 បានដក់ជាប់ក្នុងដួងចិត្តរបស់ខ្ញុំ (បន្ទាប់ពីជាង 50 ឆ្នាំ ក្រោយមក !) ។ ជាបុណ្យគ្រីស្ទម៉ាស់ដ៏មានន័យបំផុតដែលខ្ញុំមិនធ្លាប់មាន។ ខ្ញុំគិតថាគឺដោយព្រោះតែជាលើកដំបូងក្នុងជីវិតរបស់ខ្ញុំ ខ្ញុំបានរកឃើញហើយដឹងថាពិធីបុណ្យគ្រីស្ទម៉ាស់គឺមានអត្ថន័យ ជាជាងគ្រាន់តែរីករាយនឹងរដូវកាលនោះ។ ខ្ញុំគិតថា ជាលើកដំបូងនៅក្នុងរបៀប

ដ៏ពិត ហើយសំខាន់មួយ ខ្ញុំកំពុងតែទទួលសារដំណឹងល្អនៃការប្រសូត្រ និង ព្រះជន្មរបស់ព្រះគ្រីស្ទ—សារដំណឹងរបស់ទ្រង់ និងបេសកកម្មរបស់ទ្រង់ និងពលិកម្មរបស់ទ្រង់ សម្រាប់ជនឯទៀត ។

ខ្ញុំគប្បីមានទំនាក់ទំនងនឹងអនុស្សាវរីយទាំងនោះក្នុងអំឡុងវ័យក្មេង ប៉ុន្តែ—យ៉ាងហោចណាស់មិនទាន់រឹងមាំនៅឡើយ ។ ប៉ុន្តែបុណ្យគ្រីស្ទម៉ាស់នៅក្នុងប្រទេសអង់គ្លេស—គឺត្រជាក់ សើមជោគជាំ ដែលធ្វើឱ្យអារម្មណ៍នៃយុវជនអាយុ 19 ឆ្នាំកំពុងពិបាកចិត្ត—ខ្ញុំពិតជាយល់អំពីពិធីបុណ្យនោះ។ ខ្ញុំពិតជាអាចនិយាយបានថា ពីព្រោះតែបេសកកម្មរបស់ខ្ញុំ បុណ្យគ្រីស្ទម៉ាស់ដូចជាទិដ្ឋភាពជាច្រើនឯទៀតនៃដំណឹងល្អ នៃបុណ្យគ្រីស្ទម៉ាស់ ដែលបានមានអត្ថន័យកាន់តែខ្លាំង ចំពោះខ្ញុំជារៀងរាល់ឆ្នាំ ព្រោះតែបទពិសោធន៍នោះ ។

ក្នុងរដូវបុណ្យគ្រីស្ទម៉ាស់ឆ្នាំនេះ ខ្ញុំសូមផ្ញើសេចក្ដីស្រឡាញ់របស់ខ្ញុំ ជូនចំពោះពួកអ្នកផ្សព្វផ្សាយសាសនាគ្រប់រូប ទាំងបុរសនិងស្ត្រីគ្រប់រូប កងយោធានិស្សិតគ្រប់រូប និងនិយោជិតគ្រប់រូប ព្រមទាំងអ្នកធ្វើដំណើរដែលមិនបាន « មកផ្ទះសម្រាប់បុណ្យគ្រីស្ទម៉ាស់ »[1] ដូចដែលចម្រៀងបុណ្យគ្រីស្ទម៉ាស់ថ្លែងដូច្នោះ ។ ចូររក្សាសេចក្ដីជំនឿរបស់អ្នក ។ សូមរកមើលអ្វីដែលល្អនៅក្នុងស្ថានភាពរបស់អ្នក ។ ចូរធ្វើអ្វីដែលល្អចំពោះអ្នកដទៃ ។ ចូរស្វែងរកព្រះគ្រីស្ទ ដោយគ្មានកាដូខ្ចប់តុបតែងលំអរ ។ អ្នកនឹងរកឃើញថា ថ្វីបើកាលៈទេសៈខាងក្រៅរបស់អ្នកបែបណាក៏ដោយ បុណ្យគ្រីស្ទម៉ាស់—គឺដូចជានគរព្រះ « នៅកណ្ដាលអ្នករាល់គ្នា » (លូកា 17:21)។ ■

*ពី “A Mission Christmas”,* Church News *ថ្ងៃទី 17 ខែធ្នូ ឆ្នាំ 2011 ទំព័រ 10 ។*

**កំណត់ចំណាំ**

1. ជែមស៍ « គិម » ហ្គែណ្ណុន “I'll Be Home for Christmas” ឆ្នាំ 1943) ។





**ដោយ ម៉ារី អិន. យុក**
ទីប្រឹក្សាទីមួយនៅក្នុង
គណៈប្រធានយុវនារីទូទៅ

# គ្រឿងតុបតែងបុណ្យ គ្រីស្ទម៉ាស់, មិត្តភក្តិដែលលក្ខណៈ ដូចព្រះគ្រីស្ទ

ការរៀបចំដើម្បីតុបតែដើមគ្រីស្ទម៉ាស់របស់យើង ខ្ញុំបានរើចេញពីប្រអប់ឡាំងមួយ ពេញទៅដោយគ្រឿង តុបតែងគ្រីស្ទម៉ាស់ ដែលខ្ញុំមិនបានឃើញឬប្រើជាច្រើនឆ្នាំ ។ ពេលដែលខ្ញុំកំពុងតែកកាយរកក្នុងខ្សែរអំពូលភ្លើងគ្រីស្ទម៉ាស់និងក្រណាត់សំពត់ ខ្ញុំបានរកឃើញប្រអប់សម្លៀកបំពាក់ពេញទៅដោយគ្រឿងតុបតែង ដែលខ្ញុំបានប្រមូល នៅពេលខ្ញុំនៅលីវ ហើយនៅពេលខ្ញុំជាគ្រូបង្រៀននៅសាលា ។ ខ្ញុំបានរកឃើញក្រណាត់ប៉ាក់ដ៏សាមញ្ញមួយដែលគ្រាន់តែសរសេរថា “Christmas Open House—ឆ្នាំ 1984” ។ អារម្មណ៍របស់ខ្ញុំត្រូវបានទាញឱ្យត្រឡប់ទៅគិតអំពីឆ្នាំនោះ ។ ខ្ញុំមិនទាន់រៀបការ ហើយបានរើចេញដោយរុញរា ពីវួដមជ្ឈមវ័យវ័យក្មេងមួយ ទៅវួដក្រុមគ្រួសារ ។

ខ្ញុំស្រឡាញ់រដូវបុណ្យគ្រីស្ទម៉ាស់ ប៉ុន្តែគឺជាគ្រាដ៏ឯកកោរចំពោះខ្ញុំ ។ កាលមានវ័យ 30 ឆ្នាំ ហើយនៅលីវ និងពុំមានកូន ជួនកាលខ្ញុំមានអារម្មណ៍ថាឯកកោ ។ វាគឺជាការងាយស្រួល ដែលខ្ញុំមានអារម្មណ៍តូចចិត្តនឹងខ្លួនឯង ហើយបាក់ទឹកចិត្ត ដែលពេលខ្លះមានអារម្មណ៍ថា « ឱ ខ្លួនដ៏កំសត់អើយ » ។ ជាពិសេសឆ្នាំ 1984 ខ្ញុំចាំនូវការធ្វើការសម្រេចចិត្តដោយចេតនាដើម្បីនឹងយកឈ្នះលើអារម្មណ៍បែបនោះ ដោយមិនគិតពីខ្លួនខ្ញុំ ហើយរកមើលអ្វីដែលអាចធ្វើឱ្យបុណ្យគ្រីស្ទម៉ាស់រីករាយចំពោះអ្នកដទៃ ។

ខ្ញុំជាសមាជិកថ្មីនៅក្នុងវួដ ហើយបានគិតថាការបើកផ្ទះខ្ញុំទទួលសមាជិកនៃសមាគមសង្គ្រោះ នឹងជួយខ្ញុំឱ្យអបអរថ្ងៃឈប់សំរាកជាមួយគ្នា នឹងស្គាល់គេស្គាល់ឯងដែលជាបងប្អូនស្រីកាន់តែច្រើនឡើង ។

កាលដែលខ្ញុំសញ្ជឹងគិតអំពីពិធីឡើងផ្ទះនោះ ខ្ញុំបានចាំអំពីដើមគ្រីស្ទម៉ាស់តូច ដែលបានតុបតែង ស្ថិតនៅក្នុងប្រអប់គ្រឿងតុបតែង ភ្លិនទុំយុកឃី ដែលបណ្ដាមិត្តលីវទាំងឡាយរបស់ខ្ញុំបានជួយខ្ញុំ ជួយធ្វើ និងរសជាតិដ៏ផ្អែមនៃ « ទឹកផ្លែឈើលាយពណិស » របស់ម៉ាក ដែលខ្ញុំបានបម្រើជូនភ្ញៀវ ។

ខ្ញុំបានពិនិត្យមើលគ្រឿងតុបតែងជាច្រើនប្រភេទ អារម្មណ៍ដ៏កក់ក្ដៅនៃសេចក្ដីស្រឡាញ់ និងការកោតមានពេញក្នុងដួងចិត្តខ្ញុំ កាលដែលខ្ញុំបានគិតអំពីមិត្តភក្តិដូចជាព្រះគ្រីស្ទជាច្រើន ទាំងក្មេងទាំងចាស់ដែលស្រឡាញ់និងមើលថែទាំខ្ញុំ ក្នុងគ្រាលំបាក ។

ខ្ញុំបានរើសយកក្រណាត់ប៉ាក់មួយដែលមានប៉ាក់រូបព្រិលទឹកកក ដែលស្ដ្រីចំណាស់ម្នាក់បានចាក់ ឱ្យខ្ញុំ ហើយបានរំឭកខ្ញុំពីការយកចិត្តទុកដាក់របស់គាត់ចំពោះខ្ញុំ ។ ខ្ញុំបានគិតអំពីបងស្រីៗចំណាស់ៗក្នុងវួដជាច្រើន ដែលខ្ញុំធ្លាប់បានជួបក្នុងវួដចាស់ ដែលបានចែករំលែកចំណេះ របស់គេដល់ខ្ញុំ ។ ខ្ញុំបានរៀនចាក់ ប៉ាក់ និងដេរពីបងស្រីៗទាំងនេះ ដែលបានចង់លះបង់ពេលវេលារបស់គាត់ ហើយជា ពិសេស មានចិត្តអំណត់ដើម្បីធ្វើឱ្យខ្ញុំបានរីករាយដូចជាពួកគេ ។

ខ្ញុំបានកាន់ស្នែងធ្វើពីស្លាន់ ហើយបានគិតអំពីការអញ្ជើញដឹកនាំក្រុមចម្រៀង ដែលមានទេពកោសល្យផ្នែកតន្ត្រី ដែលបានអញ្ជើញខ្ញុំឱ្យចូលរួមក្នុងការហាត់ទាំងព្រលឹមអុល សម្រាប់កម្មវិធីចម្រៀងពិសេសរបស់ក្មេងជំទង់ ។ ទំនុកចិត្តរបស់គាត់ បានដក់ជាប់នៅក្នុងខ្លួនខ្ញុំនូវសេចក្ដីស្រឡាញ់ចំពោះតន្ត្រីប្រពៃណី ហើយទំនុកចិត្តដើម្បីនឹងចូលរួមក្នុងក្រុមចម្រៀង ពេញមួយជីវិតរបស់ខ្ញុំ ។

ជាមួយនឹងទឹកមុខញញឹម ខ្ញុំបានរើសគ្រឿងតុបតែងរូបតុក្កតា មីគី ម៉ោស ហើយមានអំណរគុណចំពោះប្ដីប្រពន្ធ ដែលបានឱ្យខ្ញុំលេងជាមួយកូនៗរបស់ពួកគេ ។ កូនរបស់ពួកគេបានក្លាយដូចជាកូនរបស់ខ្ញុំ ។ ខ្ញុំបានបីពពួកគេក្នុងព្រះវិហារ អានឱ្យពួកគេស្ដាប់ លេងជាមួយពួកគេ ហើយស្រឡាញ់ពួកគេ ដោយជួយបំពេញដួងចិត្តដ៏ឯកកោរបស់ខ្ញុំ ។

ព្រះសង្គ្រោះ បានបង្រៀនយើងនៅក្នុងម៉ាថាយ 10:39 បានមានបន្ទូលថា៖ « អ្នកណាដែលរកបានជីវិតខ្លួន នោះនឹងត្រូវបាត់ជីវិតទៅ តែអ្នកណាដែលបាត់ជីវិត ដោយយល់ដល់ខ្ញុំ អ្នកនោះនឹងបានជីវិតវិញ » ។

ការសម្រេចចិត្តដោយចេតនាក្នុងឆ្នាំ 1984 ដើម្បី « បំភ្លេចខ្លួនខ្ញុំ » ដោយសម្លឹងទៅខាងក្រៅ ពិតជាបទពិសោធន៍ផ្លាស់ប្ដូរក្នុង « ការរកឃើញ » ខ្លួនខ្ញុំ ។ កាលដែលខ្ញុំគិតអំពីអតីតកាល ខ្ញុំបានដឹងថា មានមនុស្សជាច្រើន ដែលបានធ្វើតាមតាមព្រះបន្ទូល របស់ព្រះអង្គសង្គ្រោះ ហើយបានបំភ្លេចពីជីវិតរបស់គេសម្រាប់ខ្ញុំ ។ *គ្រឿងតុបតែងគ្រីស្ទ*ម៉ាសបានក្លាយទៅជាការរំឭកដ៏ផ្អែមល្ហែមអំពី*ព្រះគ្រីស្ទ*ដូចជាមិត្តទាំងឡាយ ។ ■

ទេវរូបភាព © BUSATH PHOTOGRAPHY; ទេវរូបភាពដោយស្តុក ស្ទ័



# កន្សែងដៃបុណ្យ គ្រីស្ទម៉ាស់

**ដោយស្កុត អិម មួយ**
ទស្សនាវដ្ដីសាសនាចក្រ

រៀងរាល់ឆ្នាំ ពេលខ្ញុំនៅក្មេង ខ្ញុំបានជួយម្ដាយខ្ញុំខ្ចប់អំណោយគ្រីស្ទម៉ាស់សម្រាប់ក្រុមគ្រួសារ ។ ខ្ញុំមានបងប្អូនដែលបានរៀបការហើយ 5 នាក់ និងក្មួយប្រុសស្រី 13 នាក់ ដូច្នេះហើយ នេះពុំមែនជាភារកិច្ច ងាយស្រួលឡើយ ។ ប៉ុន្តែថ្វីបើជាការខ្ចប់មិនល្អក្តី ខ្ញុំបានសង្កេតឃើញថា យើងតែងតែរៀបចំខ្ចប់កន្សែងដៃមួយសម្រាប់បងស្រីរបស់ខ្ញុំជានិច្ច ។ ថ្វីបើម្ដាយរបស់ខ្ញុំឱ្យសម្លៀកបំពាក់ឈុតរាត្រី ឬអាវឬប្រដាប់ប្រដារផ្ទះបាយខ្លះក្ដី គែតែងតែមានកន្សែងដៃសម្រាប់ អ៊ែន ជានិច្ច ។ ខ្ញុំដឹងថាកន្សែងដៃគឺមានប្រយោជន៍ និងមានតម្លៃថោក ប៉ុន្តែខ្ញុំបានចាប់ផ្ដើមឆ្ងល់ថា តើបងស្រីរបស់ខ្ញុំនឹងគិតដូចម្ដេចអំពីការទទួលអំណោយដដែលនេះ។

នាខែធ្នូមួយ ទីបំផុត ខ្ញុំបានសួរថា ៖ « ឱ្យកន្សែងដៃទៅបង អ៊ែន មួយទៀតហើយ ? ម៉ាក់ ម៉ាក់ហាក់ដូចឱ្យកន្សែងដៃទៅគាត់ស្ទើរតែរាល់ឆ្នាំ ។ តើម៉ាក់ បានគិតទេថា ប្រហែលជាបងស្រីមានកន្សែងដៃគ្រប់គ្រាន់ហើយ មកដល់ពេលនេះ ? តើបងស្រី ត្រូវការវាប៉ុន្មានទៀតទៅ ? ហើយកញ្ចប់អំណោយមួយទៀតដែលផ្ញើតាមប្រៃសណីយ៍ វាមានតម្លៃថ្លៃជាង ។ ខ្ញុំមិនគិតថា ម៉ាក់គប្បីធ្វើបែបនេះទេ » ។

ម៉ាក់របស់ខ្ញុំបានដាក់កន្ត្រៃចុះមួយឡែកសិន ។ « ម៉ាក់ចង់ប្រាប់រឿងមួយដល់កូន ។ រួចហើយ ប្រហែល

រចនារូបភាពដោយ សែ៊ម ឡូឡឺរ៍

ជាកូននឹងយល់ ។ រឿងនេះបានកើតឡើងមុននឹងកូនឯងកើតមក ។

« កូនដឹង ពីរបៀបដែលម៉ាក់មកទីក្រុងនេះ » ។ (កូនដឹង ។ ក្រុមគ្រួសាររបស់ម៉ាក់ មានការភ្ញាក់ផ្អើលណាស់ នៅពេលគាត់បានរៀបការនឹងពោះម៉ាយម្នាក់ដែលមានកូន បួននាក់ ប៉ុន្តែអ្វីដែលគួរឱ្យតក់ស្លុតទៅទៀតនោះ គឺថាគាត់នឹងត្រូវ ចាកចេញពីប្រទេសហូឡង់ មកកាន់សហរដ្ឋ អាមេរិកទៀត) ។ « ប៉ុន្តែមានរឿងខ្លះ ដែលកូនមិនដឹង ។ នៅពេលយើងមកដល់ទីនេះ យើងគ្មានអ្វីទាល់តែសោះ ។ ជីវិតគឺពិបាកក្រៃលែង ។ ឪពុករបស់កូន បានធ្វើការពីរកន្លែង ប៉ុន្តែទទួលប្រាក់ឈ្នួលតិចណាស់ ។ ម៉ាក់បានធ្វើការបោកគក់ និងអ៊ុត ។ តែយើងនៅតែពុំមានលុយគ្រប់គ្រាន់ដដែល ។

« ក្នុងពេលនោះ អ៊ែន មានអាយុ 17 ឆ្នាំ ហើយបានដឹងថា យើងបានជំពាក់គេយ៉ាងច្រើន ។ នាងបានសម្រេចចិត្តថានាងអាចជួយរំលែកខ្លះៗ ។ នាងបានចេញទៅធ្វើការ ។ នាងរកបានការងារមួយនៅក្នុងក្រុង ក្នុងហាងលក់ស្ករគ្រាប់ ។ នាងត្រូវជិះឡានក្រុងទៅធ្វើការ ឈរនៅឯតុគិតលុយពេញមួយថ្ងៃ ។ នាងបានឱ្យប្រាក់ខែរបស់នាងមកយើងស្ទើរតែទាំងអស់ ទុកតែបន្តិចបន្តួចគ្រប់គ្រាន់សម្រាប់តែថ្លៃ ជិះឡានក្រុងប៉ុណ្ណោះ និងទិញអាហារថ្ងៃត្រង់បរិភោគប៉ុណ្ណោះ ព្រោះនាងមិនអាចទុកអាហារក្រោយតុគិតលុយឡើយ ។

« អ៊ែន បានប្រាប់ម៉ាក់ថា នាងរីករាយនឹងការងារនាង ហើយថាប្រាក់ឈ្នួលរបស់នាងអាចជួយយើងបាន ។ ប៉ុន្តែនាងមិនដែលប្រាប់ម៉ាក់ថា នាងព្រួយចិត្តពីប្អូនៗប្រុសរបស់នាងឡើយ ។ បុណ្យគ្រីស្ទម៉ាស់នឹងមកយ៉ាងឆាប់ៗ ។ មិត្តភក្តិសញ្ជាតិអាមេរិកកាំងថ្មីរបស់គេកំពុងតែនិយាយអំពីសម្ភារក្មេងលេងដែលពួកគេបានសុំសាន់តា ឱ្យយកមកឱ្យពួកគេ ។ ចុះប្រសិនបើ សាន់តាមិនបានយកអំណោយណាមួយមកផ្ទះយើងវិញនោះ ?

« ពីរបីថ្ងៃមុនថ្ងៃបុណ្យគ្រីស្ទម៉ាស់ អ៊ែន បានឱ្យលុយមួយចំនួនដល់ម៉ាក់ ។ ប៉ុន្តែវាពុំមែនជាថ្ងៃបើកប្រាក់របស់នាងនោះទេ ។ ម៉ាក់បានសួរនាងថា តើកូនបានលុយនេះមកពីណា ។ នាងបានប្រាប់ម៉ាក់ថា នាងបានសន្សំលុយនេះ ដោយការមិនបរិភោគអាហារថ្ងៃត្រង់ ។ ប្រាក់វាមិនច្រើនទេ ប៉ុន្តែម៉ាក់បានដឹងថា កូនម៉ាក់ មិនបានបរិភោគអាហារថ្ងៃត្រង់អស់ជាច្រើនសប្ដាហ៍ហើយ ។ នាងបានប្រាប់ម៉ាក់ថា សូមឱ្យយកលុយនេះទៅទិញអំណោយគ្រីស្ទម៉ាស់ ឱ្យប្អូនៗរបស់នាង ។ នាងបានទុកចិត្តម៉ាក់ ដែលជាម្ដាយក្រោយ ដើម្បីនឹងទិញអំណោយដែលត្រឹមត្រូវ ។

« ម៉ាក់បានទិញរបស់របរបន្តិចបន្តួច ។ ប៉ុន្តែម៉ាក់បានសម្រេចចិត្តនឹងធ្វើបុណ្យគ្រីស្ទម៉ាស់ សម្រាប់ក្រុមគ្រួសារទាំងមូលតែម្ដង ។ ទិញក្រូចឃ្វិច សម្រាប់ទុកបរិភោគ សាប៊ូម៉ាកខ្លាឃ្មុំ គូល័រទៀន កូនឡានលេងតូចៗ ស្រោមជើងសម្រាប់ឪពុកកូន ។ ហើយម៉ាក់បានទិញកន្សែងដៃឱ្យអ៊ែន ។ គឺជាកន្សែងធម្មតា ប៉ុន្តែម៉ាក់បានអង្គុយប៉ាក់វាទាំងកណ្ដាលអាធ្រាត ដើម្បីឱ្យវាស្អាត ។ ម៉ាក់រីករាយណាស់ ចំពោះកូនស្រីថ្មីរបស់ម៉ាក់ ដែលកំពុងតែផ្ដល់ដល់យើងនូវបុណ្យគ្រីស្ទម៉ាស់ ។ ម៉ាក់ចង់ឱ្យអំណោយពិសេសសម្រាប់បុណ្យគ្រីស្ទម៉ាស់ដល់នាងផងដែរ ។

« ថ្ងៃបុណ្យគ្រីស្ទម៉ាស់មកដល់ ។ យើងបានភ្ញាក់ផ្អើលនៅពេលមិត្តភក្តិនៅសាសនាចក្ររបស់យើងបានយកដើមឈើគ្រីស្ទម៉ាស់ នឹងប្រអប់ពេញទៅដោយអំណោយ ។ ពួកគេបានសុំអភ័យទោសដែលអំណោយទាំងនោះ រុំនឹងកាសែត ប៉ុន្តែវាគឺជាអំណោយដ៏ល្អក្រៃលែង ! មានរបស់របរមានប្រយោជន៍ជាច្រើន និងអាហារសម្រាប់បរិភោគ ។ រួចហើយមានរឿងដ៏ភ្ញាក់ផ្អើលមួយទៀត ចំពោះអំណោយសម្ងាត់របស់អ៊ែន និងម៉ាក ៖ សានតា បានមកផ្ទះរបស់យើង ! ប្អូនៗរបស់កូនរីករាយក្រៃលែង ! មិនយូរប៉ុន្មានរបស់របរបានដាក់នៅលើកម្រាលឥដ្ឋក្នុងបន្ទប់ទទួលភ្ញៀវតូចនោះ កូនឡានជ័ររត់ឆ្វេងឆ្វាត់ពីខាងលើ និងខាងក្រោមកាសែត ។ មានក្រដាសកាសែតគ្រប់ទីកន្លែង ! ហើយអ៊ែន បានបើកអំណោយរបស់នាង ហើយបានឃើញកន្សែងដៃ ។ នាងបានយំ ។ ម៉ាក់បានយំតិចៗដែរ ។

« យើងបានធ្វើអាហារបុណ្យគ្រីស្ទម៉ាស់ជាមួយគ្នា ។ អូ ! យើងមានបង្អែមដែលយើងមិនមានជាយូរណាស់មកហើយ ! រួចហើយយើងបាននាំគ្នាសំអាតចេញ ។ អ៊ែន បានដាក់កន្សែងដៃរបស់នាងទុក ។ ប៉ុន្តែវាបានបាត់ទៅ ។ យើងបានរកមើលគ្រប់ទីកន្លែង ។ ហើយម៉ាក់បានគិតថា ពុទ្ធោអើយ ! ឪពុករបស់កូនបានដុតក្រដាសកាសែតអស់ហើយ ។ តើកន្សែងដៃបានដុតក្នុងភ្លើងមែនទេ ? ប្រហែលជាអញ្ចឹងហើយ ពីព្រោះយើងរកវាមិនឃើញសោះ ។ ប៉ុន្តែអ៊ែន មិនត្អូញត្អែទេ ។ អ្វីដែលបានកើតឡើង បានកើតឡើងរួចទៅហើយ ។ នាងបាននិយាយថា នាងរីករាយពីព្រោះប្អូនប្រុសៗរបស់នាងរីករាយ ។

« បុណ្យគ្រីស្ទម៉ាស់បន្ទាប់ ម៉ាក់បានឱ្យកន្សែងដៃមួយទៀតទៅអ៊ែន ។ ម៉ាក់ ប្រុងប្រយ័ត្នថា កន្សែងដៃនេះនឹងមិនបាត់ទៀតឡើយ ។ នៅពេលនាងបានរៀបការហើយរើចេញទៅឆ្ងាយ ម៉ាកបានផ្ញើកន្សែងដៃបុណ្យគ្រីស្ទម៉ាស់ទៅឱ្យនាង ។ ម៉ាក់មិនឱ្យកន្សែងដៃដល់នាងឥឡូវនេះទៀតទេ តែម៉ាក់ជឿថានាងនៅត្រូវការវា ។ ម៉ាក់ឱ្យកន្សែងដៃដល់នាង ដើម្បីប្រាប់នាងថាម៉ាក់នឹងមិនភ្លេចអំពីអ្វីដែលនាងបានធ្វើក្នុងបុណ្យគ្រីស្ទម៉ាសដំបូងឡើយ ។

ពីរបីឆ្នាំក្រោយមក បន្ទាប់ពីម្ដាយរបស់ខ្ញុំបានប្រាប់ខ្ញុំអំពីរឿងនេះ យើងអាចធ្វើបុណ្យគ្រីស្ទម៉ាស់ជាមួយក្រុមគ្រួសារទាំងមូល ។ ជាការរំភើបណាស់ ដែលខ្ញុំបានមើលឃើញបងស្រីរបស់ខ្ញុំលាកន្សែងដៃមួយឡើង ។ ខ្ញុំបានឃើញភ្នែករបស់នាងរលីងរលោងកាលដែលនាងបានលូកដៃទៅ ហើយក្ដាប់ដៃម្ដាយរបស់ខ្ញុំយ៉ាងណែន ។ ខ្ញុំយល់ ។ វាមិនត្រឹមតែជាកន្សែងដៃមួយប៉ុណ្ណោះទេ ។ វាគឺជាអនុស្សាវរីយដ៏ពិសេសនៃសេចក្ដីស្រឡាញ់ អំណោយ និងពលិកម្មរបស់ពួកគេ ។ តាមវិធីដ៏ងាយៗវារំឭកខ្ញុំអំពីមូលហេតុដែលយើងធ្វើពិធីបុណ្យគ្រីស្ទម៉ាស់—ពីព្រោះវា គឺជាអំណោយដ៏ធំ នឹងជាទីស្រឡាញ់ដែលទាមទារឱ្យមានការលះបង់ ។ ■

# « តើខ្ញុំឆ្លើយសំណួររបស់មិត្តខ្ញុំ អំពីព្រះវិហារបរិសុទ្ធបានដោយរបៀបណាទៅ បើខ្លួនខ្ញុំផ្ទាល់ មិនសូវដឹងអំពីព្រះវិហារបរិសុទ្ធផងនោះ ? »

វាមានការពិបាកដើម្បីនិយាយអំពីអ្វីមួយដែលយើងមិនយល់ ហើយមានចំណុចជាច្រើនដែលយើងមិនអាចយល់អស់ពីព្រះវិហារបរិសុទ្ធ លុះត្រាតែយើងអាចទៅទីនោះដោយខ្លួនយើងផ្ទាល់ ។ នៅក្រៅព្រះវិហារបរិសុទ្ធយើងមានការប្រុងប្រយ័ត្នពីរបៀបដែលយើងពិភាក្សាគ្នាអំពីពិធីបរិសុទ្ធទាំងឡាយនៃព្រះវិហារបរិសុទ្ធ ពីព្រោះពិធីទាំងនោះគឺពិសិដ្ឋ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏យើង អាចនិយាយគ្នាអំពីពរជ័យ និង គោលបំណងទាំងឡាយនៃព្រះវិហារបរិសុទ្ធបានដែរ ។ យើងអាចប្រាប់មិត្តភក្តិរបស់យើងថា នៅក្នុងព្រះវិហារបរិសុទ្ធ សមាជិកទាំងឡាយរៀនអំពីសេចក្តីពិតដ៏នៅអស់កល្បជានិច្ច ទទួលពិធីបរិសុទ្ធពិសិដ្ឋទាំងឡាយសម្រាប់ខ្លួនគេផ្ទាល់ និង ធ្វើពិធីបរិសុទ្ធទាំងនេះជំនួសឱ្យបុព្វការីជនរបស់ពួកគេ ព្រមទាំងមនុស្សដទៃទៀតដែលបានទទួលមរណៈភាព ។

បើអ្នក ស្គាល់ព្រះវិហារបរិសុទ្ធឱ្យបានច្រើន នោះវាជួយ រៀបចំខ្លួនរបស់អ្នកកាន់តែប្រសើរក្នុងការឆ្លើយនូវសំណួរទាំងឡាយរបស់មិត្តភក្តិអ្នក ។ ដើម្បីរៀនបន្ថែមទៀតនោះ សូមប្រឹក្សាជាមួយឪពុកម្តាយ ឬអ្នកដឹកនាំទាំងឡាយនៃសាសនាចក្ររបស់អ្នក ។ អ្នក និង មិត្តភក្តិទាំងឡាយរបស់អ្នកក៏អាចអានច្បាប់ចេញផ្សាយពិសេសនៃ*លីអាហូណា*ស្តីអំពីព្រះវិហារបរិសុទ្ធ (ខែ តុលា ឆ្នាំ 2010) និងស្វែងរកចម្លើយនៅគេហទំព័រ Mormon.org នៅក្រោមពាក្យ « Temples » នៅក្នុងសំណួរទាំងឡាយដែលចោទសួរញឹកញាប់ ។

អ្នកក៏អាចចែកចាយផងដែរ អំពីអារម្មណ៍ដែលអ្នកបានទទួលអំពីព្រះវិហារបរិសុទ្ធ ។ បើសិនអ្នកធ្លាប់ទៅព្រះវិហារបរិសុទ្ធដើម្បីធ្វើបុណ្យជ្រមុជទឹក ឬធ្លាប់ទៅបរិវេណព្រះវិហារបរិសុទ្ធ នោះអ្នកអាចប្រាប់មិត្តភក្តិទាំងឡាយរបស់អ្នក អំពីអារម្មណ៍នៃភាពសុខសាន្តដែលអ្នកបានមាននៅពេលអ្នកនៅទីនោះ ។

បើសិនមិត្តភក្តិទាំងឡាយរបស់អ្នកសួរថា តើហេតុអ្វីព្រះវិហារបរិសុទ្ធមិនបើកទ្វារសម្រាប់មនុស្សគ្រប់គ្នា នោះអ្នកអាចពន្យល់ថា ពីព្រោះតែមានកិច្ចការពិសិដ្ឋដែលត្រូវធ្វើនៅក្នុងព្រះវិហារបរិសុទ្ធ មានតែអ្នកដែលបានរៀបចំខ្លួនខាងវិញ្ញាណ និង មានប័ណ្ណចូលព្រះវិហារបរិសុទ្ធដែលមានសុពលភាពប៉ុណ្ណោះទើបអាចចូលបាន ។ មុនពេលព្រះវិហារបរិសុទ្ធទាំងឡាយត្រូវបានធ្វើការឧទ្ទិសឆ្លង ការបើកសម្ពោធអនុញ្ញាតឱ្យមនុស្សនៅក្នុងសហគមន៍ដើរទស្សនាព្រះវិហារបរិសុទ្ធ និងរៀនបន្ថែមទៀតអំពីវា ។ បន្ទាប់ពីព្រះវិហារបរិសុទ្ធត្រូវបានឧទ្ទិសឆ្លងរួច មនុស្សគ្រប់គ្នាអាចទស្សនាបរិវេណខាងក្រៅ ។ បើអាចធ្វើទៅបាន សូមអញ្ជើញមិត្តភក្តិរបស់អ្នកមកចូលរួមពិធីសម្ពោធ ឬមកទស្សនានៅបរិវេណព្រះវិហារបរិសុទ្ធជាមួយអ្នក ។

## សូមឱ្យមានភាពសក្តិសមសម្រាប់ព្រះវិហារបរិសុទ្ធ



ខ្ញុំនឹងប្រាប់មិត្តភក្តិទាំងឡាយរបស់ខ្ញុំ អំពីអ្វីដែលព្រះវិហារបរិសុទ្ធតំណាងចំពោះខ្ញុំ ៖ សុភមង្គល កម្លាំង ការបូជា និង ក្រុមគ្រួសារដ៏នៅអស់កល្បជានិច្ច ។ ខ្ញុំនឹងពន្យល់ពីរបៀបដើម្បីរក្សាខ្លួនឱ្យមានភាពសក្តិសម ។ បើសិនជាពួកគេដឹងថា ខ្ញុំបានរស់នៅស្របទៅតាមព្រះវិហារបរិសុទ្ធ នោះគឺជាគោលដៅមួយសំខាន់បំផុតរបស់ខ្ញុំ នោះពួកគេនឹងទទួលអារម្មណ៍នៃព្រះចេស្តានៃព្រះវិហារបរិសុទ្ធ ។ មនុស្សគ្រប់គ្នាអាចឃើញពីភាពស្រស់ស្អាតនៅផ្នែកខាងក្រៅនៃព្រះវិហារបរិសុទ្ធ ប៉ុន្តែតាមរយៈការរស់នៅដ៏ត្រឹមត្រូវ នោះខ្ញុំអាចបង្ហាញមិត្តភក្តិទាំងឡាយរបស់ខ្ញុំ ពីសេចក្តីសង្ឃឹម និង សុភមង្គលដែលយើងបានទទួលនៅពេលយើងចូលទៅក្នុងព្រះវិហារបរិសុទ្ធ ។

*អែមម៉ា អ័រ. អាយុ 18 ឆ្នាំ យូថាយ៍ ស.រ.អ*

## សូមអញ្ជើញមិត្តភក្តិទាំងឡាយរបស់អ្នកឱ្យរៀនបន្ថែមទៀត



សូមប្រាប់មិត្តភក្តិទាំងឡាយរបស់អ្នកពីអ្វីគ្រប់យ៉ាងដែលអ្នកដឹង—បើសិនជានោះសមរម្យ ។ សូមប្រាប់ពួកគេថា យើងមិនពិភាក្សាអ្វីៗអំពីព្រះវិហារបរិសុទ្ធឡើយ ព្រោះវាពិសិដ្ឋ ។ បើសិនពួកគេសួរអ្វីដែលអ្នកមិនដឹង សូមប្រាប់ពួកគេដោយត្រង់ថា អ្នកអត់ដឹងទេ ។ ហើយបើសិនពួកគេចង់ដឹងបន្ថែមទៀត សូមអញ្ជើញពួកគេទៅកាន់ព្រះវិហារ ហើយប្រាប់ពួកគេថា ព្រះប្រទានពរដល់អស់អ្នកដែលរក្សាបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ដោយចំណេះដឹងខាងវិញ្ញាណបន្ថែមទៀត ។ យើងជឿលើការសិក្សាអំពីរឿងរ៉ាវខាងវិញ្ញាណ មួយបន្ទាត់ម្តងៗ មួយសិក្ខាបទម្តងៗ ។

*ខាមេឡា ប៊ី អាយុ 18 ហ្វីលីពីន*

## សូមអធិស្ឋានទូលសុំព្រះវិញ្ញាណដើម្បីប្រាប់ពីចម្លើយរបស់អ្នក



ដើម្បីឆ្លើយសំណួរទាំងឡាយរបស់មិត្តភក្តិខ្ញុំ ទីមួយ ខ្ញុំត្រូវអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌អំពីអ្វីដែលត្រូវនិយាយ ។ វាត្រូវការភាពអត់ធ្មត់ច្រើន ប៉ុន្តែវានឹងសក្តិសមដើម្បីរង់ចាំ ព្រះវិញ្ញាណដើម្បីប្រាប់អ្នកអំពីអ្វីដែលត្រូវនិយាយ ។ ទីពីរ ទៅព្រះវិហារ និង ពិធីបុណ្យជ្រមុជនៅព្រះវិហារបរិសុទ្ធ ដើម្បីទទួលបានចំណេះដឹងខាងវិញ្ញាណបន្ថែមទៀត ។ នៅពេលមិត្តរបស់ខ្ញុំសួរសំណួរអំពីព្រះវិហារបរិសុទ្ធ នោះខ្ញុំប្រាប់នាងថា បុណ្យជ្រមុជទឹកត្រូវបានធ្វើឡើងសម្រាប់បុព្វការីជនរបស់យើងដែលបានស្លាប់ទៅដោយមិនមាន

*ចម្លើយទាំងឡាយគឺមានបំណងដើម្បីជួយ និងជាទស្សនវិស័យ មិនមែនជាការប្រកាសអំពីគោលលទ្ធិសាសនាចក្រនោះទេ ។*

ឱកាសទទួលយកដំណឹងល្អ កាលដែលពួកគេនៅមានជីវិត ។ បន្ទាប់មកនោះ នៅក្នុងស្ថានសួគ៌ពួកគេមានជម្រើសដើម្បីទទួល ឬបដិសេធពិធីបរិសុទ្ធនោះ ។
*លីឌីយ៉ា ភី. អាយុ 13ឆ្នាំ ហ្វ្លរីដា ស.រ.អ*

## សូមអញ្ជើញមិត្តភក្តិទាំងឡាយរបស់អ្នកឱ្យជួបពួកអ្នកផ្សព្វផ្សាយសាសនា

នៅពេលមិត្តភក្តិទាំងឡាយសួរខ្ញុំពីព្រះវិហារបរិសុទ្ធនោះខ្ញុំនិយាយថា វាគឺជាដំណាក់របស់ព្រះអម្ចាស់ ជាកន្លែងដែលយើងអាចធ្វើពិធីបរិសុទ្ធពិសេសៗ ដែលរក្សាយើងឱ្យជិតស្និទ្ធនឹងព្រះវរបិតាសួគ៌របស់យើង ហើយអាចធ្វើឱ្យយើងត្រឡប់ទៅរកទ្រង់វិញ ។ ខ្ញុំក៏សួរមិត្តភក្តិទាំងឡាយរបស់ខ្ញុំផងដែរ បើសិនពួកគេចង់ជួបពួកអ្នកផ្សព្វផ្សាយសាសនាដើម្បីរៀនបន្ថែមទៀត ។ បើពួកគេថាអត់ចង់ជួបទេ នោះខ្ញុំនឹងកត់ត្រាសំណួររបស់ពួកគេ ហើយសួរពួកអ្នកផ្សព្វផ្សាយសាសនាដោយខ្លួនខ្ញុំផ្ទាល់ ។ បន្ទាប់មក ខ្ញុំនឹងប្រាប់ឱ្យមិត្តភក្តិទាំងឡាយរបស់ខ្ញុំដឹងពីអ្វីដែលខ្ញុំបានដឹងនោះ ។ ធ្វើបែបនេះ ខ្ញុំក៏អាចរៀនបន្ថែមទៀតអំពីព្រះវិហារបរិសុទ្ធផងដែរ ។
*គីមមី អេចជ៍ អាយុ 13 ម៉ុនថាណា ស.រ.អ*

## សូមបង្ហាញរូបភាព របស់ព្រះវិហារបរិសុទ្ធទាំងឡាយ



ខ្ញុំចូលចិត្តអានសៀវភៅ ដែលមានដាក់រូបព្រះវិហារបរិសុទ្ធដែលនៅជុំវិញពិភពលោក ។ ខ្ញុំបានដឹងថា ការពន្យល់របស់ខ្ញុំមិនពេញលេញឡើយ នៅពេលមានមិត្តម្នាក់សួរខ្ញុំអំពីព្រះវិហារបរិសុទ្ធ ។ ដូច្នេះខ្ញុំបានយកសៀវភៅដែលនិយាយអំពីព្រះវិហារបរិសុទ្ធ ហើយបង្ហាញដល់នាងពីព្រះវិហារបរិសុទ្ធ គោលបំណងរបស់ព្រះវិហារបរិសុទ្ធ និង អំណរគុណដ៏ខ្លាំងដែលយើងមាន ចំពោះការទៅព្រះវិហារបរិសុទ្ធ ។ ខ្ញុំបានសម្រេចចិត្តថា អញ្ជើញនាងមកកាន់ព្រះវិហារនៅថ្ងៃអាទិត្យ នោះអ្នកផ្សព្វផ្សាយសាសនា និង គ្រូសាលាថ្ងៃអាទិត្យអាចជួយនាងឱ្យរៀនបន្ថែមទៀតបាន ។
*ជេស៊ីកា អេ អាយុ 18 ឆ្នាំ ឥណ្ឌូណេស៊ី*

## សូមនិយាយជាមួយឪពុកម្ដាយរបស់អ្នក



សូមស្វែងរកចម្លើយទាំងឡាយរបស់អ្នក ។ សូមអានព្រះគម្ពីរ និងសួរគ្រូសាលាថ្ងៃអាទិត្យ សំណួរទាំងឡាយ តែងតែត្រូវបានឆ្លើយ អ្វីដែលអ្នកត្រូវធ្វើនោះគឺស្វែងរកវា ។ សូមអធិស្ឋានអំពីវា ! នៅពេលដែលខ្ញុំមានសំណួរអំពីព្រះវិហារបរិសុទ្ធ នោះខ្ញុំសួរឪពុកម្ដាយរបស់ខ្ញុំ ។ វាងាយស្រួលដើម្បីនិយាយជាមួយពួកគាត់ ហើយមានឆន្ទៈដើម្បីជួយ ។
*ព្រាយសុន ប៊ី អាយុ 18 យូថាយ៍ ស.រ.អ*

## សូមទៅព្រះវិហារបរិសុទ្ធ

បើសិនយើងព្យាយាមទៅព្រះវិហារបរិសុទ្ធកាន់តែញឹកញាប់តាមដែលអាចធ្វើទៅបាន នោះយើងអាចស្គាល់ព្រះវរបិតាសួគ៌របស់យើងកាន់តែប្រសើរឡើង ។ នោះមានន័យថា យើងអាចអធិស្ឋានទៅកាន់ទ្រង់អំពីសំណួរទាំងឡាយរបស់មិត្តយើង ។ បើយើងមិនដឹងច្រើនអំពីព្រះវិហារបរិសុទ្ធទេ នោះមានន័យថាយើងត្រូវតែសិក្សាបន្ថែមទៀត ។ រាល់ពេលមុនទៅព្រះវិហារបរិសុទ្ធ នោះសូមសិក្សា និង អធិស្ឋានអំពីអ្វីដែលអ្នកគប្បីនឹងគិតខណៈពេលនៅព្រះវិហារបរិសុទ្ធនោះ ។ បន្ទាប់មកយើងអាចឆ្លើយនូវសំណួរទាំងឡាយដូចជា « តើអ្នកមានអារម្មណ៍យ៉ាងដូចម្ដេចនៅព្រះវិហារបរិសុទ្ធ ? »
*សារ៉ា ធី. អាយុ 14ឆ្នាំ អៃដាហូ ស.រ.អ*



**បរិសុទ្ធចំពោះព្រះអម្ចាស់**

ព្រះវិហារបរិសុទ្ធជាកន្លែងដ៏បរិសុទ្ធ ជាកន្លែងនៃវិវរណះ ជាកន្លែងនៃសេចក្ដីសុខសាន្តមួយ ។ វាជាព្រះដំណាក់របស់ព្រះអម្ចាស់ ។ វាបរិសុទ្ធចំពោះព្រះអម្ចាស់ ។ វាគួរតែបរិសុទ្ធចំពោះយើង » ។

ប្រធាន ហាវើដ ដបុលយូ. ហ៊ីនធើរ (ឆ្នាំ1907–95)
“The Great Symbol of Our Membership,” *Tambuli,* ខែ វិច្ឆិកា ឆ្នាំ 1994 ទំព័រ 6 ។

## សំណួរបន្ទាប់
## « តើខ្ញុំអាចទប់ទល់នឹងការល្បួងដោយរបៀបណា ? »

សូមផ្ញើចម្លើយរបស់អ្នកទៅត្រឹមថ្ងៃទី 15 ខែ មករា ឆ្នាំ 2013, គេហទំព័រ liahona.lds.org, ដោយអ៊ីម៉ែលទៅកាន liahona@ldschurch.org, ឬ ដោយផ្ញើសំបុត្រទៅកាន់ ៖

Liahona, Questions & Answers 1/13
50 E. North Temple St., Rm. 2420
Salt Lake City, UT 84150-0024, USA

ចម្លើយអាចនឹងធ្វើការកែសម្រួលឡើងវិញ ដោយព្រោះវែងពេក ឬដើម្បីភាពច្បាស់លាស់ ។

ព័ត៌មាន និងការអនុញ្ញាតខាងក្រោមត្រូវតែបញ្ចូល ៖ (1) នាម និងគោត្តនាម (2) ថ្ងៃខែឆ្នាំកំណើត (3) វួដ ឬសាខា (4) ស្តេក ឬមណ្ឌល (5) សំបុត្រអនុញ្ញាតដែលមានជាលាយលក្ខណ៍អក្សររបស់អ្នក ហើយប្រសិនបើអ្នកអាយុក្រោម 18 ឆ្នាំ នោះត្រូវមានសំបុត្រអនុញ្ញាតពីឪពុកម្ដាយអ្នកជាលាយលក្ខណ៍អក្សរ ( អ៊ីមែល អាចទទួលយកបាន ) ដើម្បីធ្វើការបោះពុម្ពចម្លើយ និងរូបថតរបស់អ្នក ។

# របៀបដើម្បី**ថ្វាយអំណោយដល់ព្រះគ្រីស្ទ**



**ដោយ ប្រធាន**
**ហិនរី ប៊ី អាវរិង**
ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ

**របៀបដែលយុវវ័យបាន អនុវត្តតាមចំណុចនេះ**

« ខ្ញុំអញ្ជើញមិត្តភក្តិម្នាក់មកកាន់ព្រះវិហារ មកចូលរួមសកម្មភាពម្ហូបឆ្នាំឆល ឬអាហារពេលល្ងាច ។ ការខ្វាយខ្វល់បន្តិចបន្តួចអាចមានប្រសិទ្ធភាពខ្លាំង ដើម្បីជួយនរណាម្នាក់ឱ្យដឹងថាយើងស្រឡាញ់ពួកគេ » ។
អាម៉ែនដ៍ អេហ្វ ។

« ខ្ញុំព្យាយាមសរសេរសំបុត្រទៅកាន់ពួកអ្នកផ្សព្វផ្សាយសាសនាទាំងឡាយ ដែលចេញពីវួដរបស់ខ្ញុំ » ។
ជេនទី អ័រ ។

« ពេលខ្លះ វាគ្រាន់តែធ្វើជាមិត្តម្នាក់សម្រាប់អស់អ្នកដែលត្រូវការជំនួយប៉ុណ្ណោះ » ។
រាយអ៊ិន ប៊ី

ដកស្រង់ចេញពីសុន្ទរកថាការប្រជុំធម្មនិដ្ឋានបុណ្យគ្រីស្ទម៉ាស់របស់គណៈប្រធានទីមួយ « អំណោយនៃព្រះអង្គសង្គ្រោះ » ។

អារម្មណ៍នៃបុណ្យគ្រីស្ទម៉ាស់ដាក់នៅក្នុងដួងចិត្តរបស់យើងនូវបំណងដើម្បី**ផ្តល់សេចក្តីអំណរ**ដល់មនុស្សផ្សេងទៀត ។ ការប្រារព្ធពិធីបុណ្យគ្រីស្ទម៉ាស់ជួយយើងឱ្យ**រក្សាសេចក្តីសន្យារបស់យើងដើម្បីចងចាំដល់ព្រះអម្ចាស់ជានិច្ច**និងអំណោយទាំងឡាយរបស់ទ្រង់ដល់ពួកយើង ។ ហើយការចងចាំនេះបង្កើតនូវបំណងក្នុងចិត្តរបស់យើង ដើម្បី**ថ្វាយអំណោយទាំងឡាយដល់ទ្រង់** ។

ទ្រង់បានមានព្រះបន្ទូលប្រាប់យើងពីអ្វីដែលយើងអាចថ្វាយដល់ទ្រង់ ដើម្បីធ្វើឱ្យទ្រង់សព្វព្រះទ័យ ។ ទីមួយ ដោយសារសេចក្តីជំនឿលើទ្រង់ នោះយើងអាច**ថ្វាយ ចិត្តសង្រេង និង វិញ្ញាណទន់ទាប** ។ យើងអាចប្រែចិត្ត ហើយធ្វើសេចក្តីសន្យាពិសិដ្ឋទាំងឡាយជាមួយទ្រង់ ។

ទីពីរ អ្នកអាចថ្វាយទ្រង់នូវអំណោយនៃការធ្វើអ្វីមួយសម្រាប់មនុស្សដទៃទៀត ដូចអ្វីដែលទ្រង់នឹងធ្វើសម្រាប់ពួកគេ ។ មាននូវចំណុចជាច្រើនក្នុងព្រះគម្ពីរម៉ាថាយដែលយើងអាចធ្វើ ។ នៅក្នុងនោះយើងអានព្រះបន្ទូលរបស់ព្រះប្រោសលោះយើង ដែលយើងទាំងអស់គ្នាសង្ឃឹមដើម្បីស្តាប់ និង និយាយនៅពេលយើងឃើញទ្រង់បន្ទាប់ពីជីវិតនេះ ៖

« នោះពួកមនុស្សសុចរិតនឹងទូលសួរទ្រង់ថា ព្រះអម្ចាស់អើយ តើយើងខ្ញុំបានឃើញទ្រង់ស្រេកឃ្លាន ហើយបាន**ថ្វាយទ្រង់សោយ**ពីកាលណា ? ឬស្រេកទឹក ហើយបានទ្រង់សោយពីកាលណា ?

« តើយើងខ្ញុំបានឃើញទ្រង់ជាអ្នកដទៃ ហើយបានទទួលទ្រង់ពីកាលណា ? ឬទ្រង់អាក្រាត ហើយបាន**បំពាក់ថ្វាយទ្រង់**ពីកាលណា ?

« ឬតើយើងខ្ញុំបានឃើញទ្រង់ឈឺ ឬជាប់គុក ហើយ**បានមកឯទ្រង់**ពីកាលណា ?

« នោះស្តេចនឹងឆ្លើយទៅគេថា យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា ដែលអ្នករាល់គ្នាធ្វើការទាំងនោះ ដល់អ្នកតូចបំផុតក្នុងពួកបងប្អូនយើងនេះ នោះឈ្មោះថាបានធ្វើដល់យើងដែរ » (ម៉ាថាយ 25:37–40) ។

នៅក្នុងព្រះបន្ទូលទាំងនោះ ព្រះអម្ចាស់បានបញ្ជាក់យ៉ាងច្បាស់ពីអំណោយទាំងឡាយ ដែលយើងអាចថ្វាយដល់ទ្រង់ ដែលចេញពីការដឹងគុណរបស់យើង ។ រាល់**ការធ្វើល្អ**គ្រប់យ៉ាងដល់មនុស្សគ្រប់គ្នាក្លាយជាការធ្វើល្អចំពោះទ្រង់ ពីព្រោះទ្រង់ស្រឡាញ់កូនចៅទាំងអស់របស់ព្រះវរបិតាសួគ៌ ។ ដោយសារទង្វើទាំងនោះបាននាំមកនូវ សេចក្តីអំណរ ដល់ទ្រង់នោះវាក៏នាំសេចក្តីអំណរដល់ព្រះវរបិតាទ្រង់ផងដែរ ដោយទ្រង់មានគុណបំណាច់ដ៏លើសលុបចំពោះយើង ។

នៅក្នុងរដូវកាលបុណ្យគ្រីស្ទម៉ាស់ នោះអ្នកទាំងអស់គ្នាភាគច្រើននឹងស្វែងរករបៀបទាំងឡាយ ដើម្បីផ្តល់អាហារដល់មនុស្សដែលស្រេកឃ្លាន ។ នៅពេលដែលអ្នកធ្វើបែបនេះ នោះអ្នកនាំសេចក្តីអំណរដល់ព្រះអម្ចាស់ហើយ ។ ប៉ុន្តែទ្រង់បានបង្រៀនយើងថា មានរបៀបជាមួយដើម្បីថ្វាយដែលជា**អំណោយដ៏មានតម្លៃ និង អស់កល្បជានិច្ច** ។ ទ្រង់មានព្រះបន្ទូលថា « ខ្ញុំជានំប៉័ងជីវិត ៖ អ្នកណាដែលមកឯខ្ញុំ នោះនឹងមិនឃ្លានទៀតឡើយ ហើយអ្នកណាដែលជឿដល់ខ្ញុំ ក៏មិនត្រូវស្រេកដែរ » (យ៉ូហាន 6:35) ។ ក្នុងចំណោមសេចក្តីសប្បុរសទាំងអស់ សេចក្តីសប្បុរសមួយដ៏ធំបំផុតដើម្បីថ្វាយដល់ទ្រង់នោះគឺ**ការបង្ហាញផ្លូវដល់អស់អ្នកដែលយើងស្រឡាញ់ ហើយបម្រើឱ្យទៅរកទ្រង់**ដែលជាប្រភពតែមួយគត់នៃជីវិតដ៏នៅអស់កល្បជានិច្ច ។ ■



រូបថតដោយ ក្រិស្ទីណា ស្មិត

# ឱ ចូរយើងមកក្រាបថ្វាយទ្រង់

« យើងរីករាយនឹងការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ ជាពន្លឺនៃពិភពលោក ដែលបានអញ្ជើញយើងទាំងអស់គ្នាមករកទ្រង់ និង មករកពន្លឺរបស់ទ្រង់ » ។

អែលឌើរ ផាទ្រិក ខែរ៉ុន នៃពួកចិតសិបនាក់ « ឱ ចូរយើងមកក្រាបថ្វាយទ្រង់ » លីអាហូណា ខែធ្នូ ឆ្នាំ 2011 ទំព័រ 42 *Ensign* ខែធ្នូ ឆ្នាំ 2011 ទំព័រ 30 ។



*ស៊ីម៉ូនកំពុងថ្វាយការគោរពដ៏ជ្រាលជ្រៅចំពោះព្រះគ្រីស្ទជាទារក* ដោយ ហ្គ្រេក អុលសិន © 1987 ហាមថតចម្លង

# តើអ្វីទៅជាការ ដើរលេងជាគូ ?



**ដោយ លែរី អិម. គីបសុន**
ទីប្រឹក្សាទីមួយនៅក្នុង
គណៈប្រធានយុវជនទូទៅ

*ការចំណាយពេលជួបទល់មុខគ្នាជាមួយមនុស្សដទៃគឺសំខាន់ ដើម្បីកសាងមិត្តភាពដ៏ពិត ។*

នៅពេលដែលខ្ញុំមានឯកសិទ្ធដើម្បីជជែកជាមួយ យុវជន និង យុវនារីទាំងឡាយទូទាំងសាសនាចក្រ ជាញឹកញាប់ ខ្ញុំឮថា ខណៈដែលអ្នកទាំងអស់គ្នាជាច្រើនទាក់ចាប់អារម្មណ៍ដើម្បីកសាងមិត្តភាពឱ្យបានប្រសើរជាងជាមួយមនុស្សភេទផ្ទុយគ្នា ជាញឹកញាប់ អ្នកពិបាកដោយមិនដឹងពិតប្រាកដពីរបៀបដើម្បីធ្វើវា ។

វាហាក់បីដូចជាថា ដោយសារប្រព័ន្ធផ្សព្វផ្សាយសង្គមទាំងអស់នោះយើងនឹងទាក់ទងគ្នាបានប្រសើរជាងមុនយ៉ាងស្រួល ។ ទោះជាណាយ៉ាងក៏ដោយ តាមរបៀបជាច្រើន នោះបច្ចេកវិទ្យាអាចធ្វើឱ្យយើងមានទំនាក់ទំនងដែលមានអត្ថន័យតិចតួចផងដែរ ។ តាមរយៈទំនាក់ទំនងតាមអ៊ីនធើណេត ការផ្ញើសារតាមទូរស័ព្ទ អ៊ីម៉ែល និង ការបង្កើតមិត្តតាមបណ្ដាញសង្គម មិនអាចបង្កើតនូវការការពារដល់ទំនាក់ទំនងនោះឱ្យបានគង់វង្សរហូតនោះទេ ។ ការចំណាយពេលជួបមុខទល់គ្នាជាមួយមនុស្សដទៃគឺសំខាន់ដើម្បីកសាងមិត្តភាពដ៏ពិត ។

យុវវ័យដ៏អស្ចារ្យរបស់យើងអើយ វាគឺជាពេលសម្រាប់អ្នកដើម្បីពាំនាំមកវិញនូវការតាក់តែងពីបុរាណសម្រាប់វេលាដែលយុវជន និង យុវនារីត្រូវជួបគ្នាសម្រាប់បទពិសោធន៍ខាងសង្គម ។ អ្នកប្រហែលធ្លាប់ឮពាក្យនោះ និង បទពិសោធន៍នេះដែលត្រូវបានគេហៅថាការដើរលេងជាគូរួចហើយ ។

## ចម្លើយចំពោះសំណួរទាំងឡាយដែលចោទសួរជាញឹកញាប់

អ្នកទាំងអស់គ្នាជាច្រើនមានសំណួរទាក់ទងនឹងការដើរលេងជាគូ និង ការប្រឹក្សាដែលមាននៅក្នុងកូនសៀវភៅថ្មី *ដើម្បីកម្លាំងនៃយុវជន* ។ ទាំងនេះគឺជាសំណួរដែលគេសួរខ្ញុំ ព្រមទាំងមានចម្លើយមកពីសៀវភៅណែនាំដ៏អស្ចារ្យនេះ ។

**ខ្ញុំមិនដឹងថា ខ្ញុំបានត្រៀមខ្លួនរួចជាស្រេចដើម្បីដើរលេងជាគូរនោះឡើយ ។ តើមានហេតុផលពិសេសអ្វីខ្លះ ដែលខ្ញុំគួរតែដើរលេងជាគូដែរឬទេ ?**

ការដើរលេងជាគូទាក់ទងនឹងហេតុផលមួយចំនួន ។ *ដើម្បីកម្លាំងនៃយុវជន* ពន្យល់ថា ការដើរលេងជាគូ « អនុញ្ញាតឱ្យយុវជនម្នាក់ និង យុវនារីម្នាក់ស្គាល់គ្នាកាន់តែច្បាស់ឡើង ។ នៅក្នុងវប្បធម៌ដែលការដើរលេងជាគូរាប់ទុកថាសមហេតុផល វាអាចជួយអ្នកឱ្យរៀន និង អនុវត្តនូវជំនាញខាងសង្គម អភិវឌ្ឍមិត្តភាពមានភាពសប្បាយរីករាយ និង រហូតរកឃើញដៃគូដ៏អស់កល្បជានិច្ចម្នាក់ » ។[1]

**យើងដឹងថាយើងមិនគួរដើរលេងជាគូមុនពេលយើងមានអាយុ16 ឆ្នាំឡើយ និង កុំដើរលេងជាគូជាមួយនរណាម្នាក់ជាពិតប្រាកដឱ្យសោះក្នុងពេលដែលអ្នកនៅក្មេងនៅឡើយ ។ ហេតុអ្វី ?**

*ដើម្បីកម្លាំងនៃយុវជន* និយាយថា ៖ « ចូរកុំដើរលេងជាគូរហូតទាល់តែអ្នកមានអាយុ 16ឆ្នាំសិន ។ នៅពេលដែលអ្នកចាប់ផ្ដើមដើរលេងជាគូ សូមទៅជាមួយនឹងគូផ្សេងទៀត ។ ចូរចៀសវាងពីការដើរលេងជាគូញឹកញាប់ជាមួយនឹងដៃគូដដែលៗ ។ ការអភិវឌ្ឍន៍ទំនាក់ទំនងស៊ីជម្រៅពីវ័យក្មេងពេក អាចកំណត់ចំនួនមនុស្សផ្សេងទៀតដែលអ្នកជួប និង ប្រហែលជាអាចនាំទៅរកភាពអសីលធម៌ » ។[2]

**យុវជនម្នាក់ចង់ឱ្យខ្ញុំដើរលេងជាគូជាមួយគាត់ ប៉ុន្តែខ្ញុំពិតជាមានអារម្មណ៍ថា គាត់មិនមានបទដ្ឋានដូចខ្ញុំនោះទេ ។ តើខ្ញុំគួរតែធ្វើយ៉ាងដូចម្ដេច ?**

*ដើម្បីកម្លាំងនៃយុវជន* បង្រៀនថា ៖ « សូមរើសយកការដើរលេងជាគូជាមួយអ្នកដែលមានបទដ្ឋានសីលធម៌ខ្ពស់ ហើយដែលជួយអ្នកឱ្យរក្សាបទដ្ឋានរបស់អ្នក ។ ... ចូរមាននូវការគោរព និង សុភាពរាបសារ នៅពេលដែលអ្នកស្នើសុំដើរលេងជាគូ ឬនៅពេលដែលអ្នកទទួលយក ឬបដិសេធនរណាម្នាក់ » ។[3]

រចនារូបថតដោយ សេវាកម្មបោះពុម្ព និងអាវីឌ ស្ទូឌី © IRI



**ពេលខ្លះខ្ញុំមិនអាចគិតឃើញអ្វីឡើយ ក្រោយពីមើលខ្សែភាពយន្តសម្រាប់ការដើរលេងជាគូ ។ តើខ្ញុំគួរតែធ្វើយ៉ាងដូចម្ដេច ?**

*ដើម្បីកម្លាំងនៃយុវជន*ផ្ដល់គោលការណ៍ដ៏មានប្រយោជន៍ទាំងនេះថា ៖ « សូមដាក់ផែនការសកម្មភាពដើរលេងជាគូដែលមានសុវត្ថិភាព វិជ្ជមាន និង មិនចំណាយច្រើន ហើយជួយអ្នកឱ្យបានស្គាល់គ្នា ។ ចូរទៅតែទីកន្លែងណាដែលអ្នកអាចរក្សាបទដ្ឋានរបស់អ្នកបាន និង នៅជាប់នឹងព្រះវិញ្ញាណ » ។[4]

ចំណុចសាមញ្ញទាំងបួននោះគឺ—ការដើរលេងជាគូដែលមានសុវត្ថិភាព វិជ្ជមាន មិនចំណាយច្រើន និង កន្លែងដែលព្រះវិញ្ញាណគង់នៅជិត—នោះនឹងទុកឱកាសសម្រាប់ការដើរលេងជាគូជាច្រើនទៀត ។

ខណៈដែលខ្ញុំគិតជាមួយភរិយារបស់ខ្ញុំអំពីបទពិសោធន៍នៃការដើរលេងជាគូលើកដំបូងរបស់ពួកយើង នៅពេលយើងទៅតែពីរនាក់ ឬទៅជាមួយដៃគូដទៃទៀត បទពិសោធន៍ដែលគួរ ឱ្យចងចាំជាងគេនោះ គឺជាពេលដែលយើងចំណាយអស់តិច ឬមិនចំណាយសោះ ហើយយើងនៅតែអាចមានការសន្ទនា និង ទំនាក់ទំនងដ៏មានន័យ ។

## ការពារគុណធម៌គ្នាទៅវិញទៅមក

ខ្ញុំសូមបញ្ចប់ជាមួយនឹងការដកស្រង់ដ៏សំខាន់មួយទៀតពី*ដើម្បីកម្លាំងនៃយុវជន* និង បន្ទាប់មកជាចំណុចចុងក្រោយបង្អស់ ។ ទីមួយ « ចូរចងចាំថាយុវជន និង យុវនារីម្នាក់ៗដែលដើរលេងជាគូត្រូវទទួលខុសត្រូវដើម្បីការពារកិត្តិយស និង គុណធម៌គ្នាទៅវិញទៅមក » ។[5] នៅពេលអ្នកដើរលេងជាគូ សូមប្រាកដថាអ្នកមិនធ្វើអ្វីដែលអ្នកនឹងមានការខ្មាស់អៀនឡើយ ។ ដូចប្រធាន ថូម៉ាស អេស. ម៉នសុន បានបង្រៀនថា « ការដើរលេងជាគូ សូមប្រព្រឹត្តនឹងដៃគូរបស់អ្នក ដោយការគោរព ហើយរំពឹងទុកថា ដៃគូរបស់អ្នកនឹងបង្ហាញពីការគោរពដូចគ្នាសម្រាប់អ្នកដែរ » ។[6]

## ភាពខុសគ្នារវាងការដើរលេងជាគូ និង ការចែចង់

ទីបំផុត ទោះបីជាមានអ្នកខ្លះបានឱ្យនិយមន័យ *ការដើរលេងជាគូ* ថាជា « ការចែចង់ » ក៏ដោយ ការដើរលេងជាគូនៅក្នុងសាសនាចក្រក្នុងចំណោមយុវវ័យ វាមិនបានបញ្ជាក់ថាពួកគេមាន « ស្នេហាជាប់លាប់ » ឬមិនអាចដើរលេងជាមួយអ្នកដទៃទៀតបាននោះទេ ។ តាមបទដ្ឋានសាសនាចក្រ បំណងនៃការដើរលេងជាគូគឺ ជាឱកាសមួយសម្រាប់ទំនាក់ទំនងសង្គមដែលអាចបង្កើតមិត្តភាពជាច្រើន ។

នៅពេលអ្នកចូលដល់វ័យមជ្ឈិមវ័យរបស់អ្នក—សម្រាប់យុវជនបន្ទាប់ពីបេសកកម្ម—នោះព្រះអម្ចាស់មានព្រះបន្ទូលថា « ប៉ុន្តែក្នុងព្រះអម្ចាស់ នោះបុរសមិនមែនជាឥតពឹងអាស្រ័យដល់ស្ត្រីឡើយ ហើយស្ត្រីក៏មិនមែនជាឥតពឹងអាស្រ័យដល់បុរសដែរ (កូរិនថូសទី 1 11:11) ។ នេះហើយជាពេលដែលការដើរលេងជាគូ ក្លាយជាការចែចង់ ដូចដែលបានសង្កត់ធ្ងន់នៅក្នុងកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ៖ « សូមធ្វើឱ្យការដើរលេងជាគូ និង អាពាហ៍ពិពាហ៍ជាអទិភាពដ៏ខ្ពស់មួយ ។ ចូរស្វែងរកដៃគូមួយដែលមានភាពស័ក្តិសមដើម្បីទៅកាន់ព្រះវិហារបរិសុទ្ធ ដើម្បីផ្សាភ្ជាប់អ្នកសម្រាប់ពេលនេះ និង អស់កល្បអស់កាលជានិច្ច ។ ការរៀបអាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធ និង ការបង្កើតក្រុមគ្រួសារដ៏អស់កល្បមួយ គឺចាំបាច់នៅក្នុងផែនការនៃសុភមង្គលរបស់ព្រះ » ។[7] ■



## ចែកចាយរឿងរបស់អ្នក

តើអ្នកបាបទទួលបទពិសោធន៍ដោយការអនុវត្ត តាមការប្រឹក្សាមកពីការណែនាំទាំងនេះនៅក្នុង *ដើម្បីកម្លាំងនៃយុវជន*ដែរឬទេ ?

- ការបម្រើ
- ភាពបរិសុទ្ធខាងផ្លូវភេទ
- ដង្វាយមួយភាគក្នុងដប់ និង ដង្វាយផ្សេងៗ
- ការងារ និង ភាពខ្លួនទីពឹងខ្លួន

សូមអ៊ីម៉ែលពីបទពិសោធន៍របស់អ្នកទៅកាន់ liahona@ldschurch.org ដោយមានដាក់ "For the Strength of Youth" នៅក្នុងប្រអប់ subject ។ សូមដាក់ឈ្មោះពេញរបស់អ្នក ថ្ងៃខែឆ្នាំកំណើត វួដ និង ស្ដេក និង ការអនុញ្ញាតរបស់ឪពុកម្ដាយ (តាមអ៊ីម៉ែល) ដើម្បីបោះពុម្ពចម្លើយរបស់អ្នក ។

**កំណត់សំគាល់**

1. *ដើម្បីកម្លាំងនៃយុវជន* (ឆ្នាំ 2011) ទំព័រ 24 ។
2. *ដើម្បីកម្លាំងនៃយុវជន* ទំព័រ 24 ។
3. *ដើម្បីកម្លាំងនៃយុវជន* ទំព័រ 24–25 ។
4. *ដើម្បីកម្លាំងនៃយុវជន*ទំព័រ 24 ។
5. *ដើម្បីកម្លាំងនៃយុវជន* ទំព័រ 24 ។
6. ថូម៉ាស អេស ម៉នសុន "Standards of Strength," *New Era,* ខែ តុលា ឆ្នាំ 2008 ទំព័រ 5 ។
7. *ដើម្បីកម្លាំងនៃយុវជន* ទំព័រ 25 ។



# ដោយសារតែ ក្រុមគ្រួសារ

**ដោយ ហ៊ីការី ឡូហ្វទូស**
ទស្សនាវដ្ដីរបស់សាសនាចក្រ

គ្មានក្រុមគ្រួសារពីរណាដែលដូចគ្នានោះទេ ប៉ុន្ដែព្រះបានតែងតាំងគ្រួសារជា « អង្គភាពសង្គមមួយដ៏សំខាន់បំផុតនៅក្នុងពេលនេះ និង អស់កល្បអស់កាលជានិច្ច » ។[1] មិនថាអ្នករស់នៅទីណា ឬគ្រួសារអ្នកមានគុណសម្បត្តិបែបណានោះទេ ដំណឹងល្អអាចជួយអ្នកឱ្យអភិវឌ្ឍទំនាក់ទំនងកាន់តែរឹងមាំជាងមុន និង ពង្រឹងខាងវិញ្ញាណដែលវានាំមកនូវសុភមង្គលកាន់តែច្រើនមកក្នុងគ្រួសាររបស់អ្នក ។ សូមអានពីយុវវ័យទាំងនេះដែលមកពីជុំវិញពិភពលោកដែលបាននិយាយអំពីហេតុផលដែលថាក្រុមគ្រួសារសំខាន់ចំពោះពួកគេ ។

*តើអ្នកធ្លាប់បានគិតអំពីអ្វីៗទាំងអស់ដែលអ្នកត្រូវបានប្រទានពរដោយបានធ្វើជាផ្នែកមួយនៃគ្រួសារដែរឬទេ ?*





**គ្រួសារគឺអស់កល្បអស់កាលជានិច្ច**

អ៊ីរីន មកពី រដ្ឋ ខារ៉ូលីណា ខាងជើង ស.រ.អ និង គ្រួសាររបស់នាង (ខាងឆ្វេង) តែងតែមាននូវគោលបំណងមួយនៅក្នុងចិត្តថា ៖ ក្លាយជាគ្រួសារដ៏នៅអស់កល្បអស់កាលជានិច្ចមួយ ។ ទោះជាបីជា ឪពុករបស់អ៊ីរីនមិនមែនជាសមាជិកនៃសាសនាចក្រក៏ដោយ ។

« ពិតណាស់ថាម៉ាក់ និង បងប្អូនបង្កើតទាំងឡាយរបស់ខ្ញុំចង់ឱ្យប៉ាទទួលចំណែកនៃពរជ័យទាំងឡាយនៃដំណឹងល្អ ។ ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទធ្វើឱ្យយើងរីករាយ ហើយយើងចង់ឱ្យប៉ាទទួលចំណែកនៃសុភមង្គលនោះ ។ អ៊ីរីន និយាយថា « យើងក៏ចង់ផ្សារភ្ជាប់ជាគ្រួសារមួយយ៉ាងខ្លាំងផងដែរ » ។

ដោយបានប្ដេជ្ញាចិត្តដើម្បីប្រែក្លាយជាគ្រួសារដ៏នៅអស់កល្បជានិច្ចមួយ នោះអ៊ីរីន និង បងប្អូនបង្កើតទាំងឡាយ និង ម្ដាយរបស់នាងបានធ្វើយ៉ាងអស់ពីសមត្ថភាពដើម្បីរក្សាបទបញ្ញត្តិ ហើយអភិវឌ្ឍសេចក្ដីជំនឿកាន់តែរឹងមាំ ហើយពួកគេបានអធិស្ឋានទាំងអស់គ្នាដើម្បីឱ្យដួងចិត្តរបស់ឪពុករបស់ពួកគេចាប់ចិត្តនឹងដំណឹងល្អ ។

ទោះបីជាវាត្រូវការរយៈពេលច្រើនឆ្នាំក៏ដោយ នៅទីបំផុតឪពុកអ៊ីរីនបានជ្រមុជទឹក និង បានបញ្ជាក់ ។ ដប់ថ្ងៃ



បន្ទាប់ពីបុណ្យជ្រមុជទឹករបស់គាត់ គាត់អាចធ្វើបុណ្យជ្រមុជទឹកឱ្យប្អូនប្រុសស្រីរបស់អឺរីន ។ មិនជាយូរប៉ុន្មានទេ គ្រួសាររបស់ពួកគេនឹងសម្រេចគោលដៅ ដើម្បីផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ។

## គ្រួសារនាំមកនូវកម្លាំង និង ការគាំទ្រ

ចាប់តាំងពីឪពុករបស់ពួកគេបានទទួលមរណភាពទៅ អេលីស្សាបែត និង ប្អូនប្រុសរបស់នាងឈ្មោះ អ៊ុណា មកពី ខេមម៉េរ៉ូន ប្រទេសអាហ្វ្រិក ត្រូវពឹងលើម្តាយរបស់ពួកគេ ។ អេលីស្សាបែត និយាយថា « គាត់ជាប្រភពជំនួយដល់ពួកយើងចាប់តាំងពីឪពុករបស់យើងស្លាប់ទៅ ។ ព្រះបានប្រទានពរ និង ការពារយើងក្នុងកិច្ចការគ្រប់ជំពូកដែលយើងធ្វើ » ។

គ្រួសាររបស់អេលីស្សាបែត (ខាងលើ) ជួបជុំគ្នាបន្ទាប់ពីឪពុកនាងបានស្លាប់ ។ បន្ទាប់មក ពួកគេបានចូលសាសនាចក្រនៅក្នុងឆ្នាំ 2010 អេលីស្សាបែត និង អ៊ុណាបានរៀនអំពីសារៈសំខាន់នៃគ្រួសារដ៏នៅអស់កល្បជានិច្ច ។

អេលីស្សាបែតនិយាយថា « អ្វីមួយដែលសំខាន់បំផុតនោះគឺយើងបានដឹង [មកពីដំណឹងល្អ] អំពីសារៈសំខាន់នៃគ្រួសារ » ។ « គ្រួសារមានសារៈសំខាន់យ៉ាងអស្ចារ្យសម្រាប់ខ្ញុំ ពីព្រោះតាមរយៈគ្រួសាររបស់ខ្ញុំ នោះខ្ញុំអាចប្រែក្លាយទៅជាមនុស្សម្នាក់ដូចសព្វថ្ងៃនេះ » ។

## គ្រួសារនាំមកនូវការរីកចម្រើន និង សេចក្តីសុខសាន្ត

អាឌីណា មកពីស្វីសស្សឺលែន បានរៀនពីរបៀបដែលសមាជិកគ្រួសារអាចជួយគ្នាទៅវិញទៅមក ដើម្បីអភិវឌ្ឍទេពកោសល្យ នៅពេលដែលពួកគេរីករាយនឹងសកម្មភាពលេងកំសាន្តជាមួយគ្នា ។[2] គ្រួសាររបស់នាងដាក់ផែនការប្រចាំខែ ដើម្បីដើរកម្សាន្តទៅកន្លែងដែលពួកគេអាចរៀនពីចំណង់ចំណូលចិត្តទៅវិញទៅមក ។ នាងនិយាយថា « យើងមានឱកាសដើម្បីផ្តល់ឱ្យបងប្អូនរបស់យើងនូវការយល់ដឹងយ៉ាងជ្រាលជ្រៅ និង សេចក្តីស្រឡាញ់នៅក្នុងជីវិតរបស់ពួកយើង » ។ មានពេលមួយនោះ ឪពុករបស់នាងបានបង្រៀនគ្រួសារអំពីរបៀបដើម្បីបង្ហាត់សត្វឆ្កែ (ខាងក្រោម) ។ អាឌីណាចាំថា « វាអស្ចារ្យណាស់ដើម្បីឃើញពីភាពសប្បាយរីករាយរបស់គាត់ និង ពីក្តីរីករាយដែលគាត់មានដើម្បីចែកចាយពីសារៈសំខាន់មួយនៃជីវិតរបស់គាត់ និង ចំណង់ចំណូលចិត្តរបស់គាត់ជាមួយយើង » ។

តាមរយៈសកម្មភាពរបស់គ្រួសារទាំងនេះ នោះអាឌីណាបានអភិវឌ្ឍជំនាញជាច្រើន ។ នាងបានកត់សម្គាល់ពីភាពសុខសាន្តកាន់តែច្រើននៅក្នុងជីវិតរបស់នាងផងដែរ ៖ « ក្រុមគ្រួសារជាកន្លែងមួយដែលខ្ញុំអាចសម្រាកពីភាពតឹងតែងនៃជីវិតប្រចាំ និង ដកដង្ហើមយ៉ាងសុខសាន្ត ព្រមទាំងទទួលបានកម្លាំង និង ដឹងថាខ្ញុំមិនឈរម្នាក់ឯងទេនៅក្នុងជីវិតនេះ ។ ខ្ញុំមានអំណរគុណសម្រាប់អ្វីៗទាំងនេះ ពីព្រោះពិភពលោកសព្វថ្ងៃនេះមានសន្ទុះ និង មមាញឹកណាស់ ។ ខ្ញុំរីករាយដែលខ្ញុំមានកន្លែងដើម្បីទទួលកម្លាំង និង សម្រាក » ។



### ភក្តីភាពនៃក្រុមគ្រួសារ

« បុព្វហេតុដែលសំខាន់បំផុត*នៃជីវិតរបស់យើង*គឺគ្រួសាររបស់យើង ។ បើយើងនឹងលះបង់ខ្លួនយើងដើម្បីបុព្វហេតុនេះ នោះយើងនឹងកែរលម្អរាល់ទិដ្ឋភាពដទៃទៀតទាំងអស់ក្នុងជីវិតរស់នៅយើង ហើយនឹងប្រែក្លាយជាគំរូ និង ជាពន្លឺ ដឹកនាំមួយចំពោះមនុស្សទាំងអស់ក្នុងផែនដីនេះ ក្នុងនាមជាប្រជាជនម្នាក់ និង ជាសាសនាចក្រមួយ ។

**អែលឌើរ អិម រ័សុល បាឡឺដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « អ្នកដែលបាត់នឹងត្រូវរកឃើញវិញ »** ***លីអាហូណា*** **ខែ ឧសភា ឆ្នាំ 2012 ទំព័រ 94 ។**

ទោះបីជាហេតុផលរបស់ពួកគេផ្សេងៗពីគ្នាក៏ដោយ យុវវ័យទាំងនេះបានដឹងថា ពួកគេអាចទីពឹងលើក្រុមគ្រួសាររបស់ពួកគេសម្រាប់ការគាំទ្រ សេចក្តីសុខសាន្ត និង សេចក្តីស្រឡាញ់ ។ ■

**កំណត់ចំណាំ**

1. *សៀវភៅណែនាំគ្រួសារ* (កូនសៀវភៅ ឆ្នាំ 2001) ទំព័រ 1 ។
2. សូមមើល « គ្រួសារ៖ ការប្រកាសដល់ពិភពលោក » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2010 ទំព័រ 129 ។

រូបថតផ្តល់ដោយគ្រួសារ







# អំណោយ ដែល អ្នកពុំអាច វេចខ្ចប់បាន



ដោយ អេលីស អាឡិចសាន់ដ្រា ហូមស៍

នៅក្នុងរដូវកាលគ្រីស្ទម៉ាស់ ជាញឹកញាប់យើងផ្ដោតលើការផ្ដល់អំណោយទាំងឡាយដល់អ្នកដែលយើងស្រឡាញ់ ។ ប៉ុន្តែសូមចងចាំថា មានអំណោយអស្ចារ្យមួយចំនួនដែលអ្នកមិនអាចវេចខ្ចប់បានឡើយ ។ ទាំងនេះគឺជាអំណោយមួយចំនួនដែលមិនអាចបំភ្លេចបានដែលអ្នកអាចជូនឪពុកម្ដាយរបស់អ្នក ។



## ការបម្រើ

អំណោយមួយក្នុងចំណោមអំណោយអស្ចារ្យទាំងនោះដែលអ្នកអាចជូននោះ គឺជាការបម្រើ ។ ឪពុកម្ដាយរបស់អ្នកនឹងពេញចិត្តវា ។

- សំអាតផ្ទះ ។
- ជួយមើលថែទាំប្អូន ។
- រៀបចំ និង សំអាតតុអាហារ ។
- ចំអិនអាហារសម្រាប់គ្រួសាររបស់អ្នក ។
- លាងចាន ឬបោសឥដ្ឋ ។
- ជួយបងប្អូនធ្វើកិច្ចការសាលា ។
- អាស្រ័យទៅលើកន្លែងដែលអ្នករស់នៅ ជួយចូកព្រិលចេញពីផ្លូវដើរ ឬដកស្មៅក្នុងសួនច្បារ ។

រចនារូបថតដោយ សេវាកម្មបោះពុម្ព និង រ៉ូប៊ើត ខេស៊ី © IRI







### ពេលវេលាសម្រាប់គ្រួសារ

ទោះបីជាអ្នកមានកាលវិភាគរវល់យ៉ាងណាក៏ដោយ សូមលៃពេលវេលាសម្រាប់គ្រួសាររបស់អ្នក ។ វត្តមានរបស់អ្នកនឹងជួយគាំទ្រដល់ឪពុកម្ដាយរបស់អ្នក ហើយពួកគាត់នឹងអរគុណអ្នកសម្រាប់កិច្ចខិតខំរបស់អ្នក ។

- ចូលរួមក្នុងរាត្រីជួបជុំក្រុមគ្រួសារ (ដោយពុំចាំបាច់ឱ្យគេ រំឭកប្រាប់នោះឡើយ) ។
- លេងជាមួយបងប្អូនរបស់អ្នក ។
- មកទទួលទានអាហារពេលល្ងាចឱ្យទាន់ពេល ។
- និយាយ និង ស្ដាប់សមាជិកទាំងឡាយនៃគ្រួសារ ។
- ចូលរួមនៅក្នុងការអធិស្ឋាន និងការអានព្រះគម្ពីរជាគ្រួសារ ។
- សូមចំណាយពេលវេលាជាមួយគ្រួសាររបស់អ្នក ជាជាងមិត្តភក្ដិរបស់អ្នក ឬអញ្ជើញមិត្តភក្ដិទាំងឡាយរបស់អ្នកមកចូលរួមសកម្មភាព របស់គ្រួសារ (ដោយមានការអនុញ្ញាតពីឪពុកម្ដាយរបស់អ្នក) ។







### ការតាំងចិត្ត

សូមឱ្យឪពុកម្ដាយរបស់អ្នកដឹងថាអ្នកកំពុងតាំងចិត្តដើម្បីធ្វើអ្វីមួយដែលសំខាន់ ។ របៀបដ៏ល្អបំផុតដើម្បីបង្ហាញការតាំងចិត្តរបស់អ្នក គឺការចាប់ផ្ដើមពីពេលឥឡូវនេះ ហើយបន្តធ្វើវា ។

- រៀបចំដើម្បីបម្រើបេសកកម្ម (សម្រាប់ពួកយុវជន) ។ បើអាចធ្វើទៅបាន សូមចាប់ផ្ដើមពីពេលឥឡូវនេះដោយសន្សំថវិកាបេសកកម្ម ។
- សូមសិក្សាព្រះគម្ពីរជាប្រចាំថ្ងៃ ។
- សូមសន្សំ ប្រាក់ចំណូលរបស់អ្នក ។
- ទៅរៀនដោយពុំរអ៊ូរទាំ ហើយធ្វើកិច្ចការសាលារបស់អ្នកឱ្យបានទាន់ពេល ។
- ចូលរៀនថ្នាក់សិក្ខាសាលា ។ បើសិនអ្នកចូលរៀនថ្នាក់សិក្ខាសាលានៅពេលព្រឹក សូមក្រោកពីគេងដោយខ្លួនឯង ។
- រៀបចំសម្រាប់អាពាហ៍ពិពាហ៍ព្រះវិហារបរិសុទ្ធ ។ សូមធ្វើបញ្ជីមួយអំពីគុណសម្បត្តិសំខាន់ៗទាំងឡាយ ដើម្បីស្វែងរកស្វាមីឬភរិយាម្នាក់នាពេលអនាគត បន្ទាប់មកអភិវឌ្ឍគុណសម្បត្តិទាំងនោះចេញពីខ្លួនអ្នក ។



### ឥរិយាបថ

ឪពុកម្ដាយរបស់អ្នកនឹងអរគុណចំពោះឥរិយាបថល្អរបស់អ្នកដែលអ្នកធ្វើចំពោះពួកគាត់ និង សមាជិកគ្រួសារដ៏ទៃទៀត ។

- សូមមានឥរិយាបទវិជ្ជមាន ។
- ចូរកុំចាប់កំហុសឪពុកម្ដាយ ឬបងប្អូនរបស់អ្នកឡើយ ។
- បង្កើតទម្លាប់មួយដើម្បីនិយាយថាអរគុណ សូម្បីតែចំពោះរឿងតូចតាចក៏ដោយ ។
- សូមសរសេរសំបុត្រថ្លែងអំណរគុណដល់ឪពុកម្ដាយរបស់អ្នកសម្រាប់អ្វីៗទាំងអស់ដែលពួកគាត់បានធ្វើសម្រាប់អ្នក ។
- សូមដោះស្រាយជម្លោះទាំងឡាយជាមួយឪពុកម្ដាយ ឬបងប្អូនរបស់អ្នកដោយគ្មានកំហឹង ឬជម្លោះ ។
- សូមរាប់ពរជ័យទាំងឡាយរបស់អ្នក—ដោយត្រង់ៗ ។ សូមធ្វើបញ្ជីមួយអំពីអ្វីៗដែលអ្នកធ្លាប់បានធ្វើ ដោយសារមានការគាំទ្រពីឪពុកម្ដាយរបស់អ្នក ហើយសូមចែកចាយបញ្ជីនោះជាមួយពួកគាត់ ។ ■

# កូរិនថូស ទី 1 15:20–22

*នៅក្នុងខគម្ពីរទាំងនេះ សាវកប៉ុលបានប្រកាសថា ការរស់ឡើងវិញរបស់ព្រះគ្រីស្ទមានន័យថាមនុស្សគ្រប់គ្នានឹងរស់ឡើងវិញម្ដងទៀត ។*



**២០ តែឥឡូវនេះ ព្រះគ្រីស្ទទ្រង់មានព្រះជន្មរស់ពីស្លាប់**
**ឡើងវិញជាពិត ជាផលដំបូងពីពួកអ្នកដែលបានដេកលក់**
**ទៅហើយ ២១ ដ្បិតដែលសេចក្ដីស្លាប់បានមកដោយសារ**
**មនុស្ស នោះសេចក្ដីដែលមនុស្សស្លាប់បានរស់ឡើងវិញ**
**ក៏មកដោយសារមនុស្សដែរ ២២ ព្រោះ ដូចជាគ្រប់មនុស្ស**
**ទាំងអស់បានត្រូវស្លាប់ ក្នុងលោកអ័ដាមជាយ៉ាងណា នោះ**
**គ្រប់គ្នាក៏នឹងបានប្រោសឲ្យរស់ ក្នុងព្រះគ្រីស្ទយ៉ាងនោះដែរ**



### ឥឡូវនេះ តើព្រះគ្រីស្ទមានព្រះជន្មរស់ពីស្លាប់ហើយឬ

« គ្មានពាក្យសំដីណានៅក្នុងអណាចក្ររបស់សាសនាគ្រីស្ទដែលមានអត្ថន័យ ចំពោះខ្ញុំជាងពាក្យទាំងឡាយដែលបាននិយាយដោយទេវតាទៅកាន់ម៉ារា អ្នកស្រុកម៉ាក់ដាឡា និង ម៉ារា នៅពេលដែលពួកគេ ទៅជិតដល់ផ្នូរ ដើម្បីមើលថែ ព្រះកាយរបស់ព្រះអម្ចាស់របស់ពួកគេថា ៖ « ហេតុអ្វីបានជាមករកព្រះអង្គដែលមានព្រះជន្មរស់នៅក្នុងទីខ្មោចស្លាប់ដូច្នេះ ? ទ្រង់មានព្រះជន្មរស់ឡើងវិញ ហើយមិនគង់នៅទីនេះទេ » (លូកា 24:5–6) ។

« ព្រមជាមួយនឹងពាក្យប្រកាសនេះ អ្នកទាំងឡាយណាដែលបានរស់នៅ និង មរណជនទាំងឡាយ ព្រមទាំង ជនឡាយណាដែលឥឡូវនេះកំពុងរស់នៅ និង នៅថ្ងៃណាមួយនឹងត្រូវស្លាប់ និង អ្នកទាំងឡាយណាដែលនឹងត្រូវចាប់កំណើត និង ត្រូវស្លាប់ដែលទើបតែត្រូវបានសង្គ្រោះ ។

« ដោយសារតែជ័យជំនះរបស់ព្រះគ្រីស្ទលើសេចក្ដីស្លាប់ នោះយើងនឹងត្រូវបានរស់ឡើងវិញ ។ នេះគឺជាការប្រោសលោះដល់ព្រលឹង ។

ប្រធាន ថូម៉ាស អេស. ម៉នសុន “He Is Not Here but Is Risen,” *លីអាហូណា* ខែ មេសា ឆ្នាំ 2011 ទំព័រ 4 ។



### នោះគ្រប់គ្នាក៏នឹងបានប្រោសឱ្យរស់ក្នុងព្រះគ្រីស្ទ

« ខ្ញុំឆ្ងើងឆ្ងល់ថា តើយើងពេញដោយអំណរគុណដ៏មហិមាចំពោះសេចក្ដីជំនឿដ៏ស្មោះត្រង់របស់យើងចំពោះការរស់ឡើងវិញជាសាកលនេះដោយរបៀបណា ។ ការធានាអះអាងនៃជីវិតអមតភាពគឺជាគ្រឹះ ចំពោះសេចក្ដីជំនឿរបស់យើង ។ …

« នៅក្នុងដំណើរដ៏នៅអស់កល្បជានិច្ចរបស់យើង ការរស់ឡើងវិញគឺជាគំនូសសញ្ញាដ៏ធំក្រៃលែងដែលបង្ហាញពីចុងបញ្ចប់នៃភាពរមែងស្លាប់ ហើយជាការចាប់ផ្ដើមនៃជីវិតអមត ។ …យើងក៏ដឹងផងដែរពីវិវរណៈសម័យទំនើប ថាបើគ្មានការរួមគ្នានៃវិញ្ញាណ និង រូបកាយរបស់យើងនៅក្នុងការរស់ឡើងវិញទេនោះ យើងមិនអាចទទួលបាន ‹ នូវភាពពោរពេញនៃសេចក្ដីអំណរឡើយ › (គ .ស. 93:33–34) ។

អែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « ការរស់ឡើងវិញ » *លីអាហូណា* ខែ កក្កដា ឆ្នាំ 2000 ទំព័រ 17–18 ។

### ផលដំបូងពីពួកអ្នកដែលបានដេកលក់ទៅហើយ

*ផលដំបូង*—ផ្លែឈើ បន្លែ និង គ្រាប់ធញ្ញជាតិដែលបានទុំមុនរដូវច្រូតកាត់ ។

តាមច្បាប់របស់ម៉ូសេ ផលដំបូងដែលត្រូវថ្វាយជាដង្វាយបរិសុទ្ធដល់ព្រះអម្ចាស់ដើម្បីបង្ហាញអំណរគុណ និង ភក្ដីភាព ។ ដោយសារផលដំបូងជាសញ្ញាថា រដូវច្រូតកាត់ត្រូវបានចាប់ផ្ដើម ហើយមានគ្រាប់ដំណាំជាច្រើនទៀតពុំទាន់ដុះនៅឡើយ នោះសាវកប៉ុលបាននិយាយថា ព្រះយេស៊ូវគ្រីស្ទគឺជាអ្នកទីមួយក្នុងមនុស្សដែលស្លាប់ (អ្នកដែលបានដេកលក់ទៅហើយ) ដើម្បីរស់ឡើងវិញម្ដងទៀត ហើយមានមនុស្សជាច្រើនទៀតនៅពុំទាន់រស់ឡើងវិញនៅឡើយ ។

### ដូចជាគ្រប់មនុស្សទាំងអស់បានត្រូវស្លាប់ក្នុងលោកអ័ដាមយ៉ាងណា

ព្រោះអ័ដាម និង អេវ៉ាបានធ្លាក់ នោះមនុស្សទាំងអស់ត្រូវតែស៊ូទ្រាំនឹងសេចក្ដីស្លាប់ខាងសាច់ឈាម (សូមមើល នីហ្វៃទី 2 9:6; ម៉ូសេ 6:48) ។

*កំណត់ចំណាំរបស់អ្នកបោះពុម្ពផ្សាយ ៖ នៅទំព័រ នេះពុំមែនមានន័យថា វាពន្យល់ដ៏ទូលំទូលាយពីខគម្ពីរដែលបានជ្រើសរើសនោះទេ វាគ្រាន់តែជាចំណុចចាប់ផ្ដើមមួយសម្រាប់ការសិក្សាផ្ទាល់ខ្លួនរបស់អ្នកប៉ុណ្ណោះ ។*

*រូបគំនូរដោយ ស៊ីម៉ុន ឌី*




# ផ្ដល់អាហារដល់អស់អ្នកដែល ស្រេកឃ្លាន

*តាមរយៈមធ្យោបាយតូចតាច យើងអាចបំពេញនូវសេចក្ដីត្រូវការធំៗបាន—ទាំង ខាងសាច់ឈាម និង វិញ្ញាណ។*

**ដោយ ដាល្ល៊ីន ស៊ី រីលខក**

ក្នុងខែ ធ្នូ ឆ្នាំ 2004 ខ្ញុំកំពុងបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង នៅក្នុង លីនស៍ សោ ប៉ូឡូ ប្រេស៊ីល ។ វួដ និងសាខាក្នុងមូលដ្ឋានបានសម្រេចចិត្តដើម្បីចូលរួមកម្មវិធី “Natal sem Fome” (បុណ្យគ្រីស្ដម៉ាស់លុបបំបាត់ភាពអត់ឃ្លាន) ប្រចាំឆ្នាំរបស់ប្រទេសប្រេស៊ីល ។ ដោយបង្កើតជាក្រុមអង្គភាពជាច្រើន—រួមទាំងក្រុមយោធា មកពីកងកម្លាំងប្រេស៊ីល អ្នករត់សំបុត្រ និង ក្រុមសាសនាដទៃមួយចំនួនទៀត—យើងបានប្រមូលអាហារជាច្រើនពីអ្នកជិតខាងហើយក្រោយមកបានផ្ដល់ឱ្យអ្នកក្រីក្រនៅទីក្រុងនោះ ។ យើងក៏បានប្រើប្រាស់ឱកាសដ៏អស្ចារ្យនេះ ដើម្បីចែកជូនប័ណ្ណចែកចាយផងដែរ ឬ យើងហៅឈ្មោះប័ណ្ណនោះថាជា « ប័ណ្ណមិត្តភាព » ។ មានប័ណ្ណប្រហែល 2000 ត្រូវបានចែក ។

មានសមាជិកជាច្រើនបាននិយាយពីអារម្មណ៍ដ៏អស្ចារ្យ ដែលពួកគេបានទទួលនៅពេលដែលពួកគេបានបម្រើ ហើយចែកចាយពីអារម្មណ៍នៃបុណ្យគ្រីស្ដនៅក្រោមកំដៅព្រះអាទិត្យដ៏ក្ដៅនៃប្រទេសប្រេស៊ីល ។ វាជាទិដ្ឋភាពដ៏គួរឱ្យចាប់អារម្មណ៍មួយ ដោយឃើញទាហានទាំងឡាយចែកប័ណ្ណទាំងនោះ ដែលមកពីសាសនាចក្រដែលពួកគេមិនមែនជាសមាជិកផងនោះ ។

មួយសប្ដាហ៍ក្រោយមក យើងបានទទួលការស្នើរសុំ ឌីវីឌីបុណ្យគ្រីស្ដម៉ាស់*អំណរដល់លោក*ចំនួន 127 ដែលមានក្រុមចម្រៀងរោងឧបោសថមរមន ។ សប្ដាហ៍បន្ទាប់ទៀត យើងបានទទួលការស្នើរសុំចំនួន 22 បន្ថែមទៀត ។ ដៃគូរបស់ខ្ញុំ និង ខ្ញុំបានចាប់ផ្ដើមបង្រៀនមនុស្សទាំងនេះ ហើយអាចចូលទៅផ្ទះមនុស្សជាច្រើនដោយសារតែកិច្ចការមួយនេះ ។

ខ្ញុំនឹងមិនភ្លេចសេចក្ដីអំណរ និង សេចក្ដីស្រឡាញ់នៃកិច្ចការពិសេសនោះឡើយ នៅពេលដែលយើងបានជួយចែកចាយដំណឹងល្អ និង នាំមកនូវការជួយសង្គ្រោះដល់ភាពស្រេកឃ្លានរបស់គ្រួសារជាច្រើន ។ សេចក្ដីស្រេកឃ្លានទាំងខាងវិញ្ញាណ និង ខាងសាច់ឈាមត្រូវបានកាត់បន្ថយ ។

ខ្ញុំដឹងថាតាមរយៈកិច្ចការតូចតាច និង ងាយៗ (ដូចជាការចែកប័ណ្ណ) នោះកិច្ចការធំ និង អស្ចារ្យ (ដូចជាសេចក្ដីសង្គ្រោះនៃព្រលឹងមនុស្ស) អាចសម្រេចបាន ។ បទពិសោធន៍នេះបង្ហាញឱ្យឃើញថា មាននូវឱកាសជាច្រើនដែលនៅជុំវិញយើងក្នុងអំឡុងបុណ្យគ្រីស្ដម៉ាស់ និង រដូវកាលផ្សេងៗទៀត ដែលនាំមកនូវការណ៍អស្ចារ្យ នឹងចម្លែកនេះ ។ ■

*ឌីវីឌីអំណរដល់លោកនិង ប័ណ្ណចែកចាយសម្រាប់ឌីវីឌីមាននៅគេហទំព័រ* store.lds.org ។




# ការធំឡើងជាមួយគ្នា ក្នុងនាមជាឌីកុន

ទោះបីពួកគេមើលទៅខុសពីគ្នាក៏ដោយ ក៏យុវជនទាំងពីរនេះ មានចំនុចជាច្រើនដែលដូចគ្នា ។

ថៃល័រ ដបុលយូ មានកំពស់ ប្រាំមួយហ្វីត (1.8ម៉ែត្រ) សក់ពណ៌ក្រហម នឹងពាក់ស្បែកជើងលេខ 13 ។ ហ្វ៊ែរិត វី. មានកំពស់ បួនហ្វីត និង ប្រាំបីអ៊ីង (1.4 ម៉ែត្រ) សក់ពណ៌ត្នោត នឹងពាក់ស្បែកជើងលេខ 2 កន្លះ ។ ទោះបីជាពួកគេមានភាពខុសគ្នាផ្នែករាងកាយក៏ដោយ ក្រុមគ្រួសាររបស់ពួកគេចាត់ទុកពួកគេថាជា « កូនភ្លោះ » ពីព្រោះពួកគេជាមិត្តភក្តិជិតស្និទ្ធនឹងគ្នា ហើយមានគុណសម្បត្តិជាច្រើនដែលដូចគ្នា ។

ហ្វ៊ែរិត និង ថៃលើរ ទាំងពីរនាក់មានអាយុ 12ឆ្នាំ ហើយនៅក្នុងកូរ៉ុមឌីកុនដូចគ្នា ។ ពួកគេទាំងពីរនាក់ចូលចិត្តលេងកីឡា ចំណាយពេលវេលាជាមួយក្រុមគ្រួសាររបស់ពួកគេ និង រៀនអ្វីៗដែលថ្មីៗ ។ ពួកគេទាំងពីរនាក់ក៏មានទីបន្ទាល់អំពីដំណឹងល្អ ហើយក៏ព្យាយាមគោរពបព្វជិតភាពអើរ៉ុនដែរ ។ ហ្វ៊ែរិត និយាយថា « យើងត្រូវតែបំពេញកាតព្វកិច្ចបព្វជិតភាពរបស់យើង ដើម្បីយើងអាចរៀន » ។

ពួកគេទាំងពីរនាក់រីករាយក្នុងការបំពេញកាតព្វកិច្ចទាំងនោះដោយការចែកនំប៉័ង និង ទឹក និង ការប្រមូលដង្វាយតមអាហារ ។

ពួកគេក៏ជួយស្វាគមន៍ឌីកុនផ្សេងទៀតនៅក្នុងវួដរបស់ពួកគេ ដោយអញ្ជើញពួកគេមកកាន់ព្រះគ្រីស្ទ ។ ហ្វ៊ែរិត និយាយថា « បើសិនឌីកុនម្នាក់មិនទៅព្រះវិហារទេ នោះម្នាក់ក្នុងចំណោមពួកយើង សរសេរសារខ្លីមួយទៅឌីកុននោះ នូវអ្វីទាំងអស់ដែលយើងបានរៀននៅព្រះវិហារ ។ បន្ទាប់មកយើងឱ្យសំបុត្រទៅគាត់ ហើយនិយាយថា « សូមមកព្រះវិហារ » ។

ហ្វ៊ែរិត និង ថៃល័រក៏ចូលរួមធ្វើ កាតព្វកិច្ចចំពោះព្រះ ។ ពួកគេម្នាក់ៗបានដាក់ផែនការដើម្បីអានព្រះគម្ពីរទាំងឡាយឱ្យបានច្រើនទៀត ។ ថៃល័រ និយាយថា « វាពិតជាអាចជួយសេចក្ដីជំនឿរបស់អ្នក ហើយពង្រឹងទីបន្ទាល់របស់អ្នក » ។

យុវជនទាំងនេះគឺជាឌីកុនគឺដូចជាអ្នកដែរ ឬអ្នកទាំងឡាយឯទៀតដែលអ្នកស្គាល់ ។ មានអ្វីៗជាច្រើនដែលធ្វើឱ្យពួកគេខុសពីគ្នា ហើយមានអ្វីៗជាច្រើនដែលធ្វើឱ្យពួកគេស្រដៀងគ្នា ។ ប៉ុន្តែអ្វីដែលសំខាន់បំផុតនោះ គឺពួកគេទាំងពីរជាកូនរបស់ព្រះ ហើយប្រាថ្នាដើម្បីបម្រើទ្រង់ រួមគ្នាក្នុងកូរ៉ុមបព្វជិតភាពរបស់ពួកគេ ។ ■

## របៀបដើម្បីបង្កើតសាមគ្គីភាពកូរ៉ុម

នៅពេលដែលអ្នកត្រូវបានតែងតាំងជាឌីកុន ដូចជា ថៃល័រ និង ហ្វ៊ែរិត នោះអ្នកក្លាយជាផ្នែកមួយនៃកូរ៉ុមបព្វជិតភាព ។ ទាំងនេះគឺជាយោបល់មួយចំនួនពីរបៀបដើម្បីអ្នកអាចជួយបង្កើតសាមគ្គីភាពនៅក្នុងកូរ៉ុមរបស់អ្នក ៖

- ដាក់បញ្ចូលមនុស្សគ្រប់គ្នា ។
- ធ្វើការបម្រើរួមគ្នា ។
- ផ្ដល់ការលើកទឹកចិត្ត ។
- ស្ដាប់គ្នាទៅវិញទៅមក ។
- ធ្វើតាមការណែនាំពីអ្នកដឹកនាំទាំងឡាយ ។
- ជួយគ្នាទៅវិញទៅមក ដើម្បីរស់នៅតាមបទដ្ឋាននៃដំណឹងល្អ ។

ថតរូបដោយ ម៉ាធីវ រី ហ្វ្រីមែន



**ដោយអែលឌើរ**
**ឌី ថត គ្រីស្តូហ្វឺសិន**
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

*សមាជិកទាំងឡាយនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ត្រូវបានហៅឱ្យធ្វើជាសាក្សីពិសេសរបស់ព្រះយេស៊ូវគ្រីស្ទ។*

# តើខ្ញុំអាចក្លាយជាសាក្សីម្នាក់របស់ព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ?



យើងគឺជាសាក្សីទាំងឡាយរបស់ព្រះយេស៊ូវគ្រីស្ទ នៅពេលយើងរស់នៅបែបនោះដោយគិតអំពីការបង្រៀនរបស់ទ្រង់ ។ របៀបដែលយើងប្រព្រឹត្ត និយាយ មើល និង សូម្បីតែគិតគួរតែគិតអំពីទ្រង់ និង ពីរបៀបទាំងឡាយរបស់ទ្រង់ ។

យើងគឺជាសាក្សីរបស់ព្រះយេស៊ូវគ្រីស្ទ នៅពេលយើងរស់នៅដោយមានអាកប្បកិរិយារីករាយដែលបង្ហាញចេញមកដោយសេចក្តីជំនឿរបស់យើងលើទ្រង់ ។

យើងគឺជាសាក្សីរបស់ព្រះយេស៊ូវគ្រីស្ទ នៅពេលយើងនិយាយជាមួយអ្នកដទៃអំពីអារម្មណ៍របស់យើងអំពីទ្រង់ ។

យើងគឺជាសាក្សីរបស់ព្រះយេស៊ូវគ្រីស្ទ នៅពេលយើងថ្លែងទីបន្ទាល់ទៅកាន់អ្នកដទៃ និង ជួយពួកគេឱ្យរៀន និង ធ្វើតាមទ្រង់ ។

រចនារូបភាព ដោយ ហេកា ប្រ៊ូស៍

*កែសម្រួលមកពី* “Becoming a Witness of Christ,” *លីអាហូណា ខែ មីនា ឆ្នាំ 2008 ទំព័រ 58–63 ។*



# អំណោយរបស់ខ្ញុំដល់ ព្រះយេស៊ូវ

**ដោយរ៉ាឈែល លីន បាអឺ**

ផ្អែកទៅលើដំណើររឿងពិត

« *កូនចៅរបស់ព្រះ មកថ្វាយបង្គំ នាំអំណោយនៃសេចក្ដីស្រឡាញ់ថែមទៀត* » (“The Shepherd’s Carol,” *ចម្រៀងកុមារ 40*) ។

ដល់ពេលសម្រាប់រាត្រីជួបជុំក្រុមគ្រួសារហើយ ! » ប៉ាបានហៅ ។ ខ្ញុំប្រញាប់ប្រញាល់ទៅកាន់បន្ទប់ទទួលភ្ញៀវ ។ យើងតែងតែធ្វើអ្វីៗដែលសប្បាយៗនៅរាត្រីជួបជុំក្រុមគ្រួសារនៅសប្ដាហ៍ដំបូងនៃខែធ្នូ ។

ប្អូនស្រីរបស់ខ្ញុំឈ្មោះ មីស្បែល រត់ទៅមុនខ្ញុំ ហើយលោតទៅលើកៅអីទន់ពណ៌ខៀវ ។

« អត់យុត្តិធម៌ទេ ! » ។ ខ្ញុំបានស្រែក ។ « ឯងបាន អង្គុយលើកៅអីនោះហើយកាលពីសប្ដាហ៍មុន ។ វាជាវេនរបស់ខ្ញុំ » ។

នាងជជែកប្រកែកថា « ខ្ញុំមកដល់មុន អញ្ចឹងខ្ញុំត្រូវអង្គុយទីនេះ » ។ « បងអាចអង្គុយនៅលើសាឡុងទៅ » ។

ខ្ញុំស្រែកគំហកថា « បងមិនចង់អង្គុយនៅលើសាឡុងទេ » ។

ខ្ញុំបានដើរដោយខឹងទៅកៅអីយោលនោះ ហើយទាញវាចេញ ដើម្បីកុំឱ្យខ្ញុំមើលឃើញមុខរបស់មីស្បែល ។ ពេលខ្លះនាងធ្វើឱ្យខ្ញុំខឹងខ្លាំងណាស់ ! នាងគិតថា នាងអាចបានអ្វីៗទាំងអស់ដែលនាងចង់បាន ។ នៅពេលណាក៏ដោយដែលខ្ញុំត្អូញត្អែរ ម៉ាក់បានប្រាប់ខ្ញុំថា ខ្ញុំមិនត្រូវមានចិត្តកំណាញ់ទេ ។

បន្ទាប់ពីគ្រួសាររបស់យើងច្រៀងទំនុកដំកើង និងអធិស្ឋានរួច ប៉ាបានមានប្រសាសន៍ ថា « បុណ្យគ្រីស្ទម៉ាស់គឺជាពេលមួយដ៏រំភើប ហើយយើងត្រូវតែចងចាំអត្ថន័យដ៏ពិតនៃថ្ងៃឈប់សម្រាកនេះ ។ យប់នេះយើងនឹង ចាប់ផ្ដើមជាមួយនឹងអំណោយទាំងឡាយរបស់យើងដល់ព្រះយេស៊ូវ » ។

អំណោយទាំងឡាយរបស់យើងដល់ព្រះយេស៊ូវ ។ ខ្ញុំបានភ្លេចអំពីរឿងនោះហើយ !

ប៉ាបានបន្តថា « យើងប្រារព្ធពិធីបុណ្យគ្រីស្ទម៉ាស់ ពីព្រោះព្រះយេស៊ូវ បានប្រសូត » « ទ្រង់បានធ្វើឱ្យយើងទទួលអំណោយដ៏មហិមាបំផុតនោះគឺ—ជីវិតដ៏នៅអស់កល្បជានិច្ចជាមួយព្រះវរបិតាសួគ៌ » ។

« តើអ្វីទៅដែលទ្រង់បានសុំឱ្យយើងផ្ដិតបស្ទងទៅទ្រង់វិញនោះ ? » ម៉ាក់បានសួរ ។

បងប្រុសរបស់ខ្ញុំបានឆ្លើយថា « ធ្វើតាមទ្រង់ និង រក្សាបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ » ។

រចនារូបភាពដោយ ឡូរ៉ា អែនជ្រូស



ខ្ញុំបានដឹងភ្លាមថាអ្វីទៅគួរតែជាអំណោយរបស់ខ្ញុំនោះ ។ ព្រះយេស៊ូវបានបង្រៀនយើងឲ្យស្រឡាញ់មនុស្សដទៃ សូម្បីតែពួកគេធ្វើឲ្យយើងខឹងក៏ដោយ ។ ខ្ញុំដឹងថាព្រះយេស៊ូវចង់ឲ្យខ្ញុំស្រឡាញ់ប្អូនស្រីរបស់ខ្ញុំ ។ ខ្ញុំបានសរសេរថា « ខ្ញុំនឹងធ្វើល្អដាក់មីស្សែល » ។

យើងបានដាក់ក្រដាសរបស់យើងទៅក្នុងប្រអប់មួយដែលរុំដោយក្រដាសពណ៌ទឹកមាស ។ យើងបានដាក់ប្រអប់នៅខាងក្រោមដើមគ្រីស្ទម៉ាស់ ។ គ្រប់ពេល ដែលយើងមើលទៅប្រអប់នោះ យើងបានចងចាំពីអំណោយរបស់ព្រះអង្គសង្គ្រោះដល់ពួកយើង និង អំណោយរបស់យើងដល់ទ្រង់ ។

ពីរបីថ្ងៃក្រោយមក ខ្ញុំបានឃើញថាមីស្សែលបានពាក់អាវដែលខ្ញុំស្រឡាញ់បំផុតដោយមិនបានសុំការអនុញ្ញាតពីខ្ញុំឡើយ ។ ខ្ញុំចង់ស្រែកដាក់នាង ។ បន្ទាប់មកខ្ញុំបានងាកមើលទៅប្រអប់ពណ៌ទឹកមាសនោះ ហើយចងចាំពីសេចក្ដីស្រឡាញ់ដ៏ធំរបស់ខ្ញុំចំពោះព្រះយេស៊ូវ ។ ខ្ញុំអាចបង្ហាញសេចក្ដីស្រឡាញ់ដល់ទ្រង់ដោយការធ្វើល្អដាក់ប្អូនស្រីរបស់ខ្ញុំ ។ ខ្ញុំបាននិយាយថា « ថ្ងៃនេះឯងមើលទៅស្អាតណាស់ មីស្សែល » ។

នាងបានញញឹម ។

« ឲ្យខ្ញុំសុំទោសដែលខ្ញុំមិនបានសុំការអនុញ្ញាតពីបងដើម្បីពាក់អាវនេះ ។ បងអត់នៅពេលដែលខ្ញុំយកវាមកពាក់ ហើយខ្ញុំចង់មើលទៅស្អាតជាងធម្មតាសម្រាប់ពិធីជប់លាងបុណ្យគ្រីស្ទនៅថ្នាក់របស់ខ្ញុំថ្ងៃនេះ » ។

ខ្ញុំទទួលអារម្មណ៍កក់ក្ដៅ ។ ខ្ញុំសប្បាយចិត្តដែលខ្ញុំបានរើស ដើម្បីធ្វើល្អដាក់មីស្សែលជាជាងខឹងនឹងនាង ។

អស់រយៈពេលពេញមួយខែ ខ្ញុំព្យាយាមចងចាំពីអារម្មណ៍ល្អនោះ ហើយគោលបំណងរបស់ខ្ញុំគឺប្រែក្លាយដូចជាព្រះយេស៊ូវ ។ ខ្ញុំមានភាពអត់ធ្មត់ និងមានសេចក្ដីស្រឡាញ់កាន់តែប្រសើរឡើង ។

នៅយប់មុនថ្ងៃបុណ្យគ្រីស្ទម៉ាស់ ប៉ាបានអានរឿងប្រសូតកម្ម ហើយយើងទាំងអស់គ្នាបានសម្ដែងរឿង ។ ខ្ញុំបានសម្រេចចិត្តដើម្បីធ្វើជាទេវតាភក្តិជាងឈ្លោះជាមួយមីស្សែលដែលនាងចង់ដើរតួជាម៉ារី ។

បន្ទាប់មកយើងបានបើកប្រអប់មាសនោះ ហើយអានយ៉ាងឮៗពីអំណោយទាំងឡាយរបស់យើងដល់ព្រះយេស៊ូវ ។ នៅពេលខ្ញុំអានសំបុត្ររបស់ខ្ញុំ ម៉ាក់បានមានប្រសាសន៍ថា « ម៉ាក់បានកត់សម្គាល់ឃើញថា កូនបានធ្វើល្អច្រើនជាងមុនចំពោះមីស្សែល ។ ម៉ាក់សូមសរសើរកូនណាស់ ! »

ខ្ញុំក៏មានចិត្តរីករាយផងដែរ ។ ខ្ញុំមិនបានបើកកញ្ចប់អំណោយអ្វីមួយនៅឡើយទេ ប៉ុន្តែខ្ញុំបានទទួល នូវអ្វីដែលពិសេសរួចទៅហើយ ៖ គឺជាអារម្មណ៍មួយមកពីព្រះវិញ្ញាណបរិសុទ្ធបានប្រាប់ខ្ញុំថាខ្ញុំបានធ្វើអ្វីដែល ត្រឹមត្រូវ ។ ■

ម៉ាក់បានឲ្យក្រដាស និង ប៊ិចដល់យើងម្នាក់មួយ ។ យើងត្រូវសរសេរពីរបៀបដែលយើងនឹងបង្ហាញព្រះយេស៊ូវថាយើងស្រឡាញ់ទ្រង់ ។ នោះគឺជាអំណោយរបស់យើង—ដើម្បីជ្រើសរើសអ្វីៗដែលយើងនឹងធ្វើដើម្បីប្រែក្លាយដូចជាព្រះយេស៊ូវ ។



« រដូវកាលបុណ្យគ្រីស្ទម៉ាស់នេះ តាមរយៈប្រពៃណីជាច្រើននៃបុណ្យគ្រីស្ទម៉ាសរបស់ ពួកយើងទាំងអស់គ្នា នោះខ្ញុំសង្ឃឹមថា យើងផ្ដោតចិត្តទុកដាក់ជាចម្បងទៅលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ » ។

**អែលឌើរ រ័សុល អិម ណិលសុន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ “Christ the Savior Is Born,” *New Era,* ខែ ធ្នូ ឆ្នាំ 2006 ទំព័រ 2 ។**

# ទំព័ររបស់កុមារ



### ពួកគេចូលចិត្តមើលព្រះវិហារបរិសុទ្ធ

ក្នុងៗថ្នាក់អង្គការបឋមសិក្សាមកពី ឡា ហ្វ្រ៉ារីដា ជាវួដទីបី នៅក្នុង សាន់ទីអាហ្គោ ឈីលី បានទៅទស្សនាបរិវេណព្រះវិហារបរិសុទ្ធដោយមានអ្នកដឹកនាំថ្នាក់អង្គការបឋមសិក្សារបស់ពួកគេ និង សមាជិកនៃគណៈប៊ីស្សពទៅជាមួយផងដែរ ។ នៅពេលពួកគេដើរទស្សនាសួនច្បារដ៏ស្រស់ស្អាត ពួកគេបាននិយាយគ្នាពីគោលបំណងនៃព្រះវិហារបរិសុទ្ធ ហើយពួកគេបានច្រៀងបទ « ខ្ញុំចូលចិត្តមើលព្រះវិហារបរិសុទ្ធ » (*ចម្រៀងកុមារ* 95) ។ ពួកគេក៏បានមើលវីដេអូអំពីព្រះជន្មរបស់ព្រះយេស៊ូវគ្រីស្ទផងដែរ ។



### សូមមកព្រះវិហារបរិសុទ្ធ

ខ្ញុំសូមផ្ញើការស្វាគមន៍ពីព្រះវិហារបរិសុទ្ធ ។ វាគឺជាថ្ងៃមួយដ៏អស្ចារ្យនៅពេលដែលខ្ញុំ និង កុមារៗដទៃទៀតមកពីស្តេក លីបើរតាត អេក្វាឌ័រ អាចទៅទស្សនាបរិវេណនៃព្រះវិហារបរិសុទ្ធ ហ្គុយ៉ាហ្គីល អេក្វាឌ័រ ។ យើងអញ្ជើញក្មេងទាំងអស់លើពិភពលោក ដើម្បីមើលព្រះវិហារបរិសុទ្ធ បើសិនពួកគេអាចធ្វើបាន វាជាកន្លែងដ៏ស្រស់ស្អាតណាស់ ។

**អាយដា វី អាយុ 10 ឆ្នាំ អេក្វាឌ័រ**




វាគឺជាបុណ្យគ្រីស្ទម៉ាស់—ព្រះគ្រីស្ទទ្រង់ប្រសូតហើយ *ដោយ អ្លូលខ្សី អូ អាយុ 9ឆ្នាំ ប្រទេស ណៃជើរៀ ។*



ការស្តារឡើងវិញនៃបព្វជិតភាពអើរ៉ុនដោយ *ហ្វែលីប អិល អាយុ 12 ឆ្នាំ ប្រទេស ប្រេស៊ីល ។*

### ខ្ញុំនឹងបង្រៀនអំពីព្យាការី យ៉ូសែប ស្ម៊ីធ



ព្រៃពិសិដ្ឋដោយ *អាកស្សែល ស៊ី ។*



នៅក្នុងថ្នាក់អង្គការបឋមសិក្សាយើងបានរៀនបទ « ការអធិស្ឋានដំបូងរបស់ យ៉ូសែប ស្ម៊ីធ » (*ទំនុកដំកើង* លេខ 14 ហើយឥឡូវនេះវាគឺបទដែលខ្ញុំពេញចិត្ត ។ ពេលខ្ញុំធ្វើជាអ្នកផ្សព្វផ្សាយសាសនា ខ្ញុំនឹងចែកចាយអំពីរឿងព្រៃពិសិដ្ឋជាមួយមនុស្សដែលខ្ញុំបង្រៀន ។ ខ្ញុំស្រឡាញ់ព្រះយេស៊ូវគ្រីស្ទ និង ព្យាការី យ៉ូសែប ស្ម៊ីធ ។ ខ្ញុំដឹងថាសាសនាចក្រពិត ។

**អាកស្សែល ស៊ី អាយុ 5 ឆ្នាំ ប្រទេស ពេរូ**



### គំនូររបស់ប្រធាន ម៉នសុន

ការសិក្សារយៈពេលប្រាំមួយខែ ថ្នាក់អង្គការបឋមសិក្សានៅវួដ ហ្វូជី នៅក្នុង ស្ស៊ីស៊្សូកា ប្រទេសជប៉ុន បានបង្កើតគំនូរ chigiri-e ជាការប្រមូលផ្តុំមកពីក្រដាសហែកដោយដៃ ជាគំនូរប្រធាន ថូម៉ាស់ អេស. ម៉នសុន ។ វាចំណាយពេលវេលា និង ធ្វើការច្រើន ប៉ុន្តែគ្រប់គ្នាបានធ្វើការរួមគ្នា ខណៈពេលដែលគិត និង រៀនអំពីប្រធាន ម៉នសុន ។



### នាងរីករាយជាមួយនឹងរាត្រីជួបជុំក្រុមគ្រួសារ

សាហលេណា ស៊ី អាយុ 9 ឆ្នាំ មកពី កូស្តា រីកា ទទួលអារម្មណ៍ភ្លាមៗថានាងជាសមាជិកនៃសាសនាចក្រ បន្ទាប់ពីនាងបានជ្រមុជទឹកដោយឪពុករបស់នាង ។ នាងរីករាយជាមួយនឹងរាត្រីជួបជុំក្រុមគ្រួសារ នូវមេរៀនអំពីព្រះយេស៊ូវគ្រីស្ទ ។ នាងក៏ចូលចិត្តទៅសាលារៀន និង លេងជាមួយមិត្តភក្តិទាំងឡាយរបស់នាងផងដែរ ។

# « មករកព្រះគ្រីស្ទ »។

—ម៉ូរ៉ូណៃ 10:32



# ពន្លឺនៃលោកិយ



**ដោយ ឃីមប៊ើរលី រីឌ**

ផ្អែកទៅលើដំណើររឿងពិត

*« ព្រោះដូចជាគ្រប់មនុស្សទាំងអស់បានត្រូវស្លាប់ក្នុងលោក អ័ដាមជាយ៉ាងណានោះ គ្រប់គ្នាក៏នឹងបានប្រោសឱ្យរស់ក្នុងព្រះគ្រីស្ទយ៉ាងនោះដែរ » (កូរិនថូសទី 1 15:22)* ។

អ៊ុំរីនបានឈរនៅវិសាលដ្ឋាននៃព្រះវិហារបរិសុទ្ធ នៅទីក្រុង សតល៍ លេក ដោយមើលរូបចម្លាក់នៃឆុតឆាករឿងអំពីការប្រសូត និង រងចាំសម្រាប់តន្ត្រី និង រឿងទាំងឡាយដើម្បីចាប់ផ្ដើម ។ ភ្លើង ពណ៌ជាច្រើននៃបុណ្យគ្រីស្ទម៉ាស់បានចាំងឆ្វេឆ្វាតជុំវិញនាង ។ ប៉ុន្តែវាហាក់បីដូចជាមិនដូចជារដូវការបុណ្យគ្រីស្ទម៉ាស់ទេ ។

« តើកូនមិនអីទេឬ ? » ម្ដាយបានសួរនាង ។

អ៊ុំរីនបានងក់ក្បាល ប៉ុន្តែនាងពុំប្រាកដក្នុងចិត្តនោះទេ ។

កាលពីប៉ុន្មាន ថ្ងៃមុន ក្មេងប្រុសម្នាក់ដែលរៀននៅក្នុងថ្នាក់ជាមួយ អ៊ុំរីន នៅសាលារៀនបានស្លាប់ដោយគ្រោះថ្នាក់ឡានបុកគ្នា ។ នាងបានឃើញមនុស្សជាច្រើនបានយំនៅពិធីបុណ្យសព ហើយនាងខ្លួនឯងក៏យំខ្លាំងផងដែរ ។ នាងមិនបានស្គាល់ក្មេងប្រុសនោះច្បាស់ទេ ប៉ុន្តែអ៊ុំរីនបានដឹងថា គ្រួសាររបស់គាត់ ស្រឡាញ់គាត់ដូចជាគ្រួសាររបស់នាងស្រឡាញ់នាងដែរ ។ នាងមានអារម្មណ៍ភ័យខ្លាចក្នុងការដឹងថា អ្វីៗបែបនោះក៏អាចកើតឡើងដល់ក្មេងៗដែលមានអាយុស្របាលនាងដែរ ។

ឥឡូវនេះនាងមិនមានអារម្មណ៍រំភើបសម្រាប់បុណ្យគ្រីស្ទម៉ាស់នោះទេ ។ នាងមានអារម្មណ៍ភ័យព្រួយគ្រប់ពេល—ភ័យពេលជិះឡាន ភ័យពេលបែកពីឪពុកម្ដាយរបស់នាង ភ័យក្នុងការចាកចេញពីផ្ទះខ្លាចក្រែងមានករណីអាក្រក់ណាមួយកើតឡើងចំពោះនាងខណៈពេលនាងនៅឆ្ងាយ ។ ពន្លឺភ្លើងពណ៌បុណ្យគ្រីស្ទម៉ាស់ទាំងអស់នៅវិសាលដ្ឋាននៃព្រះវិហារបរិសុទ្ធមិនអាចលុបបំបាត់នូវភាពភ័យខ្លាចពីក្នុងចិត្តនាងបានឡើយ ។ តើនាងអាចរីករាយនៅក្នុងពិភព ដែលនាងមិនមានសុវត្ថិភាពជានិច្ចដោយរបៀបណា ?

ប៉ាបានមានប្រសាសន៍ថា « វាដល់ពេលដែលត្រូវចាប់ផ្ដើមហើយ » ។ គាត់បានចង្អុលទៅកន្លែងតាំងរូបប្រសូតកម្ម ។

អូប៉ាល័រចាប់ផ្ដើមបន្លឺសម្លេងខ្លាំងៗឡើង ហើយសម្លេងក៏បានបន្លឺឡើង ។ តន្ត្រីបានលេង ហើយភ្លើងហ្វាបានបញ្ចាំងចុះទៅលើរូបចម្លាក់នៃអ្នកគង្វាលចៀម ហោរា ម៉ារី និង យ៉ូសែប ។ អ៊ុំរីនបានស្ដាប់រឿងដែលនាងបានស្ដាប់ហើយ ។ ព្រះទារកយេស៊ូវបានប្រសូត ហើយផ្ទុំក្នុងស្នូក ។ ទេវតាបានច្រៀង ។ អ្នកគង្វាលចៀមបានថ្វាយបង្គំ ។ ពួកហោរាបានមានក្ដីអំណរ ។

អ៊ុំរីនបានមើលទៅទឹកមុខរបស់ឪពុកម្ដាយរបស់នាង ហើយមនុស្សកុះករបានប្រមូលគ្នាជុំវិញកន្លែងតាំងរូបប្រសូតកម្មនោះ ។ ពួកគេហាក់បីដូចជារីករាយ ។ ប៉ុន្តែហេតុអ្វីបានជាមនុស្សគ្រប់គ្នារីករាយ

រចនាដោយ ស៊ីវ ព្រុ





« ព្រះយេស៊ូវគ្រីស្ទគឺជា ... ពន្លឺនៃលោកិយ ពីព្រោះតែគំរូរបស់ទ្រង់ និង ការបង្រៀនរបស់ទ្រង់បានបំភ្លឺផ្លូវដល់យើងសម្រាប់ ដើរត្រឡប់ទៅទីវត្តមានរបស់ព្រះវរបិតារបស់យើងនៅឋានសួគ៌វិញ » ។

**អែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមពួកសាវកដប់ពីរនាក់ “The Light and Life of the World,” *Ensign,* ខែ វិច្ឆិកា ឆ្នាំ 1987 ទំព័រ 64 ។**

អំពីព្រះទារកយេស៊ូវ ព្រោះការប្រសូតរបស់ទ្រង់មិនបានបញ្ឈប់រឿងអាក្រក់ឱ្យកើតឡើងបានទេ ? អ៊ុរីន មិនចូលចិត្តសំណួរដែលវិលវល់ក្នុងខួលក្បាលរបស់នាងឡើយ ។ អ្វីដែលនាងចង់នោះគឺ ការបញ្ឈប់អារម្មណ៍ដែលភ័យខ្លាច ។

រឿងបានបញ្ចប់ ហើយសម្លេងរបស់ព្យាការីដែលបានថត បានបន្លឺឡើងតាម អូប៉ាល័រ ។ លោកបានថ្លែងទីបន្ទាល់របស់លោក និង អានខមួយពីព្រះគម្ពីរបរិសុទ្ធ ៖ « ព្រោះដូចជាគ្រប់មនុស្សទាំងអស់បានត្រូវស្លាប់ក្នុងលោកអ័ដាមជាយ៉ាងណានោះ គ្រប់គ្នាក៏នឹងបានប្រោសឱ្យរស់ក្នុងព្រះគ្រីស្ទយ៉ាងនោះដែរ » (កូរិនថូសទី 1 15:22) ។

បេះដូងរបស់អ៊ុរីនបានលោតញាប់ជាងមុន ។ នាងបាននិយាយពាក្យទាំងនោះម្តងទៀតក្នុងចិត្តរបស់នាង ដោយព្យាយាមដើម្បីចាំពាក្យទាំងនោះ ។ *ព្រោះដូចជាគ្រប់មនុស្សទាំងអស់បានត្រូវស្លាប់ ក្នុងលោកអ័ដាមជាយ៉ាងណានោះ គ្រប់គ្នាក៏នឹងបានប្រោសឱ្យរស់ក្នុងព្រះគ្រីស្ទយ៉ាងនោះដែរ*

ព្រះគម្ពីរបាននិយាយថា*មនុស្សគ្រប់គ្នា*នឹងស្លាប់—ទាំងចាស់ ទាំងក្មេង—គឺមនុស្សគ្រប់គ្នា ។ ជាការពិតណាស់ អ៊ុរីនដឹងអំពីខនោះ ប៉ុន្តែនាងមិនបានគិតឱ្យបានហ្មត់ចត់អំពីវាកាលពីមុនឡើយ ។ នាងគិតថានាងនៅក្មេងពេកដើម្បីគិតអំពីរឿងបែបនោះ ។ ប៉ុន្តែនាងមិនមែនក្មេងពេកទេដើម្បីមានទីបន្ទាល់នៃសេចក្តីពិតនោះ ៖ ដោយសារតែព្រះយេស៊ូវគ្រីស្ទ *មនុស្សគ្រប់គ្នា*នឹងរស់ម្តងទៀត ។ នោះជាមូលហេតុដែលពួកអ្នកគង្វាលចៀម និង ពួកហោរាបានមានសេចក្តីអំណរ ។ ពួកគេបានយល់ ពីអ្វីដែលព្រះយេស៊ូវបានយាងមកដើម្បីធ្វើលើផែនដី ។

អ៊ុរីនបានសម្លឹងមើលពីកន្លែងដាក់ស្នូកតូចទៅបង្អួចមួយទៅបង្អួចមួយនៅក្នុងមជ្ឈមណ្ឌលអ្នកទស្សនានៅពីក្រោយកន្លែងតាំងរូបប្រសូតកម្ម ។ នៅក្នុងអគារនោះ មានពន្លឺភ្លើងមួយបានជះលើរូបចម្លាក់ដ៏ធំរបស់ព្រះយេស៊ូវ លាតព្រះហស្តរបស់ទ្រង់ដែលមាននូវស្នាមដែកគោល ។ អ៊ុរីនបានគិតពីទារកតូចនោះដែលនៅក្នុងស្នូកនោះ និង ពីរបៀបដែលទ្រង់ចម្រើនវ័យធំឡើងជាម្នាក់ដែលមានគ្រប់ទាំងព្រះចេស្តា ។ ហើយទ្រង់បានជ្រើសរើសដើម្បីបូជាព្រះជន្មទ្រង់សម្រាប់នាង ។ ទ្រង់បានប្រសូត ដើម្បីឱ្យនាងអាចរស់ម្តងទៀត ។ មិនថាមានរឿងអ្វីនឹងកើតឡើងនោះទេ អ៊ុរីនអាចមានអារម្មណ៍សុខសាន្តនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះយេស៊ូវ ។

សេចក្តីសុខសាន្តបានគ្របដណ្តប់លើនាង ។ នាងមិនអាចពន្យល់ពីអារម្មណ៍ទាំងនោះបានទេ ប៉ុន្តែការភ័យខ្លាចរបស់នាងត្រូវបានរសាយបាត់ទៅ ។ នៅពេលដែលនាងបានមើលទៅរូបចម្លាក់នៃព្រះយេស៊ូវគ្រីស្ទ ភ្លាមៗនោះនាងបានសម្គាល់ឃើញពីផ្ទៃមេឃដ៏ងងឹត មានចាំងនូវពន្លឺខ្លាំងជាពន្លឺភ្លើងគ្រីស្ទម៉ាស់ទៅទៀត ។ នាងបានមានអារម្មណ៍ពោរពេញដោយភាពកក់ក្តៅនៃសេចក្តីសង្ឃឹមដែលមានពន្លឺក្នុងចិត្តនាង ។ ■

អ្នកអាចប្រើមេរៀន និង សកម្មភាពនេះ ដើម្បីរៀនសូត្របន្ថែមទៀតពីបាវចនាថ្នាក់កុមារសម្រាប់ខែនេះ

# ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រារបស់ព្រះ

ស្រមៃមើលការធ្វើដំណើរឆ្លងកាត់សមុទ្រខ្សាច់ ។ ការធ្វើដំណើរផ្លូវឆ្ងាយ ការជិះអូដ្ឋវារលាក់ ហើយ អ្នកពុំធ្វើដំណើរតាមផែនទីទេ ! ផ្ទុយទៅវិញ អ្នកទៅតាមផ្កាយ ។ តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេច ? តើអ្នកនឹងមានសេចក្តីជំនឿក្នុងការបន្តដំណើរទៀតទេ ?

កាលពីពីរពាន់ឆ្នាំកន្លងផុតទៅ ពួកហោរាពិតជាបានធ្វើបែបនោះ ។ ពួកគេបានឃើញផ្កាយដ៏ភ្លឺ នៅទិសខាងកើត ហើយបានធ្វើដំណើរទៅបេថ្លេហិមដោយមានអំណោយដ៏អស្ចារ្យដើម្បីថ្វាយបង្គំព្រះគ្រីស្ទជាបុត្រតូច ។ ហើយមិនមែនមានតែពួកហោរាប៉ុណ្ណោះទេដែលបានមើលផ្កាយនោះ ។ នៅចុងម្ខាងនៃមហាសមុទ្រ នៅទ្វីបអាមេរិកឯនោះវិញ ពួកសាសន៍នីហ្វៃបានឃើញផ្កាយនោះដែរ ហើយបានដឹងថាព្រះយេស៊ូវគ្រីស្ទព្រះរាជបុត្រានៃព្រះបានប្រសូតហើយ ។

សព្វថ្ងៃនេះ ការគិតអំពីផ្កាយនោះ រំឭកយើងពីព្រះអង្គសង្គ្រោះ ។ ផ្កាយនោះបានបំភ្លឺនៅទីងងឹត ហើយបានបង្ហាញផ្លូវដល់ពួកហោរា គឺដូចជាអ្វីដែលព្រះយេស៊ូវបានបង្ហាញយើងពីរបៀបដើម្បីរស់នៅ ។ ផ្កាយគឺនៅតែដដែរ គឺដូចជាសេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះសម្រាប់យើងផងដែរ ។ ពេលក្រោយនៅពេលអ្នកមើលទៅផ្កាយ សូមចងចាំថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រារបស់ព្រះ ហើយជាពន្លឺនៃលោកិយ ! ■

## សកម្មភាព ជ.ផ.ត ៖ និមិត្តសញ្ញានៃព្រះអង្គសង្គ្រោះ

ព្រះយេស៊ូវបានប្រៀបធៀបខ្លួនរបស់ទ្រង់ទៅនឹងរបស់ជាច្រើន ។ តាមរយៈការសិក្សាពីការប្រៀបធៀបនេះ យើងរៀនបន្ថែមទៀតពីទ្រង់ ។ សូមអានខគម្ពីរទាំងនេះជាក្រុមគ្រួសារ ហើយពិភាក្សាពីអ្វីដែលនិមិត្តសញ្ញាទាំងនេះប្រាប់យើងអំពីព្រះអង្គសង្គ្រោះ ។



អ្នកគង្វាលចៀម (សុភាសិត 23:1)



កូនចៀម (សូមមើលយ៉ូហាន 1:29)



នំប៉័ង (សូមមើលយ៉ូហាន 6:51)



ទឹក (សូមមើលយ៉ូហាន 4:14)



ថ្ម (សូមមើលនីហ្វៃទី 2 8:1)

### ចម្រៀង និង ព្រះគម្ពីរ

- "The Nativity Song" *ចម្រៀងកុមារទំព័រ* 52–53
- គោលលទ្ធិ និង សេចក្តីសញ្ញា 11:28

ខាងឆ្វេង ៖ រចនារូបដោយ ម៉ៃខល ក្រ៊ិត ខាងស្តាំ ៖ រចនារូបដោយ ជូឌី អេស ដាហ្វ៍ ISTOCKPHOTO.COM និង ISTOCKPHOTO.COM/ADYNA



## សម្រាប់តែអ្នក

សូមតុបតែងបុណ្យណូអែលដើម្បីចងចាំពីរបៀប ដែលព្រះអង្គសង្គ្រោះប្រទានពរដល់ជីវិតរបស់អ្នក ។ សូមកាត់យករូបផ្កាយ ហើយបិតដាក់វាលើក្រដាសរឹង ។ នៅខាងខ្នងនៃគ្រឿងតុបតែង សូមបិតរូបថតអ្នក ឬគ្រួសាររបស់អ្នក ហើយសរសេរអ្វីដែលអ្នកចង់ធ្វើតាមព្រះយេស៊ូវគ្រីស្ទ ដែលជាពន្លឺនៃលោកិយ ។ សូមចោះរន្ធនៅពីលើ ហើយដាក់ខ្សែអំបោះតាមរន្ធនោះដើម្បីធ្វើគ្រឿងតុបតែង ។

# ការអធិស្ឋាន នៅ បុណ្យគ្រីស្ទម៉ាស់ ត្រូវ បានឆ្លើយតប




**ដោយ ភេហ្គី ស្ទុនឃិន**

ផ្អែកទៅលើដំណើររឿងពិត

*« ព្រះអម្ចាស់នឹងទឹកចាំដល់សេចក្ដីអធិស្ឋានទាំងឡាយនៃពួកសុចរិត ដែលត្រូវបានថ្វាយដល់ទ្រង់ដើម្បីពួកគេ » (មរមន 5:21) ។*



ភេគីបានភ្ញាក់ពីដំណេក នៅព្រឹកថ្ងៃបុណ្យគ្រីស្ទម៉ាស់ ។ នាងរំភើបដើម្បីទទួលបានប្រដាប់ក្មេងលេងថ្មីៗ និង ញុំអាហារបុណ្យគ្រីស្ទម៉ាស់សប្បាយៗ ។ ប៉ុន្តែនៅពេលនាងបានមើលទៅជុំវិញខ្លួននាង នោះនាងបានដឹងថាឆ្នាំនេះមានភាពប្លែក ។ ទោះបីជាឪពុករបស់នាងខំប្រឹងធ្វើការយ៉ាងណាក៏ដោយ ក៏នៅតែមានប្រាក់បន្តិចបន្តួចប៉ុណ្ណោះ សម្រាប់គ្រួសាររបស់នាង ។

គ្មានសញ្ញាណាមួយដែលថានឹងមានការញុំអាហារបុណ្យគ្រីស្ទម៉ាស់កើតឡើងឡើយ ។ ថាសបន្លែនៅទទេស្អាត ហើយគ្មានអាហារនៅក្នុងទូរទឹកកកទេ ។

ភេគី និង បងប្រុសរបស់នាង ម៉ាលខូមបានដើរទៅមាត់ទ្វាបន្ទប់គេងរបស់ឪពុកម្ដាយពួកគេ ហើយបានឃើញពួកគាត់លុតជង្គង់នៅក្បែររបស់ពួកគាត់ ។ ពួកគេស្ដាប់ដោយស្ងាត់ស្ងៀមនៅពេលម្ដាយ និងឪពុកពួកគេបានអធិស្ឋានសូមឱ្យព្រះវរបិតាសួគ៌នឹងជួយឱ្យគ្រួសារពួកគេមានម្ហូបអាហារ ។

ភេគី បាននិយាយទៅ ម៉ាលខូលម ថា « តោះ » « ទៅក្រៅ » ។

ភេគី និង ម៉ាលខូមបានទៅខាងក្រៅ ហើយបានទៅបេះស្លឹកត្នោតព្រៃមួយចំនួនដែលដុះនៅក្បែរ





សួន ។ ប្រហែលជាគ្មានប្រដាប់ក្មេងលេងទេនៅឆ្នាំនេះ ប៉ុន្តែពួកគេនៅតែអាចធ្វើឱ្យផ្ទះរបស់ពួកគេទទួលបាននូវបរិយាកាសនៃ បុណ្យគ្រីស្ទម៉ាស់ ។

ពួកគេទទួលអារម្មណ៍ល្អ បន្ទាប់ពីពួកគេបានតុបតែងផ្ទះជាមួយនឹងស្លឹកត្នោតព្រៃពណ៌បៃតងនោះ ប៉ុន្តែវានៅតែគ្មានសញ្ញាថាមានអាហារសម្រាប់ញ៉ាំនោះទេ ។

ម្ដាយបាននិយាយថា « ព្រះអម្ចាស់នឹងប្រទានដល់យើង » ។ « ឥឡូវសូមរៀបចំតុអាហារទៅ » ។

ឪពុកបានរៀបចានទៅលើតុ ខណៈពេលដែលម្ដាយដាក់សម និង ស្លាបព្រា ។

ក្មេងៗមើលមុខគ្នាទៅវិញទៅមក ដោយងឿងឆ្ងល់ក្នុងចិត្ត ។ តុអាហាររៀបចំរួច ប៉ុន្តែនៅតែគ្មានអាហារទៀត ។ ពេលសម្រាប់អាហារពេលព្រឹកបានកន្លងផុតទៅ ហើយពេលសម្រាប់អាហារថ្ងៃត្រង់ក៏ជិតមកដល់ដែរ ។ ភេគីអាចទទួលអារម្មណ៍ថាកូរពោះ ។ នាងឆ្ងល់ថា តើក្រុមគ្រួសាររបស់នាងនឹងទទួលអាហារដោយរបៀបណា ។

នាឡិកាដើរដល់ម៉ោង 12:00 បន្ទាប់មក 12:30 បន្ទាប់មកទៀត 12:45 ។ នៅតែគ្មានអ្វីសោះ ។ បន្ទាប់មកទៀត ភេគីបានឮសម្លេងគោះទ្វា ។

នាងរត់យ៉ាងលឿនទៅបើកទ្វា ហើយបានភ្ញាក់ផ្អើលដែលឃើញ គ្រួសារ ឃើក ឈរនៅទីនោះ ។ ពួកគេបានកាន់ ភ្លៅជ្រូក នំប៉ុង មាន់ សាឡាដ និង បង្អែម ។ ភេគីស្ទើរតែមិនជឿនឹងភ្នែកខ្លួនឯងសោះ ។

បងប្រុស ឃើកបាននិយាយថា « នៅពេលពួកយើងកំពុងអង្គុយញ៉ាំអាហារបុណ្យគ្រីស្ទម៉ាស់របស់យើង នោះយើងបានគិតដល់អ្នកទាំងអស់គ្នា » ។ « យើងសង្ឃឹមថាអ្នកអាចញ៉ាំអាហារនេះ » ។

ឪពុកបានចាប់ដៃបងប្រុស ឃើក ហើយម្ដាយបានចាប់ផ្ដើមរៀបចំតុអាហារនៅផ្ទះបាយ ។ ភេគី នៅតែមានអារម្មណ៍ភ្ញាក់ផ្អើល ។ នាងបានបើកភ្នែកធំៗសំឡឹងទៅម្ដាយ និង ឪពុក ហាក់បីដូចជា ពួកគាត់ដឹងរឿងនេះជាមុនអញ្ចឹង ។

ភេគីបានដឹងថា អារម្មណ៍ដែលនាងបានទទួលនៅព្រឹកនោះថាជា អារម្មណ៍ដ៏ត្រឹមត្រូវ ។ បុណ្យគ្រីស្ទម៉ាស់ឆ្នាំនេះ*គឺ*ខុសពីសព្វដង ។ នេះគឺជាបុណ្យគ្រីស្ទម៉ាស់ដែលនាងបានរៀនថា ព្រះវរបិតាសួគ៌បានឮ ហើយឆ្លើយតបការអធិស្ឋាន ។ ហើយនោះគឺជាអំណោយដ៏ល្អបំផុត ដែលនាងធ្លាប់បានទទួល ។ ■



« ការអធិស្ឋានដោយរាបសារ និង ទំនុកចិត្ត នាំមកនូវការដឹកនាំ និង សេចក្ដីសុខសាន្ត » ។

**អែលឌើរ រីឆាត ជី ស្កត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់**
**"Using the Supernal Gift of Prayer"**
**_លីអាហូណា_ ខែ ឧសភា ឆ្នាំ 2007 ទំព័រ 8 ។**

# នំសាំងវិចរបស់មិត្តសម្លាញ់

**ដោយ ហៃឌី ផូលម៉ែន**

ផ្អែកលើដំណើររឿងពិត

1. វិលេម បានឡើងក្នុងឡានក្បែរ ដេរេមី ហើយដាក់ខ្សែក្រវ៉ាត់សុវត្ថិភាពរបស់គាត់ ។




2. ម្ដាយរបស់ដេរេមី បានចាប់ផ្ដើមបើកឡាន ហើយវិលេមបានបើកប្រអប់បាយថ្ងៃត្រង់របស់ខ្លួន ។ វិលេមបានដកយកនំសាំងវិចដែលមានដាក់ប៊ើរសណ្ដែកដី និង ចាហួយ ហើយបានខាំមួយម៉ាត់យ៉ាងធំ ។



3. ដេរាមីបានសំឡឹងមើលនំសាំងវិចរបស់វិលេម ។ វាមើលទៅគួរឱ្យឆ្ងាញ់ណាស់ ។ ដេរាមីឃ្លាន ។




រចនារូបភាពដោយ ស្កុត ភេក

# សូមធ្វើជាមិត្ត

របៀបមួយដែលអ្នកអាចធ្វើជាមិត្តម្នាក់ គឺដោយការជួយក្មេងៗដទៃទៀត ។ វីលេម និង ជេរេមី ចង់ធ្វើអ្វីៗដែលល្អៗដល់ក្មេងៗផ្សេងទៀតនៅសួនកុមារ ។ សូមគូរជារង្វង់នៅលើរូបក្មេងនៅសួនកុមារដែលត្រូវការជំនួយ ។



គំនូរព្រាងដោយ ស្ទីវ អេក

# ទំព័រផាត់ពណ៌



**យ៉ូសែប ស៊្មីធ បានឃើញ និង បានថ្លែងទីបន្ទាល់ពី ព្រះយេស៊ូវគ្រីស្ទ ។**

« ទ្រង់មានព្រះជន្មរស់ ! ត្បិតយើងខ្ញុំបានឃើញទ្រង់ គង់នៅខាងស្ដាំព្រះហស្ដនៃព្រះ ហើយយើងខ្ញុំបានឮសំឡេងដែលថ្លែងទីបន្ទាល់ថា ទ្រង់គឺជាបុត្រាបង្កើតតែមួយនៃព្រះវរបិតា » (គ. និង ស. 76:22–23)

រចនារូបភាពដោយ យ៉ារ៉េត ប៊ែកស្ត្រេន

## សមាជិកទាំងឡាយត្រូវបានអញ្ជើញឱ្យចែកចាយដំណឹងល្អ តាមរយៈការជាវទស្សនាវដ្ដី

**ដោយ ហ៊ិតធើរ វិតធល ហ្រ៊ិចលី**
ព័ត៌មាន និង ព្រឹត្តិការណ៍នានាអំពីសាសនាចក្រ

ក្រុងនាមជាប្រធានផ្នែកគ្រប់គ្រងសម្ភាររបស់សាសនាចក្រសម្រាប់ប្រទេសថៃ កាណូវ៉ាន់ វង់វីរ៉ាហ្វាប់ ត្រូវចាត់ចែងសំណើរនានាជាទៀងទាត់ពីសមាជិកសាសនាចក្រចំពោះសម្ភារ និង គ្រឿងបរិក្ខាទាំងឡាយរបស់សាសនាចក្រដូចជា សម្លៀកបំពាក់ពិសិដ្ឋ និង ការបោះពុម្ពទាំងឡាយរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

ប៉ុន្តែថ្ងៃមួយគាត់មានការភ្ញាក់ផ្អើល នៅពេលស្រ្ដីម្នាក់បានមកលេងការិយាល័យរបស់គាត់ដើម្បីបន្តការជាវទស្សនាវដ្ដីសាសនាចក្រ ។ អំពីការជាវទស្សនាវដ្ដីនេះនៅទូទាំងពិភពលោក ជាទូទៅសមាជិកទាំងឡាយបន្តការជាវទស្សនាវដ្ដីរបស់ពួកគេតាមរយៈអ្នកតំណាងទស្សនាវដ្ដីក្នុងអង្គភាពរបស់ពួកគេ ។ តែផ្ទុយទៅវិញ ស្រ្ដីម្នាក់នោះបានពន្យល់ថា គាត់គ្មានអ្នកតំណាងទស្សនាវដ្ដីនៅក្នុងវួដទេ ។ គាត់ជាអ្នកកាន់សាសនាព្រះពុទ្ធ ហើយបានរៀនអំពីទស្សនាវដ្ដីរបស់សាសនាចក្រនៅពេលដែលមិត្តម្នាក់របស់គាត់ដែលជាសមាជិកសាសនាចក្របានជាវទស្សនាវដ្ដីធ្វើជាអំណោយសម្រាប់គាត់ ។

បងស្រី វង់វីរ៉ាហ្វាប់ បានសរសេរថា ៖ « គាត់បានចាប់ផ្ដើមប្រាប់ខ្ញុំអំពីរឿងដ៏អស្ចារ្យទាំងឡាយរបស់ទស្សនាវដ្ដីសាសនាចក្រ និង ពីគុណតម្លៃដ៏ល្អរបស់ទស្សនាវដ្ដីចំពោះកូនៗរបស់គាត់ » ។ « នៅពេលកូនៗរបស់គាត់ត្រឡប់មកពីសាលារៀន ហើយ បានឃើញទស្សនាវដ្ដី នោះពួកគេសែនរំភើប ហើយពួកគេអាន និង អាន ទស្សនាវដ្ដីទាំងនោះចប់ក្នុងរយៈពេលដ៏ខ្លី ។

ស្រ្ដីនោះបានសរសើរពី « គុណតម្លៃដ៏អស្ចារ្យ » របស់ទស្សនាវដ្ដី និង ការបង្រៀនកូនៗរបស់គាត់ឱ្យមានសីលធម៌ និង ការនិយាយស្ដីល្អ ។ នាងបានមានការស្ងើចសរសើរយ៉ាងខ្លាំង ថានាងនឹងបន្តការជាវសម្រាប់ខ្លួនគាត់ផ្ទាល់ និង ជាវធ្វើជាអំណោយដល់អ្នកធ្វើការជាមួយគាត់ ដូច្នេះកូនៗរបស់ពួកគេអាចទទួលបានផលប្រយោជន៍ផងដែរ ។

បងស្រី វង់វីរ៉ាហ្វាប់ បានសរសេរថា ៖ « សូម្បីតែអ្នកមិនមែនជាសមាជិកក៏អាចទទួលអារម្មណ៍ និង ឃើញពីគុណតម្លៃ [របស់ទស្សនាវដ្ដី] ហើយ [ពួកគេ] ចង់ចែកចាយពីគុណតម្លៃនោះជាមួយមនុស្សដទៃទៀត » ។

អ្នកដឹកនាំទាំងឡាយនៃសាសនាចក្របានបន្តលើកទឹកចិត្តសមាជិកទាំងឡាយនៃសាសនាចក្រឱ្យអាន ហើយ ចែកចាយទស្សនាវដ្ដីសាសនាចក្រជាមួយមនុស្សដទៃទៀត ។

អែលឌើល អិល. ថម ភែរី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានលើកយកពីសារៈប្រយោជន៍ដ៏ច្រើនរបស់ទស្សនាវដ្ដីសាសនាចក្រ ។ លោកបានមានប្រសាសន៍ថា ៖ « វិញ្ញាណដ៏ល្អនៅក្នុងទស្សនាវដ្ដីទាំងនេះនឹងជួយចាក់បំពេញភាពកក់ក្ដៅ, សេចក្ដីស្រឡាញ់ និង កម្លាំងនៃដំណឹងល្អក្នុងគេហដ្ឋានរបស់អ្នក » (“The Importance of the Family,” *លីអាហូណា* ខែ ឧសភា ឆ្នាំ 2003 ទំព័រ 42) ។

អែលឌើរ គ្រែក អេ ខាតុន នៃពួកចិតសិបទាក់បម្រើជាជំនួយការនាយកប្រតិបត្តិនៅក្នុងផ្នែកបព្វជិតភាព និង ការបោះពុម្ពនៃទស្សនាវដ្ដីសាសនាចក្រ ហើយលោកបានឃើញពីគុណតម្លៃដែលទស្សនាវដ្ដីទាំងនោះមានចំពោះបុគ្គលម្នាក់ៗ ។

លោកបាននិយាយថា ៖ « ទស្សនាវដ្ដីសាសនាចក្រទាំងឡាយគឺជាផ្នែកសំខាន់មួយនៃសម្លេងដ៏មានឥទ្ធិពលនៃសាសនាចក្រតាមរយៈអ្វីៗដែលជាការទូលន្មានរបស់ព្យាការីមកពីព្រះអម្ចាស់ដែលអាចធ្វើឱ្យមនុស្សទាំងអស់ដែលជាកូនចៅរបស់ព្រះវរបិតា គ្រប់អាយុទាំងអស់ដឹងពីបញ្ហាទាក់ទងនឹងពិភពលោកសព្វថ្ងៃនេះ ។ ក្នុងខែនិមួយៗ មានអត្ថបទសុន្ទរកថាដែល គួរឱ្យចាប់អារម្មណ៍ និង ទាក់ទាញជាច្រើនដែលមានស្ថានភាពត្រូវនឹងមនុស្សទាំងអស់ទូទាំងផែនដី មិនថាពួកគេជាសមាជិក ឬ មិនមែនជាសមាជិកនៃសាសនាចក្រក៏ដោយ ។ អ្នកដែលស្វែងសេចក្ដីពិតទាំងអស់ទទួលបានសារៈប្រយោជន៍ជាច្រើនតាមរយៈការបង្រៀន និង សេចក្ដីណែនាំដែលមានការបំផុសគំនិតដែលរកឃើញនៅក្នុងទស្សនាវដ្ដីទាំងនោះ » ។

បើសិនជាអ្នកជាវទស្សនាវដ្ដីសាសនាចក្រគ្រប់រូបផ្ញើការបញ្ជាជាវសម្រាប់ជាអំណោយដល់មិត្តភក្តិ ឬ សាច់ញាតិដែលមិនមែនជាសមាជិក នោះនឹងមានអ្នកជាវថ្មីជិត 1.7 លាននាក់ដែលនាំឱ្យស្គាល់ នឹងទាក់ទងជាមួយសាសនាចក្រជារៀងរាល់ខែ ។

តាមរយៈឃ្លាំងទំនិញតាមអ៊ីនធើរណែតរបស់សាសនាចក្រនៅលើគេហទំព័រ—store.lds.org—នោះបុគ្គលគ្រប់រូបអាចបញ្ជាទិញទស្សនាវដ្ដីមួយក្បាល

ជំនួយក៏អាចទទួលបានតាមរយៈការទាក់ទងអ្នកតំណាងទស្សនាវដ្ដីក្នុងមូលដ្ឋាន, អ៊ីម៉ែលទៅ help@store.lds.org ឬ ទូរស័ព្ទទៅអ្នកតំណាងសេវាកម្មអតិថិជនប្រចាំប្រទេស ។ បញ្ជីនៃលេខទូរស័ព្ទសម្រាប់អ្នកតំណាងតាមប្រទេសទាំងនេះមាននៅគេហទំព័រ store.lds.org ។ សូមចុចលើពាក្យ **Contact Us** ខាងក្រោមពាក្យ **Customer Support** នៅខាងក្រោមទំព័រ បន្ទាប់មកសូមចុច **by telephone** ខាងក្រោមពាក្យ **Contact Us** ។

រូបថតដោយ វិក វ៉ាលែនស៍




*សមាជិកទាំងឡាយត្រូវបានលើកទឹកចិត្តឱ្យចែកចាយដំណឹងល្អជាមួយមិត្តភក្តិ និង គ្រួសារដែលមិនមែនជាសមាជិកគ្រប់អាយុ គ្រប់សាសនា និង គ្រប់សាវតារទាំងអស់តាមរយៈការជាវទស្សនាវដ្ដីសាសនាចក្រធ្វើជាអំណោយដល់ពួកគេ ។*

ឬ ច្រើនក្បាល ឬ ជាវទស្សនាវដ្ដីទាំងនោះធ្វើជាអំណោយដល់សមាជិកគ្រួសារ ឬ មិត្តភក្តិ បានយ៉ាងលឿន និង ងាយស្រួល ។ ទស្សនាវដ្ដី *Friend* ទស្សនាវដ្ដី *New Era* និង *Ensign* គឺមានតែជាភាសាអង់គ្លេសប៉ុណ្ណោះ តែចំពោះ *លីអាហូណា* វិញមានអត្ថបទជាច្រើនដូចគ្នានឹងអត្ថបទដទៃទៀតដែលបោះពុម្ពនៅក្នុង ទស្សនាវដ្ដីទាំងបីដែលមានតែជាភាសាអង់គ្លេសនោះ ហើយលីអាហូណាមានបោះពុម្ពជាច្រើនភាសា ។

ប៊ីស្សពម្នាក់នៅក្នុងស្តេក អារីស្សូណា ភេអូរៀ បានឃើញថា ការជាវទស្សនាវដ្ដី *Friend* ធ្វើជាអំណោយដល់ក្មេងៗនៅក្នុងវួដរបស់គាត់កាលពីយូរមកហើយបានក្លាយជាវិធី មួយដ៏មានប្រសិទ្ធភាពដើម្បីជួយពួកគេឱ្យទទួលបានពាក្យពេជន៍របស់ព្យាការី និង សាវកទាំងឡាយដែលរស់នៅ ។

ពេណេឡុប ប៊ី វ៉ូតរូដ មកពី តិចសាស ស.អា.រ បានផ្ញើ*លីអាហូណា* ដែលជាការជាវធ្វើជាអំណោយដល់បងប្អូនជីដូនមួយរបស់នាង ព្រមទាំង មិត្តភក្តិ និង គ្រូបង្រៀននៅក្នុងប្រទេសផ្សេងមួយទៀត ។

នាងបានសរសេរថា ៖ « ខ្ញុំសង្ឃឹមថា ទស្សនាវដ្ដីនេះនឹងជួយ [ បងប្អូនជីដូនមួយរបស់ខ្ញុំ ] រៀនពី សារៈសំខាន់នៃការធ្វើ និង ការរក្សាសេចក្ដីសញ្ញាទាំងឡាយ » ។ នាងបានបន្តដោយនិយាយថា ការជាវទស្សនាវដ្ដីធ្វើជាអំណោយគឺជាវិធីមួយនៃ « ការរៀបចំផ្លូវសម្រាប់ [មិត្តភក្តិ] ដើម្បីស្ដាប់ និង ទទួលយកដំណឹងល្អដែលបានស្តារឡើងវិញនៅថ្ងៃណាមួយក្នុងពេលខាងមុខ » ។

ដើម្បីធ្វើការបញ្ជាទិញ ឬ ជាវធ្វើជាអំណោយ សូមចូលទៅកាន់គេហទំព័រ store.lds.org ។ ព័ត៌មាននៃការបញ្ជាទិញទស្សនាវដ្ដីគឺនៅខាងឆ្វេងដៃនៃទំព័រ ។ ដំណើរការនៃការបញ្ជាទិញតាមអ៊ីនធើរណែតជួយបុគ្គលម្នាក់ៗឱ្យ បន្តជាវ, ជាវលើកដំបូង និង ជាវធ្វើជាអំណោយ ។

គេហទំព័រ store.lds.org មានជាភាសាចិន, អង់គ្លេស, បារាំង, អាល្លឺម៉ង់, អ៊ីតាលី, ជប៉ុន, កូរ៉េ, ព័រទុយហ្គាយ, រុស្ស៊ី និង អេស្ប៉ាញ ។ អស់អ្នកដែលមិនចេះភាសាទាំងនោះ ឬ អស់អ្នកដែលមិនមាន អ៊ីនធើរណែតនោះអាចធ្វើការបញ្ជាទិញទស្សនាវដ្ដី ឬ ជាវធ្វើជាអំណោយតាមរយៈការទាក់ទង ឬ ទៅសួរនៅមជ្ឈមណ្ឌលចែកចាយសាសនាចក្រ ដែលមានទីតាំងនៅក្នុងប្រទេសជាច្រើន ។ ■

# គេហទំព័រ ភាសា ផ្ដល់នូវឯកសារទាំងឡាយនៃសាសនាចក្រ ច្រើនជាង 100 ភាសា

សម្រាប់សមាជិកទាំងឡាយនៅជុំវិញពិភពលោកដែលមិននិយាយភាសាណាមួយក្នុងចំណោមភាសាទាំង 10 នេះរួមមាន—ចិន, អង់គ្លេស, បារាំង, អាល្លឺម៉ង់, អ៊ីតាលី, ជប៉ុន, កូរ៉េ, ព័រទុយហ្គាល់, រុស្សី និង អេស្ប៉ាញ—នោះការរកឯកសារទាំងឡាយរបស់សាសនាចក្រជាភាសាជាតិរបស់ពួកគេអាចក្លាយជាឧបគ្គសមួយ ។ ប៉ុន្ដែសម្រាប់អ្នកដែលស្គាល់គេហទំព័រភាសារបស់ LDS.org នោះអាចរកបានឯកសារសំខាន់ៗរបស់សាសនាចក្រដោយគ្រាន់តែធ្វើការចុចពីរ ឬ បីដងប៉ុណ្ណោះលើប៊ូតុងកុំព្យូទ័រ ។

នៅផ្នែកខាងលើ ខាងស្ដាំ ឬ នៅផ្នែកខាងក្រោមខាងឆ្វេងនៃគេហទំព័រដើមរបស់ LDS.org សូមចុចលើ ***រូបភាពពិភពលោក*** ដើម្បីរកបណ្ដាញភ្ជាប់ទៅ ទំព័រភាសាទាំងអស់ ដែលមានលើគេហទំព័រ LDS.org ។ នៅចុងឆ្នាំ 2012 ក្រុមការងារនៃគេហទំព័រ LDS.org សង្ឃឹមថានឹងមានគេហទំព័រជាង 108 ភាសា រួមមានភាសា ហរវ៉ាត់ស្គី (ក្រូអាត), ម៉ាឡាកាស៊ី (ភាសានិយាយនៅប្រទេស ម៉ាដាហ្គាសស្កា) និង ធ្វី (ភាសានិយាយនៅប្រទេស ហ្គាណា) ។

*ឯកសារថ្មីៗជាច្រើនអាចបោះពុម្ព និង ទាញយកបានជាឯកសារ នោះកំពុងតែដាក់បន្ថែម នឹង បន្តដាក់បន្ថែមនៅលើគេហទំព័រ **LDS.org** ដែលមានច្រើនជាង 100 ភាសា ។*

ឯកសារទាំងឡាយដែលមាននៅតាមគេហទំព័រផ្សេងៗគ្នា ប៉ុន្ដែអត្ថបទនិមួយៗអាចបោះពុម្ព និង ទាញយកជាឯកសារបាន ។

នៅឆ្នាំនេះ ទំព័រភាសា ត្រូវបានធ្វើបច្ចុប្បន្នភាពជាមួយនឹងអត្ថបទថ្មីៗ រួមទាំង ឯកសារជា PDF នៃ *លីអាហូណា* ជាភាសាមូលដ្ឋានមានច្រើនជាង 40 ភាសា ហើយ អត្ថបទសាមញ្ញជា PDF នៃសន្និសីទទូទៅខែមេសា ឆ្នាំ 2012 មានច្រើនជាង 90 ភាសា ។ ព្រះគម្ពីរមរមនជាឯកសារ PDF មាន 99 ភាសា បានបន្ថែម ភាសាចំនួន 24 ទៀតនៅក្នុងទំព័រភាសា សម្រាប់អស់អ្នកទាំងឡាយណា ដែលប្រើប្រាស់គេហទំព័រ LDS.org ។

អត្ថបទទាំងឡាយដែលបានបកប្រែរួច ត្រូវបានដាក់បញ្ចូលទៅក្នុងគេហទំព័រស្របទៅតាមផែនការទូទាំងពិភពលោករបស់សាសនាចក្រ ដើម្បីណែនាំនូវឯកសារទាំងឡាយរបស់សាសនាចក្រជាភាសាជាក់លាក់ ។

នៅក្នុងគំរោងការណ៍លើកនេះ អត្ថបទសំខាន់ៗ—ការអធិស្ឋានសាក្រាម៉ង់, មាត្រានៃសេចក្ដីជំនឿ, សៀវភៅ *គោលការណ៍គ្រឹះនៃដំណឹងល្អ*, សុន្ទរកថាសន្និសីទទូទៅដែលបានជ្រើសរើស និង កូនសៀវភៅ *ទីបន្ទាល់របស់ព្យាការីយ៉ូសែប ស្ម៊ីធ*ដែលជាគំរូ—ដែលបានដាក់អាទិភាពឱ្យមានការបកប្រែ ។

ឯកសារទាំងឡាយដែលបានបកប្រែបន្ថែមទៀតដូចជា ព្រះគម្ពីរ, តន្ត្រី, « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » និង សារលិខិតនៃគណៈប្រធានទីមួយ និង សារលិខិតការបង្រៀនសួរសុខទុក្ខ ត្រូវបានណែនាំឱ្យស្គាល់ នៅពេលចំនួននៃសមាជិកសាសនាចក្រដែលនិយាយភាសានោះមានការកើនឡើង ។

ដោយការអនុម័តមកពីគណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ឯកសារមួយចំនួនត្រូវបានបកប្រែ សម្រាប់ប្រើប្រាស់ ។ គណៈប្រធានតំបន់ក៏អាចស្នើសុំឱ្យមាននូវការបកប្រែឯកសារមួយចំនួន សម្រាប់ជាការប្រើប្រាស់ចំពោះភាសាជាក់លាក់ណាមួយ បើសិនពួកគាត់ជូនដំណឹងអំពីតម្រូវការនោះ ។

ម៉ាត រ៉ូប៊ីនសុន អ្នកគ្រប់គ្រងផលិតកម្មជាន់ខ្ពស់នៃការបោះពុម្ពឯកសារជាអេឡិចត្រូនិច បានមានប្រសាសន៍ថា ៖ « គេហទំព័រទាំងនេះ គឺប្រើបានចំពោះសមាជិកទាំងអស់សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ព្រមទាំងការប្រើប្រាស់នៅថ្ងៃអាទិត្យ ។ អ្នកដឹកនាំក្នុងមូលដ្ឋានអាចប្រើប្រាស់ធនធានទាំងនេះសម្រាប់ការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេ ព្រមទាំងចង្អុលបង្ហាញសមាជិកទាំងឡាយឱ្យប្រើប្រាស់វាក្នុងការហោបម្រើ និង ក្រុមគ្រួសារ » ។

សាជីស អាយ៉ាវ៉ាយ៉ាន ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានមណ្ឌលយើរ៉េវ៉ាន អាមេនី ប្រាប់ឱ្យដឹងថា សមាជិកនៅក្នុងប្រទេស អាមេនី រីករាយក្នុងការប្រើប្រាស់គេហទំព័រជាភាសា អាមេនី ដើម្បីបោះពុម្ពឯកសារទាំងឡាយដែលជួយពួកគេឱ្យបំពេញការហៅរបស់ពួកគេ ។ ពួកគេក៏អាចប្រើប្រាស់គេហទំព័រនោះដើម្បីទទួល និង អានព័ត៌មានអំពីសាសនាចក្រ ហើយរកឯកសារ សន្និសីទទូទៅជាភាសាកំណើតរបស់ពួកគេ ។ ■



# ការប្រារព្ធពិធីខួបកំណើតរបស់ប្រធាន ម៉នសុន នាពេលរាត្រី ដោយមានបទចម្រៀង, តន្ត្រី, ការអបអរសាទរ

**ដោយ ហ្គើរី អាវ៉ាន់ធ៍**
*អ្នកយកព័ត៌មាន* ព័ត៌មានអំពីសាសនាចក្រ

នៅក្នុងការប្រារព្ធពិធីខួបកំណើតគម្រប់អាយុ 85 ឆ្នាំដ៏អធិកអធម និង ជាកិត្តិយស របស់ប្រធាន ថូម៉ាស អេស ម៉នសុន នោះមានមនុស្សប្រហែល 20000 នាក់បានមកពេញមណ្ឌលសន្និសីទកាលពី ថ្ងៃទី 17 ខែ សីហា ឆ្នាំ 2012 សម្រាប់រាត្រីដែលមានតន្ត្រី, ការនិទានរឿង និង ការអបអរសាទរនៅក្នុងកម្មវិធីមួយដែលហៅថា « ថ្ងៃពិសេស ៖ ការប្រារព្ធពិធីខួបកំណើត » ។

នៅក្នុងកម្មវិធីនោះរួមមាន តន្ត្រី និង សារលិខិតមួយចំនួននៃការសម្ដែងនៅ ផ្លូវ (ប្រត់វេ) Broadway ដែលជាចំណូលចិត្តរបស់ប្រធាន ម៉នសុន និង ចម្រៀងដ៏បំផុសគំនិតផ្សេងទៀត នៅក្នុងការប្រារព្ធពិធីខួបកំណើតគម្រប់ 85 ឆ្នាំរបស់លោក ដែលបានប្រារព្ធឡើងនៅថ្ងៃទី 21 ខែ សីហា ។

ប្រធាន ម៉នសុន បានអង្គុយនៅកៅអីជួរមុនគេនៅក្នុងបន្ទប់នោះជាមួយភរិយារបស់លោក គឺ ហ្វ្រានស៊ីស ចនសុន ម៉នសុន និង សមាជិកទាំងឡាយនៃគ្រួសាររបស់ពួកលោក ។

ប្រធាន ហិនរី ប៊ី អាវរិង ទីប្រឹក្សាទីមួយនៃគណៈប្រធានទីមួយ បានប្រាប់ពីការមើលឃើញនូវការអបអរសាទរមួយចំពោះប្រធាន ម៉នសុន នៅលើ « ផ្លូវនៃវាលខ្សាច់មួយនៅជនបទនៃ រដ្ឋអារីហ្សូណា » ជាទីកន្លែង ដែលប្រធាន ម៉នសុន បានឈប់ហើយចាប់ដៃជាមួយស្វាមីភរិយាមួយគូ និង កូនតូចៗរបស់ពួកគេ ប៉ុន្តែបានបន្តស្វាគមន៍ដោយអត់ធ្មត់រហូតដល់អស់មនុស្សជាច្រើនទៀតដែលមានវត្តមាននៅទីនោះ ។

ប្រធាន អាវរិង បានមានប្រសាសន៍ថា លោកបានឃើញប្រធាន ម៉នសុន « ធ្វើជាតំណាងរបស់ព្រះអម្ចាស់ដើម្បីចេញទៅសួរសុខទុក្ខមនុស្ស » ជាទូទៅរួមមានទាំងកូនក្មេង នៅទូទាំងពិភពលោក ។ លោកមានប្រសាសន៍ថា « មិនគ្រាន់តែអស់អ្នកដែលលោកបានស្វាគមន៍ប៉ុណ្ណោះទេ ដែលបានទទួលអារម្មណ៍ដ៏ពិសេសនោះទេ ប៉ុន្តែអារម្មណ៍ពិសេសនោះថែមទាំងមានដល់ពួកយើងរាល់គ្នាដែលជាអ្នកឃើញព្រឹត្តិការណ៍នោះផងដែរ ។ ដោយសារតែការទទួលអារម្មណ៍នៃក្ដីស្រឡាញ់នោះ យើងមានការផ្លាស់ប្ដូរ រូបខ្ញុំមិនមែនជាមនុស្សដូចមុនទៀតទេ សូម្បីតែអ្នកចូលរួមទាំងនោះក៏មានការផ្លាស់ប្ដូរដែរ » ។

ប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ ទីប្រឹក្សាទីពីរនៃគណៈប្រធានទីមួយ ក៏បានអបអរសាទរដល់ប្រធាន ម៉នសុន នៅថ្ងៃខួបកំណើតដ៏ពិសេសនោះផងដែរ ។ លោកបានមានប្រសាសន៍ថា . . . « ប្រធាន ម៉នសុន ប្រធានគឺជាមិត្តភក្ដិម្នាក់ដែលបាននាំពន្លឺមកទីងងឹត ហើយប្រធានគឺជាព្យាការីរបស់ព្រះនៅក្នុងសម័យរបស់យើង ។ ពួកយើងស្រឡាញ់ និង គាំទ្រលោកប្រធាន ។ ពួកយើងអធិស្ឋានសម្រាប់លោកប្រធាន » ។

*« ថ្ងៃពិសេស ៖ ការប្រារព្ធពិធីខួបកំណើត » បានរំឭកឡើងវិញពីខ្សែជីវិតរបស់ប្រធាន ម៉នសុន កាលពី—កុមារភាព, អាពាហ៍ពិពាហ៍, ការបម្រើជាយោធា និង ការបម្រើសាសនាចក្រ—តាមរយៈតន្ត្រី និង ចម្រៀង ។*

មានព្រះវិហារ, សាសនា និង អ្នកដឹកនាំស៊ីវិលដទៃជាច្រើនទៀត ព្រមទាំងមិត្តភក្ដិចាស់ បានធ្វើការអបអរសាទរដល់ប្រធាន ម៉នសុន តាមរយៈការថតវីដេអូស្វាគមន៍ជាមុន ។ លោកក៏ត្រូវបានទទួលស្គាល់សម្រាប់ការចូលរួមក្នុងក្រុមកាយរិទ្ធិអស់រយៈពេលជាច្រើនឆ្នាំផងដែរ ។

នៅក្នុងការបញ្ចប់កម្មវិធីនោះ ប្រធាន ម៉នសុន បានដកស្រង់ម្ដងទៀត នូវពាក្យពេចន៍ និង កំនាព្យ របស់ កវីនិពន្ធជនជាតិ ស្កុត គឺលោក ជេមស៍ បារៀ ដែលបានសរសេរថា « ព្រះបានប្រទានអនុស្សាវរីយដល់យើង នោះយើងអាចរក្សាផ្កាកូលាបនៅក្នុងខែ មិថុនា ទុកសម្រាប់ជីវិតរបស់យើងនៅខែ ធ្នូ » (សូមមើល ឡូរ៉ែនស៍ ជេ ភីធើរ សម្រួលដោយ *Peter's Quotations: Ideas for Our Time* (ឆ្នាំ 1977 ) ទំព័រ 335) ។

ប្រធាន ម៉នសុនបានមានប្រសាសន៍ថា « យប់នេះខ្ញុំបានទទួលអនុស្សាវរីយច្រើនសន្ធឹកសន្ធាប់ណាស់ » ។

សំខាន់ជាងនេះទៅទៀត នៅលើឆាកវេទិកា នៃមណ្ឌលសន្និសីទត្រូវបានតុបតែងដោយផ្កាកុលាបពណ៌លឿងរាប់រយទង ដែលជានិមិត្តសញ្ញានៃ « ថ្ងៃពិសេស » នៃខួបកំណើតរបស់លោក ។ ■



ថតរូបដោយ ជេប្រា ហ្គើស

## ស្តេកដំបូងគេដែលបានបង្កើតនៅក្នុងប្រទេស ខេប វើដ

កាលពីថ្ងៃអាទិត្យ ទី 29 ខែ មេសា ឆ្នាំ 2012 អែលឌើរ អ៊ីរិច ដបុលយូ កូពីសឆ្កេរ ដែលកាលនោះបម្រើជាប្រធានតំបន់អឺរ៉ុប បានបង្កើតស្តេកដំបូងគេនៅក្នុងប្រទេស ខេប វើដ (ឬហៅថា ប្រទេស កាបូ វើដ) នៅក្នុងរដ្ឋធានី ប្រាយា ដោយមានពួកបរិសុទ្ធច្រើនជាង 1000 នាក់បានចូលរួម ។

ប្រាយា ខេប វើដ ត្រូវបានហៅ និង ញែកចេញដើម្បីធ្វើជាប្រធាន ស្តេក រ៉ូស៊ីវីលធ៍ តិក្សសៃរ៉ា ថ្មីនោះ ដោយមាន អាឌីលសុន ម៉នធើរអូ ជាទីប្រឹក្សាទីមួយ និង ហូសេ ផីយែ ជាទីប្រឹក្សាទីពីរ ។

## ការឧទិសឆ្លងជាថ្មីរបស់សាលាជំនុំទីក្រុង ឡុងដ៍ បានពង្រីកការផ្សាយដំណឹងល្អដល់មនុស្សជាច្រើន

ប្រវត្តិសាស្ត្ររបស់សាសនាចក្រ នៅ ហ៊ីត ផាក ក្នុងទីក្រុង ឡុងដ៍ ប្រទេស អង់គ្លេស ត្រូវបានធ្វើការជួសជុលកែជា ថ្មី ហើយបានឧទិសឆ្លងជាថ្មីជាសាលាជំនុំសម្រាប់ការថ្វាយបង្គំ និង ជាមណ្ឌលសម្រាប់ភ្ញៀវទស្សនា មុនការប្រកួតកីឡាអូឡាំពិកឆ្នាំ 2012 កាលពីថ្ងៃទី 1 ខែ កក្កដា ឆ្នាំ 2012 ។

អែលឌើរ អ៊ីរិច ដបុលយូ កូពីសឆ្កេរ នៃពួកចិតសិបនាក់ ដែលកាលនោះបម្រើជាប្រធានតំបន់អឺរ៉ុប បានឧទិសឆ្លងអគារនោះជាថ្មី ។ លោកមានប្រសាសន៍ថា « ខ្ញុំសង្ឃឹមថា ក្នុងអំឡុងពេលច្រើនឆ្នាំទៀត នឹងមានមនុស្សរាប់រយលាននាក់ចូលមកក្នុងអគារនេះដើម្បីរៀនអំពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ » ។

## ការប្រារព្ធពិធីការលូតលាស់របស់សាសនាចក្រនៅក្នុងប្រទេស នូវ ខាលេដូនៀ

កាលពីថ្ងៃទី 27 ខែ ឧសភា ឆ្នាំ 2012 អែលឌើ ជេម ជេ ហាមូឡានៃពួកចិតសិបនាក់ ដែលជាប្រធានតំបន់ប៉ាស៊ីភិច បានរៀបចំស្តេកដំបូងគេនៅក្នុងប្រទេស នូវ ខាលេដូនៀ ដែលមានសមាជិកសាសនាចក្រចំនួន 800 នាក់បានមកទស្សនា ។

អែលឌើរ ហាមូឡា បានមានប្រសាសន៍ថា « ពួកបរិសុទ្ធថ្ងៃចុងក្រោយ និង ប្រជាជននៃ ប្រទេស នូវ ខាលេដូនៀ ទាំងអស់នឹងទទួលបានពរជ័យនៅពេលដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទត្រូវបានបង្រៀន ហើយត្រូវបានទទួលយកដោយប្រជាជនច្រើនឡើងៗ »

ស្តេក នូមៀ នូវ ខាលេដូនៀ គឺជាស្តេកថ្មីដែលមានសមាជិកសរុប 2000នាក់ និង មានសាលាប្រជុំចំនួនប្រាំបី ។

ចចជា ហ្គីឌី ដែលត្រូវបានហៅឱ្យធ្វើជាប្រធាន ស្តេកដំបូងគេបាននិយាយថា « បេសកកម្មសំខាន់បំផុតរបស់យើងគឺដើម្បីបង្រៀនដំណឹងល្អ និង គោលការណ៍ទាំងឡាយនៃដំណឹងល្អដល់ប្រជាជននៃប្រទេស នូវ ខាលេដូនៀ ដែលនឹងនាំមកនូវសុភមង្គលសម្រាប់ពួកគេ, សម្រាប់ក្រុមគ្រួសារ និង សម្រាប់អ្នករួមការងាររបស់ពួកគេ និង សហគមន៍របស់ពួកគេ » ។ ម៉ាក ម៉ូស្សែលីន និង ធើរី ហ្គូរដេ ត្រូវបានហៅធ្វើជាទីប្រឹក្សារបស់គាត់ ។

ថតរូបដោយ អែលឌើរ ហូសេ អេ ឌីញ៉ូវ៉ា



*សមាជិកនៃគណៈប្រធាន ស្តេក ប្រាយា ខេប វើដ គឺ (ពីឆ្វេងទៅស្តាំ) ៖ អាឌីលសុន ម៉នធើរអូ ជាទីប្រឹក្សាទីមួយ, រ៉ូស៊ីវីលធ៍ តិក្សសៃរ៉ា ជាប្រធាន និង ហូសេ ផីយែ ជាទីប្រឹក្សាទីពីរ ។*

### បច្ចុប្បន្នភាព

គណៈប្រធានទីមួយបានប្រកាសការផ្លាស់ប្តូរមួយនៅក្នុងគណៈប្រធានតំបន់អាមេរិកកណ្តាល ដោយចាត់តាំងជាថ្មីដល់ អែលឌើរ រ៉ូប៊ើត ស៊ី ហ្គេ ទៅកាន់ ទីស្នាក់ការកណ្តាលរបស់សាសនាចក្រ ហើយ ហៅ អែលឌើរ ខារិ អ័រ ដាន់ខេនក្នុងតំណែងរបស់លោក ជាទីប្រឹក្សាទីពីរ ។ ការផ្លាស់ប្តូរនេះត្រូវបានកែប្រែការចាត់តាំងដែលមាននៅក្នុងតារាងចាត់តាំងតំបន់ដែលបានបោះពុម្ពនៅក្នុងខែ សីហាក្នុង *Ensign* និង *លីអាហូណា* ។

## សាលាប្រជុំពួកបរិសុទ្ធថ្ងៃចុងក្រោយដំបូងគេនៅក្នុងប្រទេស អេស្យូពី

សមាជិកទាំងឡាយនៅក្នុងប្រទេស អេស្យូពី បានឃើញរួចមកហើយពីពរជ័យទាំងឡាយដែលបានមកពីសាលាប្រជុំដំបូងគេនៅក្នុងប្រទេសនេះ ។ សាលាប្រជុំនោះ មានទីតាំងនៅលើមហាវិថី នៅចន្លោះ ទីក្រុង អាឌីស អាបាបា និង ទីក្រុងអាដាម៉ា ជាអគារមានកំពស់បីជាន់ និង រួមមានទីលានចតឡាននៅជាន់ក្រោមដី ។

ប៉ុន្តែអ្វីដែលសំខាន់ជាងផ្នែកបច្ចេកទេសនៃសាលាប្រជុំនោះគឺ ជារបៀបដែលសាលាប្រជុំនោះបម្រើជានិមិត្តសញ្ញានៃសេចក្តីជំនឿដល់សមាជិកក្នុងសាខា ដែលពួកគេពីមុនធ្លាប់បានប្រជុំនៅក្នុងលំនៅដ្ឋានឯកជនដែលមិនឆ្ងាយពីអគារថ្មីប៉ុន្មានឡើយ ។

ប្រធាន ដេប្រើ ស្ស៊ីត ដែលជាប្រធានសាខា អ៊ីហ្វ្រែម អេមៀរ៉ូ មែកូទីន បាននិយាយថា « រាល់ពេលដែលខ្ញុំទៅក្បែរអគារថ្មី នោះខ្ញុំត្រូវបានរំឭកពីសេចក្តីសញ្ញារបស់យើង ។ គឺដូចពេលមេទ័ព មរ៉ូណៃ បានលើកទង់ឥស្សរភាពឡើង នោះខ្ញុំត្រូវបានពង្រឹង » ។

# សេចក្ដីអធិប្បាយ

### *លីអាហូណា* ផ្ដល់ចម្លើយទាំងឡាយ

ខ្ញុំជាសមាជិកនៃសាសនាចក្រតាំងពីកើតមក ។ មានពេលខ្លះខ្ញុំពុំបានឱ្យតម្លៃលើពរជ័យជាច្រើននៃដំណឹងល្អនៅក្នុងជីវិតរបស់ខ្ញុំឡើយ ។ បន្ទាប់មកនៅពេលខ្ញុំគិតអំពីពរជ័យទាំងនោះ នោះខ្ញុំដឹងថា ខ្ញុំមិនអាច ថ្លែងអំណរគុណដល់ព្រះវរបិតាសួគ៌របស់ខ្ញុំឱ្យបានគ្រប់គ្រាន់សម្រាប់អ្វីៗដែលខ្ញុំបានទទួលឡើយ ។ ពរជ័យមួយក្នុងចំណោមពរជ័យទាំងនោះគឺទស្សនាវដ្ដី *លីអាហូណា* ដ៏បំផុសគំនិត ។ វាពិតជាអស្ចារ្យណាស់រាល់ពេលដែលខ្ញុំអានទស្សនាវដ្ដីនោះ ខ្ញុំទទួលបានចម្លើយដែលខ្ញុំចង់បាននោះ ។ សូមអរគុណសម្រាប់សារលិខិតទាំងនេះ ។

**ឡូតមីណា អិល អាយុ 13 ឆ្នាំ ប្រទេស អាហ្សង់ទីន ។**

### ទីបន្ទាល់របស់យើងរីកលូតលាស់

*លីអាហូណា* បានផ្លាស់ប្ដូរជីវិតរបស់ខ្ញុំ និង គ្រួសារខ្ញុំ ។ លីអាហូណាគឺជាឧបករណ៍ដ៏អស្ចារ្យ ពីព្រោះមនុស្សម្នាក់អាចរៀន ហើយទទួលបានចំណេះដឹងពីវា ។ សូមអរគុណដល់ទស្សនាវដ្ដី ពួកយើងត្រូវបានពង្រឹង ហើយ ទីបន្ទាល់របស់យើងអំពីសាសនាចក្ររីកលូតលាស់ ។

**អាណា ម៉ាស្សែឡា អ៊ីស្សែទីត ហ្វូយូស៍ ប្រទេស កូឡុំប៊ី**

## យោបល់ទាំងឡាយសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

*ច្បាប់នេះមានទូវអត្ថបទ និង សកម្មភាពទាំងឡាយដែលអាចប្រើប្រាស់សម្រាប់ធ្វើរាត្រីជួបជុំក្រុមគ្រួសារបាន ។ ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួន ។*

**« ប្រពៃណីនៃពន្លឺ និង ទីបន្ទាល់ » ទំព័រ 10 ៖** សូមសង្ខេបអត្ថបទ និង ពិចារណាអំពីការអញ្ជើញគ្រួសាររបស់អ្នកដើម្បីបង្កើតជំនួយចក្ខុ ដើម្បីបង្ហាញពីគោលបំណងនៃប្រើរន្ទា ។ សូមពិភាក្សាពីរបៀបដែលសាសនាចក្រផ្ដល់ដល់គ្រួសាររបស់អ្នកនូវ « រន្ទា » ដើម្បីឡើងឱ្យបានខ្ពស់សម្រាប់ កសាងគ្រួសាររបស់អ្នក និង អ្វីៗផ្សេងទៀតនៃជីវិតរបស់អ្នក ។

**« ពួកព្យាការីនៅរដូវបុណ្យគ្រីស្ទម៉ាស់ » ទំព័រ 20 ៖** បន្ទាប់ពីអានដំណើររឿងខ្សែជីវិតរបស់ព្យាការីទាំងឡាយ សូមពិចារណាដោយចែកចាយនូវបទពិសោធន៍មួយចំនួនដែលអ្នកមាននៅក្នុងជីវិតរបស់អ្នក ឬ ជីវិតរបស់មនុស្សដទៃទៀត ដែលបានដក់ក្នុងដួងចិត្តដោយសារបទពិសោធន៍ពិសេសនៅអំឡុងពេលបុណ្យគ្រីស្ទម៉ាស់កន្លងមក ។ អ្នកអាចនឹងពិភាក្សាពី របៀបដើម្បីធ្វើតាមគំរូរបស់ព្យាការីទាំងឡាយអំឡុងពេលរដូវនេះ ។

**« សុវត្ថិភាព និងសន្តិភាពនៃកាន់តាមព្រះបញ្ញត្តិទាំងឡាយ » ទំព័រ 32 ៖** អស់អ្នកដែលមានកូនតូចៗអាចឱ្យពួកគេគូររូបភាពរបស់មនុស្សដែលធ្វើអំពើសុចរិតនៅតាមផ្លូវទៅកាន់ព្រះវិហារបរិសុទ្ធ ។ ក្រុមគ្រួសារផ្សេងទៀតអាចពិចារណាដោយអានអត្ថបទទាំងមូល ហើយពិភាក្សាវា ដោយបញ្ជាក់ថា « ផ្លូវដែលនាំទៅកាន់សុភមង្គលចាប់ផ្ដើមជាមួយ . . . ការគោរពប្រតិបត្តិតាមព្រះបញ្ញត្តិទាំងឡាយ » ។

**« របៀបដើម្បីថ្វាយអំណោយដល់ព្រះគ្រីស្ទ » ទំព័រ 48 ៖** សូមអានអត្ថបទមកពីប្រធាន ហិនរី ប៊ី អាវរិងជាមួយគ្នា ។ ប្រហែលជាកូនៗរបស់អ្នកអាចកត់ទុកពីអ្វីដែលពួកគេចង់ថ្វាយដល់ព្រះអង្គសង្គ្រោះសម្រាប់បុណ្យគ្រីស្ទម៉ាស់ ហើយវេចខ្ចប់ការសរសេរ របស់ពួកគេនោះជាអំណោយបុណ្យគ្រីស្ទម៉ាស់មួយ ។ សូមពិភាក្សាដោយពិចារណាពីមនុស្សដែលពួកគេស្គាល់ដែលអាចប្រើប្រាស់ជំនួយខាងសាច់ឈាម ឬ ខាងវិញ្ញាណ ឬ ទាំងខាងសាច់ឈាម និង ខាងវិញ្ញាណ ។

**« ការអធិស្ឋានក្នុងថ្ងៃបុណ្យគ្រីស្ទម៉ាស់បានទទួលចម្លើយ » ទំព័រ 68 ៖** សូមអានដំណើររឿងអំពី ភេជីស្កនខេនជាមួយគ្រួសាររបស់អ្នក ។ អ្នកអាចនឹងចែកចាយពីពេលវេលា ដែលអ្នកបានទទួលចម្លើយចំពោះ ការអធិស្ឋានរបស់អ្នក ហើយ សូមលើកទឹកចិត្តកូនៗរបស់អ្នកឱ្យធ្វើដូចគ្នាផងដែរ ។ សូមពិចារណាលើគ្រប់ចម្លើយ ដែលគ្រួសាររបស់អ្នកបានទទួលពីការអធិស្ឋាន នៅអំឡុងពេលរដូវបុណ្យគ្រីស្ទម៉ាស់ ។

## ការអំពាវនាវសុំយោបល់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

លី*អាហូណា* កំពុងស្វែងរកយោបល់ និង បទពិសោធន៍ទាំងឡាយ សម្រាប់រាត្រីជួបជុំក្រុមគ្រួសាររបស់អ្នក ។ យោបល់ទាំងនោះអាចជាយោបល់ខ្លីៗ—ដោយគ្រាន់តែប្រាប់ ពី រាត្រីជួបជុំក្រុមគ្រួសារដ៏មានជោគជ័យ ឬដ៏មានអត្ថន័យ ឬ របៀបដែលអ្នកកែច្នៃរាត្រីជួបជុំក្រុមគ្រួសាររបស់អ្នកឱ្យត្រូវនឹងតម្រូវការជាក់លាក់នៅក្នុងគ្រួសាររបស់អ្នក ។

សូមផ្ញើយោបល់ និង បទពិសោធន៍ទាំងឡាយរបស់អ្នក (ជាភាសាអ្វីក៏បាន) ទៅកាន់អ៊ីម៉ែល liahona@ldschurch.org ។ សូមសរសេរឈ្មោះពេញរបស់អ្នក, អាសយដ្ឋានអ៊ីម៉ែល និង ឈ្មោះ វួដ ឬ សាខា និង ស្ដេក ឬ មណ្ឌលរបស់អ្នក ។

### ទីបន្ទាល់ដែលមិនចេញស្ដី

កូនប្រុសរបស់ខ្ញុំឈ្មោះ ដេរីក ដែលមានជំងឺពិការខួរក្បាល មានន័យថាវាពិបាកដើម្បីនិយាយ ។ ដេរីក ស្រឡាញ់រាត្រីជួបជុំក្រុមគ្រួសារ ហើយ ចំណាយពេលជាច្រើនខែដើម្បីរៀបចំមេរៀនដើម្បីចែកចាយជាមួយគ្រួសារ ។

មេរៀនដ៏អស្ចារ្យបំផុតរបស់វានោះគឺ « សុបិនរបស់លីហៃ » ។ ដេរីកបានចងខ្សែពេញទាំងក្នុង និង ក្រៅផ្ទះផងដែរ ។ យើងបានចាប់ផ្ដើមមេរៀនដោយស្ដាប់ស៊ីឌីនៃទំនុកតម្កើងបទ « ខ្ញុំជឿលើព្រះគ្រីស្ទ » ហើយមើលទៅកាន់រូបភាពនៃសុបិនរបស់លីហៃដែលដាក់បង្ហាញនៅលើតុ ។ បន្ទាប់មក ដេរីក បាននាំពួកយើង ម្ដងម្នាក់ៗ តាមខ្សែនោះ ។

នៅពេលយើងដើរតាមខ្សែនោះ មានរូបភាពព្រះគ្រីស្ទជាច្រើននៅជ្រុងម្ខាង ហើយមានការរំខានផ្សេងៗ (ដូចជា វិទ្យុ, ទូរទស្សន៍ និង ល្បែងកម្សាន្ត) នៅជ្រុងម្ខាងទៀត ។ យើងបានដឹងថាយើងនឹងទៅដល់ទីដៅនៅពេលយើងឮបទ—ដែលដេរីក ចូលចិត្តគឺបទ « ខ្ញុំដឹងថាព្រះប្រោសលោះខ្ញុំនៅរស់ » ។

បន្ទាប់ពីគ្រប់គ្នាបានឆ្លងដល់ទីដៅ នោះ ដេរីក បានបើកឌីវីឌីរឿង *The Testaments* ហើយបានឱ្យពួកយើងមើលឆុតចុងក្រោយ នៅពេលដែលព្រះយេស៊ូវគ្រីស្ទ បានលេចអង្គទ្រង់ដល់ប្រជាជននៅទ្វីបអាមេរិក ។ ព្រះវិញ្ញាណបានជិតដាមជាខ្លាំងនៅពេលកូនប្រុសរបស់ខ្ញុំបានបង្ហាញ ទីបន្ទាល់របស់វាអំពីព្រះអង្គសង្គ្រោះដោយមិនប្រើពាក្យសម្ដីណាមួយឡើយ ។

**វីនឌី ថមសុន ស.អា.រ**



**ដោយ អែលឌើរ ឃ្វីនធិន អិល ឃុក**
នៃកូរ៉ុមនៃពួកសាវក ដប់ពីរនាក់

# ពន្លឺ, កិច្ចការសាធារណៈ និង ក្ដីអំណរក្នុងដំណឹងល្អ

ពីរបីឆ្នាំកន្លងទៅ នៅពេលអែលឌើរ អិម. រ័សុល បាឡឺដ និង រូបខ្ញុំជាអ្នកប្រឹក្សាអ្នកមានសិទ្ធអំណាចទូទៅដល់ផ្នែកកិច្ចការសាធារណៈសាសនាចក្រ យើងបានដឹងថាប្រព័ន្ធផ្សព្វផ្សាយតែងតែបើកចំហទាក់ទងមនុស្សទាំងឡាយ ដែលមិនមែនជាសមាជិកនៃសាសនាចក្រដែលចង់ដឹងពីសាសនាចក្រ ។ ដោយមានប្រាថ្នាចង់ផ្លាស់ប្ដូរ អែលឌើរ បាឡាដ និង រូបខ្ញុំ ក្រោមការដឹកនាំរបស់គណៈប្រធានទីមួយ បានចាប់ផ្ដើមធ្វើទស្សនកិច្ចជាមួយក្រុមប្រឹក្សាភិបាលខាងផ្នែកបោះពុម្ពរបស់ការសែតសំខាន់ៗ ដោយចែកចាយសារលិខិតថា ក្នុងនាមជាពួកបរិសុទ្ធថ្ងៃចុងក្រោយ យើងអាព្យាក្រឹតក្នុងឆាកនយោបាយ ។ យើងមិនទទួលមុខតំណែងនៅក្នុងនាមជាបេក្ខជនឬគណបក្សណានោះទេ ។ ទោះបីជាយ៉ាងណាក៏ដោយ យើងពិតជាចង់ធ្វើមនុស្សម្នាក់ដែលប្រាប់ពីសេចក្ដីជំនឿផ្ទាល់ខ្លួនរបស់យើង ។ យើងបានប្រាប់ពួកគេថា « យើងចង់ឱ្យអ្នក មកជួបយើង ហើយនិយាយជាមួយយើងបើសិនជានោះជាការពិភាក្សាគ្នាពីអ្វីដែលយើងជឿ » ។

ទស្សនកិច្ចទាំងនោះត្រូវបានទទួលលទ្ធផលយ៉ាងល្អ ហើយយើងឃើញថាការស្នើរសុំរបស់យើងត្រូវបានយល់ព្រម ។ ហើយឥឡូវនេះយើងឃើញថាមានការយល់ដឹងកាន់តែជាក់ច្បាស់ពីពួកបរិសុទ្ធថ្ងៃចុងក្រោយក្នុងចំណោមប្រព័ន្ធផ្សព្វផ្សាយ ។ ផ្នត់គំនិតចាស់ៗមួយចំនួនត្រូវបានលប់បំបាត់ ហើយយើងឃើញថា មានមនុស្សផ្សេងទៀតបានទទួលស្គាល់យើងថាជាមនុស្សដែលមានចរិតល្អ ដែលព្យាយាមធ្វើឱ្យជីវិតមនុស្សមាននូវទស្សនៈខាង ការអប់រំ និង ចំណេះដឹង ។ យើងក៏កត់សម្គាល់នូវភាពពិតជាក់ស្ដែងនៅខាងក្រៅសាសនាចក្រផងដែរថា ពួកបរិសុទ្ធថ្ងៃចុងក្រោយ មិនដូចគ្នាទាំងអស់នោះទេ សមាជិករបស់យើងគឺខុសប្លែកៗពីគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ក្នុងរបៀបដ៏ល្អ និង គួរឱ្យចាប់អារម្មណ៍ ។

ជាមួយនឹងការផ្លាស់ប្ដូរអាកប្បកិរិយា នេះ វាជាពេលមួយដ៏ប្រសើរដើម្បីក្លាយជាសមាជិកនៃសាសនាចក្រ ហើយសម្រាប់ឱ្យសមាជិកហ៊ានចេះនិយាយ និង ឆ្លើយសំណួរពីមិត្តភក្ដិ និង អ្នកជិតខាងទាំងឡាយរបស់ពួកគេអំពីសេចក្ដីជំនឿរបស់ពួកគេ ។ នៅពេលយើងធ្វើដូច្នេះ នោះគ្មានអ្វីដែលសំខាន់ជាងថា យើងទទួលអារម្មណ៍អំណរហើយថាយើងរីករាយនៅក្នុងដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទឡើយ ។ យើងដឹងពីលទ្ធផលចុងក្រោយនូវអ្វីដែលនឹងកើតឡើង យើងស្គាល់ព្រះយេស៊ូវគ្រីស្ទថាទ្រង់ជានរណា ហើយយើងមានឱកាសដែលព្រះវរបិតាជាទីស្រឡាញ់គង់នៅឋានសួគ៌ប្រទានពរដល់យើង ។

*តើថ្នាក់សាន់ប៊ីម នឹងត្រូវធ្វើអ្វីជាមួយនឹងកិច្ចការសាធារណៈ ? វាមានច្រើនណាស់ នៅពេលដែលវាតំណាងឱ្យសេចក្ដីអំណរនៃដំណឹងល្អ ។*

ខ្ញុំឃើញវាគួរឱ្យចាប់អារម្មណ៍ថា សមាជិកដែលជាពួកអ្នកផ្សព្វផ្សាយសាសនាដ៏ល្អបំផុតរបស់យើង ដែលជាអ្នកដែលស្វែងរកឱកាសដើម្បីចែកចាយដំណឹងល្អ គឺជានិច្ចកាលជាមនុស្សដែលពោរពេញទៅដោយសេចក្ដីអំណរ ។ កាលពីខ្ញុំនៅជានាយកប្រតិបត្តិការិយាល័យនៃអ្នកផ្សព្វផ្សាយសាសនា ភ្លាមនោះយើងបានកត់សម្គាល់ពីបុណ្យ ជ្រមុជទឹកមួយចំនួននៅ ប្រទេស បារាំង ។ ដោយភាពអស្ចារ្យ យើងឆ្ងល់អំពីមូលហេតុ ហើយវាមានហេតុផលជាច្រើន ។ ប៉ុន្តែហេតុផលសំខាន់មួយ គឺស្ត្រីម្នាក់ដែលទៅធ្វើការនៅព្រឹកថ្ងៃច័ន្ទ ហើយបាននិយាយអំពីថ្នាក់សាន់ប៊ីម ។ បន្ទាប់ពីថ្ងៃឈប់សម្រាកនាងនឹង—មានអំណរដ៏អស្ចារ្យ និង រីករាយ—ដោយប្រាប់អ្នកធ្វើការជាមួយនាងអំពីបទពិសោធន៍បង្រៀនក្មេងរបស់នាងកាលពីម្សិលមិញ ។ មិនយូរប៉ុន្មាន មិត្តភក្ដិរបស់នាងទាំងនោះតែងចង់ដឹងភ្លាមៗ អំពីថ្នាក់សាន់ប៊ីម ។ តើកិច្ចការនោះបានធ្វើអ្វីខ្លះទៅ ? នេះគឺជាក្រុមមនុស្សដែលរស់នៅក្នុងស្ថានភាពដូចគ្នាដែលយើងទាំងអស់គ្នាមាន អំពីពិភពលោក និង អនាគតរបស់យើង ភ្លាមៗនោះ មានបុគ្គលម្នាក់ ដែលមិនគ្រាន់តែរីករាយមួយមុខប៉ុណ្ណោះទេ គឺថែមទាំងរីករាយអំពីកូនចៅ—ដែលជាទំពាំងស្នងឬស្សីនាពេលអនាគតផងដែរ ។ បងស្រីម្នាក់នេះពិតជាស្រឡាញ់ព្រះអង្គសង្គ្រោះ ហើយសេចក្ដីស្រឡាញ់នោះវាបានរីកស្គុះស្គាយឡើង ។ អ្នករួមការងារជាមួយគាត់ចង់ដឹងបន្ថែមទៀត ។

បើសិនជាយើងរីករាយជាមួយអ្វីដែលយើងមាន បើសិនជាយើងទទួលបានអំណរ និង បង្ហាញវា នោះយើងនឹងរឹតតែសប្បាយ ។ យើងធ្វើអ្វីដែលព្រះអម្ចាស់ចង់ឱ្យយើងធ្វើ យើងប្រែក្លាយជាមនុស្សប្រសើរជាងមុន ហើយដោយមានទំនាក់ទំនងជាមួយនឹងអ្នកដែលនៅជុំវិញយើងនោះ—ទាំងកូនចៅ និង មិត្តភក្ដិ និង អ្នកជិតខាងទាំងឡាយរបស់យើង—នឹងកាន់តែសប្បាយផងដែរ ។ សេចក្ដីអំណរគឺជាគន្លឹះ នៅពេលដែលយើងចែកចាយសេចក្ដីអំណរអំពីដំណឹងល្អ នោះយើងបំពេញអ្វីដែលព្រះអម្ចាស់បានសព្វព្រះទ័យឱ្យយើងធ្វើដើម្បីបានសម្រេច ។ ■

*កែរសម្រួលមកពីការសម្ភាសន៍នៅប៉ុស្ដិ៍រ៉ាឌីយ៉ូមរមន ។ ដើម្បីស្ដាប់បទសម្ភាសន៍ទាំងស្រុង ជាភាសាអង់គ្លេស សូមចូលទៅកាន់គេហទំព័រ mormonchannel.org/conversations/27 ។*

## ព្រះគម្ពីរមរមន ជាអំណោយមួយមកពីព្រះវរបិតាសួគ៌

យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1:29–35, 42–54, 59–60



យ៉ូសែប ស្ម៊ីធ



ទេវតាមរ៉ូណៃ





ឆ្នាំនេះមាន *លីអាហូណា* ជាច្រើនច្បាប់នឹងមានរូបភាពមួយឈុតពីព្រះគម្ពីរមរមន ។ ដើម្បីធ្វើឱ្យវារឹងមាំ និង ងាយស្រួលប្រើ សូមកាត់រូបទាំងនោះចេញ ហើយបិទវាដោយកាវ ឬ ស្កុតទៅនឹងក្រដាសរឹង ថង់ក្រដាសតូចៗ ឬឈើសម្រាប់កាន់ ។ សូមទុកដាក់រូបមួយឈុតៗនៅក្នុងស្រោមសំបុត្រមួយ ឬថង់មួយ ព្រមទាំងបិទស្លាកដែលប្រាប់ពីកន្លែង ដើម្បីស្វែងរករឿងនិទានព្រះគម្ពីរ ដែលស្របទៅនឹងរូបទាំងឡាយនោះ ។

រចនារូបភាព ដោយ បេស និង វាយថេកឃើរ







ព្រះយេស៊ូវគ្រីស្ទ បំភ្លឺជាពន្លឺនៃលោកិយ ដូចជា
ពន្លឺដែលតុបតែងនៅបរិវេណព្រះវិហារបរិសុទ្ធ
មួយចំនួននៅរដូវបុណ្យគ្រីស្ទម៉ាស់ ជា
ការអញ្ជើញឱ្យអ្នកទស្សនា មករីករាយនឹង
ភាពសុខសាន្តនៃក្ដីអំណរ ដែលមាននៅទីនោះ
ហើយជាការអញ្ជើញមនុស្សទាំងអស់
ឱ្យមកទទួលសេចក្ដីសុខសាន្ត និង អំណរ ដែលទ្រង់ប្រទានឱ្យ តាមរយៈពិធី
បរិសុទ្ធនៃដំណឹងល្អ ជាពិសេសអ្នកទាំងឡាយដែលបានទទួលពិធីបរិសុទ្ធ
ទាំងនោះនៅក្នុងដំណាក់ដ៏បរិសុទ្ធរបស់ទ្រង់ ។ នៅក្នុងចំណោមនៃក្ដីអំណរដ៏
មហិមាបំផុត ដែលមនុស្សគ្រប់រូបអាចមាន នោះគឺជាការដឹងថា តាម
រយៈពិធីបរិសុទ្ធនៃការផ្សាភ្ជាប់ក្នុងព្រះវិហារបរិសុទ្ធ នោះអាពាហ៍ពិពាហ៍មួយ
អាចនៅខ្ជាប់ខ្ជួនហួសពីសេចក្ដីស្លាប់ ហើយចំណងគ្រួសារអាចមាននៅជា
យូរអង្វែង ។ សូមមើល « ការផ្លាស់ប្រែដ៏ពិសិដ្ឋ» ទំព័រ 24 « ការផ្ដោតទៅ
លើគ្រួសារដ៏ជានិរន្តន៍ » ទំព័រ 28 និង « ពន្លឺនៃលោកិយ » ទំព័រ 64 ។

CAMBODIAN
4 02104 92258 3

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ